ឧស្សាន៍ សម្តេចក្រឡាហោម

ស ខេង



ឆ្នាំ ២០២៣

លំដាប់មាតិកា

១-សច្ចធម៌ប្រវត្តិសាស្ត្រ កម្ពុជា-វៀតណាម
២-ត្រៀមខ្លួនចំពោះផ្លូវទៅមុខនៃជាតិយើងជានិច្ច
៣-ឱ្យតែយើងរក្សាបានឯកភាព និងសាមគ្គីភាព
៤-ស្មើគ្នាចំពោះមុខច្បាប់ និងគោលការណ៍
៥-គ្រឿងញៀនវាយលុកសង្គមយើងហើយ
៦-ប្រយ័ត្នជំពាក់ការទទួលខុសត្រូវចំពោះសង្គមជាតិ
៧-ខ្ញុំនិយាយបែបឆ្ងន់បន្តិចមែន ក៏ប៉ុន្តែ...
៨-អាជ្ញាធរ ត្រូវឈរកណ្តាល ហើយអត់ធ្មត់
៩-ភូមិន្ទរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន
១០-អ្នកមូលដ្ឋានក៏ជាម្ចាស់ទឹកដីនេះដែរ
១១-និយាយឱ្យគេស្តាប់បាន ហើយយកទៅធ្វើកើត
១២-ឃុំវដបន្តវេនដើម្បីអ្វី?
១៣-អ្នកខ្លះយកពាក្យស្នេហាជាតិធ្វើជាខែល
១៤-លើកកម្ពស់ផលប្រយោជន៍ជាតិ
១៥-វប្បធម៌ផលប្រយោជន៍ជាតិរបស់មន្ត្រីជប៉ុន
១៦-ឃុំវដក្នុងឋានៈជាសមាជិកបក្ស
១៧-ជម្នះឧបសគ្គ ប្តូរយកបទពិសោធ
១៨-ផ្ទះក្បែរផ្លូវជាតិ បច្ចុប្បន្នសម្បូរ អនាគតនឹងខ្សត់
១៩-អ្វីៗតែងតែមានទំនាស់និងបញ្ហា

២០-ពិចារណាបង្កើតវិធីសាស្ត្រជួយបន្ទាបអ្នកញៀនថ្នាំ
២១-មិនមានបំណងអ្វី ក្រៅពីចង់រួមចំណែក
២២-ទំនាក់ទំនងរវាងនគរបាលជាតិជាមួយប្រជាពលរដ្ឋ
២៣-យើងធ្វើទៅជានយោបាយជាតិរួចហើយ
២៤-ដំបូង OK ឯកភាព! ចុងក្រោយចង់រាវែក
២៥-កុំទុកបញ្ហាសល់ច្រើន ហើយធ្វើច្បាលៗ
២៦-ទុកពេលឱ្យថ្នាក់ដឹកនាំលើៗដោះស្រាយការងារជាតិផង
២៧-តំណាលរឿងខ្មែរក្រហមស្កាត់ប្លាញ់នៅស្ពានទឹកថ្លា
២៨-ការងារណាក៏មានឧបសគ្គ សំខាន់តាំងចិត្តជម្នះ!
២៩-គន្លឹះសំខាន់មួយជួយការពារសន្តិភាព
៣០-សម្តេចតេជោ ចង្អុលឱ្យបង្កើនចំនួនគណៈអភិបាល
៣១-អំណោយធំបំផុត គឺយុត្តិធម៌សង្គម
៣២-ព័ត៌មានក្លែងក្លាយ មិនបកស្រាយ នឹងក្លាយជាពិត!
៣៣-បដិសេធសំណើរបស់មិត្តចិន
៣៤-ប្រទេសខ្លះមិនទទួលពលរដ្ឋខ្លួនឯង
៣៥-ផ្ទេរឯកឧត្តម សាយ សំអាល់ ឱ្យទៅជួយព្រះសីហនុ
៣៦-វិមជ្ឈការ ចាប់កំណើតនៅព្រះសីហនុ
៣៧-ល្បែងប្រជាធិបតេយ្យ មានគេ មានយើង!
៣៨-ទស្សនវិស័យសាលាជាតិរដ្ឋបាលមូលដ្ឋាន
៣៩-ឯកឧត្តម ម៉ុង រិទ្ធី កាន់សោឃ្លាំងបក្ស

៤០-មិនស្គាល់មូលដ្ឋាន ប្រៃថាមិនស្គាល់ជីវភាពពលរដ្ឋ
៤១-សៅរ៍-អាទិត្យមន្ត្រីសម័យនេះ និងកុងសីសម័យមុន
៤២-ស្នាដៃយុត្តិធម៌ដ៏ធំរបស់គណបក្សប្រជាជនកម្ពុជា
៤៣-បំផុសឱ្យពលរដ្ឋហ៊ានិយាយពីបញ្ហាមូលដ្ឋាន
៤៤-យើងកំពុងដើរលើផ្លូវត្រូវហើយ កុំបែរទៅណាទៀត!
៤៥-បើបរាជ័យ ខ្ញុំមិនសុខចិត្ត!
៤៦-របបប្រជុំ
៤៧-បទពិសោធជានាយកខុទ្ទកាល័យ
៤៨-ទន្ទឹមនឹងរបបប្រជុំ គឺរបបចុះមូលដ្ឋាន
៤៩-យើងចេះតែសំពះសុំសន្លឹកឆ្នោតឬ?
៥០-បើយើងអាក្រក់ដូចខ្មែរខ្លះដើរនិយាយមែន ម្លេះសម...!
៥១-អ្នកនយោបាយពូកែរំអួយ
៥២-ហេតុផលនៃឱ្យ CPP ចាញ់ឆ្នោត នៅអាណត្តិទី១!
៥៣-ពីមុនផ្ទះមួយបក្សច្រើន ហើយឈ្លោះគ្នាទៀត
៥៤-ដាច់ខាតមិនឱ្យជួលដីតាម៧ំដែន!
៥៥-ផ្តើមគំនិតហើយពិគ្រោះយោបល់
៥៦-កសាងអនាគតកូនចៅ គឺកសាងអនាគតជាតិ
៥៧-ក្រឡាហោមខេង និងខេត្តបាត់ដំបង
៥៨-ប្រៀបធៀបចុះ ប៉ុន្តែសត្យានុម័តផង
៥៩-មនុស្សលង់ទឹក ធ្វើម៉េចឱ្យតែបានរស់!

៦០-គោរពពេលវេលាតាំងពីតូច
៦១-សុំអត់មានកំហុសទេ មិនសុំបានមានកំហុស
៦២-ទោះមិនឃើញកម្ពុជាមានចំណូលខ្ពស់ ប៉ុន្តែ...
៦៣-អាយុ១១ឆ្នាំទើបបានចូលរៀន
៦៤-កុំភ្លេចមេរៀន និងបទពិសោធដ៏ជូរចត់
៦៥-ខ្មែរគ្មានជម្រើស ឬវៀតណាមឈ្លានពាន?
៦៦-បិទច្រមុះយើងដៃលទើបរួចផុតពីសេចក្តីស្លាប់!
៦៧-គ្មានខ្លង់ប្រើថវិកាជាតិ តែវត្តខ្មែររីកចម្រើន
៦៨-បរិមាណនិងគុណភាពក្នុងព្រះពុទ្ធសាសនាខ្មែរ
៦៩-ម្ហាស់លុយអភិវឌ្ឍន៍ឃុំ សង្កាត់?
៧០-បន្លំឈ្មោះបេក្ខជនឈរឆ្នោត
៧១-ក្រសួងខ្លះមិនសហការគ្នា...
៧២-អគ្គនាយកដ្ឋានដៃលបំបែកភាពស្មុគស្មាញរបស់ជាតិ
៧៣-មិនត្រូវឱ្យបញ្ហាអន្តោប្រវេសន៍វិលមកវិញទៀយ
៧៤-សញ្ជាតិខ្មែរ មិនមែនឱ្យតែសុំ ដឹងតែសុំបានទេ
៧៥-បើសន្តិសុខតាមបុរី និងខុនដូខ្លាំង
៧៦-វិធីបែងចែកការទទួលខុសត្រូវ
៧៧-បើប្រជាពលរដ្ឋមិនយល់ផង គាត់ម៉ែចនឹងគាំទ្រ!
៧៨-សំខាន់បានមកលើកទឹកចិត្ត
៧៩-មើលតែមួយជំនាន់យើងនេះទៅ

៨០-រាស្ត្រឱ្យលុយទៅរដ្ឋ ចិញ្ចឹមយើងមួយជីវិត
៨១-សង់ស្ពានធ្វើផ្លូវជាភារកិច្ចរដ្ឋមែន តែរដ្ឋសម័យណា?
៨២-ឈរឈ្មោះឃុំ សង្កាត់ ត្រូវតែចេះអក្សរ!
៨៣-បក្សតែពេលបោះឆ្នោតទេ...
៨៤-ល្បិចដេកផ្ទះឈ្នះឯង
៨៥-យើងខុសតែទស្សន: និងជំហរគ្នាទេតើ!
៨៦-ប្រកាន់គោលការណ៍!
៨៧-កុំទាល់តែមានតំណែង ទើបមានទំនួលខុសត្រូវ
៨៨-អត់មានទៅណាផ្សេងក្រៅពីហ្នឹងទេ!
៨៩-ពេលមានសិទ្ធិ មានអំណាច ខេត្តក៏ធ្វើការលឿន
៩០-បើប្រជាជនគាំទ្រ អ្នកឯងឡើងកាន់អំណាចទៅ!
៩១-រំលឹករឿងជិះខ្នងម្ដាយចក្រ
៩២-យើងមិនមែនចេះតែកេះកែកាំភ្លើងទេ
៩៣-សូមទោសពលរដ្ឋឃុំព្រៃកាសរ
៩៤-បើកបេះដូងឱ្យទូលាយ កុំចង្អៀតចង្អល់
៩៥-ឃើញយើង គេសឹងតែស្ពោះទឹកមាត់ដាក់
៩៦-កម្មវត្ថុនិងរបៀបវរ:ត្រូវបន្តធ្វើ
៩៧-មុខងារកាឫកិច្ចនិងមុខងារជម្រើស
៩៨-យើងរក្សាបានសាមគ្គីភាពផ្ទៃក្នុងយ៉ាងរឹងមាំ
៩៩-ស្មោះត្រង់ ហើយបើកចំហ

១០-ខ្ញុំក៏មិនសប្បាយចិត្ត និងមិនគាំទ្រដូចគ្នា

១០១-ធ្វើតាមប្រជាជនមិនសូវខុសទេ...

១០២-ឈ្នះដើម្បីឈ្នះ ឈ្នះឱ្យមានកិត្តិយស!

១០៣-មិនត្រូវភ្លេច និងមើលស្រាល

១០៤-ពុំទាន់មានបក្សណាល្អជាងCPP

១០៥-ព្រះមហាក្សត្រ

១0៦-កុំថាពួកអារអស់ហ្នឹងគ្មានធ្វើអ្វីទេ

១០៧-បើមានបក្សគេខ្លះដូចទំនង

១០៨-ចង់បានផ្លូវពីភ្នំពេញបុកទៅក្រុងព្រៃវែង

១០៩-ចុះទៅភូមិពលរដ្ឋនៅទន្លេសាប

១១0-យើងប្រឹងណាស់ ទម្រាំគេទទួលស្គាល់!

១១១-ទោះមិនបោះឆ្នោតឱ្យយើង តែគាត់ទៅបោះឆ្នោត

១១២-ត្បូងឃ្មុំ និងគាស់ក្រឡង ផ្តើមគំនិតបង្កើតនៅលើមេឃ

១១៣-CPP ធ្វើសង្គ្រាមយកអំណាច ប៉ុន្តែ...!

១១៤-យើងមានពិសោធច្រើន ធ្យៀបនឹងបក្សផ្សេង!

១១៥-ពេលជាប់ឆ្នោតក្លាយជាក្រុមប្រឹក្សាឃុំ សង្កាត់

១១៦-ឈ្លោះគ្នានៅតុប្រជុំ ចប់ប្រជុំរាប់អានគ្នាធម្មតា

១១៧-ការព្យាករណ៍រាសន:ឃុំ សង្កាត់ ឆ្នាំ២0២២

១១៨-ជយោពីរសម័យ

១១៩-សេចក្តីស្រែកឃ្លានរបស់បក្ស

១២០-ជ័យជម្នះដ៏គួរឱ្យសរសើរ
១២១-ជោគជ័យមួយទៀត
១២២-ផ្តល់ដំបូន្មានសិស្សនគរបាលជាតិ
១២៣-ទស្សនៈ«ង.ប.»
១២៤-អព្យាក្រឹត្យភាព និងការដើរចេញពី គ.ជ.ប.
១២៥-រួមគ្នាលុបបំបាត់វប្បធម៌ចោទស្មានៗ
១២៦-គូប្រជែង ខុសពីគូបក្ខដិបក្ខ
១២៧-វប្បធម៌ថ្មីមួយនៃជនជាតិយើង
១២៨-បក្សតែពេលប្រជែង
១២៩-គេមិនពេញចិត្ត ទុកច្រកឱ្យគេដើរ
១៣០-បទល្មើសគ្រឿងញៀនគម្រាមប្រព័ន្ធធនាគារ
១៣១-តួអង្គរួមចំណែកពង្រឹងយុត្តិធម៌សង្គម
១៣២-ការងារថ្លៃថ្នូរទាំងអស់ តែ...
១៣៣-បុគ្គលអង្គរដើរក្រទៅ...!
១៣៤-សាមគ្គីផ្ទៃក្នុងជាតិ
១៣៥-បទពិសោធចុះហត្ថលេខា
១៣៦-បើមិនរៀន មានតែដើរចេញ!
១៣៧-កុំសន្មត់ថារៀនចប់ជានៃតែងតាំង!
១៣៨-នៅពេលវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០
១៣៩-ប្រាក់ សុវណ្ណ ជានរណាដែរ?

១៤០-ពាក្យមិនគួរនិយាយទេ!
១៤១-ទទួលស្គាល់ព្រៃនៅមាន ប៉ុន្តែ...
១៤២-ចំណុចខ្សោយយើង ជាចំណុចខ្លាំងគេ!
១៤៣-គ្នាយើងខ្លះធ្លាប់ភ័យដែរហ្នឹង
១៤៤-អនុស្សាវរីយ៍កសាងជាតិនៅព្រះវិហារ
១៤៥-ចុះទៅធ្វើការ ឃើញតែទ្រុងជ្រូក
១៤៦-អីចឹងបានជាគេឱ្យយើងរៀន
១៤៧-ប្រជាពលរដ្ឋម្នាក់ជានគរបាលម្នាក់
១៤៨-ហេតុនាំឱ្យឡើង ឬមិនឡើងសក្តិ?
១៤៩-ដើមហេតុនាំឱ្យអធិការបានពាក់សក្តិ៥
១៥០-អភិបាលរាជធានី ខេត្ត គួរបង្កើនអាយុចូលនិវត្តន៍?
១៥១-មេទ័ព ស៊ុនវ៉ូ និងរឿងគ្រឿងញៀន
១៥២-ជាប់នៅសៀមរាប តែផ្ទេរទៅភ្នំពេញ
១៥៣-សុំសាលានៅកន្លែងបោះឆ្នោត មើលម្រាមដៃសិន
១៥៤-មួយជីវិតយើងវាតែប៉ុណ្ណឹង
១៥៥-ប្រើឱ្យគ្រប់លទ្ធភាព ដើម្បីបម្រើពលរដ្ឋ
១៥៦-ចង់ឱ្យសង្គមរីកចម្រើន ទើបគាត់សុំយើង
១៥៧-គាត់សុំ ព្រោះគាត់ជឿយើង
១៥៨-បើជិះមិនខុស មានរស់រវីមួយរៀល!
១៥៩-ការចាប់ផ្តើមបណ្តុះបណ្តាលនគរបាលជាតិ

១៦០-រៀនហើយធ្វើ ធ្វើហើយរៀន!
១៦១-ប្រយ័ត្នលើសតែខ្វះ!
១៦២-ពីមុនរើសហើយចែក ឥឡូវចែកហើយចាំរើស
១៦៣-នគរបាលអាជីព
១៦៤-ខ្លាចអន់ខុសមួយ មិនកែខុសមួយទៀត
១៦៥-កុំផ្តោតតែព្រះសីហនុ!
១៦៦-កុំភ្លេចថាមានអធិការកិច្ច និងសវនកម្ម!
១៦៧-ក្រោយខ្មែរក្រហម សម្តេច ស ខេង កាន់៤ខេត្ត
១៦៨-ឈ្នះសមរភូមិក្បាលបឹងសេះជាមួយសម្តេច សាយ ឈុំ
១៦៩-ធនធានប្រែងកាត និងធនធានមនុស្ស
១៧០-សម្តេច ជា ស៊ីម និងសាកលវិទ្យាល័យនៅកំចាយមារ
១៧១-កុំរុញឱ្យគេទាល់ក្បៀនជញ្ជាំង
១៧២-លោក ខឹម វាសនា ប្រកាសត្រាស់ដឹង
១៧៣-ប្រតិបត្តិការ៣បូក១
១៧៤-ខ្មែរក្រហមសម្លាប់ទាំងគ្រួសារ
១៧៥-បំផុសឱ្យពលរដ្ឋចេះសួរយោបល់
១៧៦-ថ្នាក់ដឹកនាំឯលើ ស្គាល់មន្ត្រីមិនអស់ទេ
១៧៧-ម៉ែបង្ខាំងកូននៅខុសច្បាប់! ទម្រាំអ្នកដទៃ?
១៧៨-បើក្រុមហ៊ុនមានទំនាស់ជាមួយបុគ្គលិក
១៧៩-កម្មករ ក៏ជាម្ចាស់អគារ

១៨០-កសាងជាតិតាមគោលការណ៍នីតិរដ្ឋ មិនមែនល្បែងទេ!
១៨១-វិញ្ញាសាវាស់ឧត្តមគតិ ឆន្ទៈ និងសមត្ថភាព
១៨២-មេរោគមហារីកសង្គម
១៨៣-អៀនៗជាចរិតមួយនាំឱ្យអន់ថយ
១៨៤-ម្ចាស់ជំនួយគ្មានឱកាសមកថៃទាំទេ
១៨៥-ការគ្រប់គ្រងដែលនាំឱ្យសង្គមបែកបាក់
១៨៦-ទេសចរណ៍ និងសក្តានុពលមូលដ្ឋាន
១៨៧-បទពិសោធធ្វើស្បៀន!
១៨៨-ក្បាលមួយ មួកពីរ
១៨៩-លទ្ធផលរមិលគុណពលរដ្ឋឯង
១៩០-ពញ្ញាចក្រី ហេង សំរិន ជាមហាសាក្សី!
១៩១-ពេលថ្លែងនៅស្រុកកំណើត
១៩២-ខ្មាំងសត្រូវក្នុងសម័យសន្តិភាព
១៩៣-កូន និងក្មួយជួយសង់មត្តេយ្យនៅស្រុកកំណើត
១៩៤-ទៅជាថាមហាផ្ទៃប្រមូលអំណាច
១៩៥-ត្រូវប្រើគាត់ឱ្យបម្រើប្រជាជន
១៩៦-ចែកគ្នាធ្វើការ
១៩៧-ធំបំផុតអំណាចគ្រប់គ្រងមនុស្ស!
១៩៨-ករណីប៉ូលិសថៃញៀនបែកថ្នាំ
១៩៩-ព្រំដែនសិទ្ធិបញ្ចោញមតិ!

២០០-ខ្ញុំរៀនពី សម្តេចនាយក!
២០១-អំពើល្មើសពាក់ព័ន្ធហត្ថពលករខុសច្បាប់នៅកម្ពុជា
២០២-ភស្តុតាងនៃសាមគ្គីភាពផ្ទៃក្នុងជាតិ
២០៣-ដុំមាស ដុំពេជ្រ ប្រាជ្ញាប្រជុំអាស៊ាន
២០៤-យើងរួមគ្នាពង្រឹងភាពជាម្ចាស់នៅមូលដ្ឋាន
២០៥-ភូមិស្អាត ស្រែល្អ
២០៦-សារផ្ញើជូន អគ្គស្នងការ ក្រោយកិច្ចប្រជុំអាស៊ាន
២០៧-រម្លឹកប្រវត្តិរៀនសូត្រនៅកំចាយមារ
២០៨-ជួយជាតិឱ្យរស់លទ្ធភាព!
២០៩-មជ្ឈមណ្ឌលអប់រំដំបូង និងជាគំរូគេឯង
២១០-មិត្តបរទេសចាំតែជួយទេ
២១១-មិនតំបន់និយមនោះទេ
២១២-ឯកឧត្តម ជាវ តាយ សុំលាលែងពីអភិបាលខេត្ត
២១៣-មិនស្គាល់មុខ និងក៏មិនសូវលឺឈ្មោះ ប៉ុន្តែ...
២១៤-ច្បាប់មិនតម្រូវ តែយើងមានគោលការណ៍
២១៥-កុំឱ្យពួកឧក្រិដ្ឋជនកាច់សំបុកទាន់!
២១៦-បើគ្មានអំពើល្មើស ម្តេចមានជនរងគ្រោះ?
២១៧-តិចថាអត់យល់មួយ អត់យល់ពីរចុះ!
២១៨-សម័យយើង ឃើញផ្សែងឡានតាមហិត
២១៩-កូនបង្រៀនឪពុក

២២០-ធនធានមនុស្សគឺជាទ្រព្យសម្បត្តិគន្លឹះ
២២១-ចាប់បានតែគ្រឿងញៀន មិនទាន់ជោគជ័យទេ
២២២-សូម្បីអាល្លឺម៉ង់នៅមានអ្នកប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល
២២៣-លួចមាន់ លួចឆ្កែ អនុវត្តទោសសហគមន៍
២២៤-ដេញជើងមន្ត្រីខ្ជិល យកតែរូចខ្លួន
២២៥-វប្បធម៌បែងចែកក្រុមការងារចុះមូលដ្ឋាន
២២៦-សាលាពុកផុយ ឬគំនិតពុកផុយ?
២២៧-ប្រវត្តិទីតាំងសង់វិមានឯករាជ្យបាត់ដំបង
២២៨-ដណ្តើមអំណាចតាមចុងបិច កុំចុងកាំភ្លើង!
២២៩-បើមិនប្រយ័ត្ន យើងអាចលិចលង់
២៣០-ផ្តាំក្រុងបាត់ដំបង
២៣១-ទ្រព្យសម្បត្តិដូនតា
២៣២-សង្គមមួយដែលល្អទៅបាន
២៣៣-មន្ត្រីខ្មែរឥស្លាម
២៣៤-ធ្វើជាប្រចាំនិងគ្មានទីបញ្ចប់
២៣៥-វិជ្ជាជីវៈ និងយុត្តិធម៌
២៣៦-ការប្រើកម្លាំងឱ្យចំជំនាញ
២៣៧-ប្រពន្ធ និងតំណែងចៅហ្វាយស្រុក យកមួយណា?
២៣៨-ស្មើទូតអាមេរិកប្រាប់ សម រង្ស៊ី ដកផែនការ
២៣៩- ជាខ្មែរដែរទេ ម្តេចនិយាយមិនចេះគិត!

២៤០-បើមិនប្រើវិធីបោះឆ្នោត ខ្មែរនឹងរវល់តែច្បាំងគ្នា

ចំណាប់អារម្មណ៍

បើមិនចាប់ផ្តើមផង ម្តេចនឹងមានបទពិសោធ...!

ខ្ញុំរីករាយណាស់ នៅពេលដឹងថាសហការីខ្ញុំ គឺលោក **វ៉ែន វ៉ែនៈ** បានបន្តរៀបរៀងសៀវភៅ **ទស្សនៈសម្តេចក្រឡាហោម ស ខេង ឆ្នាំ២០២២** ដែលជាស្នាដៃទី៣ របស់គាត់។ ការរីករាយនេះ គឺដោយសារខ្ញុំដឹងច្បាស់ថា គាត់មានបន្ទុកការងារច្រើនត្រូវទទួលខុសត្រូវ....។

ខ្ញុំក៏ជាអ្នកនិពន្ធ និងរៀបរៀងសៀវភៅមួយរូបដែរ ហើយខ្ញុំដឹងច្បាស់ថា ការងារនេះ នឹងមិនអាចសម្រេចទៅបានដោយងាយៗឡើយ ប្រសិនបើគ្មានការព្យាយាម និងការយកចិត្តទុកដាក់ស្វែងយល់ឱ្យបានស៊ីជម្រៅ។ ជាក់ស្តែងខ្លឹមសារនៃសៀវភៅនេះបានបញ្ជាក់ឱ្យឃើញច្បាស់ថា អ្នករៀបរៀងបានខិតខំសម្រិតសម្រាំង ពាក្យពេចន៍ប្រកបដោយអត្ថន័យដែល **សម្តេចក្រឡាហោម ស ខេង** មានប្រសាសន៍ក្នុងកិច្ចប្រជុំ និងកម្មវិធីជាច្រើនកន្លែង នាអំឡុងពេលកាន់មុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ខ្ញុំសង្ឃឹមថាសៀវភៅនេះ នឹងបន្តរួមចំណែកផ្តល់នូវពុទ្ធិល្អៗជូនអ្នកអានទាំងឡាយ ដែលស្រេកឃ្លានចំណេះដឹង ស្របតាមទស្សនៈ ***រៀនជាដរាប និងគ្មានទីបញ្ចប់***...។

សូមជូនពរ អ្នករៀបរៀង មានសុខភាពល្អ មានសំណាងល្អ និងសូមទទួលបានជោគជ័យគ្រប់ភារកិច្ច....។

ថ្ងៃចន្ទ ១០រោច ខែមិគសិរ ព.ស.២៥៦៩

ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥

ឆួច សុឃៈ

អ្នកនាំពាក្យរាជរដ្ឋាភិបាល

សេចក្តីថ្លែងអំណរគុណ!

នេះជាសៀវភៅទី៣ហើយ ដែលខ្ញុំបានសរសេររៀបរៀងអំពីទស្សន: **សម្តេចក្រឡាហោមសខែង**។ ខ្ញុំសូមអរគុណលោក លោកស្រី ដែលកន្លងទៅបានរួមចំណែកជួយជ្រោមជ្រែងការរៀបចំសៀវភៅទី១ និងទី២។ ស្នាដៃនេះ ខ្ញុំសូមថ្លែងអំណរគុណលោកបងរបស់ខ្ញុំ ព្រមទាំងលោក លោកស្រី ដែលបានចូលរួមជ្រោមជ្រែង រួមទាំងជួយពិនិត្យអក្ខរាវិរុទ្ធសៀវភៅនេះ រួមមាន ព្រះភិក្ខុ យ៉ា យ៉ាន លោក រឿន ភារុន លោក ប៊ិន ប៊ុណ្ណា លោក សំ នឿន លោក ម៉ឺន រស្មី លោក ច័ន្ទ សុភាព លោក រស់ សុខហ៊ាង លោក ឆាយ រដ្ឋា លោក វ៉ែន ពន្លឺ លោក សេង បូលីន លោក ចិន ណារិន កញ្ញា អន អមរា កញ្ញា សេង សុខហ៊ិន លោក គង់ សារ៉ាន់ និងលោក ម៉ែន សុភក្ត្រា។

ខ្ញុំសូមក៏សូមអរគុណជាអនេកចំពោះ លោក ហេង ដារ៉ា និងលោក ឃឿន សុឃុន ដែលបានជួយរចនាក្របសៀវភៅនេះ។

ក្នុងចំណោះនេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី មិត្តអ្នកអាន ដែលតែងតែផ្តល់ការលើកទឹកចិត្ត និងផ្តល់មតិយោបល់ល្អៗ មកកាន់ខ្ញុំ ដើម្បីអភិវឌ្ឍន៍ការងាររៀបរៀងសៀវភៅនេះ តាំងពីដើមគ្រារហូតមក...។

សេចក្តីផ្តើម

ទស្សន:របស់ សម្តេចក្រឡាហោម ស ខេង ទាំង **២៤០ ចំណងជើង** ក្នុងស្បៀវភៅនេះ ជាសម្រង់ខ្លឹមសារ ដែលខ្ញុំបាទជា អ្នករៀបរៀង យល់ឃើញជារឿងនោមតថាមានតម្លៃសម្រាប់ អ្នកអាន។ អ្នកអាន ឬមហាជនទូទៅ ជាពិសេសអ្នកបានស្តាប់ ប្រសាសន៍ **សម្តេចក្រឡាហោម** ផ្លែងក្នុងកម្មវិធីនានា ពេញមួយ ឆ្នាំ២០២២នោះក៏អាចមានចំណាប់អារម្មណ៍លើប្រសាសន៍ជា ច្រើនទៀតរបស់ **សម្តេច** ដែរ។

ខុសពីស្បៀវភៅ **ទស្សន:សម្តេចក្រឡាហោម ស ខេង ឆ្នាំ ២០២០** និង**ឆ្នាំ២០២១** ស្នាដៃនេះ ពុំដាក់បញ្ចូលរូបភាពឡើយ។ ម្យ៉ាងដើម្បីកុំឱ្យស្បៀវភៅកាន់តែក្រាស់ និងម្យ៉ាងទៀត ដើម្បីទុក លទ្ធភាព ជូនមិត្តអ្នកអានបានផ្តោតអារម្មណ៍ ទៅលើខ្លឹមសារ ទស្សន:នីមួយៗ។ ផ្តើមពីខ្លឹមសារទី១ មានចំណងជើងថា **សច្ចធម៌ ប្រវត្តិសាស្ត្រ កម្ពុជា-វៀតណាម** ស្បៀវភៅនេះ នឹងបញ្ចប់ដោយ ខ្លឹមសារទី២៤០ មានចំណងជើងថា **បើមិនប្រើវិធីបោះឆ្នោតខ្មែរ នឹងរវល់តែច្បាំងគ្នា**....។

តទៅនេះ សូមគោរពរអញ្ជើញមិត្តអ្នកអាន ស្វែងយល់ពី ទស្សន: **សម្តេចក្រឡាហោម ស ខេង** ដោយមេត្រីភាព...។

សូមអរគុណ!

«...យើងត្រូវហ៊ានជម្នះឧបសគ្គ និងការលំបាក
ដើម្បីប្តូរយកបទពិសោធ...»

១-សច្ចធម៌ប្រវត្តិសាស្ត្រ កម្ពុជា-វៀតណាម

*"បើនិយាយអំពីទំនាក់ទំនង រវាងកម្ពុជាយើង និងប្រទេសវៀតណាម យើងធ្លាប់ជួយវៀតណាម ដើម្បីឈានទៅឯកភាពទឹកដី រវាងវៀតណាមខាងជើង និងវៀតណាមខាងត្បូង។ ឯខាងវៀតណាមវិញ ក៏ធ្លាប់ជួយយើង វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ដែរ។ នេះជាប្រវត្តិសាស្ត្រ និងក៏ជាសច្ចធម៌ដ៏ជាក់ស្តែងមួយ ដែលយើងទាំងអស់គ្នា មិនអាចនឹងបំភ្លេចបានឡើយ"*

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ពិធីសម្ពោធមណ្ឌលហែលទឹកបាត់ដំបង ស្ថិតក្នុងបរិវេណសាកលវិទ្យាល័យជាតិបាត់ដំបង ក្រុងបាត់ដំបង

២-ត្រៀមខ្លួនចំពោះផ្លូវទៅមុខនៃជាតិយើងជានិច្ច

“ទាល់តែមានសន្តិភាព ទើបយើងអាចធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងនាំមកនូវជីវភាពដ៏សុខសាន្ត សម្បូរសប្បាយរបស់ប្រជាជនយើងបាន។ មានសន្តិភាព ទើបអាចធានាការឋិតថេរនៃសេរីភាព និងលទ្ធភាពធ្វើដំណើរគ្រប់ទិសទីដូចសព្វថ្ងៃ។ ដូច្នេះ ការបាត់បង់សន្តិភាព ជាការបាត់បង់អ្វីៗទាំងអស់។ យើងមានសុខសន្តិភាពជាង២ទសវត្សរ៍មែន ក៏ប៉ុន្តែ មិនត្រូវភ្លេចខ្លួនជាដាច់ខាត! ត្រូវត្រៀមខ្លួនជានិច្ចចំពោះផ្លូវទៅមុខនៃជាតិយើង ដែលអាចនឹងជួបប្រទះ នូវឧបសគ្គជាច្រើន ហើយដែលយើងត្រូវរួមគ្នាដោះស្រាយចាប់ពីបច្ចុប្បន្ននេះទៅ”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ពិធីសម្ពោធមណ្ឌលហែលទឹកបាត់ដំបង ស្ថិតក្នុងបរិវេណសាកលវិទ្យាល័យជាតិបាត់ដំបង ក្រុងបាត់ដំបង

៣-ឱ្យតែយើងរក្សាបានឯកភាព និងសាមគ្គីភាព

"ឱ្យតែយើងរក្សាបាននូវឯកភាព និងសាមគ្គីភាព គឺគ្មានឧបសគ្គណាមួយអាចមកការារាំងដំណើរទៅមុខនៃជាតិយើង បានឡើយ។ ដូច្នេះ យើងត្រូវតែប្តេជ្ញាដាច់ខាត ការពារសន្តិភាពដែលយើងរកបានដោយលំបាកនេះ ឱ្យនៅឋិតថេរគង់វង្ស។ យើងមិនអនុញ្ញាតឱ្យកម្លាំងណាមួយ មកបំផ្លាញសុខសន្តិភាពរបស់យើងបានឡើយ ទោះជាត្រូវបង់ខាតក្នុងតម្លៃណាក៏ដោយ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ពិធីសម្ពោធមណ្ឌលហែលទឹកប៉ាត់ដំបង ស្ថិតក្នុងបរិវេណសាកលវិទ្យាល័យជាតិប៉ាត់ដំបង ក្រុងប៉ាត់ដំបង

៤-ស្មើគ្នាចំពោះមុខច្បាប់ និងគោលការណ៍

"យើងខ្ញុំជាអ្នកដឹកនាំ យើងទទួលខុសត្រូវណាស់។ ដូច្នេះ មន្ត្រីយើងនៅហ្នឹងកន្លែង ឬអ្នកដឹកនាំផ្ទាល់នៅមូលដ្ឋានក៏ត្រូវប្រកាន់គោលការណ៍ឱ្យជាក់លាក់ ត្រូវគោរពច្បាប់ និងលក្ខន្តិក: នគរបាលជាតិដែលនៅជាធរមានដែរ។ ឈរស្មើគ្នាចំពោះមុខច្បាប់ និងគោលការណ៍ ដោយមិនត្រូវផ្អែកលើមនោសញ្ចេតនា ស្រលាញ់រាប់អាន ឬសាច់ញាតិមិត្តភក្តិនោះទេ។ មានន័យថា បើមន្ត្រីហ្នឹងគាត់ធ្វើការងារបានល្អ! យើងត្រូវតែផ្តល់ការលើកទឹកចិត្តឱ្យគ្នា ឬក៏មន្ត្រីណាមានស្នាដៃពិសេសអ្វីមួយ យើងក៏យកចិត្តទុកដាក់ជាពិសេសទៅតាមហ្នឹងដែរ ដោយផ្តល់នូវការតម្លើងឋានន្តរស័ក្តិ និងតួនាទី ទៅតាមសមត្ថភាព និងជំនាញជាដើម"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ពិធីប្រគល់រថយន្តជូនវរសេនាតូចនគរបាលការពារព្រំដែនគោក

៥-គ្រឿងញៀនវាយលុកសង្គមយើងហើយ

"យើងមិនត្រូវភ្លេចទេថា សព្វថ្ងៃ បើទោះជាមានសន្តិភាពពេញផ្ទៃប្រទេសក្តី ក៏ប៉ុន្តែបញ្ហាសន្តិសុខ ក៏យើងត្រូវតែបន្តយកចិត្តទុកដាក់ជាប្រចាំ ដូចជាអំពើលួច ឆក់ ប្លន់ ពិសេសបទល្មើសគ្រឿងញៀន។ តើអ្នកទាំងអស់គ្នាដឹងទេ! សព្វថ្ងៃយើងមានអ្នកជាប់ឃុំជាង ៣ម៉ឺននាក់ ទូទាំងប្រទេស។ បើគិតជាភាគរយនៃអ្នកជាប់ឃុំសរុបនេះ អ្នកពាក់ព័ន្ធគ្រឿងញៀនមានប្រមាណ ***៥៤,៥២ភាគរយ***។ *មានន័យថា គ្រឿងញៀនបានវាយលុកសង្គមយើងហើយ។ យើងមិនអាចមើលរំលងបានទេ"*

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ពិធីប្រគល់រថយន្តជូនវរសេនាតូចនគរបាលការពារព្រំដែនគោក

៦-ប្រយ័ត្នជំពាក់ការទទួលខុសត្រូវចំពោះសង្គមជាតិ

"យើងរកឃើញសារធាតុគីមី អាចផ្សំជាគ្រឿងញៀនត្រូវគេដឹកចូលប្រទេសដោយស្របច្បាប់រាប់សិបតោន។ សួរថាបញ្ហានេះអ្នកណាទទួលខុសត្រូវ? ជាដំបូងគឺត្រូវរកឱ្យឃើញអ្នកទទួលខុសត្រូវ! នរណានាំគ្នាស៊ីញ៉ែ (ចុះហត្ថលេខា) អនុញ្ញាតឱ្យនាំចូល! បន្ទាប់មកយើងរួមគ្នាដោះស្រាយ។ ការនាំសារធាតុផ្សំជាគ្រឿងញៀនចូលមកនេះ វាក៏ប្រៀបដូចចោរលួចឡានពីថៃមកខ្មែរអីចឹងដែរ។ ចោរវាមិនអាចនាំឡានទាំងមូលចូលមកទេ ប៉ុន្តែម្តងវានាំកង់ ម្តងនាំចង្កៀង ម្តងនាំម៉ាស៊ីន...ចុងក្រោយផ្គុំជាឡានតែម្តង។ ដូច្នេះ ក្រសួងផ្តល់អាជ្ញាបណ្ណ...ខ្ញុំនិយាយប៉ុណ្ណឹងដឹងហើយ! មិនបាច់ចំឈ្មោះទេ! សូម ឯកឧត្តមរដ្ឋមន្ត្រី មើលរឿងហ្នឹង។ មិនអីចឹងទេ ឯកឧត្តម នឹងជាប់ជំពាក់ការទទួលខុសត្រូវចំពោះសង្គមជាតិ ទាក់ទងការបំផ្លាញសុខភាពសាធារណៈ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ពិធីប្រគល់រថយន្តជូនវរសេនាតូចនគរបាលការពារព្រំដែនគោក

៧-ខ្ញុំនិយាយបែបឆ្ងន់បន្តិចមែន ក៏ប៉ុន្តែ...

“អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវជួយប្រាប់ក្រសួងពាក់ព័ន្ធឱ្យដឹងថាមានសារធាតុអ្វីខ្លះ ដែលគេអាចផ្សំជាគ្រឿងញៀន រួចហើយធ្វើបញ្ជីឱ្យក្រសួងពាក់ព័ន្ធដឹង។ ក្រសួងនៅពេលចេញអាជ្ញាបណ្ណ ត្រូវតែបញ្ជូនព័ត៌មានមកអាជ្ញាធរគ្រឿងញៀន មកអគ្គស្នងការ ឬក្រសួងមហាផ្ទៃដឹងដែរថា ខ្លួនអនុញ្ញាតហើយ ដូច្នេះសូមជួយតាមដានសារធាតុហ្នឹងផងថាវាទៅដល់ណា ឬគេយកធ្វើអ្វី ព្រោះបើតាមគេសុំអាជ្ញាបណ្ណ គេសុំនាំចូលមកធ្វើជី។ រឿងពិតវាមានទៅធ្វើជីស្អី! ទីបំផុតវាយកធ្វើថ្នាំញៀន។ យ៉ាងម៉េចបានមិនទាក់ទងគ្នា! មិនផ្តល់ព័ត៌មានឱ្យគ្នា សូមមើលរឿងហ្នឹង កុំមើលស្រាលវាឱ្យសោះ ខ្ញុំនិយាយនេះបែបឆ្ងន់បន្តិចមែន ក៏ប៉ុន្តែត្រូវតែនិយាយ។ សូមទោស! ខ្ញុំគ្មានបំណងអ្វីក្រៅតែពីដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ចុះបើរកឃើញរាប់តោនអីចឹងៗ តើឱ្យធ្វើយ៉ាងម៉េច? យើងត្រូវទទួលស្គាល់ថាយើងមានការខ្វះខាតលើចំណុចនេះ ហើយនាំគ្នាកែលម្អទាំងអស់គ្នា”

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ពិធីប្រគល់រថយន្តជូនវរសេនាតូចនគរបាលការពារព្រំដែនគោក

៨-អាជ្ញាធរ ត្រូវឈរកណ្តាល ហើយអត់ធ្មត់

"ខ្ញុំសូមរម្លឹកអាជ្ញាធរនិងសមត្ថកិច្ចយើងថា ទាក់ទងការតវ៉ារបស់បុគ្គលិកធ្វើការនៅក្រុមហ៊ុនណាហ្គាវើលដ៍ ត្រូវចាំថាករណីនេះជាជម្លោះការងារ ជាវិវាទការងាររវាងក្រុមហ៊ុន និងបុគ្គលិក។ បញ្ហានេះ មានយន្តការគណៈកម្មការដោះស្រាយវិវាទ ដែលមានក្រសួងការងារជាអ្នកនាំមុខ។ អាជ្ញាធរពាក់ព័ន្ធរដ្ឋបាលរាជធានី និងនគរបាលយើងជាដើម សូមបន្តអត់ធ្មត់ និងត្រូវប្រកាន់ជំហរសម្របសម្រួលក្នុងនាមជាអាជ្ញាធរ។ ខ្ញុំសូមភាគីពាក់ព័ន្ធមេត្តាអត់ធ្មត់តទៅទៀត ហើយខិតខំរកវិធីបញ្ចប់ឱ្យបានឆាប់កាលណាក៏ល្អកាលណាហ្នឹង។ បើយើងចេះតែបែរខ្នងដាក់គ្នារហូត មុខជាដោះស្រាយយ៉ាងម៉េចក៏មិនចប់ដែរ។ បើងាកមើលមុខគ្នាបន្តិចម្តងៗ ហើយនិយាយគ្នា ប្រហែលជាអាចរកឃើញដំណោះស្រាយបានឆាប់ជាងនេះ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ពិធីប្រគល់រថយន្តជូនវរសេនាតូចនគរបាលការពារព្រំដែនគោក

៩-ភូមិន្ទរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន

"ក្រោយកិច្ចព្រមព្រៀងក្រុងប៉ារីស យើងក៏បានគិតគូរជាមុនហើយថា ពិតជានឹងមានការរៀបចំក្រសួងមហាផ្ទៃ។ អរិចឹងបានជាយើងបង្កើតក្រសួងនេះ ក្រោយកិច្ចព្រមព្រៀង។ ខ្ញុំត្រូវបានគណបក្ស និងរាជរដ្ឋាភិបាលផ្តល់សេចក្តីទុកចិត្ត ឱ្យធ្វើជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាប់ពីពេលនោះមក។ យើងក៏យកចិត្តទុកដាក់រៀបចំសាលាបណ្តុះបណ្តាល គឺសាលាភូមិន្ទរដ្ឋបាល ដែលមានរហូតមកដល់បច្ចុប្បន្ន។ ចំណែកសាលាជាតិរដ្ឋបាលមូលដ្ឋាន ដែលបង្កើតឡើងនៅក្រោមក្រសួងមហាផ្ទៃនេះ ក៏មានតួនាទី និងសារសំខាន់មិនខុសអ្វីពីសាលាភូមិន្ទរដ្ឋបាលនោះដែរ។ គ្រាន់តែសាលាជាតិរដ្ឋបាលមូលដ្ឋាន យើងផ្តោតតែលើការបណ្តុះបណ្តាលមុខសញ្ញាមន្ត្រី ដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១០-អ្នកមូលដ្ឋានក៏ជាម្ចាស់ទឹកដីនេះដែរ

“ខ្ញុំជឿថានៅមានអ្នកគិតថា បើអញឡើងរដ្ឋមន្ត្រី អញត្រូវក្តាប់អំណាចទាំងអស់! ខ្ញុំថាមិនត្រូវមានទស្សនៈដូច្នេះទេ។ យើងត្រូវចែកការងារគ្នាធ្វើ ពីព្រោះយើងម្នាក់ឯងមិនអាចធ្វើអស់ទេ។ យើងធ្វើតែការងារទាក់ទងនឹងអធិបតេយ្យជាតិ យកចិត្តទុកដាក់គិតគូរ តែលើការងារមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស ហ្នឹងហើយការងាររដ្ឋមន្ត្រី។ តែបើកិច្ចការហ្នឹងទាក់ទងមូលដ្ឋាន ពាក់ព័ន្ធជីវភាពប្រចាំថ្ងៃប្រជាពលរដ្ឋ យើងចែកទៅឱ្យគេ ដែលនៅក្បែរប្រជាពលរដ្ឋហ្មងធ្វើទៅ។ ចែកហ្នឹងក៏មិនមែនថា ការងារហ្មងយើងផ្ទេរឱ្យធ្វើហើយ លោកឯងធ្វើទៅ! ប៉ុន្តែបើមិនឱ្យលុយគ្នាធ្វើ មិនឱ្យមនុស្សគ្នាប្រើ តើឱ្យគ្នាធ្វើការម៉េចហ្នឹងកើត! ត្រូវចាំថាទឹកដីនេះ វាជាទឹកដីយើងទាំងអស់គ្នា! មិនមែនជារបស់នរណាម្នាក់ទេ! ដូច្នេះយើងរំលែកការងារគ្នាធ្វើទៅ”

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១១-និយាយឱ្យគេស្តាប់បាន ហើយយកទៅធ្វើកើត

"ពេលប្រជុំ ឬណែនាំអ្វីមួយ ជាទម្លាប់ខ្ញុំ គឺខ្ញុំនិយាយឱ្យគេស្តាប់បាន និយាយឱ្យគេអាចធ្វើកើត។ អីចឹងទេ! ពេលខ្លះមិនចាំបាច់និយាយវែងពេកទេ។ វែងពេកវានាំឱ្យច្របូកច្របល់យើងអ្នកនិយាយផង ពិសេសច្របូកច្របល់ដល់គ្នាដែលជាអ្នកស្តាប់នោះផង"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១២-យុវជនបន្តវេនដើម្បីអ្វី?

"យុវជនយើងត្រូវក្តាប់ឱ្យជាប់នូវតួនាទីខ្លួន! តួនាទីខ្លួនឈរនៅត្រង់ណា? ហើយធ្វើអ្វី? ចម្លើយ គឺបញ្ហានេះ មិនជាពិបាកយល់ទេ ព្រោះយើងទាំងអស់គ្នាដឹងហើយថា យុវជនជាទំពាំងស្នងឫស្សី ជាអ្នកបន្តវេន ប៉ុន្តែបន្តវេនដើម្បីអ្វី? គឺបន្តវេនដើម្បីការពារជាតិ ការពារទឹកដី ជំរុញការរីកចម្រើន និងការកសាងប្រទេសជាតិ ការពារឯករាជ្យ និងអធិបតេយ្យជាតិឱ្យឋិតថេរគង់វង្ស។ ដូច្នេះ ផ្អែកលើតួនាទីស្នូលនេះ តើយុវជនត្រូវធ្វើអ្វីខ្លះ? ខ្ញុំគិតថាដំបូងបំផុតគឺឧត្តមគតិ! យុវជនត្រូវតែបំពាក់ឱ្យខ្លួននូវឧត្តមគតិស្នេហាជាតិ និងប្រជាជនឱ្យបានជាជាច់ខាត ព្រមទាំងលើកកម្ពស់ជាប្រចាំ នូវឧត្តមគតិដ៏បរិសុទ្ធនេះ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៣-អ្នកខ្លះយកពាក្យស្នេហាជាតិធ្វើជាខែល

*"អ្នកខ្លះគ្រាន់តែចេះស្រែកស្នេហាជាតិៗ ប៉ុន្តែយកជាតិឯងធ្វើជាខែល ទីបំផុតធ្វើសកម្មភាពបំផ្លិចបំផ្លាញជាតិឯង។ ឥស្សរជនគណបក្សប្រជាជនកម្ពុជា ប្រមាណ៦០នាក់ ដែលហ៊ានក្រោកឡើងប្រឆាំងរបបប្រល័យពូជសាសន៍ **ប៉ុល ពត** រួមគ្នាខិតខំកសាង និងអភិវឌ្ឍន៍ជាតិដល់សព្វថ្ងៃ យើងចាត់ទុកថាជាអ្នកស្នេហាជាតិដ៏បរិសុទ្ធហើយ"*

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៤-លើកកម្ពស់ផលប្រយោជន៍ជាតិ

"យុវជនត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ពាក្យហ្នឹងគឺយើងដឹង! យើងលឺគ្រប់ៗតៃគ្នាមែន! ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែអាចធ្វើបានទេ។ អ្នកខ្លះ ចេះតែនិយាយថា តម្កល់ផលប្រយោជន៍ជាតិ តែបម្រើតែផលប្រយោជន៍ក្រុម បក្ខពួក និងគ្រួសារឯង។ អីចឹង ការលើកកម្ពស់ផលប្រយោជន៍ជាតិនឹងធ្វើឱ្យជាតិយើងខ្លាំង រឹងមាំ ឋិតថេរ គង់វង្ស"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៥-វប្បធម៌ផលប្រយោជន៍ជាតិរបស់មន្ត្រីជប៉ុន

"ខ្ញុំជួបឥស្សរជនបរទេស ពិសេសជនជាតិជប៉ុន។ ពេលគាត់នៅធ្វើជាឯកអគ្គរាជទូត ការស្លៀកពាក់ហូរហែទៅតាមលក្ខណៈជាទូត ឬចំណាយថវិកាទាំងឡាយក្នុងក្របខ័ណ្ឌទូត ប៉ុន្តែពេលចប់បេសកកម្ម យើងសង្កេតឃើញគាត់ នៅបន្តធ្វើអ្វីៗទាំងអស់ដើម្បីជាតិគាត់ដដែល។ មិនមែនជាអ្នកហ៊ឺហា ឬក៏មានជាន់លើសលុបអ្វីទេ។ ទូតជប៉ុនភាគច្រើនពេលចប់អាណត្តិពីកម្ពុជា មួយចំនួនធំក៏វិលមកវិញ។ ប្រហែលមានគោលការណ៍ណាមួយក៏មិនដឹង។ អាចថាមកពីគាត់ធ្លាប់រស់នៅ និងស្គាល់ប្រវត្តិសាស្ត្រ ប្រពៃណី វប្បធម៌ខ្មែរ។ អីចឹង គាត់មកធ្វើការងារនៅខ្មែរវិញ អាចបង្កើតជាក្រុមហ៊ុន ឬជាសមាគមដើម្បី ជួយលើកម្ពស់មុខមាត់ជាតិគាត់ និងទំនាក់ទំនងជាមួយកម្ពុជាយើងដែលនេះស្តែងឱ្យឃើញថាគាត់ក៏បានធ្វើការ ដើម្បីប្រយោជន៍ជាតិមួយដែរ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៦-យុវជនក្នុងឋានៈជាសមាជិកបក្ស

"បើក្នុងឋានៈជាសមាជិកបក្ស យុវជនយើងចាំបាច់ត្រូវគោរពនិងអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីនយោបាយបក្សឱ្យបានជាប់ជាប្រចាំ និងឱ្យបានល្អ ដើម្បីមានមូលដ្ឋានធ្វើការងារ មានគំនិតផ្តួចផ្តើម ចេះច្នៃប្រឌិត ចេះលើកដៃគន្ការ រៀបចំកម្មវិធីការងារ និងចេះកំណត់ទិសដៅការងារឱ្យសមស្រប។ យើងក៏ត្រូវភ្ជាប់ឱ្យជាប់ស្ថានភាពជាក់ស្តែង និងសភាពការណ៍ប្រែប្រួលក្នុងសមត្ថកិច្ច ឬពាក់ព័ន្ធសមត្ថកិច្ចយើងដែរ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៧-ជម្នះឧបសគ្គ ប្តូរយកបទពិសោធ

"យុវជនយើងត្រូវលត់ដំកសាងខ្លួនឱ្យមានសមត្ថភាព មានចំណេះដឹង គុណធម៌ និងចាំបាច់ត្រូវតែខិតខំតស៊ូរៀនសូត្រជាប្រចាំ។ អាចរៀនសូត្រតាមរយៈសាលារៀន រៀនសូត្រពីប្រជាពលរដ្ឋ ពីមិត្តភក្តិជុំវិញ និងរៀនពីសភាពការណ៍ប្រចាំថ្ងៃ។ ការរៀនយ៉ាងដូច្នេះ វានឹងជួយដុសខាត់ការយល់ដឹងយើងឱ្យកាន់តែភ្លឺស្វាង ក្តាប់បញ្ហាបានច្រើន និងងាយស្រួលក្នុងការដោះស្រាយបញ្ហា។ យើងត្រូវហ៊ានជម្នះឧបសគ្គ និងការលំបាក ដើម្បីប្តូរយកបទពិសោធ។ បទពិសោធជាមូលដ្ឋានបង្អែកដ៏សំខាន់មួយ។ បើយើងគេចពីការលំបាកក៏វាចេះតែបានដែរ ប៉ុន្តែវាមិនអាចជួយពង្រឹងខ្លួនយើងបានឡើយ។ ផ្ទុយទៅវិញវានឹងធ្វើឱ្យយើងក្លាយជាមនុស្សទន់ខ្សោយទៅៗ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៨-ផ្លូវក្បែរផ្លូវជាតិ បច្ចុប្បន្នសម្បូរ អនាគតនឹងខ្សត់

"ការសាងសង់ផ្ទះសម្បែងតាមទីប្រជុំជនមានផ្លូវធំៗឆ្លងកាត់ អាហ្នឹងអាជ្ញាធរយើងកន្លងទៅជួនអីធ្មេចភ្នែក។ ទីបំផុតវាជាការធ្វើបាបប្រជាពលរដ្ឋទៅវិញទេ ប្រសិនយើងមិនហ្មត់ចត់តម្រូវឱ្យពួកគាត់គោរពច្បាប់ដែលកំណត់អំពីចម្ងាយពីផ្លូវមកផ្ទះដើម្បីធានាសុវត្ថិភាព។ ប៉ុន្តែខ្ញុំក៏ជឿថាដោយសារការអភិវឌ្ឍជាពិសេសមានហេដ្ឋារចនាសម្ព័ន្ធកាន់តែច្រើន ប្រជាពលរដ្ឋតាមទីប្រជុំជន តាមដងផ្លូវហ្នឹង នឹងដកថយមិនខានទេ។ ព្រោះអ្វី? ព្រោះផ្សែងឡានពុល សំឡេងឡានម៉ូតូផ្តង់ ហើយយូរៗទៅសុខភាពចុះខ្សោយ ដោយសារសម្រាន្តមិនបាន។ ឡានបើកបរច្រើនគាត់នឹងខ្លាច និងមិនចង់នៅក្បែរផ្លូវវិញហើយ។ ម្យ៉ាងបើមានការអភិវឌ្ឍកាន់តែច្រើន គាត់ចង់ទៅនៅឯណាក៏បានដែរ ព្រោះមានផ្លូវតូចធំ ភ្លើង ទឹក ឬមានសាលារៀន...។ គាត់ចង់ដាក់ម៉ាស៊ីនត្រជាក់ក៏បាន ចង់ដាក់ភ្លើងបំភ្លឺពេលយប់ក៏បាន។ ឥឡូវគាត់នៅធ្ងំគ្នាកន្លែងណាមានអារអស់ហ្នឹងសិន គាត់នៅកន្លែងមានផ្លូវ មានភ្លើង មានទឹកហ្នឹងសិន តែបន្តិចទៀតនឹងប្រែប្រួលហើយ សូម្បីតែលូវនេះក៏ចាប់ផ្តើមប្រែប្រួលបណ្តើរៗដែរហើយ ម្នាក់ៗរកតែក្បែរបឹង ក្បែរព្រែកំ ស្ងាត់ៗ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍

១៩-អ្វីៗតែងតែមានទំនាស់និងបញ្ហា

"ទ្រឹស្តីគេនិយាយថា អ្វីៗតែងតែមានទំនាស់និងបញ្ហាជាធម្មតា។ ដូចថា កាលពីមិនទាន់មានផ្លូវក៏មានទំនាស់ដែរ ទំនាស់ព្រោះអត់ផ្លូវធ្វើដំណើរ។ ដល់តែមានផ្លូវក៏មានឡានច្រើន នាំឱ្យមានបញ្ហាទៀត។ បញ្ហា ឬទំនាស់ គឺឡានច្រើនជាងផ្លូវ ផ្លូវក៏ស្ទះ ផ្លូវក៏ឆាប់ខូច។ ម្យ៉ាងទៀត កាលពីមុន ផ្លូវមិនសូវស្អាត គាត់មិនសូវបើកបរលឿនៗទេ ដល់ឥឡូវមានផ្លូវល្អ គាត់ក៏បើកលឿនៗ ព្រោះថ្នាក់ក៏ច្រើន ក៏នាំឱ្យមានទំនាស់ និងបញ្ហាច្រើនដូចគ្នា"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍

២០-ពិចារណាបង្កើតវិធីសាស្ត្រជួយបន្សាបអ្នកញៀនថ្នាំ

“ខ្ញុំកំពុងគិតជាមួយបណ្តាថ្នាក់ដឹកនាំ និងសហការី ដើម្បីដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារ និងរកវិធីជួយបន្សាបអ្នកញៀនគ្រឿងញៀន។ យើងអាចសិក្សាយកអ្នកសេពគ្រឿងញៀនទៅដាក់កន្លែងណាមួយ រួចហើយឱ្យពួកគាត់ធ្វើពលកម្ម អាហ្នឹងអាចធ្វើបាន។ ប្រទេសគេក៏ធ្វើអីចឹងដែរ គេឱ្យធ្វើការ ធ្វើពលកម្ម ដាំបន្លែ ធ្វើនេះ ធ្វើនោះ មួយថ្ងៃយ៉ាងហោចណាស់ក៏ ៨ម៉ោង ដែរ។ យើងសាកល្បងធ្វើ ហើយសូមអំពាវនាវឱ្យមានការចូលរួមគាំទ្រផង។ យើងខ្ញុំក៏ចង់បានដែរ ការរិះគន់ឬជួយគំនិតយោបល់ ប៉ុន្តែក៏ចង់បានការចូលរួមជាក់ស្តែង ថាតើអាចជួយឬអាចធ្វើអ្វីបានខ្លះ? មិនមែនយើងមិនចង់បានមតិយោបល់ ឬការរិះគន់ទេ! តែយើងចង់បានការចូលរួមជាក់ស្តែង! ចូលរួមដោះស្រាយបញ្ហាសង្គមទាំងអស់គ្នា។ ថ្នាក់ខេត្តក៏ដូចគ្នា តើយើងធ្វើអ្វីបានខ្លះ? យើងនាំគ្នាធ្វើទៅ។ យើងអាចយកពួកគាត់ទៅដាក់មួយកន្លែង ឱ្យគាត់ធ្វើស្រែ ដាំបន្លែ ធ្វើពលកម្ម ហើយរៀបចំអ្នកគ្រប់គ្រង។ ខ្ញុំជឿថាត្រឹមវិធានការប៉ុណ្ណឹងៗ ពួកយើងខេត្តៗនឹងអាចធ្វើបាន”

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍

២១-មិនមានបំណងអ្វី ក្រៅពីចង់រួមចំណែក

"ខ្ញុំមិនមានបំណងអ្វី ក្រៅតែពីចង់រួមចំណែករអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ ពិសេសសហគ្រាសធុនតូច និងមធ្យម។ ខ្ញុំមិនមែនជាអ្នកសេដ្ឋកិច្ចទេ ក៏ប៉ុន្តែខ្ញុំមានឆន្ទៈ ខ្ញុំមានបំណងបន្ទាប់ពីឆ្លងកាត់ជីវិតការងារ តាមរយៈការធ្វើដំណើរទស្សនកិច្ចប្រទេសមួយចំនួន។ នៅឆ្នាំ២០១៩ ខ្ញុំបានទៅទស្សនកិច្ចប្រទេសអាល្លឺម៉ង់ ដោយភាគីអាល្លឺម៉ង់ គាត់បាននាំខ្ញុំទស្សនកិច្ចតំបន់អតីតអាល្លឺម៉ង់ខាងកើត និងអតីតអាល្លឺម៉ង់ខាងលិច។ នៅអតីតអាល្លឺម៉ង់ខាងកើត គេផ្តោតលើឧស្សាហកម្មធុនធ្ងន់ ដោយគេមិនប្រមូលផ្តុំមនុស្សច្រើនទេ។ ប៉ុន្តែអតីតអាល្លឺម៉ង់ខាងលិច គេយកចិត្តទុកដាក់លើសហគ្រាសធុនតូច និងមធ្យម។ មែនទែនទៅយ៉ាងហោចណាស់មួយឃុំ គេមានសហគ្រាសធុនតូច និងមធ្យមមួយកន្លែង។ គេធ្វើបែបនេះ ប្រជាពលរដ្ឋក្នុងមូលដ្ឋានងាយស្រួលធ្វើការតែម្តង។ គេអាចផ្តល់ការងារឱ្យប្រជាពលរដ្ឋបានច្រើនជាងឧស្សាហកម្មធុនធ្ងន់។ ដូច្នេះខ្ញុំគិតថាសហគ្រាសធុនតូច និងមធ្យមពិតជាមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍមូលដ្ឋាន"

ក្រឡាហោមខេង

*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ពិធីពិសាអាហារសាមគ្គី ជាមួយថ្នាក់ដឹកនាំសមាគមមូលនិធិ **សម្តេចតេជោ** ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា*

២២-ទំនាក់ទំនងរវាងនគរបាលជាតិជាមួយប្រជាពលរដ្ឋ

"ប៉ុស្តិ៍នគរបាល និងមន្ត្រីនគរបាលជាតិយើង ជារួមត្រូវធ្វើខ្លួនឱ្យក្លាយជានគរបាលរបស់ប្រជាពលរដ្ឋពិតប្រាកដ។ បើមានកិច្ចការអ្វី ប្រជាពលរដ្ឋគាត់អាចទាក់ទងសុំអន្តរាគមន៍ពីយើងបានភ្លាម! គាត់សុំជំនួយពីយើងដោយមិនខ្លាចញញើត។ ដូច្នេះទេ ប៉ុស្តិ៍និងអង្គភាពនគរបាលគ្រប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋដឹងពីការងាររបស់យើង ហើយឱ្យគាត់មានលេខ ឬបណ្តាញទំនាក់ទំនងជាមួយ ដូចជាតេឡេក្រាម ឬហ្វេសប៊ុកជាដើម។ ព្រោះមធ្យោបាយនេះ ពេលណាពលរដ្ឋគាត់មានការអ្វី គាត់អាចទាក់ទងយើងបានស្រួល"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបសកម្មភាពការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ គណៈកម្មាធិការគណបក្សខេត្តព្រៃវែង

២៣-យើងធ្វើទៅជានយោបាយជាតិរួចហើយ

"តាមរយៈទស្សនកិច្ចស្រាវជ្រាវពីប្រទេសមួយចំនួនដែលគេបានធ្វើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការយូរឆ្នាំ និងក៏មានការរីកចម្រើន ខ្ញុំបានសួរគេថាអ្នកឯងធ្វើប៉ុន្មានឆ្នាំហើយ? គេថា ៣០ឆ្នាំ! ខ្លះជាង ១០០ឆ្នាំ ក៏មានដែរ។ ខ្ញុំគិតថាប្រទេសទាំងនោះ គេអាចត្រូវការពេលវេលាយូរជាងយើងមែនដោយសារពេលហ្នឹងការងារហ្នឹងថ្មី។ ដូច្នេះគាត់ធ្វើផង ស្ទាបផង។ តែយើងមានគំរូពីពួកគាត់ខ្លះហើយ អីចឹងបានខ្ញុំគិតថាប្រហែលជាមិនត្រូវការពេលយូរទេ។ ជាក់ស្តែង យើងបានបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី១ ឆ្នាំ២០០២ រហូតឆ្នាំ២០២២ គឺពេលនេះ២០ឆ្នាំរួចហើយ។ ២០ឆ្នាំ យើងអាចធ្វើបានប៉ុណ្ណឹងប្រសើរណាស់ យើងបានធ្វើទៅជានយោបាយជាតិរួចទៅហើយ មានការគាំទ្រជាទូទៅហើយ។ ប៉ុន្តែក៏មានអ្នកមិនសូវគាំទ្រដែរ គឺមិនអត់ទេ ជាពិសេសអ្នកប៉ះប្រយោជន៍! យើងផ្ទេរអំណាចធនធានទៅថ្នាក់ក្រោមជាតិ វាធ្វើឱ្យប៉ះគាត់ ដូចថា អញធ្លាប់តែក្តាប់អាហ្នឹង វាទៅជាផ្ទេររបស់អញអស់...។ នែ៎! យើងធ្វើនេះដើម្បីជាតិ ដើម្បីសង្គម និងកូនចៅយើង ត្រូវគិតយូរអង្វែង"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបសកម្មភាពការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ គណៈកម្មាធិការគណបក្សខេត្តព្រៃវែង

២៤-ដំបូង OK ឯកភាព! ចុងក្រោយចង់រារែក

"សម្រាប់បញ្ហានៅក្នុងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ បញ្ហាដែលសល់វាមានតែប៉ុន្មានចំណុចទៀតទេ ក៏ប៉ុន្តែបានសុទ្ធតែជាបញ្ហាក្តៅ។ ក្តៅយ៉ាងម៉េច? បបួលគ្នាពីដើមមក ដូចថារអ៊ាអីទេ អូខេ (OK) យើងឯកភាព ក៏ប៉ុន្តែពេលធ្វើជាក់ស្តែង បែរជាចង់រារែកវិញ។ អីចឹងទេ ខ្ញុំសូមទាំងអស់គ្នាដាក់ចិត្ត ដាក់កាយឱ្យត្រជាក់បន្តិចទៅបានទេ! យើងនាំគ្នាធ្វើការងារសម្រាប់ប្រទេសជាតិនិងសម្រាប់ប្រជាពលរដ្ឋយើង។ ការងារនេះ យើងមិនទាន់បរាជ័យកន្លែងណាមួយនៅឡើយទេ។ អ្វីដែលបានសម្រេចចិត្តក្នុងកំណែទម្រង់ ឬការផ្ទេរការងារមួយចំនួនរួចមកហើយ ដូចជាមិនទាន់បរាជ័យ ឬ តែមិនបានសោះនោះទេ។ មិនមែនធ្វើទៅគ្មានកំហុសសោះទេ មិនមែនល្អឥតខ្ចោះសុទ្ធទេ តែក៏មិនបានសេចក្តីថា មិនទៅមុខ ឬ ក៏ត្រូវតែដកថយវិញដែរ! មិនអីចឹង? អីចឹងត្រូវតែបន្តទៅមុខទៀត"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបសកម្មភាពការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ គណៈកម្មាធិការគណបក្សខេត្តព្រៃវែង

២៥-កុំទុកបញ្ហាសល់ច្រើន ហើយធ្វើច្បាលៗ

"ហ្វេសប៊ុកខ្ញុំ តែងមានមតិយោបល់ ក៏ដូចជាសំណូមពរ ហូរហៃ។ ភាគច្រើនពាក់ព័ន្ធរដ្ឋបាល និងអង្គភាពក្រោមឱវាទ បើយើងមើលមួយជ្រុងទៅវាដូចជាល្អដែរ ព្រោះយើងបានជួយដោះស្រាយជូនពួកគាត់។ ប៉ុន្តែបើមើលមួយជ្រុងទៀត វាហាក់ដូចជាបង្ហាញឱ្យឃើញថា ប្រហែលជាប្រជាពលរដ្ឋគាត់មិនសូវកក់ក្តៅជាមួយមន្ត្រីយើងខាងក្រោមហ្នុងឬយ៉ាងណា ទើបបានជាគាត់ចេះតែបំផ្លោងបញ្ហា ឬសំណូមពរនេះនោះមកលើ ឬក៏ទាមទារផ្ទាក់លើឱ្យជួយអន្តរាគមន៍ដោះស្រាយ។ អីចឹងទេបញ្ហានេះ ខ្ញុំសូមស្នើរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃទាំងអស់ សូមថាធ្វើម៉េច ត្រូវមានទំនាក់ទំនងជាមួយប្រជាពលរដ្ឋឱ្យបានល្អ ដើម្បីគាត់មានបញ្ហាអ្វីមួយ គាត់ទាក់ទងរកយើងជួយដោះស្រាយ។ ការដោះស្រាយបញ្ហានៅនឹងកន្លែងនេះល្អណាស់! លើកលែងតែយើងបានខិតខំដោះស្រាយដែរ តែដោះវាមិនចេញ ឬវាហួសពីសមត្ថភាព។ បើក្នុងសមត្ថភាព ឬសមត្ថកិច្ចយើង យើងត្រូវតែខិតខំដោះស្រាយ។ បើមិនអើពើហើយចាត់ទុកបញ្ហានោះថាជាបញ្ហាធម្មតាៗ វានឹងកាន់តែក្លាយជារឿងធំទៅថ្ងៃក្រោយ។ ខ្ញុំជួបច្រើនហើយ ជួនអីបញ្ហាច្រើនពេក មន្ត្រីយើងគាត់ក៏ច្បាលៗ មិនសូវឱ្យតម្លៃ និងយកចិត្តទុកដាក់។ អីចឹងបានខ្ញុំស្នើថា ទោះជាបញ្ហាតូចក៏ដោយ ធំក៏ដោយ

មិនត្រូវបោះចោលទេ យើងត្រូវប្រមូលមកទាំងអស់ ដើម្បីរួមគ្នាពិនិត្យដោះស្រាយ”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបសកម្មភាពការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ គណៈកម្មាធិការគណបក្សខេត្តព្រៃវែង

២៦-ទុកពេលឱ្យថ្នាក់ដឹកនាំលើៗដោះស្រាយការងារជាតិផង

“ទេ...! សម្រាប់ខ្ញុំ ក៏ដូចជា **សម្តេចតេជោ** លោកមិនធុញទ្រាន់ក្នុងការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋយើងទេ គឺចេះតែទទួលហើយ។ ប៉ុន្តែថ្នាក់ដឹកនាំខាងលើនេះ ត្រូវធ្វើការងារធំៗ និងមានវិសាលភាពទូលំទូលាយ បើមិនទូទាំងប្រទេស ក៏មានវិសាលភាពធំដែរ។ បើថ្នាក់ក្រោមមិនបានយកចិត្តទុកដាក់ទេ ហាក់ដូចជាបង្ខំឱ្យថ្នាក់ដឹកនាំលើៗ ចំណាយពេលដោះស្រាយទាំងបញ្ហាខ្លះមន្ត្រីនៅក្រោម គាត់អាចដោះស្រាយបានសោះ។ ដូច្នេះ សូមទាំងអស់គ្នាមើលបញ្ហានៅមូលដ្ឋានខ្លួន! បើមានអ្វីកើតឡើង យើងនាំគ្នាដោះស្រាយទៅ។ យើងបានណែនាំឱ្យធ្វើវេទិកាសាធារណៈ ដើម្បីឱ្យពលរដ្ឋអាចផ្តល់ព័ត៌មាន អាហ្នឹងជាវិធីរកការងារធ្វើ ចៀសវាងទាល់តែថ្នាក់លើចាត់តាំងឱ្យ ទើបបានគ្នាធ្វើ។ យើងប្រមូលយកបញ្ហាប្រជាពលរដ្ឋយើង មកធ្វើជារបៀបវារៈការងារ។ បើយើងខិតខំដោះស្រាយដែរ ប៉ុន្តែដោះវាមិនបាន សូមផ្តល់ព័ត៌មានមកខាងលើ តើមានមូលហេតុអ្វីបានជាដោះស្រាយមិនកើត? កុំទុកចោល! ព្រោះបើទុកចោល វានឹងគរធំទៅៗ ទៅជាបញ្ហាធំ និងកាន់តែពិបាកដោះស្រាយ”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបសកម្មភាពការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ គណៈកម្មាធិការគណបក្ស

២៧-តំណាលរឿងខ្មែរក្រហមស្គាត់ប្លាញ់នៅស្ពានទឹកថ្លា

"បើខ្ញុំមិនច្រឡំទេ ប្រហែលជាឆ្នាំ១៩៨៩ កាលពី **ហ៊ុល សាវ៉ន** ធ្វើជាមេបញ្ជាការយោធភូមិភាគទី៥ ខ្ញុំបានចុះទៅសួរសុខទុក្ខកងទ័ព ២៨៦ នៅសំរោង (ឧត្តរមានជ័យ)។ យើងបានជិះអេឡេក្ត (ឧទ្ធម្ភាគចក្រ) ពីហ្នឹង មកចុះនៅស្វាយស៊ីសុផុន។ គេ (ខ្មែរក្រហម) ក៏ស្វាគមន៍ (ប្លាញ់) មួយប្រាវ នៅត្រង់សាកលវិទ្យាល័យ ដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ កឹមយ៉ាន** ធ្វើនៅត្រង់ស្ពានទឹកថ្លា។ ខ្មែរក្រហមដាក់ប្រាវតែម្តង! យើងជិះអាស៊ុត (រថយន្តយោធា) ធ្វើដំណើរមកប៉ោយប៉ែត។ មកដល់យើងឡើងអគារក្បែរៗច្រកព្រំដែន គឺគ្មានមនុស្សទូទៅអីចឹងទេ មានតែកងកម្លាំង និងកងទ័ព ព្រោះពេលនោះ នៅសង្គ្រាមនៅឡើយ។ កាលហ្នឹងលោកជំទាវ **សោម គឹមសួគ៌** គាត់មកជាមួយដែរ គាត់ស្លៀកសំពត់មក ដល់តែឡើងជិះអាស៊ុត វាពិបាកគាត់ដែរ (សើច) ។ យ៉ាងណាយើងក៏ជិះមកដោយសុវត្ថិភាព។ ចង់និយាយថាកាលហ្នឹង គ្មានស្អីទេនៅច្រកទ្វារហ្នឹង! មានតែព្រៃហ្នឹងឯង។ ក៏ប៉ុន្តែជាង៣០ឆ្នាំមកនេះវាប្រែប្រួលលឿនណាស់! គឺលឿនដែលយើងមិនគួរជឿថាបានរីកចម្រើនបានប៉ុណ្ណឹង"

ក្រឡាហោមខេង

ខេត្តបន្ទាយមានជ័យ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

២៨-ការងារណាក៏មានឧបសគ្គ សំខាន់តាំងចិត្តជម្នះ!

"ការងារកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិតហើយវាមិនមែនជាការងាយស្រួល មានការលំបាក និងបញ្ហាប្រឈមមិនចេះចប់មិនចេះហើយឡើយ។ ក៏ប៉ុន្តែត្រូវចាំថា គ្មានការងារណាមិនមានឧបសគ្គ និងបញ្ហាប្រឈមនោះទេ។ សំខាន់គឺនៅត្រង់ថាយើងត្រូវតែតាំងចិត្ត និងមានឆន្ទៈឱ្យបានមុះមុតក្នុងការអនុវត្តតួនាទី និងភារកិច្ច ក្នុងដំណើរការកែទម្រង់ដ៏មានសារសំខាន់នេះ"

ក្រឡាហោមខេង

ខេត្តបន្ទាយមានជ័យ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

២៩-គន្លឹះសំខាន់មួយដួយការពារសន្តិភាព

"កាលពីមុនថ្នាក់ដឹកនាំយើងនៅមូលដ្ឋានឃុំ និងសង្កាត់ ត្រូវបានតែងតាំង ដោយថ្នាក់លើចង្អុលឈ្មោះ ឬចុចឈ្មោះឱ្យធ្វើ ពោលគឺ គ្មានការចូលរួមពីប្រជាពលរដ្ឋនោះទេ។ ក៏ប៉ុន្តែឥឡូវ យើងតែងតាំងតាមរយៈការផ្តល់មតិសម្រេចពីប្រជាពលរដ្ឋ ដោយផ្ទាល់ តាមរយៈសំឡេងឆ្នោតពីប្រជាពលរដ្ឋ។ ពលរដ្ឋ ពួកគាត់មានសិទ្ធិជ្រើសរើសមេដឹកនាំដោយខ្លួនគាត់ ស្របទៅ តាមច្បាប់។ ផ្លូវនេះ យន្តការនេះ បាននាំឱ្យយើងមានស្ថិរភាព និងសន្តិភាពទូទាំងប្រទេស។ ដូច្នេះ បើពួកគាត់ ជាមេឃុំ ចៅ សង្កាត់ បានកាន់តំណែងហើយ ធ្វើការងារមិនឱ្យប្រជាពលរដ្ឋ ពេញចិត្ត ប្រជាពលរដ្ឋគាត់មានសិទ្ធិមិនបោះឆ្នោតឱ្យទៀតនៅ អាណត្តិក្រោយ...។ ដល់អីចឹង ម្នាក់ៗនាំគ្នាខិតខំធ្វើការបម្រើ ប្រជាពលរដ្ឋ"

ក្រឡាហោមខេង

ខេត្តបន្ទាយមានជ័យ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ អគារស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

៣០-សម្តេចតេជោ ចង្អុលឱ្យបង្កើនចំនួនគណៈអភិបាល

"**សម្តេចតេជោ** *នាយករដ្ឋមន្ត្រីនៃយើង លោកបានចង្អុលឱ្យខ្ញុំដឹកនាំសិក្ខាច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យលទ្ធភាពបង្កើនចំនួនគណៈអភិបាល គឺបន្ថែមអភិបាលរង។ បង្កើននេះដោយសារយើងកាន់តែបានទម្លាក់ ឬផ្ទេរ ការងារ មុខងារ តាមបែបវិមជ្ឈការ និងវិសហមជ្ឈការទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើន។ កន្លងទៅ យើងបានកំណត់ខេត្តធំយ៉ាងហោចណាស់មានគណៈអភិបាលពី ៥ ទៅ ៧នាក់ ហើយបើខេត្តតូចមានពី ៣ ទៅ ៥នាក់។ ក៏ប៉ុន្តែមកដល់ពេលនេះ វាដល់ពិដានអស់ហើយ អត់មានខេត្តណា ៦ ឬ ៥នាក់ អីទៀតទេ គឺឡើង ៧នាក់ទាំងអស់តែម្តងសម្រាប់ខេត្តធំ ហើយក៏មិនមាន ៣ ឬ ៤ នាក់នោះដែរ គឺ ៥នាក់ ទាំងអស់ សម្រាប់ខេត្តតូច។ ដូច្នេះខ្ញុំនឹងខិតខំសម្រេចការងារនេះឱ្យបានឆាប់ ធ្វើយ៉ាងណាឱ្យបានមុនចូលឆ្នាំថ្មី។ នេះជាបំណងទេ យើងចង់យ៉ាងដូច្នេះ"*

ក្រឡាហោមខេង

ខេត្តបន្ទាយមានជ័យ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

៣១-អំណោយចំបំផុត គឺយុត្តិធម៌សង្គម

"ការផ្តល់ជំនួយសង្គ្រោះ ជំនួយជាសម្ភារៈក្តី ថវិកាក្តី និងជំនួយមនុស្សធម៌នានាក្តី វាជាការចាំបាច់ហើយ។ ក៏ប៉ុន្តែអ្វីដែលចាំបាច់ជាងហ្នឹងទៅទៀតនោះ តាមខ្ញុំយល់គឺការកសាងយុត្តិធម៌នៅមូលដ្ឋាន។ នេះគឺជាបញ្ហាគន្លឹះ។ ការដោះស្រាយបញ្ហានានានៅមូលដ្ឋាន បើយើងគ្មានយុត្តិធម៌ទេ ទោះជាយកអំណោយជូនគាត់ប៉ុន្មាន ក៏គាត់អត់ជឿយើងដែរ។ ប៉ុន្តែផ្ទុយទៅវិញ បើយើងដោះស្រាយទំនាស់នានា ឬបញ្ហាក្នុងមូលដ្ឋានជូនពួកគាត់ប្រកបដោយយុត្តិធម៌ ខ្ញុំជឿថាពលរដ្ឋ ពួកគាត់ពិតជាសប្បាយរីករាយ ពិតជាទទួលយកយើងបាន។ មិនត្រឹមតែគាត់ទេ ប្រជាពលរដ្ឋ និងសង្គមទាំងមូលនឹងទទួលយកបានដែរ។ អរិចឹងបានជាខ្ញុំស្នើដោយទទូចថា យើងខិតខំបន្តបំពេញភារកិច្ចហើយក្នុងឋានៈយើងជាមន្ត្រីរាជការបម្រើប្រជាពលរដ្ឋទៀតនោះ គឺយើងមិនត្រូវប្រកាន់និន្នាការនយោបាយ ពណ៌សម្បុរ និងរើសអើងឡើយ។ ចំណុចនេះ គឺជាការស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធសាលប្រជុំ និងសមិទ្ធផលនានាក្នុងទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកបរវេល

៣២-ព័ត៌មានក្លែងក្លាយ មិនបកស្រាយ នឹងក្លាយជាពិត!

"បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាពិសេសបទល្មើសឧក្រិដ្ឋ វានៅតែកើតឡើងជាបន្តបន្ទាប់។ បញ្ហានេះ វាបានជះឥទ្ធិពលមិនល្អដល់កិត្យានុភាពរបស់ខេត្តព្រះសីហនុ។ ម្យ៉ាងក្នុងបញ្ហានេះ វាក៏ដោយសារតែមានការផ្សាយព័ត៌មានបំផ្លើស និងព័ត៌មានមិនពិតចេញទៅក្រៅច្រើន ជាពិសេសចេញទៅក្នុងមជ្ឈដ្ឋានសាធារណជនចិន។ ទោះបីថាព័ត៌មានពិត ឬមិនពិតក៏ដោយ បើគ្មានការបកស្រាយជាក់លាក់ទេ ព័ត៌មានដែលមិនពិតសោះនោះ វាអាចក្លាយជាព័ត៌មានពិត ព្រោះគេជឿវា។ បើគេជឿមែន អ្នកវិនិយោគដែលគេបម្រុងមកវិនិយោគនៅកម្ពុជា គេនឹងលែងហ៊ានមកតែម្តង ឬក៏ស្ទាក់ស្ទើរក្នុងការមកវិនិយោគតែម្តង។ ដូច្នេះ យើងមានកាតព្វកិច្ច យើងមានភារកិច្ចដើម្បីរួមគ្នាដោះស្រាយ រួមទាំងការពន្យល់ និងប្រឆាំងនូវរាល់ព័ត៌មានក្លែងក្លាយទាំងឡាយ"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៣-បដិសេធសំណើរបស់មិត្តចិន

"ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈចិន យើងបានឯកភាពគ្នាកំណត់យកឆ្នាំ២០១៩ ជាឆ្នាំត្រូវអនុវត្តច្បាប់នៅខេត្តព្រះសីហនុ។ រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈចិន និងខ្លួនខ្ញុំ ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា យើងបានចុះហត្ថលេខា ហើយប្រគល់ភារកិច្ចឱ្យភាគីចិនមានអនុរដ្ឋមន្ត្រីម្នាក់ដឹកនាំ និងខាងកម្ពុជា មានឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** ជាអ្នកដឹកនាំ ក្នុងនាមសហប្រធានតែម្តង។ យើងក៏មានបញ្ហាមួយនិយាយមិនត្រូវគ្នា ដោយសារភាគីចិន គាត់ស្នើសុំចុះចាប់ជនល្មើសជាជនជាតិចិននៅក្នុងខេត្តព្រះសីហនុដោយខ្លួនឯង។ មានន័យថាមិនមែនគាត់ផ្តល់ត្រឹមតែព័ត៌មាន ដើម្បីសហការជាមួយយើងទេ។ យើងបានសុំឱ្យគាត់ផ្តល់ព័ត៌មាន ឬក៏ឯកសារ និងដីការពាក់ព័ន្ធហ្នឹងមុខសញ្ញាជនល្មើស ដើម្បីយើងធ្វើការងារ។ ក៏ប៉ុន្តែកាលហ្នឹង គឺគាត់ប្រុងដើរតួនាទីជាប្រតិបត្តិករចាប់ជនល្មើស។ យើងមិនឯកភាព ហើយក៏មិនអាចទទួលយកបាន ព្រោះវាទាក់ទងហ្នឹងអធិបតេយ្យភាព។ យើងបានពន្យល់ប្រាប់គាត់អីចឹង គាត់ក៏បានឯកភាពទៅ"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៤-ប្រទេសខ្លះមិនទទួលពលរដ្ឋខ្លួនឯង

"ចំណុចល្អមួយនៃកិច្ចសហប្រតិបត្តិការរវាងមិត្តចិនជាមួយយើង ល្អនៅត្រង់ថា បើយើងចាប់ជនល្មើសជនជាតិចិនហើយរៀបចំបៃបបទបណ្តេញចេញ និងស្នើឱ្យគាត់មកយកទៅវិញ គឺគាត់មកទទួលយកភ្លាម ហើយស្វាគមន៍ការងារយើងល្អណាស់។ ចំណុចនេះ ខ្ញុំសូមថ្លែងអំណរគុណភាគីចិន ព្រោះប្រសិនបើគាត់មិនទទួលយក ក៏ខ្ញុំប្រហែលជាពិបាករកកន្លែងដាក់តែម្តង។ ករណីមិនព្រមទទួលយកពលរដ្ឋខ្លួនឯងនេះ មិនមែនអត់មានទេណា៎! មានប្រទេសខ្លះ គាត់អត់ទទួលយកជនជាតិគាត់ទេ! គាត់ដឹងថាជាជនជាតិគាត់ដែរ តែពេលយើងស្នើឱ្យគាត់មកយកទៅវិញ ឬក៏យើងបញ្ជូនទៅឱ្យគាត់នៅព្រំដែន គាត់បែរជា NO! តែម្តង។ អាហ្នឹងហើយដែលយើងពិបាក ហើយយើងកំពុងដោះស្រាយ"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៥-ផ្ញើរឯកឧត្តម សាយ សំអាល់ ឱ្យទៅជួយព្រះសីហនុ

*"រាជរដ្ឋាភិបាលបានបញ្ចេញកញ្ចប់ថវិកាសនៃ្សប្រមាណជាង១០០លានដុល្លារ ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅក្រុងព្រះសីហនុ។ ខ្ញុំបានផ្តួចផ្តើមគំនិតស្នើថ្នាក់ដឹកនាំយកឯកឧត្តម **សាយ សំអាល់** ពីប្រធានក្រុមការងារស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ឱ្យមកធ្វើការងារនៅទីនេះ (ព្រះសីហនុ) ក្នុងឋានៈជាប្រធានក្រុមការងាររាជរដ្ឋាភិបាល។ ហេតុអ្វី? ពីព្រោះគាត់ជារដ្ឋមន្ត្រីបរិស្ថាន ហើយសមាជិកគណៈកម្មការឆ្នេរសមុទ្រទៀត។ ដូច្នេះគាត់មក ដើម្បីជួយលើកស្ទួយខេត្តព្រះសីហនុ"*

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៦-វិមជ្ឈការ ចាប់កំណើតនៅព្រះសីហនុ

"កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បើនិយាយឱ្យមែនទែនទៅវាមានកំណើតចេញពីខេត្តព្រះសីហនុនេះតែម្តង។ កាលហ្នឹង គឺមានសិក្ខាសាលាមួយមុនគេ រៀបចំនៅព្រះសីហនុ ដើម្បីកំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់។ **សម្តេចតេជោ** លោកក៏អញ្ជើញមកដែរកាលហ្នឹង ហើយក៏មានការចូលរួមពីជំនាញការអង្គការសហប្រជាជាតិដែរ។ ក្រោយមកជំនាញការនោះ គាត់ក៏ស្លាប់ទៅ គាត់ជាជនជាតិអាហ្វ្រិកខាងត្បូង ហើយជាអ្នកជួយតាក់តែងក្របខ័ណ្ឌយុទ្ធសាស្ត្រហ្នឹង។ បន្ទាប់មក យើងក៏រៀបចំឯកសារសម្រេចជាគោលការណ៍ និងចាប់ផ្តើមរៀបចំសេចក្តីព្រាងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបន្តរៀបចំច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលនេះជាប្រវត្តិសាស្ត្រមួយនៃកំណែទម្រង់របស់យើង"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៧-ល្បែងប្រជាធិបតេយ្យ មានគេ មានយើង!

“គិតមកដល់ពេលនេះ មានគណបក្សនយោបាយបានចុះឈ្មោះសរុប១៧គណបក្ស ហើយព្រះសីហនុនេះ មាន១១បក្សដែរ ដែលបានចុះឈ្មោះ។ ដូច្នេះ ព្រះសីហនុក៏ស្ថិតក្នុងចំណោមខេត្តមានគណបក្សច្រើនដែរ។ កុំស្មុគ អាហ្នឹងវាទៅតាមបែបអីចឹង ល្បែងប្រជាធិបតេយ្យវាអីចឹងឯង ធ្វើម៉េច បើរដ្ឋធម្មនុញ្ញយើងថាអីចឹងហ្មែន ហើយច្បាប់យើងក៏ចែងអីចឹងដែរ។ ដូច្នេះត្រូវប្រកួតប្រជែងគ្នា មានគេ មានយើង ល្អតើ អាហ្នឹងហើយគេថា អំណាចមកពីប្រជាពលរដ្ឋ គឺត្រង់ហ្នឹងឯង។ យើងធ្វើមិនត្រូវឬមិនល្អ គាត់ក៏មិនសប្បាយចិត្ត គាត់ក៏មិនខ្ចីបោះឆ្នោតឱ្យ វាតែប៉ុណ្ណឹងអំណាចគាត់ សិទ្ធិតែប៉ុណ្ណឹង តែធំណាស់អាហ្នឹង! គាត់ថាមិនអីទេ មិនជួយក៏បាន ប៉ុន្តែពេលបោះឆ្នោតខ្ញុំមិនបោះឱ្យ។ មួយម៉ាត់នេះមិនធម្មតាទេ!”

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៨-ទស្សនវិស័យសាលាជាតិរដ្ឋបាលមូលដ្ឋាន

"យើងមានសាលាជាតិរដ្ឋបាលមូលដ្ឋានហើយ។ យើងអាចនឹងគិតទៅមុខទៀត រៀបចំប្រព័ន្ធសាលានេះសម្រាប់ជួយបណ្តុះបណ្តាលធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ មន្ត្រីនៅក្រោមជាតិយើងមានច្រើន អីចឹងការបណ្តុះបណ្តាលតែមួយកន្លែងមិនបានទេ ទាល់តែរៀបចំថែម។ ឧបមាថា នៅភូមិភាគ យើងរៀបចំតាមភូមិភាគ ដាក់មួយភូមិភាគមួយកន្លែងទៅ ព្រោះមន្ត្រីនៅខេត្តឆ្ងាយៗ លំបាកឡើងចុះណាស់។ សូម្បីតែមន្ត្រីជាប់ក្រុមប្រឹក្សា ក៏យើងហៅមករៀនដែរ។ និយាយទៅឱ្យតែជាប់ឆ្នោតហៅមករៀនទាំងអស់។ ដូច្នេះ ជាទស្សនវិស័យទៅអនាគត យើងត្រូវតែរៀបចំ។ ជាយោបល់ខ្ញុំ រៀបចំឱ្យដូចសាលាប៉ូលិស។ យើងរៀបចំតាមភូមិភាគទាំង៦តែម្តង។ នេះជាយុទ្ធសាស្ត្រសម្រាប់រយៈពេលយូរអង្វែង យើងមិនធ្វើឥឡូវ ទេ។ ឥឡូវ មានខាង ADB [ធនាគារអភិវឌ្ឍន៍អាស៊ី] កំពុងគាំទ្រយើងដើម្បីរៀបចំសាលានៅភ្នំពេញ។ យើងគិតគូរណាស់ ព្រោះការបណ្តុះបណ្តាលធនធានមនុស្សជារឿងសំខាន់។ ឥឡូវឃើញមានរឿងល្អ គឺបេក្ខជនមេឃុំ ចៅសង្កាត់តាមមូលដ្ឋាន ចាប់ផ្តើមមានច្រើន អ្នករៀនដល់ថ្នាក់បរិញ្ញាបត្រ មកឈរឈ្មោះ"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៣៩-ឯកឧត្តម ម៉ុង រិទ្ធី កាន់សោឃ្លាំងបក្ស

“ឯកឧត្តម **ម៉ុង រិទ្ធី** គាត់វិវត្តខ្លួនច្រើនណាស់ តាំងពីគាត់នៅជាបុគ្គលិករបស់ខ្ញុំ ជាអ្នកកាន់សោឃ្លាំងគណបក្ស។ បើមិនជឿសួរគាត់ទៅមើល! គាត់កាន់សោឃ្លាំង គ.ជ.ប ក្រោយវត្តបទុមវតី តាំងពីសម័យ **កុយ សំផន**។ គឺតាំងពីហ្នឹងមក តែឥឡូវគាត់ធ្វើសេដ្ឋីកសិកម្ម កសិឧស្សាហកម្ម (សើច)”

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៤០-មិនស្គាល់មូលដ្ឋាន ប្រែថាមិនស្គាល់ជីវភាពពលរដ្ឋ

"ធ្វើការងារ បើយើងស្គាល់តែប៊ុយរ៉ូ (ការិយាល័យ) អត់ស្គាល់មូលដ្ឋាន គឺពីមុនគេហៅ កម្មាភិបាលជើង១០។ ការមិនស្គាល់មូលដ្ឋាន វាអាចប្រែមកថា យើងមិនដឹងពីជីវភាពរស់នៅរបស់ប្រជាជនទេ មិនដឹងថាពួកគាត់រស់នៅវេរប្រៀបម៉េចទេ! ប្លានអីដឹង បើយើងអត់ទាំងស្គាល់ផងហ្នឹង! ត្រូវដឹងថាគាត់ចង់ប្លានអ្វី? លំបាកអ្វី សំណូមពរអ្វី? ដូច្នេះទេ ខ្ញុំស្នើឱ្យចុះទៅមូលដ្ឋានហើយកំណត់ឱ្យច្បាស់លាស់ ថាចុះដើម្បីអ្វី? ជួបនរណា? ព្រោះមានអ្នកខ្លះចុះហ្នឹងគេដែរ ដូចថាមើលទៅវេរងសកម្មដែរ ប៉ុន្តែមិនសូវឃើញមានលទ្ធផលសោះ"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៤១-សៅរ៍-អាទិត្យ ម៉្លិះសម័យនេះ និងកុងសីសម័យមុន

"**សេង សំអ៊ាត** គាត់ទើបស្លាប់ឆ្នាំ២០១៥។ គាត់និយាយថាល្អើយ សម័យពួកខ្ញុំ ឯកឧត្តមអើយគ្មានទេ គ្មានចុះមូលដ្ឋានមូលអីទេ! ល្ងាចថ្ងៃសុក្រហូតថ្ងៃអាទិត្យ គ្មានអីក្រៅពីរាំវែកហ្នឹងទេ គ្មានចុះមូលដ្ឋានចុះស្អីទេ! គាត់និយាយត្រង់អីចឹងហ្អង។ តែពួកយើងមិនអីចឹងទេ ពួកយើងបានយកថ្ងៃសម្រាកដើម្បីចុះមូលដ្ឋាន។ ចុះទៅនេះមិនមែនចុះទៅរាំវែក ចុះទៅកាប់ជ្រូក កាប់មាន់ បេះដូង បេះស្វាយប្រជាជនមកដាក់ផ្ទះទេ គឺចុះទៅជួយគាត់ជួយអ្វីបានជួយហ្អង។ បើដោះស្រាយអ្វីជូនគាត់បាន នាំគ្នាដោះស្រាយហ្អងទៅ រួមគ្នាធ្វើអីចឹង យើងចាត់ទុកប្រជាជនជាចៅហ្វាយនាយ ហើយយើងជាអ្នកបម្រើ ជាអ្នកចាំទទួលសំណើសំណូមពរចាំបាច់ពួកគាត់យកមកដោះស្រាយ ដោយយកចិត្តទុកដាក់ និងយុត្តិធម៌។ ខ្ញុំធ្លាប់រម្លឹកហើយថាប្រជាជន មិនមែនគាត់មិនត្រូវការយើងចុះទៅចែករំណោយឱ្យគាត់ទេ បើយើងចែកឱ្យគាត់ គឺជាការល្អហើយ យើងបានសង្គ្រោះគាត់ នៅពេលគាត់មានបញ្ហាទៀតគឺរឹតតែចាំបាច់ហើយ។ ក៏ប៉ុន្តែអ្វីដែលគាត់ចង់បានបំផុតនោះគឺយុត្តិធម៌សង្គម។ ដូច្នេះ យើងត្រូវខិតខំធ្វើយ៉ាងម៉េចផ្តល់យុត្តិធម៌ឱ្យពួកគាត់"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៤២-ស្នាដៃយុត្តិធម៌ដ៏ធំរបស់គណបក្សប្រជាជនកម្ពុជា

"គណបក្សយើង ក៏ដូចរាជរដ្ឋាភិបាលដែល **សម្តេចតេជោ** លោកខិតខំប្រឹងប្រែងជាមួយអ្នកដឹកនាំយើងផ្សេងទៀត ដោយបានផ្តល់យុត្តិធម៌ដ៏ធំជូនប្រជាពលរដ្ឋ។ ពិតហើយមានមន្ត្រីខ្លះអាចធ្វើសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ប៉ុន្តែជាគោលការណ៍រួមរបស់រាជរដ្ឋាភិបាល និងគណបក្ស គឺពួកយើងខិតខំផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋ។ ពិសេសបំផុតនោះ គឺរាប់តាំងពីការបណ្តេញរបបប្រល័យពូជសាសន៍ និងកសាងសង្គមមួយដូចដែលពលរដ្ឋបានឃើញសព្វថ្ងៃ។ នេះគឺជាយុត្តិធម៌ដ៏ធំបំផុតមួយ។ បើយើងមិនមើលឃើញពីភាពអយុត្តិធម៌ មិនឃើញការកាប់សម្លាប់រង្គាលទេ តើធ្វើម៉េចយើងនឹងធ្វើវាបាន? យើងបានផ្តល់យុត្តិធម៌ជូនពលរដ្ឋយើង ឱ្យគាត់រួចផុតពីសេចក្តីស្លាប់ មានជីវិតរស់នៅដល់សព្វថ្ងៃ បង្កើតបានជាកូនពូនជាចៅ មានឱកាសរកវិវឌ្ឍជីវភាពរស់នៅ ទៅតាមសមត្ថភាពរៀងខ្លួន។ យើងក៏ខិតខំធ្វើម៉េច ដើម្បីបន្តផ្តល់យុត្តិធម៌ឱ្យគាត់បន្តទៀត គឺបានកាន់តែច្រើនកាលណាក៏កាន់តែងតែល្អទៅតាមហ្នឹង"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ លើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះសីហនុ

៤៣-បំផុសឱ្យពលរដ្ឋហ៊ាននិយាយពីបញ្ហាមូលដ្ឋាន

"យើងត្រូវបន្តចុះធ្វើវេទិកាសាធារណៈ ឱ្យបានគ្រប់ភូមិ ព្រោះបើយើងធ្វើតែមួយឃុំ ក្រែងមនុស្សច្រើនពេក។ ម្យ៉ាងអាចឆ្ងាយផង នាំឱ្យពិបាកដល់ប្រជាពលរដ្ឋ ធ្វើដំណើរមកចូលរួម។ យើងចុះទៅភូមិល្អជាង ហើយបើជាយោបល់ខ្ញុំ អាចធ្វើក្រោមដើមឈើ ក្រោមកុដិលោក ឬមានសាលារៀនទំនេរ ថ្ងៃសៅរ៍-អាទិត្យ ឬថ្ងៃណាគេអត់រៀន។ ពេលចុះធ្វើវេទិកាសាធារណៈ ខ្ញុំសុំថាធ្វើយ៉ាងម៉េច កុំឱ្យប្រជាពលរដ្ឋ ខ្លាចញញើតយើង។ យើងត្រូវបំផុសឱ្យគាត់ហ៊ាននិយាយ ហ៊ានថាជាមួយយើង ហើយត្រូវប្រកាន់អាកប្បកិរិយាជាអ្នកបម្រើ គាត់ជាចៅហ្វាយនាយយើង។ មិនមែនចុះទៅ ក្នុងនាមយើងជាអ្នកធំ ប្រជាជនអ្នកតូចតាចនោះទេ។ តិចថាទៅមើលស្រាលគាត់ គំរាមកំហែងគាត់ សំឡុតគាត់ អាហ្នឹងគាត់នឹងមិនហ៊ានមានមតិ មិនហ៊ាននិយាយតែម្តង។ អីចឹងយើងត្រូវលើកទឹកចិត្តគាត់ ឱ្យហ៊ាននិយាយនូវអ្វីដែលជាការពិត"

ក្រឡាហោមខេង

ប៉ាត់ដំបង ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តប៉ាត់ដំបង

៤៤-យើងកំពុងដើរលើផ្លូវត្រូវហើយ កុំបែរទៅណាទៀត!

"កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ យើងធ្វើបានផលណាស់។ បានផលយ៉ាងម៉េច? ផលទីមួយ-គឺប្រជាពលរដ្ឋគាត់មានសិទ្ធិតែងតាំងក្រុមប្រឹក្សា មេឃុំ ជំទប់ និងសមាជិកឃុំសង្កាត់ ដោយខ្លួនគាត់ផ្ទាល់ជាអ្នកបោះឆ្នោត គឺមិនមែនបុគ្គលណា ឬអ្នកមានមនោសញ្ចេតនាស្អប់ស្រលាញ់ណាមួយ ជាអ្នកតែងតាំងនោះទេ គឺប្រជាពលរដ្ឋជាអ្នកបោះឆ្នោត។ ផលទីពីរ-គឺនៅត្រង់ថា បន្ទាប់ពីយើងបង្កើតបានយន្តការនេះហើយ យើងក៏ឱ្យសិទ្ធិ ឱ្យអំណាចទៅរដ្ឋបាលឃុំ សង្កាត់ជាអ្នកសម្រេច ដើម្បីដោះស្រាយបញ្ហានៅមូលដ្ឋានទៅតាមលទ្ធភាព សមត្ថភាព និងសិទ្ធិអំណាច។ យើងក៏មិនមែនឱ្យអំណាចដោយគំហុករហូតគាត់ទ្រលែងបាននោះដែរ។ តែយើងក៏មិនធ្វើព្រងើយកន្តើយ ឬមិនគិតគូរពីការផ្ទេរអំណាចដែរ។ យើងធ្វើយ៉ាងម៉េចផ្ទេរឱ្យស្របតាមសមត្ថភាព និងលទ្ធភាពដែលគាត់ធ្វើបាន។ ខ្ញុំតែងតែនិយាយថា ពួកយើងកំពុងដើរលើផ្លូវមួយត្រូវហើយ សូមកុំបែរទៅណាទៀត ត្រូវពង្រឹងអាហ្នឹងតទៅទៀត កុំរុះរើធ្វើវាសារថ្មីទេ នេះជាគោលនយោបាយ ជាឆន្ទៈនយោបាយរបស់យើង និងប្រជាពលរដ្ឋយើង ដាច់ខាតយើងមិនឱ្យវាបរាជ័យទេ"

ក្រឡាហោមខេង

ប៉ាត់ដំបង ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តប៉ាត់ដំបង

៤៥-បើបរាជ័យ ខ្ញុំមិនសុខចិត្ត!

“ការផ្ទេរមុខងារគ្រប់គ្រងវិស័យអប់រំ ដែលកំពុងអនុវត្តសាកល្បង នៅខេត្តបាត់ដំបងនេះ ខ្ញុំសុំថា ត្រូវតែធ្វើឱ្យខាងតែបាន ដើម្បីជាគំរូមួយ។ ចៀសវាងការទុកចន្លោះប្រហោង ដែលនាំឱ្យមានការបកស្រាយនានា។ បើបរាជ័យ វាមិនត្រឹមតែធ្វើឱ្យការផ្ទេរវិស័យអប់រំមួយ ទេបរាជ័យ វាក៏នឹងធ្វើឱ្យវិស័យផ្សេងៗទៀតបរាជ័យដែរ។ គេយកអាហ្នឹងមួយជាគំរូ គេថាឃើញទេ...! ធ្វើអត់កើតផងហ្នឹង! គេថាបរាជ័យហើយ! តែមួយម៉ាត់មក ចប់ហ្មង! ធ្វើអីទៀត! អីចឹង ខ្ញុំសុំទទូចស្នើថាធ្វើឱ្យបាន! តាមខ្ញុំដឹង ដូចជាពាក់កណ្តាលឆ្នាំនេះ ឬក្រោយការបោះឆ្នោតឃុំ សង្កាត់យើងនឹងប្រជុំដកបទពិសោធរវាង គ.ជ.អ.ប. ជាមួយក្រសួងអប់រំ និងរដ្ឋបាលខេត្តបាត់ដំបង។ ពេលហ្នឹង ខ្ញុំស្នើអញ្ជើញរដ្ឋបាលរាជធានី ខេត្តផ្សេងៗទៀតឱ្យមកចូលរួម។ ព្រោះយើងមុខតែផ្ទេរទៅហើយ! អត់មានទុកស្អីទៀតទេ...! នេះជាចំណុចសំខាន់ ដោយសារវាត្រូវតែទៅមុខទៀត! ហើយអាហ្នឹងវាក៏ជាខ្លឹមសារពិតនៃកំណែទម្រង់ស៊ីជម្រៅ។ សរុបមក ខ្ញុំស្នើយកចិត្តទុកដាក់ផ្ញើ! ដាច់ខាតត្រូវធ្វើឱ្យបាន! មិនឱ្យបរាជ័យទេ! បើបរាជ័យ ខ្ញុំអត់សុខចិត្ត...!”

ក្រឡាហោមខេង

បាត់ដំបង ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តបាត់ដំបង

៤៦-របបប្រជុំ

" របបប្រជុំ! គឺជាគោលការណ៍សំខាន់ និងជាចម្បងមួយ នៃរបៀបរបបធ្វើការរបស់រដ្ឋបាលថ្នាក់នីមួយៗ។ អីចឹង ត្រូវតែពិនិត្យ ឧបមាថា ឥឡូវឆ្នាំ២០២២ យើងកំណត់យ៉ាងហោចណាស់ប្រជុំ១០ដង! ឬ១២ដង! ឬ២០ដង! ត្រូវកំណត់ឱ្យច្បាស់ ហើយកំណត់ថាប្រជុំមួយលើកៗ នឹងមានរបៀបវារៈអ្វីខ្លះ? អ្នករៀបចំកម្មវិធីប្រជុំក៏គួរទុកបម្រុងពេលវេលាយ៉ាងហោចណាស់ក៏៣០ភាគរយដែរ ករណីមានកិច្ចការចៃដន្យណាមួយត្រូវធ្វើ។ ដូច្នេះ យើងកំណត់មួយឆ្នាំប្រជុំបានប៉ុន្មានដង? ប្រជុំលើកទី១ធ្វើអី? លើកទី២ធ្វើអី?... រហូតដល់ប្រជុំលើកទី១២ធ្វើអីខ្លះ...? យើងដាក់ក្នុងរបៀបវារៈតែម្តង។ បើធ្វើបាន ពិសេសមែនទែន! អាហ្នឹងអាចថាខាង គ.ជ.អ.ប. ខាងអគ្គរដ្ឋបាលក្រសួងមហាផ្ទៃ សហការគ្នាជួយគាំទ្ររបៀបរៀបចំខ្លឹមសារនៃការប្រជុំនេះ"

ក្រឡាហោមខេង

ប៉ាត់ដំបង ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តប៉ាត់ដំបង

៤៧-បទពិសោធជានាយកខុទ្ទកាល័យ

“ខ្ញុំធ្លាប់ធ្វើដែរ នាយកខុទ្ទកាល័យមជ្ឈិមបក្ស ហើយក៏ធ្វើការពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំហ្នឹងដែរ។ គឺអត់មានប្រជុំចៃដន្យទេ អត់មានថាត្រូវប្រជុំថ្ងៃនេះក៏ហៅប្រជុំភ្លាមដោយគ្មានហេតុផលនោះទេ! ឬចង់ប្រជុំថ្ងៃនោះ ក៏ហៅប្រជុំ! រត់តាមអីចឹងអត់បានទេ អត់មានទេ។ យើងកំណត់ថា ប្រជុំសន្និបាតលើកនេះត្រូវធ្វើអី? សន្និបាតលើកនោះត្រូវធ្វើអី? ត្រូវនិយាយរឿងអី? យើងព្រាងទុកជាមុនឱ្យស្រេចដើម្បីរៀបចំកិច្ចប្រជុំ។ ហ្នឹងសម័យមុនផង តែឥឡូវក៏វាមិនខុសគ្នាអីដែរ យើងធ្វើដូចគ្នា។ ឧបមាថា ឥឡូវប្រជុំរឿងទន្លាននាក់កាប់ដីព្រៃរដ្ឋ បើប្រជុំហើយដោះស្រាយចប់ យើងលុបវាចោលទៅ តែបើមិនទាន់ចប់ទេ យើងដាក់ប្រជុំរំកិលពាក់ខែទៀត។ ស្រុក ក្រុង ខណ្ឌ ឃុំ សង្កាត់ក៏ដូចគ្នា ត្រូវសិក្សាពីការងារហ្នឹងដែរ។ នេះជាការបញ្ជាក់ឱ្យឃើញថាយើងរៀបចំខ្លួន ឱ្យទៅជាយន្តការដឹកនាំពិតប្រាកដ និងជាក់លាក់មួយ។ មិនអាចធ្វើតាមនឹកឃើញទេ យើងត្រូវតែមានផែនការច្បាស់លាស់។ តាមខ្ញុំធ្លាប់រៀនសូត្រពីបទពិសោធការងារកន្លងមក មិនអាចឱ្យការងាររត់តាមយថាកម្មទេ”

ក្រឡាហោមខេង

ប្រាត់ដំបង ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តប្រាត់ដំប

៤៨-ទន្លឹមនឹងរបបប្រជុំ គឺរបបចុះមូលដ្ឋាន

"មុននេះយើងនិយាយហើយថា នាំគ្នាអង្គុយទៀងទាត់ប្រជុំដោះស្រាយបញ្ហា ដាក់គោលការណ៍ និងវិធានការផ្សេងៗក្នុងការងារដឹកនាំ និងគ្រប់គ្រង។ នេះជាការងារមួយហើយ ក៏ប៉ុន្តែការងារបន្ទាប់ គឺចុះទៅមូលដ្ឋានជាក់ស្តែង ទៅស្វែងយល់ពីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ចុះតាមខ្នងផ្ទះ។ កុំតែចុះទៅរំខានគាត់ យើងចុះដើម្បីជឹងសុខទុក្ខគាត់ ហើយដោះស្រាយបញ្ហាជូនគាត់។ ថ្ងៃមុន ខ្ញុំបាននិយាយនៅស្រុកបវេលហើយថា សម្រាប់ប្រជាពលរដ្ឋយើង គាត់មិនមែនថាមិនត្រូវការយើងជួយសារុង ជួយក្រមា ឬលុយមួយម៉ឺន ពីរម៉ឺនរៀលទេ។ ពិតហើយក៏គាត់ត្រូវការដែរ ប៉ុន្តែគាត់ត្រូវការពីយើងធំមែនទែននោះ គឺសង្គមមួយដែលយុត្តិធម៌។ មានន័យថា ដោះស្រាយបញ្ហានានាប្រកបដោយយុត្តិធម៌។ អាហ្នឹងហើយគាត់ចង់បាន! យើងទាំងអស់គ្នាក៏ចង់បានបែបនេះដែរ ព្រោះវាជាកត្តាគន្លឹះនាំឱ្យស្រុកទេសមានស្ថិរភាព និងរីកចម្រើន"

ក្រឡាហោមខេង

ប៉ាត់ដំបង ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តប៉ាត់ដំបង

៤៩-យើងចេះតែសំពះសុំសន្លឹកឆ្នោតឬ?

“មានអ្នកនយោបាយខ្លះគេបានរិះគន់ និងទិតៀនវាយប្រហារថាយើងអត់បានធ្វើអីទេ! គេថាយើងចេះតែធ្វើ ពេលរៀបចំការបោះឆ្នោត គឺសំពះសុំសន្លឹកឆ្នោតពីពលរដ្ឋ។ តើនេះជាការពិត ឬមិនពិត? ចម្លើយទុកឱ្យប្រជាពលរដ្ឋ លោកវាយតម្លៃចុះ។ ក្នុងឋានៈយើងជាអ្នកប្រតិបត្តិការ ជាអ្នកដឹកនាំផ្ទាល់ក្នុងកិច្ចការនេះ យើងដឹងហើយថា ក្នុងប្រវត្តិសាស្ត្រយើង តាំងពីក្រោយសម័យអាណាព្យាបាលបារាំង ដែលយើងដណ្តើមបានឯករាជ្យដោយស្នាព្រះហស្ត **សម្តេចឪ** ដល់ពេលនេះ យើងឃើញច្បាស់ថា សុខសន្តិភាព ស្ថិរភាពជាតិ យើងមិនដែលមានដូចពេលនេះទេ។ យើងបានដឹកនាំបង្រួបបង្រួម និងផ្សះផ្សាជាតិដោយគ្មានឧទ្ធាមក្រៅច្បាប់ កាន់អាវុធប្រឆាំងរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតរបស់ពលរដ្ឋឡើយ។ យើងមិនមិនចេះធ្វើអី ដូចគេនិយាយឡើយ! យើងចេះធ្វើតាំងពីប្រទេសជាតិមានសង្គ្រាមបៃតបាក់ខ្ទេចខ្ទី ចង់ធ្លាក់ដល់ប៉ាតាល រហូតទីបំផុតយើងស្រោចស្រង់កេរ្តិ៍ឈ្មោះ និងមុខមាត់ជាតិ តាមរយៈការបញ្ចប់សង្គ្រាម និងនយោបាយឈ្នះ-ឈ្នះ ដែល **សម្តេចតេជោ** លោកឆ្តើមគំនិតធ្វើឱ្យមានសុខសន្តិភាពរហូតដល់ពេលនេះ”

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២

៥០-បើយើងអាក្រក់ដូចខ្មែរខ្លះដើរនិយាយមែន ម្លេះសម...!

"បើគេមិនទទួលស្គាល់យើង អាចដោយសារប្រទេសយើងហ្នឹងវាមានការបែកបាក់ កាប់ចាក់គ្នា ឬជាប្រទេសមហាពុករលួយ ឃោរឃៅ គ្មានច្បាប់ គ្មានទម្លាប់ ឬអាណាធិបតេយ្យជាដើម។ ចុះបើវាពិតជាអរិចឹងដូចគេថាមែន សួរថាតើមាននរណាគេមកប្រទេសយើង នរណាគេមកសហការជាមួយយើង? គេមិនដែលយកលុយគេ មកចាក់ចោលនៅប្រទេសយើងទេ។ បើជាអ្នកវិនិយោគវិញ គេមកដើម្បីផលចំណេញ បើមិនចំណេញគេមិនមកទេ! មិនអរិចឹង! ដូច្នេះ បើយើងអាក្រក់ដូចខ្មែរយើងខ្លះដើរនិយាយមែននោះ ម្លេះគេមិនមកធ្វើការជាមួយយើង ឬក៏មិនមកទេសចរណ៍នៅប្រទេសយើងទេ! អ្នកវិនិយោគក៏គេមិនយកលុយមកដាក់ទុនវិនិយោគនៅប្រទេសយើងច្រើនដូចសព្វថ្ងៃនេះដែរទេ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តព្រៃវែង

៥១-អ្នកនយោបាយពូកែរអួយ

"អ្នកដើរនិយាយ អ្នកដើរថា អ្នករិះគន់គេហ្នឹង គឺគេពូកែនិយាយរបស់គេហ្នេន...(សើច) អើ! មានមាត់ក៏ចេះតែនិយាយទៅ តែដល់គេថាឱ្យវិញ តាំងមកនិយាយ តាំងទៅស្រែកអ្ហោយថាអរាហ្នឹងអត់ប្រជាធិបតេយ្យទេ ថាគេសម្លុត គេគំរាមកំហែងវាទៅជារឿងផ្សេងអីចឹងទៅ។ អីចឹងបានខ្ញុំថា អ្នកនយោបាយប្រឆាំងយើងខ្លះ គឺពូកែតែម្តង ពូកែអារឿងរអួយហ្នឹងតែម្តង។ ខ្ញុំមិនបង្អាប់នរណាទេ ប៉ុន្តែសម្រាប់យើងជាអ្នកកាន់អំណាច មិនថាថ្នាក់ជាតិ ឬក្រោមជាតិទេ យើងប្រកាន់គោលការណ៍ច្បាប់បង្កលក្ខណៈឱ្យគ្រប់គណបក្សធ្វើសកម្មភាពដោយសេរី ប៉ុន្តែគណបក្សនយោបាយទាំងនោះទៅវិញទេ ចេះតែចូលចិត្តដើរបញ្ច្រាស់ច្បាប់។ ពួកគេចេះតែនិយមខាងបំផ្លើស ឬបង្ខូចនូវអ្វីដែលមិនមែនជាការពិត។ ជួនអីជារឿងតូចមួយសោះ បែរជានាំគ្នាពង្រីកឱ្យទៅជាភ្នំក៏មានដែរ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តព្រៃវែង

៥២-ហេតុផលឱ្យ CPP ចាញ់ឆ្នោត នៅអាណត្តិទី១!

"ខ្ញុំធ្លាប់និយាយហើយថាគេរៀបចំ! ចង់និយាយថាម៉េច? គឺគេរៀបចំឱ្យអ្នកថ្មីឈ្នះ! គេមិនឱ្យអ្នកចាស់ឈ្នះទេ! អាហ្នឹងខ្ញុំនិយាយជាសាធារណៈបាន ព្រោះមានភស្តុតាងឡូហ្សិក (Logic) អីចឹងហ្អង! បើឱ្យគណបក្សប្រជាជនកម្ពុជាឈ្នះការបោះឆ្នោតដដែល តើគេបោះឆ្នោតធ្វើអ្វីទៀត។ ព្រោះគណបក្សប្រជាជនកម្ពុជាពេលនោះ កំពុងដឹកនាំប្រទេសស្រាប់ហើយហ្នឹង! ចុះបើបោះឆ្នោតហើយគណបក្សប្រជាជនកម្ពុជាឈ្នះ តើក្រុម **ហ៊ុន សុីនបុិច** ចូលស្រុកទេ? ក្រុម **សុីន សាន** ចូលស្រុកទេ? ក្នុងពេលដែលខ្មែរក្រហមនៅក្រៅស្រាប់ មិនមកចូលរួមបោះឆ្នោតផងនោះ។ បើដូច្នេះមែន បេសកកម្មអង្គការសហប្រជាជាតិ (UN) នឹងបរាជ័យ។ យើងសាកល្បងគិតមើលវាទៅអីចឹង។ បើ **ហ៊ុន សុីនបុិច** មិនចូលស្រុក ក្រុម **សុីន សាន** មិនចូលស្រុកសង្គ្រាមវានៅតែដដែលហ្នឹង។ អីចឹងទេ កិច្ចព្រមព្រៀងទីប៉ារីសត្រូវបំផ្លាញភ្លាមពេលហ្នុងតែម្តង។ យើងនិយាយនេះ មិនមានន័យថាដោយសារយើងចាញ់កាលណោះ បាននិយាយអីចឹងទេ! មិនមែនទេ! ដោយសារការវិភាគរបស់យើងឃើញអីចឹង និងមានអគ្គរដ្ឋទូតប្រទេសមហាអំណាច២បានមកប្រាប់ខ្ញុំ។ គេមិនបានវិភាគវែងឆ្ងាយអ្វីទេ តែគេថា ចង់បានអ្នកថ្មី"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តព្រៃវែង

៥៣-ពីមុនផ្ទះមួយបក្សច្រើន ហើយឈ្លោះគ្នាទៀត

"សូមសរសើរប្រជាជនយើងឥឡូវដែលពួកគាត់មានភាពចាស់ទុំខាងនយោបាយណាស់ បើធៀបទៅនឹងស្រុកទេសយើងដែលមានប្រវត្តិបែកបាក់ និងការទាស់ទែងផ្ទៃក្នុងពីរឥតឈប់រាប់រយឆ្នាំ។ ពីមុន ផ្ទះមួយមានបក្សច្រើន ហើយឈ្លោះគ្នាក្នុងគ្រួសារទៀត ដោយសារតែប្រកាន់បក្សពួករៀងៗខ្លួន។ តែចុងក្រោយនេះ គាត់ហាក់ដូចជាផ្សះផ្សាវិញ។ ក្នុងភូមិក៏អរិចិងដែរ ចង់មុខផ្ទះហ្នឹងដាក់គណបក្សណាក៏បាន គឺគាត់មិនបានគុំគួនស្អប់ខឹងគ្នាដូចមុនទេ។ នេះជាមោទនភាពមួយរបស់យើង បានន័យថា ប្រជាពលរដ្ឋយើងលោកចេះដឹង...។ ពួកគាត់មានភាពចាស់ទុំនយោបាយ ដែលអាហ្នឹងគួរតែទទួលបានការសរសើរ គួរតែគោរព"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តព្រៃវែង

៥៤-ដាច់ខាតមិនឱ្យជួលដីតាមព្រំដែន!

"កន្លងទៅវាមានបញ្ហាពាក់ព័ន្ធការគ្រប់គ្រងបូរណភាពទឹកដី។ ប្រជាពលរដ្ឋយើងខ្លះ គាត់បានជួលដីរបស់គាត់នៅតាមព្រំដែន ឱ្យទៅជនជាតិវៀតណាមធ្វើកសិកម្ម។ គាត់ជួលដីយកលុយ ដូចថាស្រួលមែនហើយ ប៉ុន្តែវាមិនស្រួលទេសម្រាប់ជាតិ។ ព្រោះធ្វើស្រែយូរៗទៅ អ្នកជួលហ្នឹងគាត់ទៅជាថា គាត់មកនៅលើដីហ្នឹងយូរហើយតែម្តង។ លែងបែបនេះ គឺដោះស្រាយមិនងាយចេញទេ នេះហើយជាបញ្ហា។ ដូច្នេះ អត់មានសិទ្ធិជួលទេ! ខ្ញុំគិតថាអាសិទ្ធិឱ្យជួលហ្នឹងមិនដឹងជាកម្រិតណាជាអ្នកសម្រេចឱ្យជួលទេ។ ខេត្ត ក្រុង ស្រុក ជាប់ព្រំដែន អាជ្ញាធរមូលដ្ឋានជាប់ព្រំដែន ត្រូវមើលឱ្យមែនទែន ជួលអីចឹងៗអត់ឱ្យជួលទេ! ជួលយូរទៅថាទេអាហ្នឹងដីខ្ញុំតើ!"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តព្រៃវែង

៥៥-ផ្តើមគំនិតហើយពិគ្រោះយោបល់

“រឿងប្រជុំការងារ មិនអាចបណ្តោយទៅតាមយថាកម្មទេ ព្រោះគេឱ្យយើងកាន់អំណាច គេឱ្យយើងធ្វើការ។ ដល់តែមិនបានធ្វើ តិចមកខឹងគេថាមិនឱ្យធ្វើចុះ! ដូច្នេះដល់តែបានធ្វើហើយមិនខំធ្វើ អត់បានទេអាហ្នឹង! ត្រូវដាក់កម្មវិធីប្រជុំធ្វើការ។ តាមមន្ទីរ និងក្រសួងក៏ដូចគ្នា មិនមែនធ្វើតាមដំណើរៗ ឬមានក៏ធ្វើទៅ មិនមានក៏មិនធ្វើទៅ អត់ទេ! អត់អីចឹងកើតទេ។ យើងត្រូវរត់រកការងារធ្វើ កុំឱ្យការងាររត់រកយើង។ ពិតហើយការងារវារត់រកយើងដែរ ដូចជាកូវីដ-១៩ ត្រូវឱ្យយើងធ្វើតាម រត់តាមវា គ្រោះមហន្តរាយវាមកដល់ ឬទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះអាហ្នឹងយើងត្រូវរត់តាមវា។ តែរឿងធម្មតាៗ ត្រូវផ្តើមគំនិត ថាធ្វើអ្វីខ្លះ? ត្រូវម្ចាស់ការ! អាហ្នឹងបានគេហៅថាដឹកនាំ មិនមែនបញ្ជាគេស្រែចនឹងអញ្ចេងទេ។ ផ្តើមគំនិត រួចពិគ្រោះយោបល់ធ្វើទាំងអស់គ្នា។ មិនអាចបណ្តែតបណ្តោយតាមសមាជិវៅទេ។ បើតាមសមាជិវៅ អន្តរធានហើយ។ ត្រូវចាំថាយើងទទួលប្រាក់ខែរដ្ឋ ប្រាក់ខែពលរដ្ឋ! អីចឹងត្រូវបម្រើពលរដ្ឋឱ្យអស់ថ្លៃ ខិតខំឱ្យអស់លទ្ធភាព និងគ្រប់មធ្យោបាយ”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ពិធីបិទសន្និបាតរដ្ឋបាលខេត្តព្រៃវែង

៥៦-កសាងអនាគតកូនចៅ គឺកសាងអនាគតជាតិ

"ការរួមគ្នាកសាងអនាគតកូនចៅយើង គឺជាការកំណត់ជោគវាសនារួមរបស់យើង និងប្រទេសជាតិយើង។ មិនមែនជោគវាសនាដោយឡែករបស់អ្នកណាម្នាក់ឡើយ។ បើទោះថាកូនគេ ឬកូនយើង ប៉ុន្តែយើងរួមគ្នាកសាងជោគវាសនារអនាគតជាមួយគ្នា។ យើងមិនអាចរស់នៅដោយឡែកម្នាក់ឯងបានទេ យើងស្ថិតក្នុងសហគមន៍រួមតែមួយ។ អើចឹងទេ ស្មារតីសាមគ្គីសហការជួយគ្នាទៅវិញទៅមក ពិតជាមានសារសំខាន់ និងមានប្រយោជន៍ណាស់។ផ្ទុយទៅវិញការមើលបំណាំគ្នា ការច្រណែនឈ្នានិសគ្នា ការមិនចេះជួយឈឺឆ្អាលគ្នា ជាកំហុសធ្ងងដ៏ធំ ដែលយើងត្រូវតែកែប្រែ។ អើចឹង យើងត្រូវតែខិតខំជួយគ្នា ក្នុងផ្លូវត្រូវ ហើយនាំគ្នាជួយសហគមន៍យើងឱ្យកាន់តែល្អប្រសើរ។ នេះជាផ្លូវដ៏ល្អ យើងគប្បីបន្តដើរតាមផ្លូវនេះបន្តទៅមុខទៀត"

ក្រឡាហោមខេង

*ចាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្ខាវិទ្យាល័យ **សខេង** កន្លឹ២ និងសមិទ្ធផលនានានៅស្រុកបាណន់*

៥៧-ក្រឡាហោមខេង និងខេត្តប៉ាត់ដំបង

"ខ្ញុំមិនមានកំណើតកើតជានៅខេត្តប៉ាត់ដំបងទេ ប៉ុន្តែខ្ញុំស្គាល់កន្លែងហ្នឹង(ប៉ាត់ដំបង)ហើយស្គាល់ច្រើនទៀតមិនមែនទើបតែស្គាល់ ពេលប្រទេសជាតិមានសុខសន្តិភាពនេះទេ។ ខ្ញុំស្គាល់ប៉ាត់ដំបង តាំងពីស្រុកទេសមិនទាន់ស្គាល់សុខសន្តិភាពក្នុងទសវត្សរ៍៨០ ដែលសង្គ្រាមស៊ីវិលកំពុងតែក្តៅនៅឡើយ។ ទីនេះ (ស្រុកបាណន់) ជាតំបន់មួយមានការប្រទាញប្រទង់ប្រកបដោយគ្រោះថ្នាក់។ ខ្ញុំបានធ្វើដំណើរជាមួយអតីតអភិបាលខេត្តនេះ គឺឯកឧត្តម **អ៊ុង សាម៉ី** ដែលសព្វថ្ងៃគាត់ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ គាត់ចេញពីប៉ាត់ដំបង ទៅធ្វើអភិបាលខេត្តពោធិ៍សាត់ ហើយបន្តទៅធ្វើអភិបាលខេត្តព្រៃវែង មុននឹងមកជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ ពេលហ្នឹង យើងធ្វើដំណើរតាមផ្លូវនេះជាបន្តបន្ទាប់ ដើម្បីសួរសុខទុក្ខកងទ័ពជួរមុខ រួចក៏ហួសទៅទំនប់ទឹកកង្កែតដែលខ្មែរក្រហមធ្វើ ដើម្បីលើកទឹកចិត្តកងទ័ព។ ផ្លូវនៅតំបន់នេះលំបាកវេទនាណាស់។ បងៗ លោកតា លោកយាយនៅទីនេះដឹងស្រាប់ហើយ"

ក្រឡាហោមខេង

*ប៉ាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ **សខេង** កន្លែី២ និងសមិទ្ធផលនានានៅស្រុកបាណន់*

៥៨-ប្រៀបធៀបចុះ ប៉ុន្តែសត្យានុម័តផង

“អ្នកខ្លះគេរិះគន់ថា កម្ពុជាមានសុខសន្តិភាពបានប៉ុន្មានឆ្នាំហើយតើ ម៉េចក៏កសាងប្រទេសជាតិយឺតម្ល៉េះ...? គេនិយាយដោយប្រៀបកម្ពុជា ជាមួយប្រទេសមួយចំនួនដូចជាសាំង្ហបួរ ជប៉ុន ឬប្រទេសខ្លះទៀតដែលឆ្លងកាត់សង្គ្រាមដែរ។ ខ្ញុំថាបើរយៈពេលអាចប្រៀបធៀបគ្នាបាន ក៏ប៉ុន្តែស្ថានភាពវាមិនដូចស្រុកខ្មែរ។ មិនដូចនៅត្រង់ថាកម្ពុជាវាខ្ចិចអស់រលីងតែម្តង...។ យើងនាំគ្នានិយាយថា យើងនៅក្រោមលេខសូន្យ វាបានន័យថាអត់មាន ហើយរឹតតែអត់មានទៀត ព្រោះសូន្យប្រែថាអត់មាន តែយើងនេះវាក្រោមសូន្យតែម្តង។ គ្រូឬសិស្ស រៀនសូត្របានតិចតួចសោះ ក៏គេ (ខ្មែរក្រហម) សម្លាប់ចោល! សាលារៀនក៏ស្ទើរតែគ្មានសល់។ ចុះបើអស់រលីងយ៉ាងដូច្នេះ តើឱ្យយើងមានឱកាសឯណានឹងជប់វិស័យអប់រំឱ្យលឿនដូចផ្លេកបន្ទោរវាទៅអត់រួច! យើងចាប់ផ្តើមដោយរៀនក្រោមរោងគោ ហើយមិនមែនតែតំបន់ជនបទទេ សូម្បីទីរួមខេត្តជាត់ដំបងនេះក៏រៀនក្រោមរោងគោដែរ។ ពិតហើយថាមានសាលារៀន មានអីនៅសល់ខ្លះមែន តែមើលទៅដូចរោងគោអីចឹង។ ព្រោះអត់មានជញ្ជាំងផងហ្នឹង! បើសាលាបឋមសិក្សា **ជា សុីម** ដែលនៅជិត **លោកតាដំបងត្រញូង** យើងនេះវិញ ដូចរោងគោអីចឹងសម័យហ្នុង។ ធនធានមនុស្សវាអស់តែម្តង។ ប្រៀបធៀបចុះ មិនហាម

ទេ ប៉ុន្តែសូមឱ្យសត្វានុម័តផង គ្រប់ជ្រុងជ្រោយផង។ មិនត្រូវមើលមួយជ្រុងតែអំពីរយៈពេលទេ គឺត្រូវមើលស្ថានភាពជាក់ស្តែងថា វាយ៉ាងម៉េច?

ក្រឡាហោមខេង

ប្រាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ **សខេង** កន្លឹ២ និងសមិទ្ធផលនានានៅស្រុកបាណន់

៥៩-មនុស្សលង់ទឹក ធ្វើម៉េចឱ្យតែបានរស់!

"ចេញពីខ្មែរក្រហមមក គេហ៊ុមព័ទ្ធសេដ្ឋកិច្ចយើងអ្ហា! គេហ៊ុមព័ទ្ធនយោបាយអ្ហា! ទម្រាំយើងរួចខ្លួន មិនមែនធម្មតាទេ! រួចពីខ្មែរក្រហមយើងថារួចហើយ ក៏ប៉ុន្តែទីបំផុតគេហ៊ុមព័ទ្ធនយោបាយ គេហ៊ុមព័ទ្ធសេដ្ឋកិច្ចទៅទៀត។ អីចឹង គឺមួយជាន់ហើយមួយជាន់ទៀត។ ទម្រាំយើងខិតខំរើរួចពីភាពលំបាកវេទនាមិនសាមញ្ញទេ យើងថាស្រួលទេ តែពេលធ្វើជាក់ស្តែងលំបាកណាស់ ទាមទារការប្តេជ្ញាចិត្តណាស់ ខិតខំប្រឹងប្រែងណាស់ជម្នះគ្រប់ឧបសគ្គច្រើនណាស់ ទើបយើងអាចទប់ទល់រួច ទម្រាំបានដូចសព្វថ្ងៃ។ ប្រឹងធ្វើស្រែបានអង្ករហើយ តែចង់លក់អង្ករចេញទៅក្រៅប្រទេសមិនបាន ចង់ទិញទំនិញនាំចូលក៏ពិបាក។ ចុះសួរថាម៉េចបានអីចឹង? ពីព្រោះកាលណោះ គេចោទថាវៀតណាមចូលឈ្លានពានកម្ពុជា។ តាមពិតចូលមែន! យើងអត់ត្រូវលាក់លៀមអ្វីទេ! បើចូលមែនហ្នឹង ប៉ុន្តែវាអត់មានជម្រើស តើឱ្យធ្វើម៉េចឥឡូវ ដល់តែអត់ជម្រើស ធម្មតាទេ បើយើងលង់ទឹកហើយឃើញស្មៅតោងបានក៏ចេះតែតោងហើយ ឱ្យតែបានរស់។ បញ្ហានៅត្រង់ហ្នឹង! អីចឹងបានសូមឱ្យផ្តល់យុត្តិធម៌ និងសច្ចៈធម៌ផង"

ក្រឡាហោមខេង

*ប្រាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ **សខេង** កន្លឹ២ និងសមិទ្ធផលនានានៅស្រុកបាណន់*

៦០-គោរពពេលវេលាតាំងពីតូច

"ព្រឹកមិញ ខ្ញុំក្រោកមកទីនេះ (ប្រាត់ដំបង) ម៉ោង៤កន្លះ ហើយចប់កម្មវិធីនេះក៏អស់ហ៊ានសម្រាកដៃរ ដោយសារត្រឡប់ទៅវិញខ្លាចខកម៉ោងគេ។ ខ្ញុំអស់មានចរិត(ទម្លាប់)យឺតផង តាំងពីដើមមក។ ខ្ញុំតាំងពីតូចក៏ដូចគ្នាអីចឹងដៃរ ឱ្យតែទៅរៀនមិនទាន់គេ មិនចូលសាលាតែម្តង ខ្មាសគេហ្នឹង ខ្មាសមែនទែន។ មានម្តងទៅមិនទាន់គេប្រហែល១៥ នាទី គឺមិនខ្ចីចូលរៀន សុខចិត្តមកផ្ទះវិញធ្វើព្រងើយទៅ"

ក្រឡាហោមខេង

ខេត្តប្រាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ ស ខេង គន្លឹះ ២ និងសមិទ្ធផលនានា

៦១-សុំអត់មានកំហុសទេ មិនសុំបានមានកំហុស

"រដ្ឋបាលថ្នាក់ក្រោមជាតិ សូមខិតខំភ្ជាប់ឱ្យជាប់ប្រកពចំណូល ចៀសវាងពឹងផ្អែកតែលើថវិការដ្ឋ និងសប្បុរសជន ឬក្រុមការងារ។ កុំឱ្យតែក្រុមការងារចុះមកដឹងតែពីសុំនោះ។ អ្ហេ! ការពិតហើយអត់បានហាមមិនឱ្យសុំទេ។ សុំអត់មានកំហុសទេ បើមិនសុំបានមានកំហុស។ ត្រង់អ្នកឯងឱ្យ ឬមិនឱ្យ ខ្ញុំមិនដឹង ប៉ុន្តែខ្ញុំសុំ។ បាន ឬមិនបាន មិនដឹង! តែសុំសិនហើយ។ យ៉ាងណាក៏ដោយ យើងសុំ ក៏ត្រូវមានហេតុផល មានសេចក្តីត្រូវការពិតប្រាកដដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ ចុះបើមិនសុំ វាខុសត្រង់ណាដែរ? ខុស ចង់និយាយថា យើងមិនទទួលខុសត្រូវតែម្តង នរណាធ្វើម៉ែចធ្វើទៅ! នរណាងាប់ក៏ងាប់ទៅ! អញ្ចឹមនឿខ្វល់! អាហ្នឹងហើយបានខ្ញុំថា មិនសុំគឺខុស! នេះតាមខ្ញុំយល់ទេណ៎ា! ខ្ញុំបកស្រាយអីចឹង។ វាបានន័យថា ខ្ញុំបានសុំហើយ ឬក៏ថាសុំគេដែរ តែសុំមិនបាន។ បើយើងមិនសុំ គេអាចនឹងថា ចុះបើគ្មានហើយ ម៉ែចមិនសុំ? សុំនេះ គឺសុំឱ្យត្រូវទំនង ត្រូវមានសិល្បៈនៃការសុំដែរ (សើច)"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ ស ខេង គន្លឹ២ និងសមិទ្ធផលនានា

៦២-ទោះមិនឃើញកម្ពុជាមានចំណូលខ្ពស់ ប៉ុន្តែ...

"ស្រុកទេសយើងបានដើរមកដល់លើទីតាំងមួយល្អគួរសមហើយ។ ផែនការសេដ្ឋកិច្ចជាតិយើង ប្រហែលកូនក្មួយៗបានទៅដល់ តែពួកអ៊ំ ពួកយើងចាស់ៗ ប្រហែលខ្លះដល់ ខ្លះមិនដល់ទេ។ ឆ្នាំ២០៣០ យើងប្រឹងឱ្យប្រទេសយើងក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ហើយឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។ ដូច្នេះ សល់ប្រហែល៣០ឆ្នាំ។ ៣០ឆ្នាំទៀត តើយើងនៅរស់ដល់ទេហ្នឹង? បើឥលូវម្នាក់៧០-៨០ឆ្នាំស្អែកខានស្អែកហើយហ្នឹង (សើច)។ សេដ្ឋកិច្ចយើងដល់ហ្នឹង ឬមិនដល់វាអាស្រ័យលើលក្ខខណ្ឌថាយើងមានសុខសន្តិភាពដូចសព្វថ្ងៃ ឬមិនមាន។ និយាយឱ្យការពិតចុះ តាមប្រវត្តិសាស្ត្រកន្លងមក តើមានមេដឹកនាំណាធ្វើបានរឿងហ្នឹង? កុំថាខ្ញុំមកឃោសនា តែសូមជួយវែកញែកទាំងអស់គ្នា តើជំនាន់ណាដែលខ្មែរមានសុខសន្តិភាពពេញលេញដូចសព្វថ្ងៃ?"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ ស ខេង គន្លឹះ និងសមិទ្ធផលនានា

៦៣-អាយុ១១ឆ្នាំទើបបានចូលរៀន

"ខ្ញុំមានឱកាសបានចូលរៀន មានសំណាងចូលរៀននៅអាយុ ១១ឆ្នាំទៅហើយ។ យើងគិតមើល ធម្មតាអាយុ៦ឆ្នាំ គេឱ្យចូលរៀនហើយ តែខ្ញុំ១១ឆ្នាំទើបបានចូលរៀន ហើយរៀនបានត្រឹមឆ្នាំ១៩៧០ គេក៏នាំគ្នាធ្វើរដ្ឋប្រហារ សង្គ្រាមក៏កើតឡើង តើមានពេលឯណារៀន។ នៅភ្នំពេញក៏គ្មានបងប្អូនសាច់ញាតិហ្នឹងគេ ហើយមិនទាំងស្គាល់ភ្នំពេញផង។ សាលានៅស្រុកខ្លួនឯងហ្នឹងវាមានតែ៣បន្ទប់ទៅទៀត។ រៀនចប់បឋមសិក្សា ត្រូវរៀនកន្លែងមួយទៀតចម្ងាយ ៥ទៅ៦ គីឡូម៉ែត្រឯណោះ។ ពេលខ្លះក៏ដើរ ពេលខ្លះក៏ជិះកង់អីចឹងទៅ...តស៊ូណាស់! ធ្វើម៉ែចដោយសារចង់ចេះចង់ដឹង។ ដល់ឆ្នាំ៧០ គេធ្វើរដ្ឋប្រហារ ក៏ខានរៀន"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ ស ខេង គន្លឹះ២ និងសមិទ្ធផលនានា

៦៤-កុំភ្លេចមេរៀន និងបទពិសោធដ៏ជូរចត់

"**សម្តេចតេជោ** លោកដាក់ពាក្យស្លោក **អរគុណសន្តិភាព**! មានអត្ថន័យទូលំទូលាយណាស់។ មានសុខសន្តិភាព យើងធ្វើអ្វីក៏កើតដែរ។ ខ្មែរយើងមិនមែនអន់ទេ ក្នុងប្រវត្តិសាស្ត្រយើងក៏ល្បីដែរ មិនធម្មតាឯណា តែដោយសារការឈ្លោះទាស់ទែងបែកបាក់គ្នាហ្នឹងហើយ ទើបបានជានាំឱ្យអ្នកឱនកិត្តិយសលើឆាកអន្តរជាតិ។ យើងប្តូរពីខ្លាំងមកខ្សោយ ប្តូរពីធំមកតូច ប្តូរពីរីកចម្រើនមកអន់ថយ។ យើងកុំភ្លេច គួរតែរៀនសូត្រពីមេរៀនបទពិសោធដ៏ជូរចត់ហ្នឹង។ អរិចឹងសាមគ្គី ឯកភាពក្នុងក្របខ័ណ្ឌជាតិយើងនេះ គឺជាកត្តាចម្បង និងធំណាស់។ យើងត្រូវធ្វើម៉េចការពារសុខសន្តិភាពឱ្យបាន ត្រូវធ្វើម៉េចកុំឱ្យវាបាត់បង់ទៅវិញ។ មានអ្នកខ្លះគេមិនឱ្យតម្លៃទេ ប៉ុន្តែសម្រាប់យើង នរណាមិនឱ្យតម្លៃក៏ដោយ ខ្ញុំគិតថាប្រជាពលរដ្ឋឱ្យតម្លៃណាស់សុខសន្តិភាពនេះ។ ព្រោះបើមានសង្គ្រាម សួរថាកើតសាលានេះទេ? អត់មានទេ! កូនក្មួយយើងបានរៀនសូត្រទេ? អត់ទេ! លោកគ្រូ អ្នកគ្រូបានមកបង្រៀនកន្លែងហ្នឹងទេ? ក៏អត់ដែរ។ យើងឆ្លងកាត់ហើយមិនចាំបាច់ពីណាមកប្រាប់យើងទេ! អរិចឹងរួមគ្នាការពារសុខសន្តិភាពដើម្បីកូនចៅយើងបន្តទទួលបានភោគផល"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ ស ខេង គន្លឹះ ២ និងសមិទ្ធផលនានា

៦៥-ខ្មែរគ្មានជម្រើស ឬវៀតណាមឈ្លានពាន?

"ខ្ញុំបាននិយាយប្រាប់ទូតអាម៉េរិកកាំងមួយរូប ដែលកាលណោះ គាត់ជាប្រធានបេសកកម្ម គេមិនទាន់ដាក់ទូតនៅកម្ពុជាទេ។ ក្រោយកិច្ចព្រមព្រៀងឆ្នាំ១៩៩១ ប្រទេសណាក៏គេចាត់តាំងតឹមប្រធានបេសកកម្មប្រចាំកម្ពុជាដែរ។ ប៉ុន្តែក្រោយបោះឆ្នោតឆ្នាំ១៩៩៣ ទើបយើងក្លាយជារដ្ឋមួយដែលគេទទួលស្គាល់ ហើយក៏តែងតាំងប្រធានបេសកកម្មហ្នឹងជាអគ្គរដ្ឋទូត ឬជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពតែម្តង។ ខ្ញុំប្រាប់គាត់(ទូតអាម៉េរិក)ខ្ញុំថា យើងខ្ញុំវាអត់ជម្រើសទេ! ឯកឧត្តមមើលទៅវាអត់ជម្រើសទាល់តែសោះ។ ពេលដែលប្រជាជនយើងខ្ញុំ ត្រូវរបបប្រល័យពូជសាសន៍កាប់សម្លាប់ បង្អត់អាហារ និងធ្វើទុក្ខបុកម្នេញ អង្គការសហប្រជាជាតិ (UN) បែរជាទទួលស្គាល់របបខ្មែរក្រហមឆ្កួយ! មិនមកទទួលស្គាល់យើងខ្ញុំដែលរំដោះប្រជាជនឆ្នាំ១៩៧៩ទេ ដោយគេលើកហេតុផលថាមកពីវៀតណាមចូលឈ្លានពាន។ ខ្ញុំក៏ថាមែនហ្នឹង ប៉ុន្តែព្រោះវាអត់ជម្រើស។ យើងក៏ប្រាប់គាត់ត្រង់ទៅ គាត់ក៏ថាតឹមត្រូវហ្មែន! ក្រោយមក អ្នកដឹកនាំអាម៉េរិកកាំងក៏ទៅថ្លែងការណ៍នៅប្រទេសវៀតណាម ថាតាមពិតវៀតណាមចូលមកកម្ពុជា គឺជាសកម្មភាពមនុស្សធម៌"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្ខាវិទ្យាល័យ ស ខេង គន្លឹះ ២ និងសមិទ្ធផលនានា

៦៦-បិទច្រមុះយើងដែលទើបរួចផុតពីសេចក្តីស្លាប់!

“យើងធ្លាប់ហើយតើ! គេហ៊ុមព័ទ្ធនយោបាយ សេដ្ឋកិច្ច ទំនាក់ទំនងខាងផ្លូវទូត ផ្លូវអី គឺអត់មានទេ។ ក្រោយយើងវាយផ្តួលរំលំរបបខ្មែរក្រហម សូម្បីតែជាមួយថៃក៏គ្មាន យើងមានតែជាមួយវៀតណាម និងឡាវទេ។ ចំណែក សាំងហ្គាពួរក៏គ្មាន ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន ភូមាក៏គ្មានទាំងអស់។ អាហ្នឹងហើយហ៊ុមព័ទ្ធខាងនយោបាយ គេអត់ទទួលស្គាល់យើងទេ។ ចំណែកហ៊ុមព័ទ្ធសេដ្ឋកិច្ច គឺគ្មានអ្នកវិនិយោគបរទេសអី មកជាក់ទុនអភិវឌ្ឍន៍នេះអភិវឌ្ឍន៍នោះឡើយ។ សូម្បីទំនិញនាំចូលស្រុកខ្មែរ ឬទំនិញនាំចេញពីស្រុកខ្មែរក៏អត់បាន។ អាហ្នឹងហើយគេហៅហ៊ុមព័ទ្ធនោះ។ បិទច្រមុះយើង ទាំងដែលយើងទើបរួចផុតពីសេចក្តីស្លាប់...។ បែបនេះក្តី យើងប្រឹងតស៊ូក៏ចេះតែរាចរស់បាន យើងរស់បានដោយសារសច្ចធម៌។ កាលហ្នឹងយើងប្រើពាក្យថា **ឆ្កែចេះតែព្រុស មនុស្សចេះតែដើរ**។ បានសេចក្តីថា អ្នកឯងថាម៉េចក៏ថាទៅ តែអ្វីដែលខ្ញុំបានធ្វើគឺវាត្រឹមត្រូវ វាមានយុត្តិធម៌ វាសច្ចៈធម៌ ព្រោះយើងសង្គ្រោះប្រជាជនយើងចេញពីរបបប្រល័យពូជសាសន៍”

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ ស ខេង គន្លឹះ ២ និងសមិទ្ធផលនានា

៦៧-គ្មានខ្លះប្រើថវិកាជាតិ តែវត្តខ្មែររីកចម្រើន

"រដ្ឋមិនដែលបានអនុម័តថវិកាជាតិឱ្យកសាងវត្តទេ! គឺមិនដែលដូចថា អូហ៍ឆ្នាំហ្នឹងដាក់ថវិកា១០០លានដុល្លារ ដើម្បីកសាងវត្ត គឺអត់មានទេ អត់ដែលនឹកឃើញរឿងហ្នឹងទេ។ យើងក៏មិនអាចយកថវិការអនុម័តដោយរដ្ឋសភានោះ មកចាយលើការងារវត្តអារាមហ្នឹងដែរ។ ក៏ប៉ុន្តែសួរថាតើវត្តយើងនៅទូទាំងប្រទេសមានប៉ុន្មានហ្អង? គឺមិនក្រោម៥ពាន់ទេឥឡូវ។ អីចឹងបើនិយាយពីហេដ្ឋារចនាសម្ព័ន្ធផ្នែករឹងក្នុងវិស័យសាសនា គឺសម្បូរបែបណាស់។ វត្តនីមួយៗ ព្រះវិហារមួយៗ ម៉ែអ្តោយតម្លៃជាង ១០ម៉ឺន! ២០ម៉ឺន! ឬ៥០ម៉ឺនដុល្លារក៏មាន។ បើនៅភ្នំពេញវិញជិត១លានដុល្លារក៏មានដែរ គឺសម្បើមណាស់។ និយាយនេះមិនមែនជារឿងបន្លោសទេ ចង់និយាយថា យើងឃើញព្រះពុទ្ធសាសនាខ្មែររីកចម្រើនណាស់ ទោះជាខ្មែរក្រហមបំផ្លាញខ្ទេចខ្ទីអស់ក៏ដោយ តែក្រោយមកព្រះពុទ្ធសាសនារីកចម្រើនលឿន! លឿនណាស់ វត្តក៏លឿន ព្រះសង្ឃក៏កើនរហ័ស"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅស្រុកបាណន់

៦៨-បរិមាណនិងគុណភាពក្នុងព្រះពុទ្ធសាសនាខ្មែរ

"ទន្លឹមការរីកចម្រើនខាងហេដ្ឋារចនាសម្ព័ន្ធ រឿងព្រះពុទ្ធសាសនាយើង គឺគុណភាពជាបញ្ហាសំខាន់។ បញ្ហានេះយើងត្រូវយកចិត្តទុកដាក់ទាំងអស់គ្នា យើងជួយទាំងអស់គ្នាទើបបានមិនអាចចាត់ទុកថាជាការងាររបស់ **សម្តេចព្រះសង្ឃ** ឬព្រះមន្ត្រីសង្ឃទេ។ អត់បន្ទោសនរណាទេ! តែយើងអាចមើលបាន បងប្អូនខ្មែរឥស្លាមយើងគាត់បួសទាំងអស់គ្នាតែម្តង ព្រះវិហារគាត់អត់មានអ្វីទេ ច្រហាឆ្លង! តែដល់ពេលមកជួបជុំគ្នា គាត់គោរពបានល្អណាស់ គោរពរហូត ទោះនៅលើទូកក៏គាត់គោរពបានល្អដែរ។ ចំណែកវិន័យក៏គឹងរឹងណាស់ដែរ។ ខ្ញុំមិនមែនលើកដាក់អ្វីទេ តែជាក់ស្តែងវាអីចឹង។ បើព្រះពុទ្ធសាសនាយើងវិញ មានអ្នកបួស មានអ្នកមិនបួស ប៉ុន្តែទោះបួសក៏ដោយ មិនបួសក៏ដោយ ឱ្យតែបានសីល៥ ហ្នឹង គឺល្អពេកហើយ ឬយ៉ាងហោចណាស់មិនលួចមិនប្លន់អីហូរហែនោះប្រសើរណាស់ហើយ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅស្រុកបាណន់

៦៩-ម្ចាស់លុយអភិវឌ្ឍន៍ឃុំ សង្កាត់?

"ថវិកាឃុំ សង្កាត់ ដែលរដ្ឋបានទម្លាក់មក តើយកថវិកានោះធ្វើអ្វីខ្លះ? ធ្វើបានសមិទ្ធផលអ្វី យើងត្រូវរាយការណ៍ប្រាប់ប្រជាពលរដ្ឋ យើងឱ្យគាត់ដឹង។ ពិតហើយថារាជរដ្ឋាភិបាលជាអ្នកទម្លាក់លុយ ក៏ប៉ុន្តែមែនទែនទៅ វាគឺជាលុយប្រជាពលរដ្ឋទេតើ! គាត់ជាអ្នកបង់ពន្ធបង់អីនោះ មិនលុយគាត់! ចំណែករដ្ឋឬរាជរដ្ឋាភិបាល ក៏គាត់ជាអ្នកបោះឆ្នោតឱ្យដែរ។ យើងដែលបានមកធ្វើការនៅឃុំ សង្កាត់ក៏គាត់ជាអ្នកបោះឆ្នោតឱ្យដែរ។ ដូច្នេះត្រូវតែបើកចំហឱ្យពួកគាត់ដឹងថាយើងបានធ្វើអ្វីខ្លះ! បានចាយលើអ្វីខ្លះ! ទន្ទឹមគ្នានោះដែរ មុននឹងប្រើថវិកាធ្វើអ្វីមួយ ក៏យើងគួរគិតដល់ផលប្រយោជន៍អាទិភាពរបស់ពួកគាត់ដែរ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅស្រុកបាណន់

៧0-បន្លំឈ្មោះបេក្ខជនឈរបោះឆ្នោត

"មានករណីកើតឡើងមួយចំនួនរួចហើយ តែពេលនេះខ្ញុំសូមលើកមកតែពីរកន្លែងទេ មកបង្ហាញជូន។ នៅពោធិ៍សាត់ មាននៅស្រុកក្រគរ ឃុំអន្សាចំបក់ ភូមិអន្សាចំបក់ និងនៅឃុំស្រែស្ដុក ក្នុងស្រុកកណ្ដៀង។ ចំណែកព្រៃវែងក៏មាននៅស្រុកកំពង់ត្រែបែក ឃុំកន្សោមរកា។ បញ្ហានៅត្រង់ថាគណបក្សភ្លើងទៀនបង្កករណីដូចៗគ្នា។ គាត់យកឈ្មោះប្រជាជន មកឈរឈ្មោះជាបេក្ខជនគណបក្សគាត់។ ប៉ុន្តែសាមីខ្លួននោះ គេរត់ដឹងផង! ដល់គេរត់ដឹង គេក៏តវ៉ា គេក៏ប្ដឹង! នេះជារឿងមួយដែលអគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវតែស្រាវជ្រាវ។ បើឃើញបញ្ហាហ្នឹង ហើយត្រូវចាត់ការតាមនីតិវិធីច្បាប់។ មកដាក់ឱ្យគេឈរឈ្មោះទាំងសាមីខ្លួនគេមិនដឹងយ៉ាងម៉េច! អីចឹងគេប្ដឹងបដិសេធ គឺជាការត្រឹមត្រូវ ហើយកុំស្រែកថាជាការធ្វើទុក្ខបុកម្នេញខាងនយោបាយ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ កិច្ចប្រជុំផ្សព្វផ្សាយផែនការអន្តរស្ថាប័ន ស្ដីពីកិច្ចការពារការងារពិនិត្យបញ្ជីឈ្មោះ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ

៧១-ក្រសួងខ្លះមិនសហការគ្នា...

"នេះជាវិបត្តិមួយដែរ! សព្វថ្ងៃ បើខ្ញុំពិនិត្យទៅ រវាងក្រសួងមួយ និងក្រសួងមួយទៀត ទោះមិនមែនទាំងអស់ ក៏ប៉ុន្តែមានក្រសួងមួយចំនួន ជួនអី គាត់មានតួនាទីប្រហាក់ប្រហែលគ្នា ពួកគាត់មិនសហការគ្នាប៉ុន្មានទេ។ អាហ្នឹងយើងឃើញហើយកន្លងទៅ ហើយក៏ជាបញ្ហាប្រឈមដែលត្រូវរួមគ្នាដោះស្រាយ ដើម្បីឱ្យមានកិច្ចសហការគ្នារវាងក្រសួងមួយ និងក្រសួងមួយទៀត។ ត្រូវចាំថា យើងជាតួអង្គមួយ ក្នុងចំណោមតួអង្គផ្សេងៗជាច្រើនទៀត នៅក្រោមឆត្ររាជរដ្ឋាភិបាលរបស់យើង។ អីចឹងហើយ គោលបំណងធំ គឺត្រូវធ្វើម៉េចឱ្យរាជរដ្ឋាភិបាលយើងសម្រេចបានគោលដៅ ឬបេសកកម្មជាប្រវត្តិសាស្ត្រក្នុងការបម្រើជាតិ និងប្រជាជន ដែលពេលខ្លះត្រូវការក្រសួងមួយធ្វើម្នាក់ឯង ពេលខ្លះត្រូវការធ្វើជាអន្តរក្រសួង"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៦ និងផ្សព្វផ្សាយផែនការលើកទី៧

៧២-អគ្គនាយកដ្ឋានដែលបំបែកភាពស្មុគស្មាញរបស់ជាតិ

"**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** លោកបានសម្រេចអនុញ្ញាតឱ្យបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ ខ្ញុំក៏សូមថ្លែងអំណរគុណថ្នាក់ដឹកក្រសួងមហាផ្ទៃ និងអគ្គនាយកនានា ដែលបានគាំទ្រការបង្កើតយន្តការថ្នាក់អគ្គនាយកដ្ឋានទាំងពីរនេះ និងគាំទ្រឱ្យអគ្គនាយកដ្ឋានទាំងពីរ អាចបំពេញតួនាទី ភារកិច្ចស្របតាមតម្រូវការចាំបាច់។ ខ្ញុំគិតថានេះជាបញ្ហាសំខាន់ ពីព្រោះប្រសិនបើគ្មានការគាំទ្រ និងការចូលរួមទេនោះ អគ្គនាយកដ្ឋានទាំងពីរមិនអាចសម្រេចកិច្ចការតាមការរំពឹងទុកបានឡើយ។ មកដល់ពេលនេះ យើងដឹងទាំងអស់គ្នាហើយថា អគ្គនាយកដ្ឋានទាំងពីរ ដោយឡែកនៅទីនេះ មានអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានបំពេញតួនាទីប្រកបដោយជោគជ័យ។ បានន័យថាយើងអាចបញ្ចប់បញ្ហាស្មុគស្មាញធំៗ បញ្ហាប្រឈមធំៗ និងមិនមែនសម្រាប់តែក្រសួងមហាផ្ទៃប៉ុណ្ណោះទេ គឺសម្រាប់ប្រទេសជាតិតែម្តង"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៦ និងផ្សព្វផ្សាយផែនការលើកទី៧

៧៣-មិនត្រូវឱ្យបញ្ហាអន្តោប្រវេសន៍វិលមកវិញឡើយ

"ការគ្រប់គ្រងជនអន្តោប្រវេសន៍ឱ្យបានម៉ត់ចត់ និងការអនុវត្តមានវិធានការម៉ឺងម៉ាត់ជាប់ជាប្រចាំ ដោយមិនទុកឱ្យមានអ្នកលួចចូលមករស់នៅមិនស្របច្បាប់ក្នុងប្រទេសយើង គឺជាភារកិច្ចស្នូល។ បើចូលមកគ្មានក្រដាសស្នាម គឺខុសច្បាប់! បើខុសច្បាប់ ត្រូវតែបណ្តេញចេញតាមច្បាប់របស់យើង។ យើងមិនត្រូវឃុបឃិតជាមួយ ជនអន្តោប្រវេសន៍ខុសច្បាប់ទាំងអស់នោះឡើយ ទោះជាជនជាតិណាក៏ដោយ យើងអត់មានប្រកាន់បែងចែកទេ។ ដូច្នេះ សមត្ថកិច្ចតាមព្រំដែន ស្នងការនគរបាលខេត្តជាប់ព្រំដែនក៏ដូចជាអធិការ និងប៉ុស្តិ៍នគរបាលតាមព្រំដែនត្រូវភ្ជាប់គោលការណ៍នេះឱ្យជាប់ ដឹងឱ្យច្បាស់ថាមូលដ្ឋានយើងមានជនបរទេសប៉ុន្មានស្របច្បាប់ ប៉ុន្មានមិនស្របច្បាប់។ បើមានមិនស្របច្បាប់ ត្រូវតែដោះស្រាយតាមវិធានការបណ្តេញចេញពីកម្ពុជា។ យើងអនុវត្តទៅតាមនីតិវិធីជាធរមាន តាមតួនាទី និងសិទ្ធិអំណាចយើងក្នុងនាមជាម្ចាស់ប្រទេស។ យើងមានសិទ្ធិបណ្តេញចេញ និងដោះស្រាយបញ្ហានេះ។ អីចឹងទេ កុំទុកហើយក៏កុំបណ្តែតបណ្តោយឱ្យបញ្ហានេះគរច្រើនដៃរ ពីព្រោះកាលពីពេលកន្លងទៅនោះវាគរហើយបញ្ហា! យើងក៏បានខិតខំដោះស្រាយ រហូតឥឡូវយើងបានដោះស្រាយយ៉ាងល្អប្រសើរដែលខ្ញុំពិតជាអរគុណ និងត្រេកអរណាស់។ ដូច្នេះមិនត្រូវឱ្យ

រឿងហ្នឹងវាវិលត្រឡប់មកវិញទេ។ សម្រាប់អ្នកទទួលបណ្ណស្នាក់នៅអរចិន្ត្រៃយ៍ បើបណ្ណនោះអស់សុពលភាពហើយនៅតែមិនមកបន្ត គឺស្មើនឹងរស់នៅខុសច្បាប់។ ប្លានន័យថា អ្នកឯងប្រែពីអ្នករស់នៅស្របច្បាប់ ទៅជាមិនស្របច្បាប់។ ដូច្នេះជម្រើសតាមច្បាប់ គឺត្រូវតែដេញចេញ។ តឡូវក្នុងចំណោម៩ពាន់នាក់ ដែលយើងរកឃើញ ដូចជាមាន៧ពាន់នាក់ ប្លានមកសុំបន្តសុពលភាព។ រឿងនេះយើងធ្វើយ៉ាងម៉ត់ចត់ក្នុងតួនាទីយើងជាម្ចាស់ស្រុក ម្ចាស់ប្រទេស ដើម្បីការពារឯករាជ្យ និងអធិបតេយ្យជាតិរបស់យើង។ កុំវែងឆ្ងាយពេក ការងារហ្នឹងវាជាគោលការណ៍សាកលទេ។ បើប្រជាជនខ្មែរយើងទៅរស់នៅប្រទេសគេ ទោះអាម៉េរិក ឬបារាំងក្តី ឬមួយក៏អូស្ត្រាលី កាណាដា ជាដើម ក៏គេធ្វើអីចឹងដែរ គឺបើនៅខុសច្បាប់គឺបណ្តេញចេញ”

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៦ និងផ្សព្វផ្សាយផែនការលើកទី៧

៧៤-សញ្ជាតិខ្មែរ មិនមែនឱ្យតែសុំ ដឹងតែសុំបានទេ

"តាមច្បាប់ មែនហើយគឺជនបរទេសណាក៏មានសិទ្ធិសុំចូលសញ្ជាតិខ្មែរដែរ អាហ្នឹងយើងដឹងទាំងអស់គ្នាទេតើ។ ស្រុកណាក៏វាអីចឹងដែរ គេបើកឱ្យសុំ...មានន័យថាការសុំចូលសញ្ជាតិនេះវាជាសិទ្ធិអ្នកសុំ។ ប៉ុន្តែការសម្រេចឱ្យ ឬមិនឱ្យ វាមិនមែនជាសិទ្ធិអ្នកសុំទេ...។ រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចដែលទាក់ទងរឿងហ្នឹងជាអ្នកសម្រេចទេតើ...! សុំបាន ឬមិនបាន វាមិនមែនសិទ្ធិលើអ្នកសុំថាឱ្យតែសុំ ដឹងតែបាននោះទេ។ សូមឱ្យច្បាស់ជាមួយគ្នាកន្លែងហ្នឹង។ មិនគ្រប់លក្ខខណ្ឌ គឺមិនបាន! សញ្ជាតិ មិនមែនចេះតែឱ្យអ្នកឯងងាយៗឯណា...! លក្ខខណ្ឌមានស្អីខ្លះ ច្បាប់សញ្ជាតិបានចែងហើយ យើងនាំគ្នាគោរពតាមហ្នឹងទៅ"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៦ និងផ្សព្វផ្សាយផែនការលើកទី៧

៧៥-បើសន្តិសុខតាមបុរី និងខុនដូខ្លាំង

"សព្វថ្ងៃ យើងមាននាយកដ្ឋានសន្តិសុខឯកជនដែលបាន និងកំពុងរៃអង្គវន្តសមត្ថភាពសន្តិសុខឯកជននៃក្រុមហ៊ុននានា។ ការងារនេះយើងផ្តល់តម្លៃណាស់ ពីព្រោះសន្តិសុខឯកជនជួយយើងបានច្រើន។ ដូចជាតាមខុនដូឬតាមបុរីជាដើម បើកម្លាំងសន្តិសុខគាត់ខ្លាំងហើយ គឺគ្រឿងញៀនចូលមិនចុះទេ ចង់លួចលាក់ផលិត ឬវេចខ្ចប់ចែកចាយក៏មិនងាយដែរ ព្រោះគាត់ឆែកគាត់ប្រយ័ត្ន។ ពួកចោរលួច ចោរប្លន់ក៏ចូលមិនចុះ ព្រោះម្ប៉ាងកន្លែងរស់ហ្នឹងមានរបងមានច្រកទ្វារគ្រប់គ្រងតឹមត្រូវ។ ប៉ូលិសយើង ចុះទៅធ្វើការកន្លែងហ្នុង ក៏ត្រូវការសន្តិសុខជួយសហការដែរ។ នៅតាមរូតែល ឬសណ្ឋាគារក៏ដូចគ្នា ត្រូវតែធ្វើឱ្យបានល្អ គ្រប់គ្រងឱ្យបានល្អ ហើយត្រូវច្បាស់ជាមួយគ្នាថាធ្វើនេះមិនមែនជាការរឹតត្បិតសេរីភាពអីទេ នេះជាការគ្រប់គ្រងសន្តិសុខដើម្បីសុវត្ថិភាព ត្រូវចែកឱ្យដាច់កន្លែងហ្នឹង"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៦ និងផ្សព្វផ្សាយផែនការលើកទី៧

៣៦-វិធីបែងចែកការទទួលខុសត្រូវ

"កន្លងទៅ យើងមានពិសោធទាក់ទងការរៀបចំយន្តការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ក្រសួង ស្ថាប័ននីមួយៗ ធ្វើការដោយឡែកពីគ្នា ដូចថាក្រសួងនេះធ្វើបន្តិច ក្រសួងនោះធ្វើបន្តិច ដោយមិនដឹងពីការងារគ្នាទៅវិញទៅមកទេ។ អីចឹងវាមិនជោគជ័យទេ ព្រោះវាវាយប៉ាយគ្នា។ យើងមានពិសោធមួយ គឺប្រមូលមកផ្តុំហើយចែកគ្នាធ្វើ។ ជានន័យថាធ្វើជាកម្លាំងសរុប ជាវិធានការសរុប ជាមធ្យោបាយសរុប ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ យើងរៀបចំថា បើថវិកានិងមធ្យោបាយបម្រើការងារយើងកំណត់ឱ្យក្រសួងស្ថាប័ននីមួយៗជាអ្នកទទួលដោះស្រាយ មិនមែនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាណាប័ករៀបចំថវិកាឱ្យប្រើទេ។ ជានន័យបើក្រសួងអប់រំ យុវជន និងកីឡា គាត់មានផ្នែកដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គាត់លើកគម្រោង និងផែនការថវិកាក្រសួងគាត់ទៅ ក្រសួងផ្សេងៗទៀតក៏ដូចគ្នា ខេត្តក៏ដូចគ្នា គណៈកម្មការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៃក្រសួង ស្ថាប័នខេត្តគាត់ បញ្ចូលការងារហ្នឹងក្នុងគម្រោងថវិកាគាត់។ បើឱ្យអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ជាអ្នកលើកគម្រោងតែមួយកន្លែង នឹងធ្វើឱ្យទំហំលុយឃើញច្រើនហើយទីពីរការចាត់ចែងលុយវារអត់លឿន ហើយវារអាចជ្រុះនៅ

តាមផ្លូវ ទីបំផុតប្រសិទ្ធភាពការងារវារអត់មាន នេះជាពិសោធ។ មូលហេតុខ្ញុំលើកបញ្ហានេះមកនិយាយ ពីព្រោះមានមិត្តភក្តិបរទេស គេសួរថាអ្នកឯងធ្វើម៉ែច បានអាចធ្វើការងារហ្នឹងបានរលូន? ខ្ញុំក៏បានប្រាប់គាត់តាមហ្នឹងអីចឹងទៅ”

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២

៣៧-បើប្រជាពលរដ្ឋមិនយល់ផង គាត់ម៉េចនឹងគាំទ្រ!

“កិច្ចការបម្រើជាតិ បម្រើប្រជាជននៅតាមមូលដ្ឋាន ជួនអីយើងធ្វើបានច្រើន ក៏ប៉ុន្តែបើការយល់ដឹង ឬក៏ការទទួលយករបស់ប្រជាពលរដ្ឋបានតិច នៅមានកម្រិត ឬបើកាលណាគាត់មិនយល់ទេ ម្តេចនឹងបានការគាំទ្រពីគាត់កើត? បើគាត់មិនគាំទ្រ ហើយគាត់ក៏មិនចូលរួមដែរ។ យើងធ្លាប់ដឹងអីចឹងថា បើសិនណាគាត់មានកូនស្រី ឬកូនប្រុសឬខ្លួនគាត់តែម្តង ត្រូវគេបបួលឱ្យទៅធ្វើការងារនេះ ការងារនោះបានលុយច្រើន គឺគាត់ងាយជឿតាមការឃោសនាអូសទាញណាស់។ ម្តេចបានគាត់ងាយនឹងជឿ? ព្រោះគាត់កំពុងមានជីវភាពខ្វះខាត ហើយគាត់ក៏មិនបានមកសួរនាំ ឬប្រឹក្សាជាមួយយើងជាអាជ្ញាធរនេះទៅទៀត។ ដល់តែមានរឿងកើតឡើងបានយើងដឹង ហើយសង្គ្រោះបានកូនចៅគាត់ពីប្រទេសនេះ ប្រទេសនោះជាហូរហែ។ ឧទាហរណ៍! ទៅធ្វើការ គេឱ្យនេសាទត្រី តែគេដាក់តែក្នុងសមុទ្ររត់ឱ្យឡើងគោក។ ស្គាល់តែទឹក រត់ស្គាល់គោករាប់ឆ្នាំ ទម្រាំបានមកវិញទើបគាត់ថារាងរ្អើយ។ ដូច្នេះការផ្សព្វផ្សាយរបស់រំ ត្រូវគិតលើគុណភាព ហើយគោលដៅគឺពលរដ្ឋយើងយល់ដឹង និងចូលរួមជាមួយយើង”

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២

៧៨-សំខាន់ជានមកលើកទឹកចិត្ត

"តាមរបាយការណ៍អម្បាញ់មិញ គឺសមិទ្ធផលដែលយើងសម្ពោធនៅថ្ងៃនេះ វាមិនច្រើនណាស់ណាទេ តែខ្ញុំព្រះករុណាខ្ញុំគិតថានេះជាការលើកទឹកចិត្ត។ មិនគិតថា សមិទ្ធផលនេះវាតិចតួច ឬក៏ថាមិនស័ក្តិសមនឹងខ្ញុំព្រះករុណាខ្ញុំ ត្រូវមកសម្ពោធនោះទេ។ មិនចាំទាល់តែសមិទ្ធផលហ្នឹងវាស្តើមស្តែ ឬក៏ថាវាធំចំណាយលុយច្រើន ទើបស័ក្តិសមឋានៈយើងនោះទេ។ មកនេះគឺជានមកផ្សារភ្ជាប់ទំនាក់ទំនងជាមួយប្រជាជន មានឱកាសជានគិតគូរពីសុខទុក្ខប្រជាពលរដ្ឋ។ វាមិនមែនតែកន្លែងនេះទេ កន្លែងដទៃទៀតក៏ដូចគ្នាដែរ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវត្តពោធិគុម្ព ហៅវត្តជ្រៃមាន់ ស្ថិតនៅស្រុកពាមជរ ខេត្តព្រៃវែង

៧៩-មើលតែមួយជំនាន់យើងនេះទៅ

"ពិបាកណាស់ទម្រាំបានសុខសន្តិភាពដូចសព្វថ្ងៃ យើងចំណាយពេលវេលាអស់រាប់ឆ្នាំ ចំណាយសាច់ស្រស់ ឈាមស្រស់ ជីវិតមនុស្ស កូនចៅប្រជាពលរដ្ឋ ប្តីសីជាដើម អស់ច្រើនសន្ធឹកសន្ធាប់។ អីចឹងបានជាយើងមើលឃើញថាសន្តិភាពនេះវាមានតម្លៃណាស់ គ្មានអ្វីអាចកាត់ថ្លៃស្មើបានឡើយ។ ដូច្នេះដើម្បីរក្សាសន្តិភាពនេះបាន តើយើងធ្វើអី? បញ្ហានៅត្រង់ហ្នឹង! ចៀសវាងមានសន្តិភាពហើយ យើងមិនចេះថែរក្សា មិនចេះពង្រឹង ដែលអាចនាំឱ្យសន្តិភាពបាត់ទៅវិញ។ មិនមែនតែកម្ពុជាទេ មានប្រទេសជាច្រើនលើពិភពលោក គេបានជួបប្រទះបញ្ហានេះរួចហើយ។ ការរក្សាសុខសន្តិភាពនេះ មានកិច្ចការច្រើនណាស់ដែលត្រូវធ្វើ ក្នុងនោះយើងក៏បានធ្វើខ្លះហើយ ដូចជាការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងសង្គម ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងកសាងប្រព័ន្ធយុត្តិធម៌សង្គម។ យើងខិតខំដើម្បីឱ្យកូនចៅប្រជាពលរដ្ឋមានឱកាសទទួលបានការសិក្សារៀនសូត្រដូចគ្នា។ លោកតាលោកយាយ និងបងៗអាចប្រៀបធៀបបានពីសាលារៀនសម័យយើង និងបច្ចុប្បន្ន។ កុំមើលឆ្ងាយពេក មើលតែមួយជំនាន់យើងនេះទៅ ប្រែប្រួលអ្វីខ្លះ?"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវត្តពោធិគុម្ព ហៅវត្តជ្រៃមាន់ ស្ថិតនៅស្រុកពាមជរ ខេត្តព្រៃវែង

៨០-រាស្ត្រឱ្យលុយទៅរដ្ឋ ចិញ្ចឹមយើងមួយជីវិត

“ពីមុន អ្នកចេះច្រើនបង្រៀនអ្នកចេះតិច តែឥឡូវមិនមែនអីចឹងទៀតទេ វាផ្លាស់ប្តូរអស់ហើយ។ បើជាគ្រូបង្រៀន គឺត្រូវតែចេះច្បាស់លាស់ ព្រោះយើងអ្នកបង្រៀនមនុស្ស បណ្តុះធនធានបន្តវេនរបស់ជាតិ។ ម្យ៉ាងរដ្ឋក៏បានវ៉ាប់រងយើង តាំងពីពេលជាប់ក្របខ័ណ្ឌរហូតដល់ថ្ងៃស្លាប់ រដ្ឋត្រូវចិញ្ចឹមមួយជីវិត! រដ្ឋហ្នឹងនរណា? រដ្ឋ គឺយើងទាំងអស់គ្នាហ្នឹងហើយ មិនចាំបាច់និយាយទៅណាឆ្ងាយពេកទេ។ បានន័យថា លុយដែលយកមកចិញ្ចឹមគ្រូ ចិញ្ចឹមទាំងខ្ញុំ ទាំងអ្នកទាំងអស់គ្នាជាអ្នករាជការនេះ គឺជាលុយប្រជាពលរដ្ឋហ្នុងហើយ។ ពិតហើយថា ពលរដ្ឋមិនបានមកបង់លុយឱ្យយើងអ្នកធ្វើការដោយផ្ទាល់មែន ប៉ុន្តែគាត់បានបង់ពន្ធជូនរដ្ឋ។ ដូចជាការទិញម៉ូតូជាដើម គឺរដ្ឋបានយកពន្ធរួចទៅហើយបន្ថែមលើថ្លៃម៉ូតូនោះ។ នេះគឺជាឧទាហរណ៍មួយប៉ុណ្ណោះ”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានា នៅវត្តពោធិគុម្ព ហៅវត្តជ្រៃមាន់ ស្ថិតនៅស្រុកពាមជរ ខេត្តព្រៃវែង

៨១-សង់ស្ពានធ្វើផ្លូវជាភារកិច្ចរដ្ឋមែន តែរដ្ឋសម័យណា?

"គោលដៅយើង ត្រូវខិតខំផ្លូវចាក់បេតុង ចាក់កៅស៊ូឱ្យ ឆ្ងាយដល់ភូមិ ដល់ផ្ទះប្រជាពលរដ្ឋ។ នេះហើយជាគោលដៅចុង ក្រោយមួយរបស់យើង។ ផ្លូវឆ្ពោះទៅគោលដៅនេះអាចថាឆ្ងាយ បន្តិចមែន ប៉ុន្តែក៏មិនឆ្ងាយពេកទេ បើធៀបពេលដំបូង ដែល យើងទើបចេញដំណើរ។ បើចេញដំណើរដំបូង គឺឆ្ងាយសន្លឹម ដាច់កន្ទុយភ្នែក មើលមិនឃើញតែម្តង។ ប៉ុន្តែឥឡូវ អាចមើល ឃើញហើយ កន្លែងខ្លះមើលឃើញកោះត្រើយហើយ...។ មាន អ្នកខ្លះនិយាយថាអាហ្នឹងជាភារកិច្ចរដ្ឋទេតើ! អឺ! គាត់ថាបានក៏ ថាទៅ។ ក៏ប៉ុន្តែយើង យើងវិញឆ្លើយថាត្រូវហើយ ភារកិច្ចរដ្ឋ! ប៉ុន្តែរដ្ឋសម័យណា...? ព្រោះទឹកដីនេះ វាកើតមករាប់ពាន់លាន ឆ្នាំហើយហ្នឹង។ ប្រាន់ថាពីមុនវាអត់មានផ្លូវហ្នឹងទេ តែពេល គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដឹកនាំប្រទេសវាមានអាផ្លូវ ហ្នឹង។ អីចឹងរដ្ឋមែនហ្នង តែរដ្ឋសម័យណា...? កុំនិយាយឱ្យតែ រួចពីមាត់! ខ្ញុំធ្លាប់ហើយ គេនិយាយថាបើធ្វើស្ពានពាម [ស្រុក ពាមរក៍] ហ្នឹងកើត គេវារឱ្យជិះ (សើច)។ ដល់តែយើងធ្វើស្ពាន ប្រាន ខ្ញុំក៏និយាយលេងទៅថា អ្នកនិយាយហ្នឹងមកវារមកខ្ញុំនឹង ជិះឱ្យមើល! យើងនិយាយលេងទេ មិនទៅជិះអីគាត់ទេ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានា នៅវត្តពោធិគុម្ព ហៅវត្តជ្រៃមាន់ ស្ថិតនៅស្រុកពាមជរ ខេត្តព្រៃវែង

៨២-ឈរឈ្មោះឃុំ សង្កាត់ ត្រូវតែចេះអក្សរ!

“មានបក្សខ្លះខ្ញុំមិនបញ្ចោញឈ្មោះទេ គាត់ទៅយកអ្នកមិនចេះអក្សរមួយតួ ឱ្យទៅឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់។ ទេ! ខ្ញុំមិនមែនរើសអើងនោះទេ ប៉ុន្តែសម័យហ្នឹង គឺវាទៅរអ៊ូរទាទេ។ ទៅយកអ្នកមិនចេះអក្សរឱ្យមកឈរឈ្មោះយ៉ាងម៉េច! ទៅរអ៊ូរទាទេ អត់ស្របតាមកាលៈទេសៈ ហើយថែមទាំងខុសច្បាប់។ ច្បាប់គេអត់និយាយថាឱ្យគាត់ចេះអក្សរហ្មែន តែគេចែងច្បាស់ថា ជីវប្រវត្តិសង្ខេបត្រូវតែឱ្យសាមីខ្លួនសរសេរ។ មានន័យថាម៉េច? គេថាទាល់តែបងឯង! ពូឯង! មីងឯង! ចេះអក្សរ! ចុះបើអត់ចេះអក្សរផង ម៉េចទៅសរសេរជីវប្រវត្តិកើត! បើមិនចេះសរសេរទេ ប្រែមកថាអត់ចេះអក្សរហ្នឹងហើយ។ អត់ចេះអក្សរផង ឱ្យទៅឈរក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងម៉េចនឹងកើត។ ឃុំ សង្កាត់ត្រូវធ្វើផែនការអភិវឌ្ឍ ៥ឆ្នាំ ម្តង។ តាមខ្ញុំដឹង គឺ៥ឆ្នាំធ្វើបានអីខ្លះ? បើធ្វើបានហើយ គេលុបពីផែនការ ហើយការងារណាមិនទាន់ធ្វើបាន គេរំកិលទៅមុខទៀត ហើយគេដាក់អាថ្មីបន្ថែម។ ពីមុនមក ពិតហើយថា ឃុំ សង្កាត់ ឬស្រុកអីហ្នឹងមានដៃលធ្វើផែនការអភិវឌ្ឍស្អី តែឥឡូវអត់បានទេ! ដូច្នេះត្រូវការអ្នកចេះអក្សរដើម្បីបម្រើប្រយោជន៍ប្រជាជនយើង”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានា នៅវត្តពោធិគុម្ព ហៅវត្តជ្រៃមាន់ ស្ថិតនៅស្រុកពាមជរ ខេត្តព្រៃវែង

៨៣-បក្សនៃពេលបោះឆ្នោតទេ...

"ប្រទេសយើងបានប្រកាន់របបបោះឆ្នោត ដូច្នេះមិនអាចនិយាយថាទេ... កាលពីបោះឆ្នោត ខ្ញុំបោះឱ្យអ្នកនោះ អីចឹងអ្នកនេះជាប់ឆ្នោត ខ្ញុំមិនគោរពទេ គឺមិនអាចធ្វើអីចឹងទេ! អ្នកឈ្នះឆ្នោត ទោះជាគេមកពីបក្សណាក៏ដោយ យើងត្រូវគោរពគេ ទោះមិនគាំទ្រជាបុគ្គលក្តី។ ចំណែកយើងអ្នកឈ្នះឆ្នោត ក៏មិនត្រូវបែងចែកថា អ្នកនេះអត់បោះឆ្នោតឱ្យអញ អញមិនបម្រើ អញបម្រើតែអ្នកបោះឆ្នោតឱ្យអញ ក៏មិនបានដែរ យើងជាអ្នកឈ្នះឆ្នោតដែលត្រូវមានកាតព្វកិច្ច មានការណ៍យកិច្ច ភារកិច្ចបម្រើប្រជាជនគ្រប់និន្នាការ ដោយគ្មានការបែងចែកបក្ខពួក។ នេះជាគោលការណ៍ប្រជាធិបតេយ្យ មិនបោះឆ្នោតឱ្យអ្នកហ្នឹងមែនតែបើគេឈ្នះឆ្នោតហើយ យើងត្រូវតែគោរពតាមគោលការណ៍ដឹកនាំរបស់គេ ចំណែកយើងអ្នកឈ្នះឆ្នោត ទោះជាកន្លែងនេះឬភូមិនោះ យើងចាញ់ឆ្នោតមែន តែត្រូវយកចិត្តទុកដាក់បម្រើពលរដ្ឋដូចគ្នានឹងកន្លែងឈ្នះដែរ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ទិវាសប្តាហ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោក លើកទី១៣

៨៤-ល្បិចដេកផ្ទះឈ្នះឯង

"នារំឡងបោះឆ្នោតឆ្នាំ២០១៨ មានគេរំពាវនាវពលរដ្ឋដោយប្រើពាក្យ ដេកផ្ទះឈ្នះឯង។ មានន័យថាម៉េចរអាហ្នឹង? ការបោះឆ្នោត គេគិតថាល្អឬមិនល្អ ត្រឹមត្រូវឬមិនត្រឹមត្រូវ វាចំណុះមួយផ្នែកទាក់ទងចំនួនអ្នកទៅបោះឆ្នោត។ មានន័យថា បើទោះជាទៅបោះឆ្នោតប្រឆាំងក៏ដោយ ប៉ុន្តែវត្តមានប្រជាពលរដ្ឋទៅបោះឆ្នោត វាមានន័យថា គាត់ផ្តល់ការគាំទ្រលើការបោះឆ្នោតហើយ។ ត្រង់ថាគាំទ្របក្សណាឬបក្សណា រអាហ្នឹងជារឿងមួយទៀត។ វត្តមានពលរដ្ឋចូលរួមបោះឆ្នោត វាប្រែមកថាការបោះឆ្នោតនេះល្អ ព្រោះមានពលរដ្ឋ បានទៅបោះឆ្នោតច្រើនលើសលុប។ អីចឹង ក្រុមអ្នកប្រឆាំងគាត់ខ្លាចរអាហ្នឹង! ព្រោះបើពលរដ្ឋទៅបោះឆ្នោតច្រើន វានាំឱ្យគេសន្និដ្ឋានថា ការបោះឆ្នោតល្អ។ និយាយឱ្យសាមញ្ញទៅ ទោះអ្នកទៅបោះឆ្នោត គាត់គូសខ្វែងជើងក្អែក គូសពងមាន់ ឬបោះឱ្យនរណាក៏ដោយ សំខាន់គាត់ចូលរួមសម្តែងនូវឆន្ទៈគាត់។ អីចឹងគេចង់ឱ្យអ្នកទៅបោះឆ្នោតតិចឬក្រោម៥០ភាគរយដើម្បីគេថាបោះឆ្នោតមិនប្រក្រតី។ អីចឹងគេខំប្រើពាក្យដេកផ្ទះឈ្នះឯង គឺចង់ឱ្យការបោះឆ្នោតឆ្នាំ២០១៨មិនបានការ។ ទីបំផុតពលរដ្ឋទៅបោះឆ្នោតជាង ៨០ភាគរយ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ទិវាសុខភាពចរាចរណ៍ផ្លូវគោក លើកទី១៣

៨៥-យើងខុសតែទស្សន: និងជំហរគ្នាទេតើ!

"កម្ពុជាយើង បើខ្ញុំមិនច្រឡំទេ គឺ៣០ឆ្នាំមកនេះ យើងបោះឆ្នោត១១ដងហើយ។ នេះមិនរាប់ការបោះឆ្នោតអសកលផង។ យើងបោះឆ្នោតជាបន្តបន្ទាប់ជាមួយនឹងការរីកចម្រើនជាវិជ្ជមាន។ បើកន្លងមក យើងធ្លាប់មានហើយ ផ្ទះមួយ ឬគ្រួសារមួយ ប្រកាន់បក្សផ្សេងៗគ្នា ឈ្លោះទាស់ទែងគ្នា តែឥឡូវអត់ធ្មត់បានច្រើនលើសលុប ចេះរស់នៅជាមួយគ្នាជាធម្មតា។ សង្គមប្រជាធិបតេយ្យ វាច្បៀសមិនផុតទេអាហ្នឹង។ អ្នកភូមិផងរបងជាមួយគ្នា ប្រកាន់បក្សផ្សេងគ្នាមែន តែបើមានសម្លេងឮញ៉ាញ គាត់ចែកគ្នាហូបទៅ មានអាសន្នអន់ក្រ គាត់ចេះជួយគ្នា។ អាហ្នឹងហើយល្អ កុំគិតថាបើអ្នកឯងខ្មៅហើយ នៅខ្មៅរហូត! ចង់អ្វែងអត់ប្រាយងាប់ក៏អញមិនអើត មិនឈ្លោក! ធ្វើអីចឹងអត់បានទេ មិនល្អទេ! យើងខុសតែទស្សន: និងជំហរគ្នាទេតើ! ស្រលាញ់បក្សផ្សេងគ្នាមែន តែយើងជាជាតិខ្មែរដូចគ្នា អ្នកភូមិផងរបងជាមួយគ្នា តពូជ តរម្បុរ ច្រើនជំនាន់ហើយ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ទិវាសប្តាហ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោក លើកទី១៣

៨៦-ប្រកាន់គោលការណ៍!

"មិនអាចដោយសារតែឯងគាំទ្រអញ ដូច្នេះទោះបីធ្វើអីខុស ក៏អញមិនយកទោសពៃរ៍! ធ្វើអីចឹងមិនបានទេ! ការដឹកនាំនិងការគ្រប់គ្រង ត្រូវតែមានគោលការណ៍មួយដែលគ្រប់គ្នាត្រូវតែគោរព ក្នុងនោះមានច្បាប់ជាធំ។ បើនិយាយពីគណបក្ស គឺបន្ទាត់នយោបាយគណបក្ស និងលក្ខន្តិក:របស់គណបក្ស។ មានន័យថាឱ្យតែយើងគោរពច្បាប់ គោរពនិងធ្វើតាមគោលការណ៍នានាដែលយើងបានឯកភាពជាមួយគ្នា យើងនឹងដឹកនាំការងារបានត្រឹមត្រូវជាក់ជាពុំខាន"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២ ពិធីសម្ពោធអគារទីស្នាក់ការនិងសមិទ្ធផលនានារបស់គណបក្សប្រជាជនកម្ពុជា ក្រុងព្រៃវែង

៨៧-កុំទាល់តែមានតំណែង ទើបមានទំនួលខុសត្រូវ

“មន្ត្រីយើងត្រូវយល់ទាំងអស់គ្នាថាទឹកដីនេះ គឺជាទឹកដីយើងទាំងអស់គ្នា។ មិនមែនជាទឹកដីនរណាម្នាក់ផ្តាច់មុខទេ។ អីចឹងយើងត្រូវរួមចំណែករៃកពន្ធទាំងអស់គ្នា។នរណាធ្វើអ្វីបាន នាំគ្នាធ្វើតាមតួនាទីភារកិច្ចហ្នឹងទៅ។ ធ្វើម៉េចដើម្បីការពារទឹកដីយើងឱ្យបាន អភិវឌ្ឍន៍ទឹកដីយើងឱ្យរីកចម្រើនទៅមុខ។ យើងម្នាក់ៗសុទ្ធតែមានភារកិច្ចដូចគ្នា គ្រាន់តែអ្នកខ្លះកាន់ការងារធំ ខ្លះកាន់ការងារតូច អាហ្នឹងជារឿងធម្មតា ហើយប្រទេសណា ក៏ដូចប្រទេសណាដែរ។ យើងមិនអាចនាំគ្នាទៅធ្វើរដ្ឋមន្ត្រីទាំងអស់បានទេ។ កុំចាត់ទុកថាចាំធ្វើធំ ចាំមានការទទួលខុសត្រូវ ឬចាំធ្វើនាយករដ្ឋមន្ត្រី ចាំមានការទទួលខុសត្រូវ ឬចៅហ្វាយខេត្ត ចៅហ្វាយស្រុក ទើបទទួលខុសត្រូវ ចំពោះមូលដ្ឋានយើងមិនមែនទេ កុំគិតអីចឹងអី”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខា១ខ្នង ២ជាន់ ១២បន្ទប់ នៃវិទ្យាល័យរុក្ខគិរី

៨៨-អត់មានទៅណាផ្សេងក្រៅពីហ្នឹងទេ!

"គឺមានតែរបបនយោបាយបោះឆ្នោតដូចសព្វនេះថ្ងៃទេ ដែលធានាឱ្យប្រទេសយើងមានសេចក្តីសុខ និងពុំមានសង្គ្រាម។ ដូច្នេះ នាំគ្នាប្រឹងទៅ! បក្សណាធ្វើល្អជាមួយប្រជាពលរដ្ឋ ប្រជាពលរដ្ឋគាំទ្រហើយ។ បក្សណារកសេចក្តីសុខ ឬបក្សណាដើរបំផ្លិចបំផ្លាញផលប្រយោជន៍ជាតិ និងផលប្រយោជន៍ពលរដ្ឋ អាហ្នឹងប្រជាពលរដ្ឋគាត់មុខជាដឹងហើយ។ ប្រជាពលរដ្ឋគាត់បោះឆ្នោតគាំទ្របក្សណាដែលដឹកនាំឱ្យកូនចៅគាត់ឱ្យបានរៀនសូត្រ។ គាត់បោះឆ្នោតឱ្យបក្សណា នាំជីវភាពគាត់រីកចម្រើនជាដើម។ អីចឹង បានសព្វថ្ងៃ យើងប្រកាន់យកវបបនេះ ហើយអត់មានទៅណាផ្សេងក្រៅពីហ្នឹងទេ! ដូច្នេះយើងបន្តនាំគ្នាធ្វើទៀតដើម្បីអនាគតកូនចៅយើងតទៅមុខ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខា១ខ្នង ២ជាន់ ១២បន្ទប់ នៃវិទ្យាល័យរុក្ខគិរី

៨៩-ពេលមានសិទ្ធិ មានអំណាច ខេត្តក៍ធ្វើការលឿន

"យើងបានផ្ទេរវិស័យសុខាភិបាល មកឱ្យថ្នាក់ខេត្តជាអ្នកគ្រប់គ្រង។ ដូច្នេះហើយបានជាពេលកូវីដ-១៩ចូលមកយើងឃើញថាខេត្តនីមួយៗស្ទុះស្ទា ប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីដោះស្រាយរហូតយើងទប់ស្កាត់ជំងឺនេះបានយ៉ាងល្អ។ យើងយល់ឃើញថាប្រសិនបើបណ្តោយឱ្យក្រសួងសុខាភិបាល ចាត់ចែងម្នាក់ឯងការគ្រប់គ្រងដោះស្រាយជំងឺកូវីដ-១៩ អាចនឹងស្ទុះមិនរួចទេ ក្នុងស្ថានភាពកូវីដ-១៩ តឹងតែង។ ព្រោះខេត្ត អត់មានមធ្យោបាយ អត់មានលទ្ធភាព អត់មានសិទ្ធិចាត់ចែង បើអីចឹងម៉េចហ្នឹងអាចទប់បានទៅរួច? ប៉ុន្តែពេលយើងផ្ទេរសិទ្ធិគ្រប់គ្រងចាត់ចែងមកឱ្យខេត្ត **សម្តេចតេជោ** គ្រាន់តែស្រែបញ្ជាភ្លាមតាមទូរសព្ទ ឬតាមគ្រប់ទាក់ទងគ្នាជាតេឡេក្រាមអ៊ីចេះមួយ! អ៊ីចេះពីរ! គឺមួយភ្លែតក៍ខេត្តចាត់ចែងបានប្រិបាយ៉ាងលឿន។ នេះជាអ្វីដែលយើងខិតខំដើម្បីធានាប្រសិទ្ធភាពការងារនៅមូលដ្ឋាន"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សា ១ខ្នង ២ជាន់ ស្មើ១២បន្ទប់ នៃវិទ្យាល័យរុក្ខគិរី ស្រុករុក្ខគិរី

៩០-បើប្រជាជនគាំទ្រ អ្នកឯងឡើងកាន់អំណាចទៅ!

"របបបោះឆ្នោតនេះ បើនិយាយមួយបែបទៀត គោលបំណងធំបំផុតគឺដើម្បីធានាមិនឱ្យមនុស្សចូលព្រៃកាន់កាំភ្លើងដើរបះឡើងប្រឆាំងរដ្ឋាភិបាល ធំបំផុតអាហ្នឹងហើយ។ មានន័យថាបើអ្នកឯងចង់ឡើងកាន់អំណាច ច្បាប់គេឱ្យបង្កើតគណបក្សនយោបាយមកចូលរួមប្រកួតប្រជែង ដើម្បីរកការគាំទ្រ នៅក្នុងការបោះឆ្នោតជាទៀងទាត់។ បើប្រជាជនគាំទ្រ អូខេ! (Ok) អ្នកឯងឡើងកាន់អំណាចទៅ! តែបើប្រជាជនមិនគាំទ្រទេ! តិចថាទៅចូលព្រៃដើម្បីតស៊ូចុះ! អត់ទេ ខុសច្បាប់ហើយ អាហ្នឹងទៅជាឧទ្ទាមហើយ។ អីចឹងគោលការណ៍ធំបំផុត គឺរក្សាស្ថិរភាពនយោបាយ កុំឱ្យមានការប្រឆាំងប្រដាប់អាវុធ ហើយរៀបចំការបោះឆ្នោតតាមច្បាប់ឱ្យបានត្រឹមត្រូវ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សា ១ខ្នង ២ជាន់ ស្មើ១២បន្ទប់ នៃវិទ្យាល័យរុក្ខគិរី ស្រុករុក្ខគិរី

៩១-រំលឹករឿងដិះឧទ្ធម្ភាគចក្រ

“ខ្ញុំធ្លាប់ឆ្លងកាត់ច្រើនដែរ ដិះអេឡេកូ (ឧទ្ធម្ភាគចក្រ) មានម្តងនោះ ដិះជាមួយភីឡុតយោធាខ្មែរយើងហ្នឹងឯង។ ដិះទៅខាងអន្លង់វែង។ ទៅដល់ម្តុំប្រម៉ោយរត់ឃើញសាលាស្រុក ចុមយ៉ាងម៉េចអ៊ីចេះ! វង្វេងតែម្តង! មានអីក៏បង្ខំចិត្តចុះចត ហើយមានផ្ទះប្រជាជនកំពុងការកូនទៅទៀត។ ដល់អីចឹង នាំគ្នាចូលចងដៃការកូនគេហ្នុងតែម្តង។ សួរនាំរកសាលាស្រុក គេថានៅក្រោយប្រហែល២០គីឡូ។ ចងដៃហើយក៏ហោះទៅសាលាស្រុក។ មានម្តងនោះចេញពីកំពង់សោមទៅកោះកុង ធម្មតាគេដិះ២០នាទីតែថ្ងៃហ្នុងដិះ១ម៉ោង! សួរភីឡុតក៏វាមិនមាត់ ចុះដល់ដីបានវាថាយន្តហោះឆេះមិនស្រួល(សើច)។ខ្ញុំថាអើ! អ្នែងលេងតែអីចឹងៗ អន្តរាធានហើយអ្នា។ មានម្តងទៀតជាមួយ **ប៉ុល សារឿន** ដែលកាលហ្នុងទូតអាម៉េរិកចប់អាណត្តិ គាត់ចង់ឃើញប្រាសាទព្រះវិហារ ហើយក៏ដិះអេឡេកូមកជាមួយគ្នាទៅ។ គាត់មានទាំងកូនតូចៗមកជាមួយទៀត ដល់តែហោះមកជិតភ្នំ វាហោះឡើងអត់រួច ព្រោះពពកវាក្រាស់។ អីចឹងក៏ចុះក្បែរជើងភ្នំ។ ស្រាប់តែមានកងទ័ពរត់មកព្រាតហ្នុង! ខ្លះក៏មានកាំភ្លើង ខ្លះដោះអាវ ទាល់តែមេយស្រឡះទើបឡើងលើបាន”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយគ្រូបង្រៀន គ្រូពេទ្យ សិល្បករ សិល្បការិនី ក្រុងបាត់ដំបង

៩២-យើងមិនមែនចេះតែកេះកែកាំភ្លើងទេ

"ពួកយើងខ្ញុំនេះ មិនមែនចេះតែកេះកែបាញ់កាំភ្លើងក្នុងសង្គ្រាមតែម្យ៉ាងនោះទេ។ យើងដឹកនាំសេដ្ឋកិច្ចក៏បាន! ដឹកនាំវិស័យអប់រំ កសាងធនធានមនុស្សក៏បាន! ដឹកនាំនយោបាយការបរទេសក៏បាន។ យើងធ្វើបានតាំងពីយើងឯកោ តាំងពីគេហ៊ុមព័ទ្ធនយោបាយផង សេដ្ឋកិច្ចផង រហូតឥឡូវទៅជាកម្ពុជាដើរតួនាទីរួមចំណែកដោះស្រាយវិបត្តិនានា លើសាកលលោកនិងក្នុងតំបន់។ យើងធ្វើបាន ក៏ដោយសារតែយើងឆ្លងកាត់បទពិសោធ មានការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីជាតិ និងប្រជាពលរដ្ឋរបស់យើង"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយគ្រូបង្រៀន គ្រូពេទ្យ សិល្បករ សិល្បការិនី ក្រុងបាត់ដំបង

៩៣-សូមទោសពលរដ្ឋឃុំព្រៃកតាសរ

“ខ្ញុំសូមអរភ័យទោស ពលរដ្ឋឃុំព្រៃកតាសរ ចំពោះការឆកល្វែងរបស់ថ្នាក់ដឹកនាំ និងអាជ្ញាធរមូលដ្ឋាន ដែលយើងមិនបានដោះស្រាយទាន់ពេលវេលានូវបញ្ហាផ្លូវខូចខ្លាំង...។ ខ្ញុំមិនបានព្រងើយកន្តើយទេ! ហើយខ្ញុំមានការអៀនខ្មាសណាស់ គឺខ្មាសត្រង់ថា ផ្លូវហ្នឹងមានភក់ មានល្បាប់ ដោយគ្មាននរណាគិតគូរទាន់ពេល។ យើងចេះតែខិតខំសុំឱ្យគាត់ជោះឆ្នោតឱ្យ! តើជោះឆ្នោតឱ្យយ៉ាងម៉េច បើផ្លូវរ៉ាអីចឹងៗ...។ ឥឡូវទទួលព័ត៌មានមកថា ក្រុមការងារចាប់ផ្តើមស្ថាបនាផ្លូវនោះជូនហើយ ដោយបានសាងសង់ជាផ្លូវបេតុងជូនប្រជាពលរដ្ឋតែម្តង។ ខ្ញុំសប្បាយចិត្តណាស់! បើកាលណាផ្លូវហ្នឹងបានធ្វើ ប្រៀបដូចបានឡើងឋានសួគ៌សម្រាប់ប្រជាពលរដ្ឋនៅតំបន់នោះ។ ដូច្នេះ ត្រូវធ្វើឱ្យបានល្អ ខ្ញុំអាចទៅមើលទីនោះម្តងទៀត”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ ពិធីសម្ពោធផ្សារកំពង់ពពិលស្រុកពារាំង

៩៤-បើកបេះដូងឱ្យទូលាយ កុំចង្អៀតចង្អល់

"មុននេះបន្តិច ពេលខ្ញុំដើរមក ខ្ញុំលឺពាក្យមួយគេណែនាំថា សម្តេច! នេះជាបងប្អូនដែលទើបសមាហរណកម្ម។ ខ្ញុំចង់ភ័យដែរ ព្រោះស្មានថាអ្នកមកពីប៉ែលិន ឬយ៉ាងម៉េច? សូមកុំប្រើពាក្យហ្នឹង! កុំនាំគ្នាប្រើពាក្យសមាហរណកម្មអីចឹងអី! ប្រើពាក្យសមាជិកថ្មីទៅបានហើយ។ សមាហរណកម្មវាដូចថាជ្រៅណាស់ វាដូចជាថាពីមុនហ្នឹងយើងជាបក្ខដិបក្ខស្លាប់រស់អីចឹង។ ការបង្កើតបក្សនយោបាយ ឬការមាននិន្នាការខុសៗគ្នា គឺវាមិនមែនជាគូបក្ខដិបក្ខស្លាប់រស់ស្អីនោះទេ ប៉ុន្តែវាជាគូប្រជែងដណ្តើមគ្នាធ្វើអំពើល្អជាមួយប្រជាពលរដ្ឋ ដើម្បីបានការគាំទ្រហើយបោះឆ្នោតឱ្យ។ អីចឹងទេ បើមានបងប្អូនជាសមាជិកបក្សផ្សេងគាត់មកចូលជាមួយគណបក្សយើង យើងថាសមាជិកថ្មី។ សមាជិកថ្មីហ្នឹង វាអាចមានពីរយ៉ាងទៅទៀត ទីមួយសមាជិកមកពីបក្សផ្សេងៗដែលធ្លាប់ប្រឆាំងយើង ហើយទីពីរគឺកូនចៅសមាជិកបក្សយើងស្រាប់។ ក្នុងភាពជាអ្នកដឹកនាំ និងគណបក្សគឺយើងបើកបេះដូងឱ្យទូលាយ កុំចង្អៀតចង្អល់ កុំវាយប្រហារកាច់កុងគ្នាអី"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកពាមជរ

៩៥-ឃើញយើង គេសឹងតែស្តោះទឹកមាត់ដាក់

"យើងឆ្លងកាត់ឆ្នែតហើយ គឺឆ្លងកាត់គេដាក់ទណ្ឌកម្ម ជុំទិស។ ចេញពី៧៩មក (៧ មករា ១៩៧៩) គ្មានសល់អ្វីទេ សឹងតែគ្មានសល់ជីវិតផង។ តែគេដាក់ទណ្ឌកម្មយើង គេហ៊ុមព័ទ្ធនយោបាយមិនឱ្យមានការទាក់ទងការទូតជាមួយយើង គេចាត់ទុកយើងជាអាយ៉ងដែលត្រូវបានវៀតណាមឈ្លានពាន ហើយលើកបន្តុប។ គេឃើញយើងសឹងតែស្តោះទឹកមាត់ដាក់...។ គេចង់តែគេចយើង។ យើងក៏ខ្មាសគេដែរ តែឱ្យធ្វើម៉េច បើយើងវាគ្មានជម្រើស។ យ៉ាងណាយើងបានប្រឹងពីបាតដៃទទេ ពីឯកោទាំងនយោបាយ និងសេដ្ឋកិច្ច រហូតយើងកសាងបានកម្ពុជាមួយដូចសព្វថ្ងៃ។ អានេះហើយក្តីវេទនា តែយើងតស៊ូ រហូតកសាងជាតិយើងឱ្យបានប៉ុណ្ណោះ..."

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកពាមជរ

៥៦-កម្មវត្ថុនិងរបៀបវារៈត្រូវបន្តធ្វើ

"បេសកកម្មយើងនៅមានច្រើនណាស់ ដើម្បីធ្វើម៉េចឱ្យជីវភាពប្រជាជនកាន់តែប្រសើរ។ ធ្វើម៉េចឱ្យប្រជាពលរដ្ឋយើងមានឡានជិះកាន់តែច្រើន មានផ្ទះសម្បែងរស់នៅសមរម្យ មានទឹកស្អាត មានពេទ្យព្យាបាលសុខភាពល្អ មានសាលារៀនល្អ មានគ្រូបង្រៀនល្អសម្រាប់កូនចៅយើង មានផ្លូវធ្វើដំណើរ អគ្គិសនីគ្រប់ច្រកល្ហក សម្រាប់ប្រជាពលរដ្ឋធ្វើដំណើរ ទាំងយប់ទាំងថ្ងៃ និងប្រកបកិច្ចការក្នុងជីវិត។ ទាំងអស់នេះ ក៏ជាកម្មវត្ថុ និងក៏ជារបៀបវារៈ ដែលគណបក្សប្រជាជនកម្ពុជាយើង ត្រូវបន្តធ្វើ។ ពួកយើងមិនមែនចេះតែវាយខ្ទាំង ឬមិនមែនចេះត្រឹមតែរំលាយអង្គការចាត់តាំងខ្មែរក្រហមនោះទេ។ យើងក៏ចេះដែរ ចេះកិច្ចការទំនាក់ទំនងអន្តរជាតិ យើងចេះកសាង ចេះស្ថាបនាផ្លូវ ភ្លើង ទឹកស្អាតឱ្យប្រជាជនយើងដែរ។ យើងបានធ្វើ ហើយបន្តទៀត ដើម្បីឱ្យពលរដ្ឋយើងមានជីវភាពកាន់តែប្រសើរជាងនេះ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកព្រះស្តេច

៩៧-មុខងារកាតព្វកិច្ចនិងមុខងារជម្រើស

"ការអនុវត្តមុខងារ បើថាឃុំ សង្កាត់ ក៏វាមានពីរសំខាន់ដែរ គឺទីមួយមុខងារជាកាតព្វកិច្ច និងទីពីរមុខងារជាជម្រើស។ មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលច្បាប់បានកំណត់ឱ្យឃុំ សង្កាត់ធ្វើអ្វីហើយ គឺត្រូវតែធ្វើហ្នឹង។ ចំណែកឯមុខងារជម្រើស ចង់និយាយថាឃុំ សង្កាត់នីមួយៗ វាមានស្ថានភាពមិនដូចគ្នាទេ។ ដូចជាឃុំត្រពាំងស្រែ ឃុំជីផុច ឬឃុំព្រៃឃ្លួស ស្ថានភាពមិនដូចគ្នាទេ។ អីចឹង មុខងារជម្រើស គឺបើកាលណាគាត់ឃើញថាការងារណាមួយអាទិភាពជាង តាមភាពជាក់ស្តែង អនុញ្ញាតឱ្យឃុំ សង្កាត់ហ្នឹងជាអ្នកប្រជុំសម្រេចជ្រើសរើស ឬប្រជុំកំណត់យកមកធ្វើផែនការដើម្បីអនុវត្ត"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកមេសាង

៩៨-យើងរក្សាបានសាមគ្គីភាពផ្ទៃក្នុងយ៉ាងរឹងមាំ

"ខ្ញុំសូមលើកយកបទពិសោធ គណបក្សប្រជាជនកម្ពុជា មកបញ្ជាក់ជូនថា សាមគ្គីភាព និងឯកភាពផ្ទៃក្នុង របស់យើង គឺជាកត្តាដ៏សំខាន់មិនអាចខ្វះបាន។ ថ្នាក់ដឹកនាំកំពូលៗនៃគណបក្សយើង បើទោះបីទទួលរងនូវការបំបែកបំបាក់ ការញុះញង់ពីមជ្ឈដ្ឋានខាងក្រៅ ឬពីមជ្ឈដ្ឋានបរទេសយ៉ាងណាក៏ដោយ ប៉ុន្តែអ្នកដឹកនាំបក្សយើងនៅតែរក្សាបានសាមគ្គីភាពផ្ទៃក្នុងយ៉ាងរឹងមាំ។ សាមគ្គីភាពនេះ គឺយើងផ្អែកទៅលើគោលការណ៍ គោលនយោបាយ ឬក៏បន្ទាត់នយោបាយ។ នេះជាការសាមគ្គីភាពមួយ។ ប៉ុន្តែវាក៏ចំណុះលើទំនាក់ទំនង សហប្រតិបត្តិការ និងមនោសញ្ចេតនាទៅជាមួយគ្នាដែរ។ ក៏ប៉ុន្តែចង់និយាយថា បើអ្នកណាធ្វើខុស អ្នកហ្នងទទួលខុសត្រូវ! ព្រោះវាជារឿងមួយផ្សេងទៀត។ អ៊ីចឹង សាមគ្គីឯកភាព ជាបទពិសោធថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងក៏ជាមេរៀនមួយសម្រាប់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី រួមទាំងថ្នាក់ដឹកនាំយើង ជាពិសេសបេក្ខជនក្រុមប្រឹក្សាឃុំ សង្កាត់ដែរ។ ត្រូវធ្វើម៉ែចពង្រឹងសាមគ្គី និងឯកភាពផ្ទៃក្នុងឱ្យបានរឹងមាំ ត្រូវចេះយោគយល់អធ្យាស្រ័យគ្នា ប៉ុន្តែកុំដើរហួសពីច្បាប់ និងការទទួលខុសត្រូវ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ សំណេះសំណាលជាមួយសមាជិកសមាជិកា គណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកកំពង់ត្របែក

៥៩-ស្មោះត្រង់ ហើយបើកចំហ

"ក៏ជាបទពិសោធមួយទៀតដែរ គឺភាពស្មោះត្រង់ បើកចំហ និងទូលំទូលាយ។ បានន័យថា យើងបើកទ្វារចំហ មិនចង្អៀតចង្អល់ មិនច្រណែនឈ្នានីសគ្នា លើកទឹកចិត្តអ្នកល្អ និងអ្នកមានសមត្ថភាព។ នេះក៏ជាបទពិសោធ ជាមាសជាប្រាក់ជាពេជ្ររបស់គណបក្សប្រជាជនកម្ពុជាយើងដែរ។ អរីចឹង ហើយបានជាគណបក្សយើង មានធនធានមនុស្សសម្បូរបែបតាំងពីយើងនៅបាតដៃទទេ តាំងពីអត់មានអ្នកចេះដឹង ឬក៏ថាមានតិចបំផុត បន្ទាប់ពីបញ្ចប់វគ្គ និងគ្រូបង្រៀនត្រូវខ្មែរក្រហមសម្លាប់ស្ទើរតែអស់រលីង ប៉ុន្តែយើងខិតខំប្រឹងប្រែង រហូតទីបំផុត យើងបានកសាងធនធានមនុស្សយ៉ាងច្រើន ជួយកិច្ចការងាររដ្ឋបាលគ្រប់ជាន់ថ្នាក់"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកកំពង់ត្របែក

១០០-ខ្ញុំក៏មិនសប្បាយចិត្ត និងមិនគាំទ្រដូចគ្នា

"អ្នកខ្លះដើរស្រែកថាខ្លួនស្នេហាជាតិ តែរអ៊ាត់ជាន់ជួយធ្វើអីទេ! បើរឿងស្នេហាជាតិហ្នឹង គឺគ្មាននរណាស្នេហាជាងគាត់តែម្តង។ អាហ្នឹងស្រែចតែគេចុះ តាមកម្មផលគេធ្វើហ្នុងទៅ សម្រាប់យើង យើងនាំគ្នាធ្វើតែអំពើល្អ ធ្វើឱ្យបានត្រឹមត្រូវ។ ខ្មែរយើងស្រួលណាស់ បើយើងធ្វើអំពើល្អជាមួយហើយ គាត់មិនងាយភ្លេចគុណយើងឡើយ កុំតែទៅជិះជាន់ ប្រើអំណាចដោយរំលោភ សង្កត់សង្កិន ប៉ះពាល់សិទ្ធិ និងផលប្រយោជន៍គាត់។ អាហ្នឹងហើយគាត់មិនសប្បាយចិត្តទេ ហើយក៏មិនមែនតែគាត់ដែរ សូម្បីតែខ្ញុំ ក៏មិនសប្បាយចិត្ត និងមិនគាំទ្រដូចគ្នា"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសមាជិកគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ស្រុកកំពង់ត្របែក

១០១-ធ្វើតាមប្រជាជនមិនសូវខុសទេ...

*"ការតាក់តែងកម្មវិធីនយោបាយ បើសិនណាប្រាសចាកពីបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ គឺចាត់ទុកថាខុសហើយ។ ប៉ុន្តែបើយើងយកគំនិត យកបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមកបញ្ចូល វាមិនងាយចេះខុសទេ នេះគឺជាពិសោធ។ខ្ញុំ ឯកឧត្តម **ពុំ សុខា** នៅទីនេះស្រាប់ (ប្រាភ្នំ) ពួកយើងជាសេនាធិការមួយ ក្នុងការរួមចំណែករៀបចំ សេចក្តីព្រាងកម្មវិធីនយោបាយរបស់គណបក្ស តាំងពីទសវត្សរ៍៨០មកម្លេះ។ យើងធ្វើកម្មវិធីនយោបាយទៅបាន ដោយផ្អែកលើស្ថានភាពជាក់ស្តែងរបស់ប្រទេស ផ្អែកលើសេចក្តីត្រូវការ និងជីវភាពរស់នៅរបស់ប្រជាជន។ និយាយមួយបែបទៀត យើងធ្វើតាមប្រជាជនមិនសូវខុសទេ។ ដូចថាប្រជាជនត្រូវការឱ្យកូនរៀន យើងត្រូវធ្វើសាលារៀន! បើគាត់ចង់ធ្វើទានធ្វើសីលថ្វាយបង្គំព្រះ យើងធ្វើវត្ត ឬធ្វើសាលាបុណ្យឱ្យគាត់! បើចង់ការកូនចៅទៅតាមប្រពៃណីទំនៀមទំលាប់ យើងអនុញ្ញាតឱ្យ! ឬគាត់ចង់ធ្វើស្រែជាឯកជន ឱ្យគាត់ធ្វើជាឯកជនទៅ។ ការបំពេញតម្រូវការប្រជាពលរដ្ឋ គឺជាផលនិងទ្រព្យសម្បត្តិរបស់ជាតិ។ តិចលោរអាងថាអញមេដឹកនាំ អញចង់ធ្វើអីក៏បាន អាហ្នឹងខុសហើយ"*

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកបាភ្នំ

១០២-ឈ្នះដើម្បីឈ្នះ ឈ្នះឱ្យមានកិត្តិយស!

"បើកាលណាការបោះឆ្នោតវាដំណើរការល្អ វាគ្មានអំពើហិង្សា គ្មានការគាបសង្កត់ គ្មានការគំរាមកំហែង វាដំណើរការដោយសេរី ត្រឹមត្រូវ យុត្តិធម៌ វានឹងធ្វើឱ្យអ្វីៗដែលជាប្រយោជន៍កើតឡើងទៅតាមហ្នឹងដែរ។ មានន័យថា អ្នកវិនិយោគ ឬអ្នកទេសចរជាដើមនឹងកាន់តែមកប្រទេសយើង។ មើលឱ្យវែងឆ្ងាយ មិនមែនដឹងតែពីឈ្នះនោះទេ ត្រូវឈ្នះដើម្បីឈ្នះ! បើឈ្នះដើម្បីតែចាញ់ដដែល យកវាមកធ្វើស្អី។ គេថាប្រទេសហ្នឹងយ៉ាប់ គេមិនមកវិនិយោគ ឬក៏អ្នកទេសចរគេថា ស្រុកហ្នឹងអសន្តិសុខណាស់ ដូច្នេះគេមិនមកលេងទេ អាហ្នឹងយើងខាតហើយ ខាតដោយសារឈ្នះដើម្បីចាញ់។ ចង់និយាយថានៅពេលបោះឆ្នោតយើងមានអំពើហិង្សាលើគ្នាទៅវិញទៅមក ឬមានជម្លោះ ទោះជាបុគ្គល និងបុគ្គលមែន តែវាខូចឈ្មោះគណបក្ស ខូចឈ្មោះរាជរដ្ឋាភិបាល។ អីចឹង ត្រូវឈ្នះដើម្បីឈ្នះ! បើយើងធ្វើអំពើល្អដើម្បីដណ្តើមយកជោគជ័យតាមគោលការណ៍ និងតាមច្បាប់នៃការបោះឆ្នោត យើងនឹងឈ្នះហើយមានកិត្តិយសល្អ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកកំចាយមារ

១០៣-មិនត្រូវភ្លេច និងមើលស្រាល

"យើងទើបតែមានសុខសន្តិភាព ពេញផ្ទៃប្រទេសបានជាង២០ឆ្នាំ តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោ** យើងបានសុខសន្តិភាព១០០ភាគរយ។ យើងមិនត្រូវភ្លេចហើយនាំគ្នាមើលស្រាល ឬបណ្តែតបណ្តោយឱ្យប្រទេសយើង ទៅជាមានសង្គ្រាមជម្លោះបែកបាក់ទៀតទេ។ ពិតហើយថា មានគណបក្សដទៃចូលរួមប្រកួតប្រជែងបែបប្រជាធិបតេយ្យ តែយើងជាគណបក្សចាស់ទុំ ជាគណបក្សដែលបានដឹកនាំប្រទេស តាំងពីនៅចំណុចសូន្យរហូតដល់ពេលនេះ។ យើងជាបក្សដែលធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព ពេញបរិបូរណ៍ និងមានឆន្ទៈគាំទ្រឱ្យមានការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិក សមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកកំចាយមារ

១០៤-ពុំទាន់មានបក្សណាល្អជាងCPP

"លើកលែងតែការបោះឆ្នោត ដែលរៀបចំដោយអ៊ុនតាក់ (UNTAC) រាប់ចាប់ពីការបោះឆ្នោតឆ្នាំ១៩៩៨មក យើងជោគជ័យរហូត។ នេះមានន័យថាប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស គ្រប់មជ្ឈដ្ឋាន គាត់មិនទាន់ឃើញ គណបក្សណាមានគុណសម្បត្តិមាននយោបាយ មានឧត្តមគតិល្អជាងគណបក្សប្រជាជនកម្ពុជានៅឡើយ។ ដូច្នេះហើយទើបបានជាគាត់នៅតែបន្តគាំទ្រយើងតាមរយៈការបោះឆ្នោត។ ការបោះឆ្នោតនេះទៀតក៏គ្មាននរណាទៅភ្ជង់កាំភ្លើង ឱ្យគាត់បោះឆ្នោតឱ្យនោះដែរ។ គាត់បោះឆ្នោតជាសម្ងាត់ សូម្បីបងប្អូន សាច់ញាតិក៏គាត់មិនប្រាប់ និងក៏មិនដឹងថាគាត់បោះឆ្នោតឱ្យបក្សណាដែរ។ ដូច្នេះ លទ្ធផលនៃការបោះឆ្នោតកន្លងមកនេះ វាជាការបង្ហាញពីទឹកចិត្តពលរដ្ឋមកលើគណបក្សយើង"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកស៊ីធរកណ្តាល

១០៥-ព្រះមហាក្សត្រ

"របបរាជានិយមរអាស្រ័យរដ្ឋធម្មនុញ្ញ គឺមានន័យថា ព្រះមហាក្សត្រ ព្រះអង្គទ្រង់សោយរាជ្យ ប៉ុន្តែមិនកាន់អំណាច។ ព្រះករុណាជាអម្ចាស់យើងសព្វថ្ងៃនេះ ទ្រង់គោរពណាស់ ទ្រង់គោរពរដ្ឋធម្មនុញ្ញយកតែមែនទែនតែម្តង។ ព្រះអង្គក៏ពុំដែលមានព្រះរាជសកម្មភាពណាមួយរំលោភរដ្ឋធម្មនុញ្ញនោះដែរ។ ទ្រង់ពុំបានទៅឡុកឡំហ្នឹងរឿងនយោបាយឡើយ។ ពួកយើងគោរពព្រះអង្គណាស់!"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកស៊ីធរកណ្តាល

១០៦-កុំថាពួកអារអស់ហ្នឹងគ្មានធ្វើអ្វីទេ

"គណបក្សប្រឆាំងគេអត់បានធ្វើអ្វីដូចយើងពិតមែន វាជាធម្មតាទេ ក្រុមបក្សប្រឆាំង យើងកុំទៅបន្ទោសគេ។ ខ្ញុំនិយាយនេះមិនមែនការពារបក្សប្រឆាំងទេ។ តែយើងកុំថា យ៉ើស...!ពួកអារអស់ហ្នឹងគ្មានធ្វើស្អីផង! សាលារៀនក៏មិនធ្វើ ស្អីក៏មិនធ្វើ។ ខ្ញុំថាគេមិនធ្វើមែនហ្នឹងហើយ ព្រោះគេមានអំណាចអីហ្នឹងធ្វើដូចយើង។ គេចាំតែស្រង់ចំណុចខ្សោយយើងយកទៅឃោសនាទេ។ ដូច្នេះ ត្រូវយល់ចំណុចនេះ ហើយធ្វើម៉េចកុំឱ្យមានចំណុចខ្សោយ ដូចជាការរំលោភបំពាន ឬបញ្ហាអសកម្មផ្សេងទៀត។ និយាយបែបនេះ ក៏មិនប្រាកដថាក្រុមប្រឆាំងអស់ហ្នុង ពេលមានអំណាចអាចធ្វើបានដូចយើង។ ពួកយើងនេះ ធ្វើតាំងពីបាតដៃទទេ រហូតស្រុកទេសបានដូចសព្វថ្ងៃ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកព្រះស្តេច

១០៧-បើមានបក្សគេខ្លះដូចទំនង

"ជាការពិតហើយអស់លោក លោកស្រី តាមឃុំ សង្កាត់យើងនេះ ចង់តែឈ្នះទេ បើថាមួយសង្កាត់មាន ៥អាសនៈក៏ចង់ឈ្នះទាំង៥ហ្នឹងតែម្តង បើមាន ៩អាសនៈ ក៏ចង់ឈ្នះទាំងអស់ដែរ។ ឈ្នះទាំងអស់ បើទៅវិញជាការល្អហើយ តែបើមានគណបក្សនេះ គណបក្សនោះក្រៅពីខ្លះ ដូចថាបាន១ ឬ២អាសនៈខ្លះវាក៏មានន័យដែរ មិនអត់ប្រយោជន៍ទេ។ បើនៅសង្កាត់យើងនេះមាន៥អាសនៈ យើងឈ្នះ៤ គណបក្សផ្សេងបាន១ អាហ្នឹងល្អមើល។ ដូចថាមានភាពចម្រុះ និងប្រជាធិបតេយ្យ។ តែបើយើងឈ្នះទាំងអស់ក៏មិនខុស ព្រោះប្រជាពលរដ្ឋគាំទ្រយើងទេតើ។ សរុបមកវិញ ត្រូវមានយន្តការប្រមូលគ្នាជួយធ្វើការ ផ្សះផ្សា និងបង្រួបបង្រួមគ្នា យើងធ្វើការបម្រើជាតិ និងប្រជាជនក្នុងមូលដ្ឋានយើងឱ្យបានល្អ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិ៥ ក្រុងព្រៃវែង

១០៨-ចង់បានផ្លូវពីភ្នំពេញបុកទៅក្រុងព្រៃវែង

“ខ្ញុំបានស្នើយូរហើយ មិនមែនថ្មីៗនេះទេ ខ្ញុំចង់បានផ្លូវមួយខ្សែចេញពីភ្នំពេញឆ្ពោះទៅក្រុងព្រៃវែង តែវាចំណាយថ្លៃពេក។ អ្នកសិក្សាដំបូងថាអស់៥០លានដុល្លារ ក្រោយមកឡើង ២០លានដុល្លារទៀត រហូត៧០លានដុល្លារ។ ៧០លានបែបមិនសូវស្រួល ក៏ដកថយមកសិក្សាម្តងទៀត។ សម្រាប់ខ្ញុំ ទាល់តែបានផ្លូវហ្នឹង ទើបព្រៃវែងលែងឯកោ។ ព្រោះសព្វថ្ងៃដូចឯកោនៅឡើយ។ បើជិះផ្លូវជាតិលេខ៨ មកក្រុងព្រៃវែង តាមប៉ែកខាងជើងវាប្រមាណ៣០គីឡូ បើជិះពីផ្លូវជាតិលេខ១វាប្រមាណ៤០គីឡូ។ អីចឹងទៅក៏ហួស មកក៏ហួស ហើយក្រុងព្រៃវែងនៅតែហាមាត់ទៅ...។ ខ្ញុំជឿថានឹងបានផ្លូវហ្នឹងជាក់ជាពុំខាន ព្រោះវាជាផ្លូវដែលបំពេញសេចក្តីត្រូវការប្រជាពលរដ្ឋ”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកពោធិ៍រៀង

១០៩-ចុះទៅភូមិពលរដ្ឋនៅទន្លេសាប

"ថ្ងៃមុនខ្ញុំជាមួយថ្នាក់ដឹកនាំផ្សេងទៀត យើងបានចុះទៅមើលជាក់ស្តែង នៅតំបន់បឹងទន្លេសាប។ យើងចុះដល់វត្តមួយនៅភូមិដូនទ្រី ឃុំផ្លែ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ វត្តហ្នឹងកើតតាំងឆ្នាំ១៨៨០ជាងឯណោះ។ ប៉ុន្តែវត្តឋិតនៅក្នុងតំបន់២នៃបឹងទន្លេសាប។ តាមច្បាប់ គឺមិនអាចកាន់កាប់ជាកម្មសិទ្ធិ។ ភូមិដូនទ្រីហ្នុងក៏ចំណាស់ជាង១០០ឆ្នាំហើយដែរ ប៉ុន្តែស្ថិតក្នុងតំបន់២នោះទៀត។ អីចឹងទេ ពលរដ្ឋរស់នៅតំបន់ហ្នុង គាត់មិនអាចកាន់កាប់គ្រប់គ្រងដីភូមិស្រែចម្ការគាត់បាន។ យើងក៏ចុះទៅឃើញជាក់ស្តែង។ យើងស្រាវជ្រាវទៅក៏សម្រេចកែសម្រួលការកំណត់តំបន់ឡើងវិញ។ ចង់មានន័យថា បើបញ្ហាកើតឡើងអីចឹង យើងជាអាជ្ញាធរឃុំ ឬស្រុក បើដឹងដែរ តែវាលើសសមត្ថភាពយើងដោះស្រាយ យើងត្រូវតែរាយការណ៍មកលើ ដើម្បីរួមគ្នាដោះស្រាយ។ ឥឡូវខ្ញុំចុះទៅ មិនត្រឹមតែរួមគ្នាដោះស្រាយទេ ខ្ញុំក៏តាំងចិត្តជួយវត្តហ្នឹងឱ្យរីកចម្រើនបន្ថែមទៀតដែរ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់នៅស្រុកមោងឫស្សី

១១០-យើងប្រឹងណាស់ ទម្រាំគេទទួលស្គាល់!

"យើងប្រឹងប្រែងណាស់...! ប្រឹងតាំងពីគេមិនទទួលស្គាល់ ដោយគេចាត់ទុកយើងថាជាកម្លាំងក្រៅច្បាប់ ទាំងដែលយើងជាអ្នករំដោះប្រជាជនយើងចេញ ពីការកាប់សម្លាប់ របស់ពួកខ្មែរក្រហមសោះ គេទៅជាបបួលគ្នីគ្នាគេ មកចាត់ទុកកម្លាំងត្រីភាគី (ហ៊ុនស៊ីនប៉ិច-ខ្មែរក្រហម-សីនសាន្ត) ជាកម្លាំងស្របច្បាប់ អាចអង្គុយនៅអង្គការសហប្រជាជាតិ ទាំងកម្លាំងយើងគ្រប់គ្រងទឹកដីជាក់ស្តែង៨០ភាគរយ គេថាមិនស្របច្បាប់ អ្នកគ្រប់គ្រងតែ២០ភាគរយគេថាស្របច្បាប់។ ដូច្នេះ ខ្ញុំចង់និយាយថាយើងបានប្រឹងប្រែងតស៊ូពីស្ថានភាពបែបនោះ រហូតយើងប្រែក្លាយជាកម្លាំងមួយស្របច្បាប់ ហើយជាកម្លាំងមួយមិនអាចខ្វះបាននៅព្រះរាជាណាចក្រកម្ពុជា តាំងពីពេលនោះ រហូតបច្ចុប្បន្ន និងទៅអនាគត"

ក្រឡាហោមខេង

ខេត្តឆ្លាត់ដំបង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្សក្នុងឃុំនាការយោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ស្រុកគាស់ក្រឡ

១១-ទោះមិនបោះឆ្នោតឱ្យយើង តែគាត់ទៅបោះឆ្នោត

"រឿងបោះឆ្នោត យើងត្រូវតែដឹងគុណប្រជាពលរដ្ឋ មិនមែនតែប្រជាពលរដ្ឋដែលគាំទ្រគណបក្សយើងនោះទេ គឺប្រជាពលរដ្ឋទាំងអស់។ យើងត្រូវមានទស្សនៈមួយទូលំទូលាយ ដើម្បីប្រមូលការគាំទ្រឱ្យបានច្រើន។ ហេតុអ្វី? ពីព្រោះយ៉ាងហោចណាស់ យើងត្រូវគិតថាប្រជាពលរដ្ឋ ដែលគាត់មិនបោះឆ្នោតឱ្យយើង ប៉ុន្តែគាត់ទៅចូលរួមបោះឆ្នោត។ សន្លឹកឆ្នោតមួយសន្លឹកហ្នឹង ពិតហើយគាត់បោះឱ្យបក្សដទៃ ប៉ុន្តែគាត់បានចំណាយពេលទៅបោះឆ្នោត មានន័យថា ពួកគាត់គាំទ្រការបោះឆ្នោត។ ដូច្នេះគាត់ក៏មានគុណសម្បត្តិដែរ យើងត្រូវចេះគិតជារួមអរីចឹង។ គាត់ក៏គាំទ្រឱ្យមានការបោះឆ្នោត ដើម្បីសន្តិភាព និងស្ថិរភាពក្នុងមូលដ្ឋាន និងប្រទេសជាតិ។ ចំណែកយើង គឺយើងឈ្នះឆ្នោតជារឿងរបស់យើង ដែលត្រូវខិតខំបម្រើប្រជាពលរដ្ឋទូទៅទាំងអស់។ អរីចឹងហើយសូមមេត្តាកុំឱ្យបែងចែក។ គណបក្សយើងមានបទពិសោធរឿងហ្នឹងណាស់ ផ្នាក់ដឹកនាំយើង យើងបើកចំហ យើងមិនដឹកនាំប្រទេសដោយមានការបែងចែកទេ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកគាស់ក្រឡ

១១២-ត្បូងឃ្មុំ និងគាស់ក្រឡង ផ្តើមគំនិតបង្កើតនៅលើមេឃ

"ចោះឆ្នោតហើយ (ឆ្នាំ២០០៣) នៅលើអេឡិកូ (ឧទ្ធម្ភាគចក្រ) ពីភ្នំពេញទៅសៀមរាប ដើម្បីប្រជុំសភា។ កាលណោះ **ព្រះករុណា** សម្តេចឪ **នរោត្តម សីហនុ** ព្រះអង្គគង់នៅទីនោះ ទ្រង់មិនយាងបើកសម័យប្រជុំសភានៅភ្នំពេញទេ។ លើអេឡិកូហ្នុង មានខ្ញុំ មាន **សម្តេចនាយក សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង មាន **សម្តេច សាយ ឈុំ**។ ខ្ញុំក៏បានស្នើបង្កើតខេត្តមួយ និងស្រុកមួយ។ ស្រុកមួយហ្នឹង គឺស្រុកគាស់ក្រឡនេះឯង ដើម្បីដាក់ជាតំបន់រដ្ឋបាល ងាយស្រួលជួយប្រជាពលរដ្ឋ។ ចំណែកខេត្តខ្ញុំស្នើបង្កើតខេត្តត្បូងឃ្មុំ ដោយបំបែកពីខេត្តកំពង់ចាម។ ប៉ុន្តែដោយសារមានបញ្ហាខ្លះ ក្រោយមកទើបយើងអាចបង្កើត ខេត្តត្បូងឃ្មុំបានជោគជ័យ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាចោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ស្រុកគាស់ក្រឡ

១១៣-CPP ធ្វើសង្គ្រាមយកអំណាច ប៉ុន្តែ...!

"យើងទទួលស្គាល់ថាគណបក្សប្រជាជនកម្ពុជាពិតជាមានប្រវត្តិឡើងកាន់អំណាចដោយសង្គ្រាម! ក៏ប៉ុន្តែ វាគឺជាសង្គ្រាមធ្វើឡើងដោយសារគ្មានជម្រើស ពីព្រោះយើងប្រឈមមុខ របបយោរយៅខ្មែរក្រហម។ ទោះបីជាដូច្នេះក៏ដោយ ក៏ថ្នាក់ដឹកនាំគណបក្សយើងបានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ដោយយើងផ្តល់តម្លៃដល់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ យើងបើកចំហរការចរចាបង្កើតបានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឈានទៅរៀបចំការបោះឆ្នោតជាលើកដំបូងនៅឆ្នាំ១៩៩៣ និងមានការបោះឆ្នោតជាបន្តបន្ទាប់ដល់សព្វថ្ងៃ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ពិធីជួបសំណេះសំណាលអាជីវករ ពាណិជ្ជករ សហគ្រិនវ័យក្មេង និងក្រុមការងារគ្រីស្ទបរិស័ទ ខេត្តបាត់ដំបង

១១៤-យើងមានពិសោធច្រើន ធៀបនឹងបក្សផ្សេង!

"ការដឹកនាំប្រទេសលើសាកលលោកនេះ តែងមានបញ្ហាប្រឈម មានបញ្ហាខ្វះខាត ឬការលំបាកដោយច្បៀសមិនផុត។ តែយើងចាត់ទុកបញ្ហាប្រឈម និងការលំបាកទាំងឡាយនោះថាជាការប្រឈម និងជាការលំបាកបណ្តោះអាសន្នមួយ ដែលយើងអាចដោះស្រាយបាន។ ឱ្យតែយើងមានឆន្ទៈខ្លាំងក្លា តស៊ូ និងស្មិតស្មាញដូចដែលយើងធ្លាប់ធ្វើកន្លងមក គឺតាំងពីក្រោយសម័យខ្មែរក្រហម។ យើងស្វះស្វែងរកការគាំទ្រ និងការចូលរួមពីប្រជាពលរដ្ឋកាន់តែច្រើន យើងក៏ជម្នះការលំបាកបាន ហើយក៏ទទួលបានជោគជ័យដែរ។ បើធៀបគណបក្សផ្សេង យើងមានបទពិសោធច្រើនណាស់។ បទពិសោធនជម្នះឧបសគ្គធំៗ ដូចជាការបង្ហូបបង្ហិម ផ្សះផ្សារជាតិ និងបញ្ចប់សង្គ្រាម។ ប្រសិនណាជាយើងគ្មានបទពិសោធគ្មានឆន្ទៈចិត្តចង្អៀតចង្អល់ ហើយបែងចែក ឬមានគំនុំគុំកួននោះ ប្រហែលជាយើងមិនអាចដោះស្រាយបានទេ។ យើងប្រកាន់នយោបាយបើកទូលាយ មិនប្រកាន់ មិនចង្អៀតចង្អល់ មិនបែងចែក មិនសងសឹក ទីបំផុតយើងក៏ប្រមូលបានប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋាន ដើម្បីគាំទ្រការដោះស្រាយបញ្ហា និងជម្នះការលំបាកនានា"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិក សមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុករតនមណ្ឌល

១១៥-ពេលជាប់ឆ្នោតក្លាយជាក្រុមប្រឹក្សាឃុំ សង្កាត់

"បេក្ខជនក្រុមប្រឹក្សាឃុំ សង្កាត់មកពីគណបក្សយើង ខ្ញុំសុំថាក្រោយពីការបោះឆ្នោតទទួលជោគជ័យហើយ យើងត្រូវតែពង្រឹងសាមគ្គីភាព ដើម្បីការពារគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សយើង។ បើគណបក្ស ណែនាំយ៉ាងម៉េច យើងត្រូវគោរពតាមហ្នឹង។ រាជរដ្ឋាភិបាល ណែនាំយ៉ាងម៉េច យើងត្រូវគោរពតាមហ្នឹង។ ចំណែកសមាជិកគណបក្សដទៃ គេក៏នឹងគោរពតាមគោលការណ៍បក្សគេដែរ។ អាហ្នឹងជារឿងរបស់គេ។ ក៍ប៉ុន្តែពេលក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចអនុម័តហើយ ត្រូវតែនាំគ្នាគោរពការអនុម័តនោះ ទោះគាត់ជាសមាជិកក្រុមប្រឹក្សា មកពីគណបក្សណាក៏ដោយ។ នេះជាគោលការណ៍ ជាច្បាប់ ជារបៀបរបបធ្វើការ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុករតនមណ្ឌល

១១៦-ឈ្លោះគ្នានៅតុប្រជុំ ចប់ប្រជុំរាប់អានគ្នាធម្មតា

"យើងអាចបង្កើតវប្បធម៌ល្អមួយបានតើ មានន័យថាជួនអីយើងជជែកគ្នាតឹងសរសៃកក្នុងកិច្ចប្រជុំ តែពេលចេញក្រៅតុប្រជុំ យើងអាចផឹកកាហ្វេជាមួយគ្នាបាន អាចផឹកប៊ីយ៉ែរជាមួយគ្នាបាន ឬទៅខាវ៉ារអូខេជាមួយគ្នាក៏បាន យើងចង់ឱ្យវាទៅអីចឹង។ ប៉ុន្តែយើងត្រូវពង្រឹងជំហរឱ្យបានច្បាស់លាស់ ត្រូវតែប្រកាន់គោលនយោបាយគណបក្ស ឱ្យបានច្បាស់លាស់។ មនោសញ្ចេតនា ទំនាក់ទំនងខាងក្រៅជាមួយក្រុម ឬបក្សផ្សេងវាជារឿងធម្មតា អាហ្នឹងគេហៅការតស៊ូមតិ ដើម្បីរីកចម្រើន។ យើងមិនយកគ្នាជាសត្រូវទេ មិនចាត់ទុកជាគូបដិបក្ខទេ យើងចាត់ទុកគ្នាជាគូប្រជែង។ យើងប្រជែងគ្នាតាមគោលជំហរបក្ស ដើម្បីឈ្នះឆ្នោតមែន ប៉ុន្តែទំនាក់ទំនង និងសាមគ្គីភាពក្នុងនាមជាខ្មែរ គឺរអ៊ត់បញ្ហា។ ចៀសវាងចោទគ្នាថាទេ..អាបុិហ្នឹងទៅផឹកកាហ្វេជាមួយគេរាល់ថ្ងៃ ឬសមាជិកយើងម្នាក់ហ្នឹង ឧស្សាហ៍ឃើញទៅហូបចុក ជាមួយខាងគេញឹកញាប់ ឬចោទគ្នាអ៊ីចេះមួយ អ៊ីចុះពីរ មិនបានទេ យើងមិនអាចផ្តាច់ទំនាក់ទំនងគ្នាទេ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ស្រុករតនមណ្ឌល

១១៧-ការព្យាករណ៍អាសនៈឃុំ សង្កាត់ ឆ្នាំ២០២២

"មានអ្នកទស្សន៍ទាយ ការសិក្សាតាមតួលេខជាបន្តបន្ទាប់តាំងពីការបោះឆ្នោតដំបូង នៅឆ្នាំ២០០២ រហូតបច្ចុប្បន្ន ក្នុងចំណោមអាសនៈសរុប ជាង១ម៉ឺន១ពាន់អាសនៈ ទូទាំងប្រទេស គេថាគណបក្សប្រជាជនកម្ពុជា អាចទទួលបានចន្លោះពី៨ពាន់ទៅ៩៥០០អាសនៈ។ គណបក្សផ្សេងៗពីហ្នឹង មានគណបក្សមួយនោះ (ភ្លើងទៀន) ប្រហែល២ពាន់អាសនៈ ទូទាំងប្រទេស។ នេះជាការទស្សន៍ទាយ ប៉ុន្តែទោះបែបណាក៏ដោយ យើងនៅតែឃើញគេព្យាករណ៍ថា គណបក្សប្រជាជនកម្ពុជាយើង ជាអ្នកនាំមុខ។ អាចនិយាយថាអ្នកបោះឆ្នោត ទាំងប្រជាពលរដ្ឋ និងសមាជិកបក្ស នៅតែបន្តផ្តល់ជំនឿទុកចិត្ត លើគណបក្សយើង។ នេះបើការទស្សន៍ទាយត្រឹមត្រូវ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកសង្កែ

១១៨-ជយោពីរសម័យ

"នៅជុំវិញលោកតាដំបងគ្រញូងនេះ យើងតាំងចិត្ត ពីដើមមកថាខិតខំរៀបចំឱ្យទៅជាសួនរមណីរំដ៏ល្អមួយ។ ម្យ៉ាងទាំងខាងឆ្វេង និងខាងស្តាំលោកតា យើងមានកន្លែងបណ្តុះបណ្តាលធនធានមនុស្ស។ ឥឡូវធ្វើបានច្រើនហើយ... អីចឹងទេបានថាកាលពីសម័យយើង វាខុសពីអីចឹង សម័យសង្គ្រាម បើមានគេដាក់ (ប្រាញ់ឬបំផ្ទុះគ្រាប់) មកក្តុង បើចំលើសាលាណាមួយ ឬក៏ក្តុងផ្តាច់បានស្ពានណាមួយ គេស្រែកជយោហ្មង! តែឥឡូវ បើយើងកសាងបានសាលារៀនមួយ ឬក៏ថាកសាងបានស្ពានមួយ យើងក៏នាំគ្នាស្រែកជយោដែរ ខុសពីមុនជយោខាងបំផ្លាញ!"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិកាគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ស្រុកសង្កែ

១១៩-សេចក្តីស្រែកឃ្លានរបស់បក្ស

"សេចក្តីស្រែកឃ្លានរបស់គណបក្សយើង ក្នុងការបម្រើប្រជាពលរដ្ឋ គឺមិនចេះចប់ទេ។ ដូច្នេះ យើងត្រូវការអំណាច ហើយដើម្បីបានអំណាច មិនមែនច្បាំងគ្នាទេ គឺបោះឆ្នោត និងធ្វើយ៉ាងម៉េចឱ្យប្រជាពលរដ្ឋគាំទ្រយើង។ គណបក្សយើងតែងតែប្រកាន់ខ្ជាប់ គោលការណ៍ណែនាំឱ្យមន្ត្រីខិតខំធ្វើអំពើល្អជាមួយប្រជាពលរដ្ឋ។ អំពើល្អ វាមិនចេះខុសទេ! ការដឹងសុខដឹងទុក្ខពលរដ្ឋនេះ វាជាទម្លាប់ ជាប្រពៃណី ជារាកប្បកិរិយា និងជាឧត្តមគតិគណបក្សយើងតាំងពីដើមរៀងមក។ យើងមិនគាំទ្រការប្រើអំណាចដោយរំលោភរបស់មន្ត្រីណាមួយឡើយ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ពិធីសំណេះសំណាលសមាជិកសមាជិការគណបក្ស ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ៥ ស្រុកឯកភ្នំ

១២០-ជ័យជម្នះដ៏គួរឱ្យសរសើរ

"ជ័យជម្នះដ៏គួរឱ្យកោតសរសើរនេះ ពិតជាមិនអាចកាត់ផ្តាច់បានឡើយ ពីការចូលរួមចំណែកយ៉ាងសំខាន់របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រមទាំងសកម្មជនគណបក្ស ដែលបានលះបង់ពេលវេលា និងធនធានជាច្រើន សកម្មចូលរួមគាំទ្របុព្វហេតុគណបក្សប្រជាជនកម្ពុជា ដែលតាំងពីដើមមក គឺយើងរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋគ្រប់កាលៈទេសៈ"

ក្រឡាហោម ស ខេង

ភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ សារផ្ញើជូនថ្នាក់ដឹកនាំ ក្រុមការងារគណបក្សគ្រប់លំដាប់ថ្នាក់ក្រោយចោះឆ្នោត នៃខេត្តបាត់ដំបង និងព្រៃវែង

១២១-ជោគជ័យមួយទៀត

"ជោគជ័យក្រោមបរិយាកាសស្ងប់ស្ងាត់ សុខសន្តិភាព និងគ្មានអំពើហិង្សា នៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥នេះ ក៏ជាការបង្ហាញទៅកាន់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ឱ្យឃើញនូវភាពចាស់ទុំ និងភាពម្ចាស់ការ ព្រមទាំងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់គណបក្សយើងអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា"

ក្រឡាហោមខេង

ភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ សារផ្ញើជូនកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្រោយថ្ងៃបោះឆ្នោត

១២២-ផ្តល់ដំបូន្មានសិស្សនគរបាលជាតិ

"មន្ត្រីនគរបាលយើង ត្រូវតែជានគរបាលមានសមត្ថភាព មានវិជ្ជាជីវៈ មានសីលធម៌ល្អ។ ដូចក្មួយៗដែលបានសិក្សានេះ គឺនោះហើយជាចំណេះវិជ្ជា និងជាចំណេះដឹង ដែលត្រូវប្រកាន់ខ្ជាប់ក្នុងអាជីព។ ពេលចេញបំពេញបេសកកម្ម បម្រើអង្គភាព និងប្រជាពលរដ្ឋ ត្រូវប្រែក្លាយខ្លួនឱ្យទៅជាមន្ត្រីនគរបាលល្អ។ ធ្វើម៉េចឱ្យពលរដ្ឋ គាត់មិនខ្លាចញញើតយើង ឱ្យគាត់ស្រលាញ់ ហើយជឿទុកចិត្ត និងផ្តល់កិច្ចសហការល្អជាមួយយើង។ ត្រូវចាំថា ទោះបីជាយើងមានកម្លាំងប៉ុន្មាននាក់ក៏ដោយ ក៏មិនអាចរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់បានល្អដែរ បើគ្មានការគាំទ្រ និងចូលរួមពីប្រជាពលរដ្ឋ។ នេះជាគោលការណ៍ និងជាទ្រឹស្តីមួយដែលត្រូវចងចាំ និងអនុវត្ត"

ក្រឡាហោមខេង

ខេត្តកំពង់ឆ្នាំង ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិធីបិទវគ្គបណ្តុះបណ្តាលបឋមវិជ្ជាជីវៈនគរបាលជំនាន់ទី១៥ លើកទី១ នៅសាលានគរបាលជាតិភូមិភាគ៦

១២៣-ទស្សនៈ«៦.ប.»

"ទស្សនៈ នៃការគ្រប់គ្រងនគរបាលជាតិ យើងប្រកាន់យកថា ទី១-**បញ្ចូល** សំដៅលើការបញ្ចូលក្របខ័ណ្ឌនគរបាលជាតិ ដោយឆ្លងកាត់ការប្រឡងប្រជែង។ ទី**២-បញ្ចោះ** សំដៅដល់ការបង្រៀនឱ្យចេះទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ **ទី៣-បញ្ជា** សំដៅលើការតែងតាំងឱ្យបំពេញការងារតាមជំនាញ និងផ្នែក។ **ទី៤-បញ្ចោរ** សំដៅដល់ការលើកទឹកចិត្ត ការដំឡើងស័ក្តិ ឋានៈ តួនាទី រង្វាន់ និងផ្តល់បណ្ណសរសើរ។ **ទី៥-បញ្ចោរ** សំដៅលើការអនុវត្តវិធានការ ចំពោះមន្ត្រីមានកំហុស ដូចជាការស្តីបន្ទោស ដាក់ទណ្ឌកម្ម ឬវិន័យជាដើម។ **ទី៦-បញ្ចោញ** គឺសំដៅដល់ការដក ឬលុបឈ្មោះចេញពីក្របខ័ណ្ឌនគរបាលជាតិ ប្រសិនណាបើខុសធ្ងន់ធ្ងរ ដូចជាការប្រព្រឹត្តបទល្មើស ឬប្រើប្រាស់ថ្នាំញៀនជាដើម។ និង**ទី៦-បញ្ចប់** សំដៅដល់ការរៀបចំឱ្យចូលនិវត្តន៍ ឬការបាត់បង់កាយសម្បទានវិជ្ជាជីវៈ"

ក្រឡាហោមខេង

ខេត្តកំពង់ឆ្នាំង ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិធីបិទវគ្គបណ្តុះបណ្តាលបឋមវិជ្ជាជីវៈនគរបាលជំនាន់ទី១៥ លើកទី១ នៅសាលានគរបាលជាតិភូមិភាគ៦

១២៤-អរព្យាក្រឹត្យភាព និងការដើរចេញពី គ.ជ.ប.

"មានគេសួរថាការបោះឆ្នោតឃុំ សង្កាត់ ធានាអរព្យាក្រឹត្យដែរឬទេ បើសមាជិក គ.ជ.ប. មានប្រភពចេញពីគណបក្សប្រជាជនកម្ពុជា? ខ្ញុំថាសំនួរនេះជាសំណួរខុស និងជាសំនួរដែលគេតាំងឡើយ ដោយមនោសញ្ចេតនាខឹង ឬស្អប់ណាមួយហើយ។ ពីព្រោះបច្ចុប្បន្ន ថ្នាក់ដឹកនាំ គ.ជ.ប. មានសមាសភាពមកពីប្រភពចម្រុះ ហើយច្បាប់ក៏ឆានតម្រូវឱ្យលាលែង ពីគណបក្សនយោបាយ និងមានកាតព្វកិច្ចអនុវត្ត តាមច្បាប់បោះឆ្នោត និងគោលការណ៍នានា។ ឥលូវខ្ញុំសួរវិញថា តើអតីតសមាជិក គ.ជ.ប. ដែលដើរចេញពីតួនាទី ដោយសារតែអតីតគណបក្សសង្គ្រោះជាតិត្រូវរំលាយនោះ វាជាការបង្ហាញពីអរព្យាក្រឹត្យ ឬយ៉ាងណាដែរ? អត់មាននរណាបណ្តេញគាត់សោះ គឺគាត់ដេញខ្លួនគាត់ចេញទេតើ។ ចំណុចនេះច្បាស់ណាស់ ថាពួកគាត់នៅតែមានអារម្មណ៍ និងមនោសញ្ចេតនាជាប់ជំពាក់ ជាមួយគណបក្សគាត់ហ្នឹងហើយ។ ត្រឡប់ទៅវិញ គឺគាត់ទេតើ ដែលអត់ទាន់ប្រកាន់ជំហរអរព្យាក្រឹត្យ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យជាតិបាត់ដំបង

១២៥-រួមគ្នាលុបបំបាត់វប្បធម៌ចោទស្មានៗ

"ដើរចោទថាគេលួចសន្លឹកឆ្នោត ចោទថាការបោះឆ្នោតមិនត្រឹមត្រូវ តែគណបក្សដែលដើរចោទគេនោះ បែរជានៅតែទទួលយកលទ្ធផលនៃការបោះឆ្នោត។ សួរថាហេតុអ្វី? ចម្លើយគឺដោយសារតែនេះជាបន្ទាត់នយោបាយរបស់គាត់ ឱ្យតែចាញ់គឺគាត់ថាអីចឹង...តាមមើលគឺអីចឹងហ្អង។ លេងអាក្បួនហ្នឹងអត់បានទេ។ អាវប្បធម៌ហ្នឹងមួយ លុបបំបាត់ទៅ។ ខ្ញុំស្នើគណបក្សនយោបាយ ត្រូវទទួលស្គាល់ការពិត។ ចង់និយាយថា បើគ្រាន់តែចោទស្មានៗ នាំគ្នាលុបបំបាត់ទៅអាវប្បធម៌ហ្នឹង"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យជាតិបាត់ដំបង

១២៦-គូប្រជែង ខុសពីគូបក្ខដិបក្ខ

"ពីមុនយើងធ្វើសង្គ្រាមវាយគ្នា ដោយប្រើកម្លាំងប្រដាប់អាវុធ ប្រើអំពើហិង្សាដើម្បីឡើងកាន់អំណាច ដែលអាហ្នឹងវាមិនមែនគូប្រកួតប្រជែងទេ គេហៅគូបដិបក្ខ។ មានតែសម្លាប់គ្នាទៅវិញទៅមក ឬថាមានឯងរត់អញ មានអញរត់ឯង។ តែសម័យឥឡូវ មិនមែនគូបដិបក្ខទេ យើងជាគូប្រកួតប្រជែង។ គូប្រជែងប្រែថាបើចាញ់ហើយ ទទួលស្គាល់ថាចាញ់ទៅ ហើយកាន់តែល្អ និងថ្លៃថ្នូរ គឺអបអរអរអ្នកឈ្នះ! ជូនពរអ្នកឈ្នះ! រួចហើយធ្វើការជាមួយគ្នា បម្រើប្រជាជនតាមសិទ្ធិ តាមអំណាច និងតួនាទីដែលច្បាប់បានកំណត់"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យជាតិបាត់ដំបង

១២៧-វប្បធម៌ថ្មីមួយនៃជនជាតិយើង

"ស្រុកមេសាងយើង ក៏មិនខុសពីស្រុកដទៃទៀតនៃខេត្តព្រៃវែង និងទូទាំងប្រទេសនោះដែរ គឺបងប្អូនរួមគ្នាខិតខំថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានល្អប្រើសើរ រួមចំណែកធ្វើឱ្យការបោះឆ្នោត ប្រព្រឹត្តទៅដោយសុវត្ថិភាពគ្មានអំពើហិង្សា ជាពិសេសគ្មានឃាតកម្មនយោបាយ។ ម្យ៉ាងហើយក៏ដោយសារសមត្ថកិច្ចរដ្ឋបាលស្រុក និងឃុំដែរ ប៉ុន្តែទន្ទឹមនោះវាក៏បានមកពីការគាំទ្ររបស់ប្រជាពលរដ្ឋទាំងមូល និងបានមកពីការចូលរួមរបស់គណបក្សនយោបាយ ដែលមិនបង្កបញ្ហា នាំឱ្យប៉ះពាល់ដល់ការបោះឆ្នោត។ យើងចាត់ទុកថាជាវប្បធម៌ថ្មីមួយទៀតនៃជនជាតិខ្មែរយើង ដែលយើងទើបតែបញ្ចប់សង្ក្រាមរ៉ាំរ៉ៃ និងការបែកបាក់ជាតិយ៉ាងធ្ងន់ធ្ងរ ក៏ប៉ុន្តែគំនុំសងសឹកត្រូវបានលុបបំបាត់ជាបណ្តើរៗ។ ឆ្លងកាត់ការបោះឆ្នោតបន្តបន្ទាប់ ពិសេសការបោះឆ្នោតប៉ុន្មានលើកចុងក្រោយនេះ យើងអាចទាញការសន្និដ្ឋានបានថាប្រជាពលរដ្ឋកម្ពុជាយើង មានភាពចាស់ទុំ និងរអាត់ធ្មត់ច្រើនជាងមុន ហើយពួកគាត់ក៏មិនមានគំនុំគុំកួន ឬការសងសឹកគ្នាដូចពីមុន។ ជានេះជាមោទនភាពរបស់យើង"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ ពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារវត្តខន្តីរស្មីព្រហ្មសែន ស្រុកមេសាង

១២៨-បក្សតែពេលប្រជែង

"ក្រោយបោះឆ្នោតរាណាត្តិមុន ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ មានតែមួយបក្សទេ គឺគណបក្សប្រជាជនកម្ពុជារបស់យើង។ តែឥឡូវមាន២គណបក្ស ឬច្រើនជាងនេះ។ ធម្មតាទេ គណបក្សមួយមានទស្សន:ក៍ដូចជាការយល់ឃើញមិនដូចបក្សមួយទៀតទេ ឯគំនិតក៍មិនដូចគ្នាដែរ តែងខ្វែងគ្នាហើយ។ ប៉ុន្តែយើងចាត់ទុកជាវិញ្ញាសាថ្មីមួយដែលត្រូវរៀនសម្របសម្រួលទាំងសងខាង។ អ្នកសំឡេងភាគច្រើន ពិតហើយថាអត់មានបញ្ហាអ្វីចោទឡើង គឺប្រសិនបើចង់អនុម័តអ្វីក៍បាន ដោយសារច្បាប់តម្រូវឱ្យយកមតិភាគច្រើន។ បើសំឡេងស្មើគ្នា គេយកសំឡេងប្រធានមានឧត្តមនុភាព។ យ៉ាងណាក៍ដោយ យើងក៍ត្រូវចេះផ្តល់ឱកាសឱ្យគ្នាទៅវិញទៅមកដើម្បីបញ្ចេញមតិ ហើយយើងក៍ត្រូវចេះប្រើមតិយោបល់នោះ ដើម្បីជាប្រយោជន៍រួមជូនប្រជាពលរដ្ឋដែរ។ ត្រូវចាំថា ពេលកាន់តំណែងជាក្រុមប្រឹក្សា គឺយើងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋទាំងអស់ មិនថាគាត់ជាអ្នកគាំទ្របក្សណា ឬជាបក្សណាទេ។ ពេលប្រជែង គឺបក្សរៀងខ្លួន តែពេលឈ្នះ គឺប្រជាជនតែមួយ។ ចំណុចនេះត្រូវក្តាប់ឱ្បាន។ ចំណែកពលរដ្ឋក៍ដូចគ្នា បោះឱ្បក្សណាក៍បោះទៅ យើងកុំខឹង កុំស្អប់គ្នា"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ ពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារវត្តខន្តីរស្មីព្រហ្មសែន ស្រុកមេសាង

១២៩-គេមិនពេញចិត្ត ទុកច្រកឱ្យគេដើរ

“ការឡើងក្រាមស៊ីសាច់ហុតឈាមគ្នា យើងឆ្លងកាត់ឆ្អែតហើយ!។ កម្ពុជាយើង បានជ្រើសរើសយកបបប្រជាធិបតេយ្យសេរីពហុបក្ស វាជាការត្រឹមត្រូវបំផុត។ ព្រោះរបបនយោបាយដែលយើងធ្លាប់មានពីមុនមក វារអត់ត្រូវ។ បើត្រូវមែន វាសុខហើយ វារីកចម្រើនហើយ មិនមែនវេទនានោះទេ។ ដោយសារមិនត្រូវហ្នឹងហើយ បានជាវាចេះតែបែកបាក់ជាតិ បានវាចេះតែឈ្លោះគ្នាខ្មែរ និងខ្មែរ។ អីចឹងហើយបានយើងស្រុះស្រួលគ្នាប្រកាន់យកបបនេះ មានន័យថា បើគេមិនពេញចិត្ត យើងទុកច្រកឱ្យគេដើរ ឬបើអ្នកឯងមិនពេញចិត្តបក្សខ្ញុំដឹកនាំ អ្នកឯងបង្កើតបក្សមួយទៅ ហើយប្រកួតប្រជែងគ្នាទៅ។ បើពលរដ្ឋគាំទ្រអ្នកឯងបានឈ្នះក៏ឡើងកាន់អំណាចទៅ តែបើចាញ់អ្នកឯងត្រូវគោរពអ្នកឈ្នះ។ គោរពអ្នកឈ្នះការបោះឆ្នោត ប្រែមកថាគោរពឆន្ទៈប្រជាពលរដ្ឋភាគច្រើន ដែលបោះឆ្នោតឱ្យបក្សនោះឈ្នះ”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ ពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារវត្តខន្តីរស្មីព្រហ្មសែន ស្រុកមេសាង

១៣០-បទល្មើសគ្រឿងញៀនគម្រាមប្រព័ន្ធធនាគារ

"បទល្មើសគ្រឿងញៀន ជាបទល្មើសដែលពួកឧក្រិដ្ឋជនអាចស្រូបយកប្រាក់កម្រៃ និងធនធានជាច្រើនទៀត ទៅបម្រើឱ្យកិច្ចការផ្សេងៗ តាមបំណងប្រាថ្នាគេ ក្នុងនោះក៏អាចគាំទ្រដល់ការពង្រីកអាវុធមហាប្រល័យ និងអំពើភេរវកម្មដែរ។ ព្រោះតែបញ្ហានេះ យើងត្រូវគេចាត់ជាប្រទេស ស្ថិតក្នុងបញ្ជីប្រផេះ។ យើងក៏បានខិតខំប្រឹងប្រែងដោះស្រាយ ដើម្បីការពារមុខមាត់យើងនៅលើឆាកអន្តរជាតិ ក្នុងនោះ ក៏មានការការពារប្រព័ន្ធប្រតិបត្តិការហិរញ្ញវត្ថុធនាគារ ដើម្បីកុំឱ្យចូលក្នុងបញ្ជីខ្មៅដែរ។ ដូច្នេះ ខ្ញុំស្នើអង្គពិធី បន្តគាំទ្រការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីបុព្វហេតុ ផលប្រយោជន៍ និងកិត្តិយសជាតិ។ យើងមិនត្រូវបណ្តែតបណ្តោយស៊ុមគ្រលុំជាមួយពួករកស៊ីគ្រឿងញៀន ហើយមានមនោសញ្ចេតនាជាមួយពួកវាជាដាច់ខាត"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

១៣១-តួអង្គរួមចំណែកពង្រឹងយុត្តិធម៌សង្គម

"នគរបាលជាតិ ក៏ជាតួអង្គមួយសំខាន់ ចូលរួមពង្រឹងការកសាងប្រព័ន្ធយុត្តិធម៌នៅកម្ពុជាដែរ។ ខ្ញុំនិយាយដូច្នេះ មិនមែនមានន័យថាតួអង្គមានតែនគរបាលទេ ចង់និយាយថា ជាតួអង្គមួយមិនអាចខ្វះបាន។ ខ្ញុំប្រើពាក្យហ្នឹង គឺមិនអាចខ្វះបាន! ក្នុងការកសាងប្រព័ន្ធយុត្តិធម៌សង្គម តាំងពីក្រោមដល់លើ។ មិនមែនតែកម្ពុជាទេ ប្រទេសណាក៏ដូចគ្នា។ ដូច្នេះត្រូវធ្វើឱ្យនគរបាលយើងទៅជានគរបាលរបស់ប្រជាពលរដ្ឋ កុំឱ្យពលរដ្ឋគាត់ខ្លាចនគរបាល។ យើងត្រូវខិតខំកែប្រែដើម្បីឱ្យពលរដ្ឋ មានវប្បធម៌ស្រលាញ់ចូលចិត្ត និងជឿជាក់លើនគរបាលយើង ដែលជាអ្នកបម្រើពួកគាត់។ នគរបាលយើងក៏ត្រូវចាត់ទុកប្រជាពលរដ្ឋ ជាចៅហ្វាយ ដែលត្រូវបម្រើសេវាឱ្យបានល្អដែរ។ ពលរដ្ឋ គាត់ក៏អាចក្លាយជានគរបាលដែរ ចង់និយាយថា នៅពេលគាត់មិនខ្លាចនគរបាល មានរឿងអ្វីកើតឡើង គាត់នឹងផ្តល់ព័ត៌មានឱ្យនគរបាល។ ដូច្នេះមានន័យថាជានគរបាលម្នាក់ដែរ។ ដូចថាមានជនខិលខូចចូលលួច ឬបន្លំស្នាក់នៅក្នុងភូមិ ឬឃុំគាត់ បើគាត់ដឹង គាត់នឹងផ្តល់ព័ត៌មានមកអាជ្ញាធរ នេះហើយជាអ្វីដែលយើងចង់បាន"

ក្រឡាហោមខេង

ខេត្តកំពង់ស្ពឺ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ៣ ខេត្តកំពង់ស្ពឺ

១៣២-ការងារថ្លៃថ្នូរទាំងអស់ តែ...

"ការងារថ្លៃថ្នូរទាំងអស់ តែត្រង់ថាមនុស្សទេថ្លៃថ្នូរឬមិនថ្លៃថ្នូរ។ ជួនអីឧត្តមសេនីយ៍ពាក់ផ្កាយពីរ ផ្កាយបី បែរជាយកអំណាចហ្នឹងទៅធ្វើអំពើផ្តេសផ្តាស ខ្លះរត់ការក្លែងបន្លំឯកសារ រឿងដីធ្លី ខ្លះរៀបចំល្បិចរកផលប្រយោជន៍ក្នុងការងារ អាហ្នឹងហើយមិនថ្លៃថ្នូរ។ ចាំទៅ ទោះហាន:ប៉ុណ្ណាក៏ដោយ ឬរៀនសូត្រចេះដឹងប៉ុណ្ណាក៏ដោយ មិនថ្លៃថ្នូរទេ បើធ្វើអីចឹងៗ។ គេមិនទាន់ដឹងក៏ចេះតែមិនអីហើយ តែបើបែកការណ៍ គឺជីវិតការងារ ឬក៏ជួនអីជីវិតនយោបាយតែម្តង ត្រូវចប់...!"

ក្រឡាហោមខេង

ខេត្តកំពង់ស្ពឺ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ៣ ខេត្តកំពង់ស្ពឺ

១៣៣-បុករអង្ករដើររកទៅ...!

"និយាយម្តងទៀតទៅចុះ មានអ្នកលើកសំណួរ ទាក់ទងសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយខ្ញុំក៏ឆ្លើយត្រឡប់ទៅវិញថារឿងប្រភពមនុស្ស ជាប្រធានក្តី ជាអនុប្រធានក្តី ជាសមាជិកក្តី ឬអាចនិយាយបានថារហូតមន្ត្រី គ.ជ.ប. ទៀតផង យើងមិនខ្វល់ពេកទេ។ មិនខ្វល់ក៏ដោយសារកម្ពុជាប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស។ ដូច្នេះសួរថាយើងអាចរកមនុស្សអព្យាក្រឹត្យដែលមិនជាប់ពាក់ព័ន្ធគណបក្សនយោបាយបានទេ? ខ្ញុំឱ្យបុករអង្ករដើររកទៅ។ អីចឹង វាត្រូវមានប្រភពដើមពីបក្សនេះ បក្សនោះ ឬនិន្នាការឆ្វេងស្តាំ គ្រប់ពណ៌សម្បុរដោយចៀសមិនផុត។ ចង់ប្រភពមនុស្សមកពីណាវាមិនសំខាន់ទេ។ សំខាន់ត្រង់ថា នៅពេលគាត់ចូលមក គ.ជ.ប. ច្បាប់ចែងអស់ហើយតើ គឺមានក្របខ័ណ្ឌច្បាប់ដែលអ្នកទាំងអស់គ្នាត្រូវតែគោរព និងអនុវត្ត។ អីចឹងអនុវត្តតាមច្បាប់ តាមបន្ទាត់នៃក្របខ័ណ្ឌតួនាទី សិទ្ធិអំណាច។ មិនមែនរឿងប្រភពមនុស្សមកពីណានោះទេ!"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ ពិធីបិទសន្និបាទ គ.ជ.ប.

១៣៤-សាមគ្គីផ្ទៃក្នុងជាតិ

"ប្រជាពលរដ្ឋ អញ្ជើញទៅបោះឆ្នោតយ៉ាងច្រើនសន្ធឹកសន្ធាប់ គឺជាការបញ្ជាក់ឱ្យឃើញថា គាត់គាំទ្រការបោះឆ្នោត។ បើគាត់មិនពេញចិត្ត គាត់មិនទៅបោះឆ្នោត ក៏អត់ខុសដែរ ពីព្រោះជាសិទ្ធិសេរីភាពគាត់។ ម្យ៉ាងអាចដោយសារគាត់រវល់ការងារ ឬរវល់នឹងក្រុមគ្រួសារគាត់ ឬដោយសារគាត់មិនពេញចិត្តការបោះឆ្នោត ក៏ថាបាន។ តែចំនួនសន្ធឹកសន្ធាប់នៃពលរដ្ឋទៅបោះឆ្នោត ជាការបង្ហាញឱ្យថាសាមគ្គីផ្ទៃក្នុងជាតិយើងមានកម្រិតខ្ពស់ណាស់ ក្នុងការបន្តអនុវត្តតាមមាគ៌ា ប្រជាធិបតេយ្យឆន្ទៈគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលយើងមានបំណង និងគោលដៅយ៉ាងជាក់លាក់ ក្នុងការឱ្យអនុវត្ត នូវនយោបាយនេះ ដើម្បីស្ថិរភាព និងការអភិវឌ្ឍនៅមូលដ្ឋាន"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ ពិធីបិទសន្និបាទ គ.ជ.ប

១៣៥-បទពិសោធចុះហត្ថលេខា

"ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ពួកគាត់បានចូលកាន់មុខតំណែងអស់ហើយ។ ខ្ញុំបានស៊ីញ៉ៀ (ចុះហត្ថលេខា) គឺអង្គុយស៊ីញ៉ៀអស់ហើយ។ តែមែនទែនទៅ គ្រាន់តែស៊ីញ៉ៀប្រថាប់ត្រាជូនគាត់ទេ។ សិទ្ធិមែនទែន គឺប្រជាពលរដ្ឋបោះឆ្នោតឱ្យ។ ខ្ញុំគ្រាន់តែអនុលោមភាពជូនទេតើ។ ស៊ីញ៉ៀហ្នឹង គឺថាស៊ីញ៉ៀមួយយប់មួយថ្ងៃ ស៊ីញ៉ៀឱ្យអស់ទាំង១.៦៥៤ឃុំ សង្កាត់តែម្តង។ ត្រូវតែចុះហត្ថលេខាដើម្បីពន្លឿនការចូលកាន់មុខតំណែងរបស់គាត់"

ក្រឡាហោមខេង

ខេត្តព្រះសីហនុ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ ពិធីបិទសន្និបាទ គ.ជ.ប

១៣៦-បើមិនរៀន មានតែដើរចេញ!

"ថ្ងៃនេះយើងចាត់មន្ត្រីនគរបាល មានឋានៈអគ្គនាយករងដល់អនុប្រធាននាយកដ្ឋាន ឱ្យមកធ្វើវិក្រឹតការ គឺឱ្យមករៀនហើយបើសួរថារស់ ឬនៅ? គឺមិនទាន់រស់ទេ! ព្រោះអ្នកផ្ទេរពីស៊ីវិលមកមានច្រើន ដូចជាជាង៣០០នាក់ឯណោះ។ បើថ្នាក់នាយការិយាល័យវិញ មានជាង៩០០នាក់។ អីចឹងធ្វើម៉េច? គឺត្រូវរៀន! អត់មានធ្វើម៉េចទេ! ត្រូវរៀនតែម្តង។ វគ្គក្រោយៗហ្នឹងប្រហែលមានអ្នកធំជាងហ្នឹង ខ្ញុំឱ្យធ្វើបញ្ជីហើយ។ វគ្គក្រោយដោយសារមានអ្នកខ្លះជាអគ្គនាយក អីចឹង ខ្ញុំស្នើជាជម្រើស គឺឱ្យរៀនដៃរ តែរៀនមួយថ្ងៃមួយពេល ហើយត្រូវបូក បើត្រូវរៀន៣ខែ ត្រូវរៀន៦ខែ។ ម៉េចបានអីចឹង ព្រោះបើផ្តាច់ឱ្យមករៀនតែម្តង វាក៏លំបាកដៃរ បើមិនឱ្យរៀន ក៏មិនកើត។ អាហ្នឹងសូមជូនយោបល់ខ្ញុំផង។ ធ្វើយ៉ាងណា យកអ្នកធំមករៀនទាំងអស់។ មន្ត្រីនគរបាល ដែលមានតួនាទីចាប់ពីអគ្គនាយកដ្ឋានចុះមកមិនអាចឱ្យនរណាម្នាក់ មិនបានរៀនវិជ្ជាជីវៈនគរបាលនោះទេ បើមិនព្រមមករៀន សូមដើរចេញពីនគរបាល"

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ពិធីបិទវគ្គសុក្រឹត្យការ ថ្នាក់ដឹកនាំនគរបាលជាតិកម្រិត១ និងកម្រិត២ ជំនាន់ទី១ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

១៣៧-កុំសន្មត់ថារៀនចប់បានតែងតាំង!

"ពិតហើយ ឯកឧត្តមរស់លោក បានធ្វើការងារជាក់ស្តែងច្រើន ក៏ប៉ុន្តែពេលបានរៀន យើងក៏មានគំនិតថ្មីៗថែមទៀត។ អរីចឹង មិនមែនរៀនចប់ហើយ ក៏ចប់នោះទេ។ យកមេរៀនបទពិសោធទៅកែលម្អការងារជាក់ស្តែង។ ម្យ៉ាង យើងក៏មិនត្រូវសន្មត់ថារៀនហើយត្រូវតែបានតែងតាំង ឬឱ្យឋានៈខ្ពស់យ៉ាងនេះយ៉ាងនោះវាក៏មិនត្រូវនោះដែរ។ ពីព្រោះវាអាស្រ័យលើលទ្ធផលការងារយើងឯណោះទេ។ ម្យ៉ាងទៀតក៏អាស្រ័យទៅលើសីលធម៌ គុណធម៌ កិត្តិយស និងសេចក្តីថ្លៃថ្នូរ"

ក្រឡាហោម ស ខេង

ខេត្តកណ្តាល ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ពិធីបិទវគ្គសុក្រឹត្យការ ថ្នាក់ដឹកនាំនគរបាលជាតិកម្រិត១ និងកម្រិត២ ជំនាន់ទី១ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

១៣៨-នៅពេលវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០

“ខ្ញុំឡើងមកនេះ មិនមានយោបល់អីទេ តែរម្បាញ់មិញ បើខ្ញុំស្តាប់មិនច្រឡំ លោកជំទាវ **ក្រូច សំអាន** គាត់អានរំលង គឺរំលងបន្ទាត់ទី២ នៃមាត្រា១១៩។ គាត់រំលងពាក្យថា សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ត្រូវចម្លងជូនប្រធានរដ្ឋសភា។ ខ្ញុំគ្រាន់តែបំពេញបន្ថែមប៉ុណ្ណឹងទេ ព្រោះអ្នកស្តាប់ គេស្តាប់ទៅវាឆាំឱ្យបាត់ន័យ។ សូមគោរពអរគុណ និងអរគុណ!”

ក្រឡាហោមខេង

វិមានរដ្ឋសភា ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ ប្រជុំពិភាក្សា និងអនុម័តសេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ ក្នុងកិច្ចប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦

១៣៩-ប្រាក់ សុវណ្ណ ជានរណាដែរ?

"ឯកឧត្តម **ប្រាក់ សុវណ្ណ** ជាអ្នកបានចូលរួមក្រោកឡើងតស៊ូប្រឆាំងរបបប្រល័យពូជសាសន៍។ **សម្តេច ជា ស៊ីម** បានចាត់តាំងគាត់ រួមជាមួយមនុស្ស៥នាក់ទៀត ឱ្យចូលទៅកាន់ប្រទេសវៀតណាម ដើម្បីជំរុញចលនាតស៊ូ។ តឡូវនៅសល់តែ៣នាក់ទេ ស្លាប់អស់៣ហើយ ត្រូវគ្រាប់ផង ត្រូវមីនផង។ កាលហ្នុង តំបន់ព្រៃតាទក ដែលស្ថិតនៅឃុំក្រហៅ ស្រុកកំចាយមារ មានប្រជាពលរដ្ឋប្រហែល២ម៉ឺននាក់។ ខ្មែរក្រហម បានធ្វើទុក្ខបុកម្នេញខ្លាំង ក៏នាំគ្នារុកព្រៃទាំងយប់ ទាំងថ្ងៃ បាញ់បោះ គ្មានទំនេរ។ ប្រជាជនចល័តពីកន្លែងមួយទៅកន្លែងមួយ។ **សម្តេច ជា ស៊ីម** ក៏ចាត់តាំងកម្លាំងមួយក្រុមមាន **ប្រាក់ សុវណ្ណ** ដែរ ឱ្យបញ្ចោញប្រជាជនទៅវៀតណាម។ បើមិនចេញទេ **អាពត** (ចង់សំដៅដល់កម្លាំង **កែវ ពក** មេភូមិភាគបូព៌ា ជំនួស **សោ ភឹម**) សម្លាប់អស់។ យើងមិនហ៊ានដើរផ្តេសផ្តាសទេ ដើរតាមផ្លូវដូចស្រទបចេកអីចឹង។ បើដើរខុសផ្លូវអាចប៉ះមីនអស់ជីវិត អស់ដៃ អស់ជើង។ នេះខ្ញុំរំលឹកបន្តិចពីប្រវត្តិ **ប្រាក់ សុវណ្ណ**"

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាលនិងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤០-ពាក្យមិនគួរនិយាយទេ!

*"ខ្ញុំអរអរសាទរហើយ ឯកឧត្តម **ប្រាក់ សុវណ្ណ** ដែលបានរាយការណ៍អំពីរឿងទំនាស់នានា ឬក៏បានដោះស្រាយ ដូចជាករណីដីធ្លី ដែលកន្លែងខ្លះក៏ដោះស្រាយហើយ កន្លែងខ្លះក៏ជិតហើយ ហើយក៏លែងមានអ្នកទៅភ្នំពេញ។ ខ្ញុំក៏ឈឺក្បាលដែរព្រោះបើគាត់ឡើងមក យើងត្រូវចាត់តំណាងមកជួបគាត់ មិនអាចទុកគាត់ចោលទេ។ ពីព្រះវិហារទៅភ្នំពេញហ្នឹង គាត់ត្រូវការពេលប៉ុន្មាន...គឺមិនចេះតែងាយឡើងចុះទេ។ ពិតហើយថាវាមានអ្នកជួយជ្រោមជ្រែងគាត់ឱ្យទៅ តែបើអត់មានរឿងសោះក៏គាត់មិនទៅដែរ ហើយអ្នកជួយពីក្រោយហ្នឹងក៏មិនងាយធ្វើអ្វីបានដែរ។ ត្រូវទទួលស្គាល់ថា វាពិតជាមានបញ្ហាហើយ បានជាគាត់ឡើងមក។ មានផ្សែងទើបវាមានភ្លើង! សូមច្បៀសវាង... មន្ត្រីយើងខ្លះច្រើនតែថាអាបុិហ្នឹងខូចណាស់ ឬក៏ថាអាហ្នឹងបក្សប្រឆាំង។ ខ្ញុំថាពាក្យអីចឹងៗមិនគួរនិយាយទេ សូមកុំទាន់អាលនិយាយ ហើយសូមកុំប្រើពាក្យហ្នឹង ក្នុងឋានៈយើងជាអាជ្ញាធរត្រូវមើលឱ្យច្បាស់ ទោះបីថាបក្សប្រឆាំង ឬមិនប្រឆាំងក៏ដោយ ប៉ុន្តែបើគេត្រូវ យើងត្រូវតែដោះស្រាយឱ្យគេ។ ជួនអីរអាគ្នាយើងខុសច្បាប់សោះ យើងដោះស្រាយជួយឱ្យត្រូវ... វាអយុត្តិធម៌"*

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាលនិងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤១-ទទួលស្គាល់ព្រៃនៅមាន ប៉ុន្តែ...

"ខ្ញុំដិះអេឡេក្ត (ឧទ្ធម្ភាគចក្រ) ទៅស្រុកកំពង់ស្រឡៅថ្ងៃមុន។ ដល់តែត្រឡប់មកវិញ ខ្ញុំនៅមានមោទនភាពដែរ ព្រោះដោយសារព្រៃនៅសល់គ្រាន់បើ ព្រៃឡង់យើងហ្នឹង...។ តែបើសិនណាជាយើងមិនទប់ស្កាត់ មិនការពារ អាហ្នឹងទៅមុខទៅគឺអស់ហើយ។ ព្រោះមានកន្លែងខ្លះ ទំពែកច្រើនដែរ។ តែភាគច្រើន ខ្ញុំឃើញព្រៃនៅច្រើន ខ្ញុំទទួលស្គាល់ថានៅមាន"

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤២-ចំណុចខ្សោយយើង ជាចំណុចខ្លាំងគេ!

*"រាជរដ្ឋាភិបាល បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនពលរដ្ឋទាំងអស់ដោយគ្មានការរើសអើង។ នេះជានយោបាយមួយល្អណាស់ យើងមិនបានបែងចែកសខ្មៅ ឬបក្សនេះបក្សនោះអ្វីទេ ឃើញជាក់ស្តែងហើយ។ តែក្រោយការបោះឆ្នោតឃុំសង្កាត់ យើងឃើញសំឡេងបក្សប្រឆាំង ក៏មានប្រមាណ**១លាន ៦សែនសំឡេង**ដែរ។ ដូច្នេះវាជាការបញ្ជាក់ឱ្យឃើញថា យើងនៅមានចំណុចខ្សោយ និងចំណុចខ្វះខាត ដែលធ្វើឱ្យពលរដ្ឋមួយចំនួនពួកគាត់មិនទាន់អស់ចិត្ត ឬមិនទាន់ជឿលើយើង នៅតែជឿការឃោសនារបស់ពួកប្រឆាំង។ យើងនាំគ្នាកត់សម្គាល់មើលព្រោះពួកគាត់ មិនមែនទៅយកឥទ្ធិពលពីណាមកប្រជែងយើងទេ ពួកគាត់ក្រុមប្រឆាំងហ្នឹង គឺនៅក្នុងភូមិ នៅក្នុងស្រុកយើងនេះទេតើ ដែលប្រឆាំងយើងហ្នឹង មាននៅឯណាឆ្ងាយ។ បាននិយាយថា គាត់យកតែចំណុចខ្សោយ ចំណុចសេសសល់យើង ឬក៏ភាពអសកម្មយើង ទៅធ្វើជាភាពខ្លាំងដណ្តើមសំឡេងឆ្នោត។ ខ្ញុំគ្រាន់តែទាញចំណាប់អារម្មណ៍ថា គេមានទៅខ្លាំងស្អី គេចាំតែញញឹមទេ ពេលយើងធ្វើមិនល្អជាមួយប្រជាពលរដ្ឋ"*

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤៣-គ្នាយើងខ្លះធ្លាប់ភ័យដែរហ្នឹង

“វេទិកាសាធារណៈ:ខ្ញុំគ្រាន់តែសម្គាល់ទេថា កាលពីយើងធ្វើដំបូង ឬម្តងជាពីរដង ពលរដ្ឋមិនទាន់ហ៊ានបញ្ចេញយោបល់អ្វីទេ ដោយសារតែគាត់នៅខ្លាចយើង។ ប្រជាជនគាត់នៅមានអាចចំណុចហ្នឹងដែរ។ ប៉ុន្តែបើយើងធ្វើច្រើនដងទៅគង់តែគាត់ហ៊ានមានមតិយោបល់ទេ។ ដូចគ្នាអីចឹងដែរ មន្ត្រីយើង បើធ្វើវេទិកាសាធារណៈទៅដូចជាខ្លាចៗដែរ ខ្លាចដោះស្រាយបញ្ហាពលរដ្ឋវាមិនចេញ។ តឹ្បរកុំខ្លាច ត្រូវតែហ៊ាន យើងនៅចាំទេក្រោយកិច្ចព្រមព្រៀមក្រុងប៉ារីស ក្រោយរៀបចំបោះឆ្នោត ឆ្នាំ១៩៩៣ យើងឈានចូលក្នុងរបត់នយោបាយថ្មី ពីមានបក្សតែមួយ ទៅជាមានបក្សច្រើន ហើយរៀបចំការបោះឆ្នោត តាមគោលការណ៍ប្រជាធិបតេយ្យ។ គ្នាយើងខ្លះភ័យដែរហ្នឹង (សើច) ព្រោះអត់មានពិសោធ អត់ធ្លាប់ឆ្លងកាត់ អត់សូវហ៊ានហ្នឹងគេ។ ប៉ុន្តែតឹ្បរយើងឆ្លងកាត់ច្រើនទៅ គ្នាយើងខ្លះក៏ចេះជាងគេទៀត។ គ្រាន់តែបោះឆ្នោតតំណាងរាស្ត្រ និងឃុំ សង្កាត់ គី១១ដងទៅហើយ។ អីចឹងវេទិកាសាធារណៈ យើងកុំខ្លាច យើងធ្វើឱ្យបានច្រើន ដើម្បីដោះស្រាយតម្រូវការជូនពួកគាត់ និងផ្សារភ្ជាប់ជាមួយពលរដ្ឋឱ្យស្និតស្នាល”

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤៤-អនុស្សាវរីយ៍កសាងជាតិនៅព្រះវិហារ

"ក្រុងព្រះវិហារ ពីមុនគេហៅថា ត្បែងមានជ័យ តែខ្ញុំស្នើឱ្យដាក់ថាព្រះវិហារអីចឹងទៅ។ ដាក់ទៅក៏មិនខុសដែរ ព្រោះដើម្បីនាំគ្នាចាំថាប្រាសាទព្រះវិហារ ជាប្រាសាទរបស់ខ្មែរ។ ដាក់ឱ្យរត់មាត់ ព្រោះគេចេះតែចង់បាន។ ពីមុននោះ នៅរវើរវាយឯណោះទេ ទាំងសាលាតំបន់ មន្ទីរតំបន់ គេហៅថាតំបន់១០៣។ខ្ញុំធ្លាប់រួមដំណើរជាមួយ **ប៉ែន សុវណ្ណ** មកទីនេះ កាលហ្នឹងគាត់ជាអគ្គលេខាធិការបក្ស ហើយឯកឧត្តមទេសរដ្ឋមន្ត្រី **មាស សុភា** ក៏មកដែរ។ ... (សើច) គាត់មករកឃើញយាយ (ភរិយា) គាត់នៅកន្លែងហ្នឹង។ និយាយដើមគាត់បន្តិចចុះ ព្រោះបងស្រីប្រពន្ធគាត់ហ្នឹង គេជម្លៀសមកឃុំរណសិរ្ស គឺកាលហ្នឹងហើយដែលយើងនាំគ្នាសម្រេចរើសាលាខេត្តមកដាក់នៅត្រង់ហ្នឹង"

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤៥-ចុះទៅធ្វើការ ឃើញតែទុងផ្លែក

“ខ្ញុំមានពិសោធ មន្ត្រីខ្លះ យើងបញ្ជូនគាត់ឱ្យចុះទៅធ្វើចៅហ្វាយខេត្ត ឬចៅហ្វាយស្រុក ចុះមួយថ្ងៃគាត់មើលទុងផ្លែកបានតែមួយក៏មានដែរ។ ម៉េចបានជាអីចឹង? គាត់ថាផ្លូវលំបាកពេក។ ក្នុងឋានៈយើងជាចៅហ្វាយខេត្ត ជាចៅហ្វាយស្រុក គាត់ថាផ្លូវលំបាកពេក...។ ខ្ញុំថាចុះគេឱ្យលោកឯងទៅធ្វើចៅហ្វាយខេត្ត ចៅហ្វាយស្រុក បើផ្លូវវាលំបាក ម៉េចក៏មិនធ្វើ! បើធ្វើមិនកើត ម៉េចមិនសុំ! វារអត់រាគំនិតសុំហ្នឹងទៀត រអត់គំនិតដល់ប៉ុណ្ណឹង។ អីចឹងទៅធ្វើការបានតែឃើញទុងផ្លែកមួយ។ កោតចេះទៅធ្វើចៅហ្វាយខេត្ត ទៅធ្វើក្រុមការងារហ្នឹងគេកើតដែរ។ យើងសុំទេតើ មាននរណាគេដាក់ទោស បើគេមិនឱ្យក៏ហើទៅ! ខ្លាចតែខាងលើគេឱ្យយើងធ្វើធំ តែយើងទៅប្រើអំណាច ផ្តេសផ្តាសរាហ្នឹងរាចជាប់គុក។ សុំរត់ខុសទេ ខាងលើរអ៊ូម៉ើចរអ៊ូទៅ ខ្ញុំសុំមកឱ្យប្រជាជនតើ! គាត់ត្រូវការ។ យើងគ្រាន់តែឱ្យចេះសុំសុំឱ្យទំនង សុំឱ្យត្រូវសេចក្តីត្រូវការ។ មែនទែនទៅ ប្រជាជនគាត់មិនដែលសុំយើងយកទៅទិញគោ ទិញម៉ូតូជិះខ្លួនគាត់ទេ គាត់សុំតែដើម្បីបម្រើប្រយោជន៍សាធារណៈហ្នឹងឯង”

ក្រឡាហោមខេង

ខេត្តព្រះវិហារ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ ពិធីប្រកាសមុខតំណែងអភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ

១៤៦-អ៊ីចឹងបានជាគេឱ្យយើងរៀន

"នគរបាលយើង គាត់មានតួនាទីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ ប៉ុន្តែបើយើងមិនចេះច្បាប់ ឬមិនបានរៀនជំនាញ យើងទៅធ្វើការងារនោះម្តេចហ្នឹងកើត។ ជួនអីក៏ត្រូវធ្វើសំណុំរឿងប្តឹងគេទៅតុលាការ។ ចុះបើធ្វើដោយមិនសហការជាមួយព្រះរាជអាជ្ញា ក៏មិនត្រូវ! ចង់ឆែកឆេរត្រួតពិនិត្យ ធ្វើសំណុំរឿងនេះ សំណុំរឿងនោះ ទាល់តែមានកិច្ចសហប្រតិបត្តិការជាមួយតុលាការ។ ចុះបើចោទគេខុស វាមិនអយុត្តិធម៌? បើតុលាការគាត់កាត់តាមយើងចោទទៀត អាហ្នឹង វាទៅទាំងប៉ុទាំងទ្រហើយ។ ចុះបើតុលាការ មិនកាត់តាមហ្នឹងវិញ វាក៏អាចបកបញ្ច្រាស់ដៃរថាយើងខុស ព្រោះចេះតែធ្វើសំណុំរឿងចោទគេតាមចិត្តឯងនឹកឃើញ ឬក៏ដោយសារផលប្រយោជន៍។ អ៊ីចឹងបានជាគេឱ្យយើងរៀន"

ក្រឡាហោមខេង

ខេត្តសៀមរាប ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរសុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៤៧-ប្រជាពលរដ្ឋម្នាក់ជានគរបាលម្នាក់

"ការរៀនសូត្រ វាជួយលុតដំយើង ជួយកសាងអត្តចរិត ឬកពាយើងឱ្យទៅជានគរបាលរបស់ប្រជាពលរដ្ឋ ជានគរបាលប្រជាជន ជាកូនចៅប្រជាពលរដ្ឋ កូនចៅប្រជាជន មិនមែនចៅហ្វាយនាយទេ។ អីចឹងត្រូវតែស្តាប់មតិយោបល់គេ ត្រូវចាត់ទុកប្រជាជនជាកញ្ចក់ ដើម្បីយើងឆ្លុះមើលបន្ថែមថា គាត់ពេញចិត្តសកម្មភាពយើង ឬនគរបាលយើងដែលទេ? ជឿលើសកម្មភាពនគរបាលយើង ឬមិនជឿ? បើគាត់ជឿ យើងនឹងមានលទ្ធភាពច្រើនក្នុងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់។ នគរបាលមិនត្រឹមតែយើងម្នាក់ ឬ៤ទៅ៥នាក់នៅប៉ុស្តិ៍រដ្ឋបាលទេ យើងត្រូវតែខិតខំកសាងកម្លាំងនគរបាលយើងច្រើនទៀតក្នុងភូមិ ឃុំ។ គឺប្រជាពលរដ្ឋម្នាក់ជានគរបាលម្នាក់។ យើងអាចធ្វើបាន នៅពេលយើងកសាងទំនុកចិត្តពីប្រជាពលរដ្ឋ តែបើយើងគ្មានទំនុកចិត្តពីពួកគាត់ ទៅណាក៏ពលរដ្ឋគេចមុខ គាត់មិនផ្តល់ព័ត៌មាន មិនសហការជាមួយយើងទេ។ អាហ្នឹងហើយ ចេះប៉ុណ្ណាក៏ដោយ ក៏ធ្វើការមិនកើត ធ្វើការមិនបានជោគជ័យដែរ"

ក្រឡាហោមខេង

ខេត្តស្ទឹងមានជ័យ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរសុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៤៨-ហេតុនាំឱ្យឡើង ឬមិនឡើងស័ក្តិ?

"រឿងវិភាគវាយតម្លៃផ្តល់ស័ក្តិ ឋានៈតួនាទី ត្រូវតែធ្វើឡើងដោយយុត្តិធម៌ ដោយមិនត្រូវផ្អែកលើមនោសញ្ចេតនា ឬផលប្រយោជន៍អ្វី នោះឡើយ។ បើមន្ត្រីណាមួយមិនបានឡើងស័ក្តិ យើងត្រូវបង្ហាញហេតុផលដល់គាត់ ថាហេតុអ្វីមិនឡើងស័ក្តិ។ យើងបង្ហាញគាត់ ដើម្បីឱ្យមានភាពច្បាស់លាស់ និងម្យ៉ាងឱ្យមន្ត្រីនោះកែខ្លួន ដើម្បីទទួលការលើកទឹកចិត្ត។ ចំណែកអ្នកធ្វើល្អវិញ អង្គភាពត្រូវតែមើលឱ្យច្បាស់ ហើយលើកទឹកចិត្ត។ ជួនអីមិនចាំបាច់ដល់ឆ្នាំទេ បើមានស្នាដៃពិសេស យើងក៏អាចស្នើដើម្បីផ្តល់ឋានន្តរស័ក្តិ ឬតែងតាំងឋានៈតួនាទី។ បើគាត់ដល់ឆ្នាំត្រូវចូលនិវត្តន៍ ច្បាប់បានអនុញ្ញាត ឱ្យរដ្ឋមន្ត្រីពន្យារចូលនិវត្តន៍ដោយផ្អែកលើសុខភាពមន្ត្រីនោះនៅមាំល្អ គាត់មានបទពិសោធចំណេះដឹង មានអាកប្បកិរិយាល្អ យើងក៏អាចបន្តឱ្យគាត់បាននៅប្រទេសណាក៏គេធ្វើអីចឹងដែរ"

ក្រឡាហោមខេង

ខេត្តសៀមរាប ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរសុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៤៩-ដើមហេតុនាំឱ្យអធិការបានពាក់សព្តិ៥

"កន្លងទៅ ខ្ញុំបានចុះទៅមូលដ្ឋានប៉ុន្មានស្រុក នៅជិតៗភ្នំពេញ ដូចជានៅឧត្តង្គ គងពិសី និងកៀនស្វាយ។ ពេលចុះទៅ មានអធិការនគរបាលម្នាក់ គាត់ឡើងធ្វើរបាយការណ៍។ ការពិតទៅខ្ញុំទៅមើលការងារកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិទេ តែគេហៅមន្ត្រីមូលដ្ឋានចូលរួមទាំងអស់គ្នា។ ដល់គាត់ឡើងមក ខ្ញុំសួរគាត់ថាអាយុប៉ុន្មានហើយ? គាត់ថាអាយុ៥៥ឆ្នាំហើយសម្តេច។ ដូច្នេះ មានន័យថាឆ្នាំនេះ គាត់ដល់អាយុចូលនិវត្តន៍ ទាំងមនុស្សនៅក្មេង សក់ក៏មិនមានស្កូវផងហ្នឹង។ អីចឹងក៏ជជែកជាមួយក្រសួងមុខងារសាធារណៈ ជាមួយឯកឧត្តម **ចាន់ អ៊ាន** រដ្ឋលេខាធិការទទួលបន្ទុកបុគ្គលិក នៃក្រសួងមហាផ្ទៃ ហើយក៏សម្រេចថាដំឡើងស័ក្តិដល់វរសេនីយ៍ឯក (ស័ក្តិ៥)។ ពីមុនស័ក្តិ៤កន្លះក៏ចូលនិវត្តន៍អាយុ៥៥ ដូច្នេះថែមឱ្យគាត់ស័ក្តិ៥ ធ្វើឱ្យអាយុចូលនិវត្តន៍បានដល់៦០ឆ្នាំ"

ក្រឡាហោមខេង

ខេត្តសៀមរាប ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរសុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៥០-អភិបាលរាជធានី ខេត្ត គួរបង្កើនអាយុចូលនិវត្តន៍?

“ចៅហ្វាយខេត្តសព្វថ្ងៃ អាយុ៦០ឆ្នាំចូលនិវត្តន៍ហើយតែគាត់នៅក្មេងៗនៅឡើយសោះ។ យើងក៏មិនទាន់មានដំណោះស្រាយករណីនេះទេ។ វាមានបញ្ហាប្រឈមដូចគ្នា គឺបើឱ្យចូលនិវត្តន៍ឆាប់ពេក ដូចជាថាស្តាយដែរ ព្រោះមនុស្សហ្នឹងនៅក្មេងដែរទេ នៅខ្លាំង នៅកម្លាំងមាំមួនដែរទេ។ តែមួយទៀតបើឱ្យថែមលើសពី៦០ឆ្នាំ វាវាំងស្ទះដល់មន្ត្រីក្រោមៗ មន្ត្រីក្មេងៗ។ អីចឹងវាមានមុខទាំងសកម្ម និងអសកម្មដែលយើងត្រូវរួមគ្នាពិចារណាឱ្យបានសមស្រប តាមស្ថានភាពស្រុកទេសរបស់យើង”

ក្រឡាហោមខេង

ខេត្តសៀមរាប ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរសុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៥១-មេទ័ព ស៊ុនអ៊ូ និងរឿងគ្រឿងញៀន

"កុំរារាំងការអនុវត្តច្បាប់ ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ទោះបីជាក្រុមគ្រួសារសារ សាច់ញាតិ មិត្តភក្តិក៏ដោយ។ អាហ្នឹងមិនបានទេ កុំយកមនោសញ្ចេតនាមករារាំងថាហ៊ឹម...អាហ្នឹងកូនខ្ញុំ ក្មួយខ្ញុំ ឬខ្ញុំមានកូនតែមួយហ្នឹងទេ..មិនបានទេ តិចមកសុំអង្វរ សុំលើកលែងទោស ឬសុំការជួយអន្តរាស្រ័យ។ បញ្ហានេះវាមិនពាក់ព័ន្ធបុគ្គល និងគ្រួសារទេ វាប៉ះពាល់សង្គមជាតិទាំងមូល។ និយាយចំណុចហ្នឹង មានរឿងចិនមួយ គេហៅ **មេទ័ព ស៊ុនអ៊ូ**។ ស្តេចប្រគល់ឱ្យមេទ័ព **ស៊ុនអ៊ូ** បង្ហាត់កូនទាហានស្រី ៣ពាន់នាក់។ ម្នាងឆ្វេង ម្នាងស្តាំដែលស្តេចលោកស្រឡាញ់ជាងគេហ្នឹង ឃើញគេហាត់ទាហានទៅដូចថាសប្បាយ ក៏សុំទៅហាត់ដែរ។ ដល់តែទៅ គេឱ្យធ្វើមេក្រុម មានក្រុមខាងឆ្វេង ក្រុមខាងស្តាំ។ **ស៊ុនអ៊ូ** ឆ្លាត គាត់សុំដាវអាជ្ញាសឹកពីស្តេច ដើម្បីឱ្យគេស្តាប់បញ្ជាខ្លួន។ ស្តេចក៏អូខេ! ដល់តែហាត់ទៅ ម្នាងពីរនាក់ហ្នឹងវាមិនស្តាប់បទបញ្ជាសោះ ព្រោះដំបូងថាចុះទៅដើម្បីសប្បាយ តែគេបញ្ជាស្តាំ មិនស្តាំ ឆ្វេងមិនឆ្វេង មុខមិនមុខ ក្រោយមិនក្រោយ។ **ស៊ុនអ៊ូ** ក៏សម្លាប់ចោល។ ពេលហ្នឹងកូនស្តេច ក៏មកនិយាយថា បិតាគេហ្នឹង ស្រលាញ់ណាស់នាងទាំងពីរហ្នឹង អត់នាងទាំងពីរដេកក៏មិនលក់ បក់ក៏មិនល្អើយ ស៊ីក៏មិនបានទៀត។ អីចឹងរកសម្លាប់មេទ័ព **ស៊ុនអ៊ូ**។ តែមានម្នាក់

ទៀតប្រៀបដូចជាឧបរាជ ឬានទូលថាទេ... រឿងនេះមិនខុស
មកពី **ស៊ុនអ៊ូ** ទេ! ខុសពីនាងពីរនាក់ហ្នឹងតើ! ព្រោះ **ស៊ុនអ៊ូ**
ប្រកាសហើយថាត្រូវតែគោរពបទបញ្ជា។ ព្រះមហាក្សត្រ ក៏
ប្រទានដាវអាជ្ញាសឹកទៅឱ្យ **ស៊ុនអ៊ូ** ហើយ។ អីចឹងទេ រឿងគឺ
មកពីនាងទាំងពីរនាក់មិនគោរពបញ្ជា មិនមែន **ស៊ុនអ៊ូ** ទេ។
ចុងក្រោយស្តេចហ្នឹងក៏ដើរចេញ មិនដឹងធ្វើម៉េច ព្រោះឬាន
សន្យាគ្នាហើយ។ អាកូនស្តេចហ្នឹងវាតាមរករឿង **ស៊ុនអ៊ូ** ជាប់
ដើម្បីសម្លាប់។ តែមានគេជួយការពាររហូតនាំទៅគាល់ស្តេច!
ស្តេចក៏ចិត្តទន់ ម្យ៉ាងឬានទតគម្តើរទ័ព **ស៊ុនអ៊ូ**ក៏ជក់ចិត្តដែរ។ព្រះ
អង្គក៏និយាយថាទេ...រឿងស្រីៗទាំងពីរនាក់ហ្នឹង មិនសំខាន់ទេ!
រឿងសំខាន់ គឺរាយុជីវិតប្រទេសជាតិ។ បើមិនធ្វើតាម **ស៊ុនអ៊ូ**
ទ័ពមិនខ្លាំងទេ គ្មាននរណាគោរពវិន័យ វាយគេមិនឈ្នះទេ។
ដូច្នេះ មិនត្រឹមតែលើកលែងទោសទេ តែដំឡើង **ស៊ុនអ៊ូ** ជាមេ
បញ្ជាការកំពូលកងទ័ពតែម្តង។ ...អីចឹងឬានថា មនោសញ្ចេតនា
នេះ យើងក៏មានដែរ មិនមែនរអត់ទេ។ តែបើមិនចង់ឱ្យប៉ះពាល់
បញ្ហាគ្រឿងញៀនហ្នឹង ត្រូវរអប់រំកូនចៅកុំឱ្យពាក់ព័ន្ធ។ បើពាក់
ព័ន្ធ ហើយលោតអន្តរាគមន៍ អាហ្នឹងជាប់ទាំងយើងដែរ គេក៏
សងឬយដែរ"

ក្រឡាហោម ស ខេង

ខេត្តសៀមរាប ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរ
សុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៥២-ជាប់នៅសៀមរាប តែផ្ទេរទៅភ្នំពេញ

"បើកន្លែងមួយ មានមន្ត្រីចូលនិវត្តន៍២០នាក់ តាមការចាំបាច់ត្រូវការតែមនុស្ស២នាក់ អីចឹងឱ្យតែ២នាក់ទេ ក្រៅពីហ្នឹងបញ្ជូនមកឱ្យប៉ុស្តិ៍នគរបាលរដ្ឋបាល។ ឥឡូវ គឺជ្រើសរើសមន្ត្រីប៉ូលិសនៅហ្នឹងមូលដ្ឋានតែម្តង។ មិនឱ្យផ្ទៀតលើមកយកក្របខ័ណ្ឌ រួចបានក្របខ័ណ្ឌនាំគ្នាផ្ទេរទៅភ្នំពេញទេ! អត់ទេ! អាហ្នឹងខ្ញុំជម្រះបញ្ហីម្តងជាពីរដងហើយ។ បើទោះនៅមាន ក៏វាសេសសល់តិចតួចដែរ។ ជាទូទៅ យើងបានដោះស្រាយ។ បើមិនអីចឹងទេ មន្ត្រីយើងហ្នឹង គឺថាសុំផ្ទៀកូន ផ្ទៀចៅ ខ្លះក្មួយ ខ្លះមួយ ខ្លះពីរ ខ្លះបី ប្រឡងក្របខ័ណ្ឌនៅសៀមរាប ដល់តែប្រឡងជាប់ មិននៅសៀមរាប ផ្ទេរទៅភ្នំពេញបាត់។ ខ្ញុំនិយាយឱ្យច្បាស់ម្តងទៀតហ្មង! អាក្បួនហ្នឹង វប្បធម៌ហ្នឹង កុំឱ្យមានទៀត! វាអត់ប្រយោជន៍ទាល់តែសោះ បង្កិនថវិការដ្ឋ ថវិកាជាតិ ហើយជាក់ស្តែង កន្លែងគ្នាត្រូវការកម្លាំងបែរជាអត់ដដែល"

ក្រឡាហោមខេង

ខេត្តសៀមរាប ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាល និងសួរសុខទុក្ខសិស្សនគរបាលសាលានគរបាលជាតិភូមិភាគ៤

១៥៣-សុំសាលានៅកន្លែងបោះឆ្នោត មើលម្រាមដៃសិន

"ពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខ្ញុំក៏មកបោះឆ្នោត នៅអនុវិទ្យាល័យសោហ៊ី។ ដើរចេញពីការិយាល័យបោះឆ្នោត ក៏លោកគ្រូ អ្នកគ្រូឈរចាំមួយក្រុម នៅកន្លែងហ្នឹង។ ខ្ញុំសួរមកចាំមានការអ្វីមែនទេ? គាត់ថាមកសុំសាលាសម្តេច។ ខ្ញុំក៏ថាឥឡូវអ៊ីចេះ មុននឹងខ្ញុំឆ្លើយ ខ្ញុំសុំឆែកសិន តើម្រាមដៃបានជ្រលក់ទឹកខ្មៅហើយ ឬនៅ? បើមិនទាន់ជ្រលក់ទេ ខ្ញុំអត់ឆ្លើយទេ។ ព្រោះនៅមុខកន្លែងបោះឆ្នោតផង។ បើមិនអីចឹងទេ គេចោទខ្ញុំទិញទឹកចិត្ត កើតទៅជារឿងប្តឹងប្តល់គ្នាថាបោះឆ្នោតមិនប្រក្រតី មិនតម្លាភាព មិនយុត្តិធម៌ អាហ្នឹងវារឿងទៀត។ ទោះបីខ្ញុំមិនមែនជាប្រធានគណបក្ស ឬមិនមែនជានាយករដ្ឋមន្ត្រី ប៉ុន្តែខ្ញុំក៏ជាអ្នកចូលរួមដឹកនាំបក្ស និងរាជរដ្ឋាភិបាល អីចឹងវាមិនល្អទេ។ ដល់តែពួកគាត់បង្ហាញម្រាមដៃមកសុទ្ធតែខ្មៅទាំងអស់ វាមានន័យថា បានបោះឆ្នោតទាំងអស់គ្នាហើយ។ បើអ៊ី ចឹងខ្ញុំឆ្លើយបាន! ខ្ញុំក៏ឆ្លើយឯកភាពជួយសាងសង់អគារសិក្សាជូន ទាំងពេលហ្នឹងមិនដឹងជាទៅរកលុយនៅឯណាទេ (សើច)។ ឆន្ទៈចង់ជួយ ក៏ឆ្លើយជូនភ្លាម"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ពិធីបើកការដ្ឋានបញ្ចុះបឋមសិលាអគារសិក្សាអនុវិទ្យាល័យ សោ ហ៊ី

១៥៤-មួយជីវិតយើងវាតែប៉ុណ្ណឹង

"មួយជីវិតយើងវាតែប៉ុណ្ណឹង អត់មានអ្វីលើសពីហ្នឹងទេ។ ប្រាជ្ញាន័យថា ដួយប្រជាពលរដ្ឋយើងបានច្រើនកាលណា យើងក៏សប្បាយចិត្តប៉ុណ្ណឹង។ ដួយជាតិបានច្រើនកាលណា យើងក៏សប្បាយចិត្តទៅតាមហ្នឹង។ ពីព្រោះមនុស្សយើងទាំងអស់គ្នាកើតមកមានប៉ុន្មាន ក៏ទៅវិញប៉ុណ្ណឹងដែរ។ អត់មានអ្វីលើសពីហ្នឹងទៀតទេ។ អីចឹងហើយ នៅពេលយើងមានជីវិត មានលទ្ធភាពយើងខិតខំប្រឹងប្រែងជួយស្រុកទេសយើង ជួយកូនចៅយើងទៅអនាគត។ វាល្អ វាអត់មានអ្វីខុសទេ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី១៧ ខែសីហាឆ្នាំ២០២២ ពិធីបើកការដ្ឋានបញ្ចុះបឋមសិលាអគារសិក្សាអនុវិទ្យាល័យ សោ ហឺ

១៥៥-ប្រើឱ្យគ្រប់លទ្ធភាព ដើម្បីបម្រើពលរដ្ឋ

“បំណងប្រាថ្នាពលរដ្ឋ យើងត្រូវស្វែងយល់ថា គាត់ចង់បានអ្វី? ត្រូវការអ្វី? បើធ្វើខុសពីហ្នឹង មុខជាទៅហើយ គ្មានពីណាគេគាំទ្រយើងទេ។ គណបក្សប្រជាជនកម្ពុជារបស់យើង និងរាជរដ្ឋាភិបាល យើងធ្វើអ្វីៗ តែងតែគោរពបំណងប្រាថ្នារបស់ប្រជាជន។ យើងបង្កើតច្បាប់អង្គការចំនួន២ គឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ យើងក៏បង្កើតក្រុមការងារពីរទៀតដែរ គឺក្រុមការងារគណបក្ស ដើម្បីជួយនាំយកសុខទុក្ខប្រជាពលរដ្ឋ មករាយការណ៍ឱ្យគណបក្ស ហើយគណបក្សក៏យកទៅសិក្សាដាក់ចេញគោលការណ៍ និងគោលនយោបាយដឹកនាំគ្រប់គ្រង។ បន្ទាប់មកទៀត យើងគិតថាទេ ក្រុមការងារបក្សហ្នឹងមិនគ្រប់ទេ។ យើងក៏ថែមក្រុមការងាររាជរដ្ឋាភិបាលមួយទៀត ដើម្បីចុះស្វែងយល់ពីសុខទុក្ខប្រជាពលរដ្ឋ។ គាត់កើតទុក្ខមិនសុខចិត្ត ឬមានកង្វល់ សំណើ សំណូមពរពីរឿងអ្វី? យើងត្រូវដឹង។ រឿងណាយើងដោះស្រាយបាននៅកន្លែង ក៏នាំគ្នាដោះស្រាយទៅ។ រឿងណាដោះមិនបាន ឬហួសពីសមត្ថភាព យើងរាយការណ៍ជូនថ្នាក់ដឹកនាំជួយដោះស្រាយ”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៧ ខែសីហាឆ្នាំ២០២២ ពិធីបើកការដ្ឋានបញ្ចុះបឋមសិលាអគារសិក្សាអនុវិទ្យាល័យ សោ ហឺ

១៥៦-ចង់ឱ្យសង្គមរីកចម្រើន ទើបគាត់សុំយើង

"ប្រជាពលរដ្ឋយើងខ្ញុំបានដើរច្រើនកន្លែង ហើយក៏ទទួលសំណូមពរ និងសំណើពីគាត់ ក៏ច្រើនដែរ។ គាត់អត់មិនដែលសុំលុយយើង ដើម្បីទិញឡានជិះខ្លួនគាត់ ឬទិញម៉ូតូជិះខ្លួនគាត់ទិញរទេះគោ រទេះក្របី ដើម្បីបម្រើក្រុមគ្រួសារ ផ្គាល់គាត់ទេ។ គាត់សុំសាលារៀន សុំវត្ត សុំផ្លូវជាដើម...។ គាត់សុំតែអ្វីដែលបម្រើប្រយោជន៍សាធារណៈ។ នេះបញ្ជាក់ឱ្យឃើញថាគាត់ចង់ឱ្យសង្គមរីកចម្រើន មិនមែនដើម្បីប្រយោជន៍គាត់ទេ គឺដើម្បីឱ្យសហគមន៍គាត់ បានផលប្រយោជន៍ ជាឧទាហរណ៍គាត់សុំផ្លូវ ដែលសំខាន់សម្រាប់ពួកគាត់ធ្វើដំណើរវាល់ថ្ងៃ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៧ ខែសីហាឆ្នាំ២០២២ ពិធីបើកការដ្ឋានបញ្ចុះបឋមសិលាអគារសិក្ខាអនុវិទ្យាល័យ សោ ហឺ

១៥៧-គាត់សុំ ព្រោះគាត់ជឿយើង

"មិនថាក្រុមការងារគណបក្ស ឬក្រុមការងាររាជរដ្ឋាភិបាល គឺបានបញ្ចូលគ្នានូវមន្ត្រីគ្រប់ផ្នែក មានតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល មន្ត្រីមុខងារសាធារណៈ និងមន្ត្រីនយោបាយ ដែលសុទ្ធតែមានកម្មវត្ថុគាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ មកគាំទ្រមិនមែនមកបញ្ជាខេត្ត បញ្ជាស្រុក ឬឃុំអីនោះទេ។ គឺមកជួយសហការជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ តើមកជួយគាំទ្រផ្នែកលើអ្វី? គឺជួយគាំទ្រ ដោយផ្នែកលើកម្មវិធីនយោបាយរបស់គណបក្ស និងរាជរដ្ឋាភិបាល ដើម្បីយើងរួមគ្នាធ្វើ ដូចជាធ្វើសាលារៀន ផ្តល់សេវាផ្សេងៗ ឬគាំទ្រវិស័យសន្តិសុខជាដើម។ ខ្ញុំពិតជាមានមោទនភាពណាស់ចំពោះលោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សនៅសាលា សោ ហឺ នេះ ដែលបានផ្តល់ទំនុកចិត្តដល់ខ្លួនខ្ញុំ និងសហការីខ្ញុំ ហើយស្នើឱ្យជួយសាងសង់សាលារៀន។ ព្រោះបើគាត់មិនសុំ ក៏យើងមិនហ៊ានធ្វើដែរ...។ គាត់សុំ គឺបញ្ជាក់ថាគាត់ជឿយើង ជឿថាយើងនឹងឆ្លើយតបជូនគាត់។ បើគាត់មិនជឿ មិនរាប់អានយើង មិនឱ្យតម្លៃយើង គាត់មិនខ្ចីសុំទេ ដើរក្បែកស្មាគ្នា ក៏គាត់មិនខ្ចីសុំដែរ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៣ ខែសីហាឆ្នាំ២០២២ ពិធីបើកការដ្ឋានបញ្ចុះបឋមសិលាអគារសិក្សាអនុវិទ្យាល័យ សោ ហឺ

១៥៨-បើជិះមិនខុស មានអស់អីមួយរៀល!

"តាមពិសោធ យើងឃើញថា មូលហេតុធំនៃគ្រោះថ្នាក់ចរាចរណ៍ គឺដោយសារអ្នកប្រើប្រាស់ផ្លូវហ្នឹងតែម្តង។ ដូច្នេះត្រូវដាក់ទោសទណ្ឌពិន័យគាត់ឱ្យច្រន់បន្តិច។ ទេ..! ដាក់ឱ្យច្រន់នេះ មិនចង់ធ្វើបាបគាត់ទេ ប៉ុន្តែដើម្បីការពារជីវិតគាត់វិញទេតើ! កាលកូវីដរាលដាលខ្លាំង យើងដាក់ផែនការ ដើម្បីត្រួតពិនិត្យចរាចរណ៍ហ្នឹង យើងឯកភាពគ្នាដាក់ចេញ តែគាត់មកស្រែកថា ផាកពិន័យគាត់ច្រើនៗ។ ខ្ញុំថាចុះបើគាត់មិនធ្វើខុសមានអស់អីមួយរៀល! សូមធ្វើដំណើរ ឱ្យតែត្រឹមត្រូវតាមច្បាប់ចរាចរណ៍ទៅ វាមានទៅអស់អី! ទីមួយជីវិតគាត់នៅ គឺការពារជីវិតគាត់ឯង ទីពីរគាត់អត់មានអស់លុយមួយរៀល បើគាត់គោរពច្បាប់។ តែបើគាត់បើកបរខុសច្បាប់ អាហ្នឹងខ្ញុំអត់ដឹងទេ! ជួយអត់បានទេ...! ខ្ញុំជួយដើម្បីការពារជីវិតបងប្អូនទេតើ! ដល់តែខ្ញុំនិយាយទៅដូចថាយល់ដែរ"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ កិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ប្រចាំឆមាសទី១ ឆ្នាំ២០២២

១៥៩-ការចាប់ផ្តើមបណ្តុះបណ្តាលនគរបាលជាតិ

"ការកសាងកម្លាំងនគរបាលជាតិ គឺយើងបានឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ហើយវាមិនដូចគ្នាទាំងស្រុងទេ។ ចង់និយាយថា ដំណាក់កាលដំបូងឡើយ យើងបណ្តុះបណ្តាល មិនបាន១០០ភាគរយទេ អ្នកខ្លះក៏បានបណ្តុះបណ្តាលតិចតួច ខ្លះក៏អត់តែម្តង។ នៅឆ្នាំ១៩៧៩ យើងមានឯកឧត្តម **ឡួយ សុផាត** *ជានាយកសាលា។ កាលហ្នឹងមិនមានគ្រូបណ្តុះបណ្តាលទេ មានតែចនាសម្ព័ន្ធសាលា។ គ្រូបានខាងវៀតណាមគេជួយ ហើយអ្នកខ្លះក៏បន្តបណ្តុះបណ្តាលនៅក្រៅប្រទេសដែរ។ ដល់ពេលនេះ យើងចាត់ទុកថាការបណ្តុះបណ្តាលនិងការរៀនសូត្រវិជ្ជាជីវៈនគរបាល គឺជាកាតព្វកិច្ចត្រូវបំពេញមុនគេបង្អស់។ បន្ទាប់ពីប្រឡងជាប់ជានគរបាល គឺមិនអាចរំលងបានទេ។ យើងត្រូវតាប់បញ្ហានេះឱ្យជាប់ បើមិនដូច្នេះទេវាប៉ះពាល់ដល់កំណែទម្រង់របស់យើង វាប៉ះពាល់ដល់គុណភាពនៃកិច្ចប្រតិបត្តិការរបស់កម្លាំងនគរបាលយើង"*

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦០-រៀនហើយធ្វើ ធ្វើហើយរៀន!

*"តើមន្ត្រីនគរបាលក្របខ័ណ្ឌថ្មី មកពីខេត្តទាំង៤ ចំណុះឱ្យភូមិភាគ១ មាននៅសល់មិនទាន់បានមករៀនឬទេ? (នាយកសាលាឆ្លើយ «បាទនៅមាន**សម្តេច**») អូហ៍...! ដូច្នេះ បញ្ហានេះបន្ទាប់ពីយើងប្រឡងហើយ ត្រូវតែរៀបចំបណ្តុះបណ្តាលអ្នកជាប់យ៉ាងយូរបំផុត២ខែ ឬហោចណាស់មួយខែ ក្រោយចេញលទ្ធផលប្រឡង អត់មានទុកយូរទេ។ ត្រូវតែរៀបចំឱ្យមករៀន រៀនចប់ហើយរកពេលធ្វើវិក្រឹតការថែមទៀត។ បានន័យថា រៀនចប់ហើយ គាត់ចេញធ្វើការងារជាក់ស្តែង គាត់មានបទពិសោធហើយ យើងហៅគាត់មកវិក្រឹតការបន្ថែម។ យកបទពិសោធគាត់ឆ្លងកាត់ មកផ្សារភ្ជាប់ជាមួយគ្រូ ឱ្យគ្រូបានរៀនដែរ គឺយកមកវែកញែកគ្នានៅសាលាម្តងទៀត បទពិសោធសំខាន់ណាស់"*

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦១-ប្រយ័ត្នលើសតែខ្វះ!

*"ខ្ញុំ និងសហការី មានការចន្លោះប្រហោងខ្ញុំទទួលស្គាល់ចំណុចហ្នឹង។ ព្រោះអីពីមុនយើងថាបើជ្រើសរើសប៉ូលិសប៉ុស្តិ៍កន្លែងណា យើងយកមនុស្សកន្លែងហ្នុង ឬក្បែរៗហ្នុងតែម្តង។ ចៀសវាងផ្ទើពីភ្នំពេញ សុំមួយ សុំពីរ ដល់តែជាប់ប៉ូលិស មិននៅធ្វើការមូលដ្ឋានទេ សុំទៅផ្តុំគ្នានៅតែភ្នំពេញហ្នុង។ អាហ្នឹងខាត អត់ចំណេញទេ។ យើងកំពុងកំណែទម្រង់ ដើម្បីបន្តយក្របខ័ណ្ឌលើសសេចក្តីត្រូវការ ទាំងនៅការិយាល័យ ទាំងនៅនាយកដ្ឋាន ឬអគ្គនាយកដ្ឋាន។ វិភាគមុខងារឱ្យច្បាស់ថាត្រូវការធនធានមនុស្សជាក់ស្តែង ប៉ុន្មាននាក់? យើងក៏មិនអាចចេះតែកាត់បន្តយបានលឿននោះដែរ។ ត្រូវរកវិធីដោះស្រាយឱ្យសមស្រប បើទោះវិភាគមុខងារទៅ ឃើញធនធានមនុស្សលើសក៏ដោយ។ ខ្ញុំធ្លាប់និយាយហើយថា **ប្រយ័ត្នលើសតែខ្វះ** បានន័យថា **លើសអ្នកគ្មានសមត្ថភាពធ្វើការ ប៉ុន្តែខ្វះអ្នកមានសមត្ថភាពធ្វើការ**។ ដូច្នេះអាហ្នឹងធ្វើម៉េច កុំឱ្យមានស្ថានភាពបែបហ្នឹង"*

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦២-ពីមុនរើសហើយចែក ឥឡូវចែកហើយចាំរើស

"ឥឡូវយើងផ្តល់គោលការណ៍លម្អិតជាងមុនថា កាលមុន យើងជ្រើសរើសឱ្យហើយសិន ទើបបែងចែក។ ឧបមាថាយើងបាត់ក្របខ័ណ្ឌចំនួន២៥០០ ឬ៣០០០នាក់ យើងជ្រើសរើសឱ្យបានប៉ុណ្ណឹងសិន ទើបយើងបែងចែក។ រាជធានី ឬខេត្តមួយៗបានប៉ុន្មាននាក់ បន្ទាប់មក រាជធានី ខេត្តក៏បែងចែកបន្តទៀតទៅអធិការក្រុង ស្រុក ខណ្ឌ។ ឥឡូវអត់លេងអីចឹងទេ...! យើងបញ្ជ្រាស់មកវិញ មានន័យថា បែងចែកឱ្យហើយសិនចាំជ្រើសរើស។ ឧបមាថាស្ទឹងត្រែង មានសង្កាត់ ឬឃុំណាមួយ ត្រូវការប៉ូលិសប៉ុន្មាននាក់...? ដូចថាត្រូវការ២នាក់ ឬ៣នាក់ អីចឹងបែងចែកច្បាស់លាស់ឱ្យហើយ ថាបាន២ឬ៣ គឺដឹងតែបាន។ ដូច្នេះទេ ត្រូវជ្រើសរើសអាទិភាពលើមនុស្សនៅកន្លែងហ្នឹង ឬឃុំហ្នឹង ជាកូនចៅអ្នកម៉ុំៗហ្នឹង។ រើសមិនបានចាំយើងជ្រើសរើសពីក្បែរហ្នឹង ឬតំបន់ហ្នឹង។ ខ្ញុំនឹងដឹកនាំធ្វើការងារនេះ។ យើងឱ្យទស្សនាទានមួយថា បើកាលណាឃុំ-សង្កាត់មានសុវត្ថិភាព ប្រទេសជាតិក៏មានសុវត្ថិភាពដែរ។ អីចឹងទេ កាលណានគរបាលមានសមត្ថភាពធ្វើការ នគរបាលនោះនឹងធានាបានសុខសុវត្ថិភាពឱ្យឃុំ សង្កាត់ហ្នឹងហើយ"

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦៣-នគរបាលអាជីព

"គេបាននិយាយពាក្យថានគរបាលអាជីព ហើយយើងក៏និយាយពាក្យនគរបាលអាជីពដែរ។ ម៉េចបានហៅថាអាជីព? អាជីពមានន័យថាមុខរបរគាត់ គឺនគរបាល។ ដូចកីឡាករអ៊ីចឹង មានកីឡាករមហាជន និងមានកីឡាកររអាជីព។ កីឡាកររអាជីព គឺមុខរបរគាត់ ដឹងតែពីលេងកីឡាហ្នឹងតែម្តង។ ឧទាហរណ៍កីឡាករបាល់ទាត់ ឬបាល់ទះ អាហ្នឹងអាជីពគាត់ ដឹងតែពីលេងបាល់ហ្នឹងតែម្តង។ តែបើកីឡាករមហាជនវិញ គឺពួកគាត់ធ្វើការអ្វីផ្សេងទេ ប៉ុន្តែដល់ពេលលេង ឬប្រកួត ក៏គេហៅគាត់មកលេងដូចជាកីឡាកររអ៊ុំទូកជាដើម។ បើដល់រដូវរអ៊ុំទូកហើយ គេប្រមូលគ្នាហាត់អ៊ុំទូក ដល់ថ្ងៃក៏ឡើងមកអ៊ុំសប្បាយហ្នឹងគេទៅ ឈ្នះឬចាញ់ក៏វិលទៅស្រុកធ្វើស្រែចំការធម្មតា។ ដូច្នេះ នគរបាលអាជីព ត្រូវតែចេះដឹង និងត្រូវតែមានជំនាញហ្នឹងតែម្តង។ បើជានគរបាលចរាចរណ៍ ត្រូវតែចេះដឹងអំពីច្បាប់ចរាចរណ៍ បើជានគរបាលព្រហ្មទណ្ឌ ក៏ត្រូវតែចេះច្បាប់ ឬនីតិវិធីព្រហ្មទណ្ឌ"

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦៤-ខ្លាចអន់ខុសមួយ មិនកែខុសមួយទៀត

"ក្នុងក្របខ័ណ្ឌគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ តែងតែមានការរិះគន់ ឬការទិតៀនគ្នាហើយ។ អីចឹងហើយ ប្រាជ្ញា**សម្តេចតេជោ** លោកឱ្យឆ្លុះកញ្ចក់ មុជទឹក ដុសក្អែល...។ មានន័យថា មតិយោបល់ទាំងឡាយដែលគេនិយាយ ឬទិតៀនមកវាជាកញ្ចក់។ ទោះបីកញ្ចក់ខ្លះឆ្លុះទៅរៀចមុខយើង ឬទិញមកពីប្រភពណាក៏ដោយ បើឃើញថាអីចឹងមែន យើងកែលម្អទៅ យើងកែប្រែទៅ វាអត់មានអ្វីខុសនោះទេ។ មិនមែនថា យើងយកមតិគេមកកែវានាំឱ្យអន់នោះទេ កុំនាំគ្នាយល់អីចឹង...។ បើយល់អីចឹង គឺខុស ហើយវានាំឱ្យយើងនៅតែខុសតទៅទៀត។ អាខ្លាចអន់ហ្នឹង វាខុសមួយហើយ តែអាខុសមួយទៀតនោះគឺកំហុសហ្នឹងវានៅតែខុសទៀត"

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦៥-កុំផ្តោតតែព្រះសីហនុ!

"ការជួញដូរមនុស្ស ឥឡូវវាឈានដល់ប៉ុណ្ណោះទៅទៀត! ដូចថាមនុស្សហ្នឹង គាត់មានជំនាញប្រើខួរក្បាល ឬប្រើកុំព្យូទ័រ ហើយប្រាក់ខែច្រើន មានទាំងប្រាក់រង្វាន់ ប៉ុន្តែពេលធ្វើការ គេបង្ខាំងមិនឱ្យដើរចេញទៅណា នៅធ្វើការតែក្នុងបន្ទប់ ឬក្រុមហ៊ុនហ្នឹង។ អាហ្នឹង វាក៏ជាទម្រង់មួយនៃអំពើជួញដូរមនុស្ស។ ចុះបើវាមិនមែនជាការជួញដូរមនុស្ស ម៉េចបានគាត់ប្តឹងយើង? អាហ្នឹងមួយទៅ! ទីពីរ បើមិនមែនជាការជួញដូរ ហេតុអ្វីបានជាពេលយើងចុះទៅរកឃើញថាអ្នកធ្វើការនោះរស់សុខចិត្តនៅកន្លែងហ្នឹងទៀត។ ចម្លើយមានន័យថានៅកន្លែងហ្នឹងវាធ្វើឱ្យប៉ះពាល់សិទ្ធិគាត់ហើយទើបគាត់មិននៅ។ អីចឹងបានជាយើងខិតខំធ្វើការងារនេះ ប្រកបដោយការទទួលខុសត្រូវ។ មិនអីចឹងទេ គេថាយើងបណ្តែតបណ្តោយឱ្យមានការបំពាន ជាពិសេសលើជនបរទេស។ ដូច្នេះ ខេត្តនីមួយៗមិនត្រូវគិតថាបញ្ហានេះវាកើតតែកំពង់សោម ឬក៏ភ្នំពេញនោះទេ។ អា Online នេះ! អាកុំព្យូទ័រនេះ ខេត្តណាក៏អាចធ្វើបាន ឱ្យតែមានអ៊ីធឺណិត"

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦៦-កុំភ្លេចថាមានអធិការកិច្ច និងសវនកម្ម!

"តាមច្បាប់វិនិយោគថ្មី អនុក្រឹត្យក៏បានចែងដែរ យើងផ្ទេរការសម្រេចលើការវិនិយោគមានតម្លៃ៥លានដុល្លារចុះឱ្យរដ្ឋបាលរាជធានី ខេត្ត។ **សម្តេចនាយករដ្ឋមន្ត្រី** លោកបានចុះហត្ថលេខាហើយ។ អាហ្នឹងជាការផ្ទេរបែបរឹមជ្ឈការ មិនមែនតាមបែបវិសហមជ្ឈការទេ។ តែបើអនុវត្តខុស អភិបាលខេត្តត្រូវទទួលខុសត្រូវ។ អ្នកខ្លះថាការវិនិយោគ៥លានដុល្លារ ហាក់ដូចជានៅតិច? ចុះគម្រោង៥លានដុល្លារ មិនមែនមានតែមួយឯណា? មានច្រើនទេតើ។ ដូច្នេះយើងធ្វើការងារនេះឱ្យល្អ។ ពិតណាស់នេះជាឱកាសហើយ តែមិនមែនឱកាសនិយមទេ...! តិចលោបានដៃហើយប្រឹងពីតយកចុះ។ កុំភ្លេចថាក្រសួងមហាផ្ទៃមានយន្តការពីរ គឺអធិការកិច្ច និងសវនកម្ម!"

ក្រឡាហោមខេង

ខេត្តស្ទឹងត្រែង ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ១

១៦៧-ក្រោយខ្មែរក្រហម សម្តេច ស ខេង កាន់៤ខេត្ត

"ក្រុមការងារខេត្តខ្ញុំធ្លាប់កាន់ចំនួន៤ខេត្ត មិនមែនឃុំទេ ខេត្តតែម្តង។ គ្រាន់តែវាជាខេត្តតាមផ្លូវជាតិតែមួយខ្សែ គឺខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ ខ្ញុំទទួលរ៉ាប់រងទាំងអស់។ បើបាត់ដំបងវិញ ខ្ញុំកាន់តាំងពីឆ្នាំ១៩៨៩។ ក្រោយទ័ពវៀតណាមដកចេញ ការិយាល័យនយោបាយគណបក្ស ឬឥឡូវយើងហៅថាគណៈកម្មាធិការកណ្តាល បានបែងចែកភារកិច្ចថ្នាក់ដឹកនាំ ឱ្យចុះទៅលើកទឹកចិត្តមូលដ្ឋានរួមមានខេត្ត ស្រុក ឃុំ ដើម្បីលើកទឹកចិត្តកងទ័ព ទប់ស្កាត់ការវិលត្រឡប់ នៃរបបប្រល័យពូជសាសន៍។ ពួកខ្មែរក្រហម គេនិយាយឃោសនាថា កងទ័ពវៀតណាមដកចេញ មិនដល់២៤ម៉ោងទេ រដ្ឋាភិបាលរអាយ៉ង ឬសាធារណរដ្ឋប្រជាមានិតកម្ពុជា នឹងរលាយដូចរំបិលត្រូវទឹក។ ដល់តែរឹងចឹង ថ្នាក់ដឹកនាំយើង ក៏បែងចែកភារកិច្ចឱ្យថ្នាក់ដឹកនាំចុះលើកទឹកចិត្ត និងពង្រឹងកម្លាំង"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស្រៃ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីជុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៦៨-ឈ្នះសមរភូមិក្បាលបឹងសេះជាមួយសម្តេច សាយ ឈុំ

"ខ្ញុំក៏ធ្វើទ័ពដែរ ទោះពីមុនមិនធ្លាប់ធ្វើទ័ពក៏ដោយ ប៉ុន្តែសម័យសង្គ្រាម ទោះអត់ចេះធ្វើទ័ព ក៏ត្រូវតែចេះធ្វើដែរ! គេឱ្យខ្ញុំកាន់វរសេនាតូច ប៉ុន្តែមួយវរសេនាតូចហ្នឹង ទៅមានកម្លាំងឯណាច្រើន។ ខ្ញុំប្រមូលមនុស្សបានប្រហែលៗ៣០នាក់ទេ ហើយប្រមូលកាំភ្លើងចម្រុះគ្នា ខ្លះវែង ខ្លះខ្លី ក៏មាន B40 M79ដែរ តែមេបញ្ជាការខ្ញុំនេះ អត់ចេះសោះហ្នឹង។ និយាយឱ្យវាត្រង់ អត់មានចេះធ្វើមេបញ្ជាការស្អីទេ។ ព្រោះមិនដែលធ្វើទ័ពផងហ្នឹង! អាហ្នឹងនិយាយសារភាពត្រង់ ខ្ញុំអត់ចេះភូតទេ។ ប៉ុន្តែដល់តែធ្វើទៅក៏ចេះវាយហ្នឹងគេដែរ ដោយដឹកនាំមួយមុខព្រួញជាមួយ **សម្តេច សាយ ឈុំ**។ **សម្តេច** មួយមុខព្រួញ ខ្ញុំមួយមុខព្រួញ វាយភូមិមួយគេហៅភូមិក្បាលបឹងសេះ (ខេត្តត្បូងឃ្មុំ) វាយម្ខាងម្នាក់ជាមួយ **សម្តេច សាយ ឈុំ** ក៏ឈ្នះតែម្តង។ ប៉ុន្តែដំបូងអ្នេ! (សើច) គ្រាប់កាំភ្លើងបាញ់ឡើងតែលើ ភ័យផងអីផង កុំអួត...ព្រោះយើងមិនដែលធ្វើទ័ពផងហ្នឹង! អត់ដែលធ្វើទ័ព យើងប្រកែកថាធ្លាប់ធ្វើអាហ្នឹងវាមិនត្រូវ ទៅភូតគេធ្វើស្អី! ប្រវត្តិសាស្ត្រពីណាក៏គេដឹងដែរ។ ភូតរាក់កំផែលគេដឹងតម្រូវហ្នឹង។ បើភូត ភូតឱ្យវែងឆ្ងាយបន្តិច គេចេះគិតពិចារណាដែរតើ គេដឹងប្រវត្តិខ្ញុំដែរតើ..."

ក្រឡាហោមង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រៃស្រែ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីជុយ ស្ថិតនៅឃុំបឹង៣ព្រះ ស្រុកបាភ្នំ

១៦៩-ធនធានប្រេងកាត និងធនធានមនុស្ស

"ដើម្បីការពារសុខសន្តិភាព និងអភិវឌ្ឍន៍ស្រុកទេសបានយូរអង្វែង ទាល់តែយើងមានធនធានមនុស្សល្អៗច្រើន។ នេះគឺជាកត្តាគន្លឹះតែម្តង។ មិនមែនឱ្យតែមនុស្សច្រើនហើយ ដឹងតែខ្លាំងនោះទេ ហើយក៏មិនមែនមានធនធានធម្មជាតិសម្បូរបែបទើបហៅថាប្រទេសខ្លាំង ក៏មិនមែននោះដែរ។ ប្រទេសខ្លះមានមនុស្សតិច ហើយធនធានធម្មជាតិក៏មិនជាសម្បូរដែរ ប៉ុន្តែបើមនុស្សតិចនោះគេរៀនសូត្របានចេះដឹងច្រើន គេក៏អាចធ្វើឱ្យស្រុកទេសគេរីកចម្រើន ថ្កុំងថ្កើង រុងរឿងដែរ។ មានប្រទេសខ្លះដូចជានៅអាហ្វ្រិក ប្រេងកាតមិនដឹងយកទៅណារស់ ក៏ប៉ុន្តែដោយសារមានប្រេងហ្នឹងហើយទើបទៅជាក្រវិញ។ ចុះសួរថាដោយសារអ្វី..? គឺដោយសាររត់មានធនធានមនុស្សចេះដឹងឈ្លោះតែគ្នាឯង ប្រេងកាតក៏វាដាក់បណ្តាសា។ ផលបានមកតែអ្នកធំៗ ពលរដ្ឋគ្នានៅតែក្រីក្រ មានទៅបានស្អី។ ដូច្នេះ ក៏កើតជាសង្គ្រាមស៊ីវិលហើយមានការលូកដៃពីប្រទេសក្រៅអីផង ក៏បែកបាក់ជាតិតែម្តង។ អីចឹងបានជាយើងមិនមើលស្រាលទេ ហើយខ្ញុំក៏បានរួមចំណែកជាមួយថ្នាក់ដឹកនាំ និងប្រជាជនថា បើមានលទ្ធភាពធ្វើ ត្រូវតែធ្វើ ត្រូវតែជួយអភិវឌ្ឍន៍វិស័យអប់រំ"

ក្រឡាហោម ខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស៊ែ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីជុយ ស្ថិតនៅឃុំបឹង៣ព្រះ ស្រុកបាភ្នំ

១៣០-សម្តេច ជា ស៊ីម និងសាកលវិទ្យាល័យនៅកំចាយមារ

"**សម្តេច ជា ស៊ីម** កាលគាត់មានព្រះជន្ម គាត់បានចង្អុលទៅអង្គការវេទមហាឬស្សី មានមូលដ្ឋាននៅប្រទេសអូស្ត្រាលី ដែលអង្គការនេះ គ្មានសូវមានធនធានច្រើនទេ តែមានធន្ធ: មានធនធានមនុស្ស មានគ្រូ និងមានកម្មវិធីសិក្សាល្អៗ។ ដល់តែអីចឹង **សម្តេច** គាត់ក៏ចង្អុលឱ្យមកធ្វើសាលានៅកន្លែងហ្នឹង (**សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ**) គ្នាក៏មកធ្វើមែន។ ធ្វើហើយក៏ដំណើរការតិតក់ៗទេ ព្រោះមិនមានលុយធ្វើអគារល្អៗ។ សូម្បីតែផ្ទះគ្រូក៏ប្លាំងស្លឹកស្នោត ប្រក់ស្លឹកស្នោត ផ្ទះសិស្សនិស្សិតស្មាក់ហ្នឹងក៏ដូចគ្នា។ ចំណែកសាលសហសិក្សាវិញ ធ្វើពីដែកអេតចាយប្រក់សង្កសី គ្មានក្រាលការ៉ូ ឬបេតុងអ្វីទេ រៀនលើដីតែម្តង។ ឃើញបែបនេះ ខ្ញុំក៏ចាប់ផ្តើមជួយអគារមួយខ្នងៗបន្តប់។ ក្រោយមក អង្គការហ្នឹងចង់អស់លុយ ហើយសុំដកខ្លួនចេញ។ ក្រសួងអប់រំក៏ថា បើអីចឹង លុបចោលទៅ មិនបាច់ឱ្យមានទៀតទេ។ ខ្ញុំគិតថាទេ...! បើវាមានហើយ លុបចេញយ៉ាងម៉េច? ម្យ៉ាងមានសិស្សនិស្សិតបានបណ្តុះបណ្តាលពីរបីជំនាន់ ហើយធនធានចេញទៅក៏ធ្វើការច្រើនកន្លែងដែរ។ ខ្ញុំក៏ទាក់ទងក្រសួងអប់រំ និងក្រសួងការបរទេស សុំឱ្យទុកសាលាហ្នឹង។ ទុកឱ្យខ្ញុំអ្នកជួយគាំទ្រ... ម្យ៉ាង **សម្តេច ជា ស៊ីម** លោកខិតខំណាស់ទម្រាំជំរុញឱ្យវាកើតឡើង។ តាំងពីពេលហ្នងមកខ្ញុំ

ក៏ចាប់ផ្តើមស្វែងរកការគាំទ្រជាបន្តបន្ទាប់...។ **សម្តេច** កាលពីលោកនៅមានព្រះជន្ម ខ្ញុំធ្លាប់បានអញ្ជើញមកមើលសាលាហ្នឹងម្តងដែរ។ តែកាលហ្នុង គាត់ជិះរទេះរុញទេ (មុខស្លូត) គាត់ឈឺធ្ងន់ទៅហើយ គាត់បានមកមើល គាត់សប្បាយចិត្តគាត់ណាស់ព្រោះយើងធ្វើឱ្យបានសមរម្យ សម្រាប់ជាកន្លែងរស់រំនៅតំបន់ជនបទ សម្រាប់កូនចៅយើងបានសិក្សារៀនសូត្រ។ ម្យ៉ាងកន្លែងហ្នុងកាលណោះក៏ក្រដែរ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស្រៃ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីជុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៣១-កុំរុញឱ្យគេទាល់ក្បៀនជញ្ជាំង

"ក្រុមការងារចុះមកមូលដ្ឋាន ដែលមកជួយប្រជាពលរដ្ឋនេះ ជាវប្បធម៌ និងក៏ជាគុណធម៌ដ៏ល្អមួយ។ ប្រជាជនគាត់ដឹងណាស់ហើយពីអ្វីដែលយើងធ្វើ ទើបបានជាគាត់បោះឆ្នោតគាំទ្រយើងជាបន្តបន្ទាប់។ បើក្រុមការងារនាំគ្នាចុះមកបង្កើតតែវប្បធម៌ខ្សឹបខ្សៀវ បែងចែកប្រជាជន អានេះល្អ ឬអានោះអាក្រក់! រាប់អានអានេះ មិនរាប់អានអានោះ! ធ្វើបាបអានេះបញ្ឆោអានោះ! អាហ្នឹងអត់បានទេ អត់បានតែម្តង! នយោបាយគណបក្សប្រជាជនកម្ពុជា អត់មានអីចឹងទេ។ ទោះពលរដ្ឋណាមួយនោះគាត់បោះឆ្នោតឱ្យនរណា ឬឱ្យបក្សណា តែពេលគាត់ភ្ញាក់រលឹក គាត់ក៏វិលមកគាំទ្រយើង គាត់បោះឆ្នោតឱ្យយើងវិញក៏ថាបាន។ អាហ្នឹងហើយប្រជាធិបតេយ្យ គេទុកឱ្យមនុស្សមានច្រកចេញ មានផ្លូវដើរ កុំឱ្យទាល់ក្បៀនជញ្ជាំង ឱ្យគេទាល់គឺមានជម្លោះប្រដាប់អាវុធហើយ ដូចប្រវត្តិសាស្ត្រយើងអីចឹង"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស្រៃ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីជុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៧២-លោក ខឹម វាសនា ប្រកាសត្រាស់ដឹង

"**ខឹម វាសនា** គាត់បានប្រមូលគ្នីគ្នា ទៅចំការគាត់នៅសៀមរាប។ អ្នកព្រៃវែងយើង បើនៅខាងពារាំង ឯកឧត្តម **វង្ស ពិសេន** រាយការណ៍មកថា ទៅអស់ប៉ុន្មានរយនាក់ដែរហើយ។ ខ្ញុំថាទៅក៏ទៅចុះ ក៏ប៉ុន្តែទៅតាមណា? បានអីហូប? **ខឹម វាសនា** ឯណាគាត់ចិញ្ចឹមអស់ បើរាប់ពាន់នាក់អីចឹង។ មិនមែនជាការជួបប្រជុំបក្សនយោបាយពិតមែន ប៉ុន្តែសុទ្ធតែជាសមាជិកបក្សគាត់។ ប្រជុំធម៌អារ្យថាទឹកលិច ហើយថាគាត់ជាអ្នកត្រាស់ដឹងអីចឹងទៅ។ ខ្ញុំក៏ឱ្យចៅហ្វាយខេត្តសៀមរាប ចុះទៅប្រាប់ពួកគាត់ថារាជរដ្ឋាភិបាល អត់មានហាមឃាត់អ្វីទេ។ រឿងប្រជុំអីហូរហែរយើងអត់ហាមឃាត់ទេ។ ប៉ុន្តែសុំថាធ្វើម៉េចរក្សាសណ្តាប់ធ្នាប់កុំឱ្យវាហួស។ ខ្ញុំណែនាំហ្នឹង ក្នុងន័យជួយគាត់ទៅវិញទេ! ចុះបើមនុស្សទៅជាអីចឹងទៅហើយ យើងទៅជួយទាញគាត់កុំឱ្យលង់តទៅទៀត។ ឥឡូវ គាត់ទេសនាធម៌គាត់... តើអ្នកស្តាប់បានអីហ្នុង? មានតែបញ្ហា ព្រោះអ្នកខ្លះលក់ឡៃឡុងថោកៗអស់ហើយផ្ទះសម្បែង គោក្របី។ នែ៎! ដល់ថ្នាក់ហ្នឹង! ខ្ញុំសរសើរគាត់ថាគេចេះនិយាយអាម៉ែច បានវាទៅអីចឹងកើត។ ខ្ញុំធ្វើមិនដូចទេ។ តែយ៉ាងណា រាជរដ្ឋាភិបាលយើងមានកាតព្វកិច្ចច្បាស់លាស់លើរឿងនេះ។ ទោះពួកគាត់ជាសមាជិកគណបក្សណាក៏ដោយ តែយើងជាបក្សឈ្នះឆ្នោត យើងទទួលខុសត្រូវប្រជាជនយើង

ទាំងអស់។ យើងនិយាយទៅនេះ ក្នុងនាមអ្នកទទួលខុសត្រូវលើប្រជាជនយើង កុំឱ្យគាត់លង់តទៅទៀត។ ឥឡូវ ខ្ញុំឱ្យមនុស្សទៅគ្រប់គ្រងសភាពការណ៍ហ្នឹង។ ថ្ងៃមុនក៏ឱ្យជួបជជែកគ្នាទៀត ព្រោះកាលមុនគាត់សុំជួបជុំត្រឹមថ្ងៃទី៣០សីហា។ ខ្ញុំក៏ថាមិនអីទេ ឱ្យគាត់នៅសិនចុះ ឱ្យតែមានបាយហូប។ តែថ្ងៃ៣០សីហាហើយ គាត់ទៅជាសុំដល់ដាច់ខែកញ្ញាឯណោះវិញ។ ជឿក៏ជឿចុះ តែសួរថាបានស្អីហ្នង...? មិនស្រួលហាលភ្លៀងហាលខ្យល់ ហូបចុកមិនគ្រាន់ ហូបមិនស្អាត មកវិញមានជំងឺផងមិនដឹង។ ខ្ញុំក៏បានឱ្យហៅមកជួបមួយសារទៀត គាត់ក៏ថាសុំត្រឹមថ្ងៃ៥ ខែកញ្ញា។ អូខេ! ចុះបើថ្ងៃ៥គាត់មិនរំសាយឱ្យធ្វើម៉េច...? ខ្ញុំថាអត់មានធ្វើម៉េចទេ...! យើងអត់ធ្វើអីគាត់ទេ...! យកកម្លាំងទៅបង្ក្រាបគាត់យ៉ាងម៉េច? ដ្បិតគាត់គាំទ្រគេហ្នងហ្នែន តែគាត់ជាប្រជាពលរដ្ឋយើងទេតើ...! គាត់កំពុងចាញ់ប្រោកគេផង យើងយកកម្លាំងទៅធ្វើស្អី ឬប៉ះទង្គិចស្អី វាល្អមើលណាស់ឬ..? អត់ទេ! យើងបន្តតាមដានទៀត។ ខ្ញុំក៏សុំគោលការណ៍ណែនាំពី **សម្តេចតេជោ** ជាបន្តបន្ទាប់ដែរ ពីព្រោះការងារនេះវាពាក់ព័ន្ធសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ"

ក្រឡាហោម ស ខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស៊ែ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីជុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៧៣-ប្រតិបត្តិការពាក១

"គោលដៅ នៃប្រតិបត្តិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សរបស់យើង មានពាយ៉ាងធំៗ។ ទីមួយ-ត្រូវសង្គ្រោះជនរងគ្រោះឱ្យបានដាច់ខាត។ ទីពីរ-ត្រូវចាប់ខ្លួនបញ្ជូនទៅតុលាការឱ្យកាត់ទោសជនល្មើសមេជួញដូរ និងអ្នកពាក់ព័ន្ធ។ ទីបី-ត្រូវបិទកន្លែងអនឡាញហ្នឹង ឬកន្លែងលេងល្បែង កន្លែងប្រព្រឹត្តល្មើសហ្នឹងតែម្តង។ រឿងនេះ យើងក៏ត្រូវពន្លាតវាថា តើលុយរកស៊ីខុសច្បាប់ពាក់ព័ន្ធជួញដូរមនុស្សហ្នឹង តើពាក់ព័ន្ធបទល្មើសសម្អាតប្រាក់ដែរឬទេ? ពួកយើងមានកាតព្វកិច្ចតាមដាន និងដោះស្រាយរឿងនេះឱ្យដល់ឫសគល់"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខាសាលាបឋមសិក្សាប្រស៊ែ បឋមសិក្សាស្នែរាន និងបឋមសិក្សាជីផុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៧៤-ខ្មែរក្រហមសម្លាប់ទាំងគ្រួសារ

"សម័យខ្មែរក្រហម ក្រុមគ្រួសារខ្ញុំស្លាប់អស់៣០នាក់ គឺញាតិខាងប្រពន្ធខ្ញុំ គឺប្រពន្ធមុនដែលគាត់បានស្លាប់ទៅហើយ។ ដោយសារខ្ញុំចូលរួមតស៊ូប្រឆាំងខ្មែរក្រហម ពួកវាក៏ឃោសនាថា ឥឡូវប្តីបងឯង បានរស់នៅសុខសប្បាយហើយ មានជាយហូបគ្រប់គ្រាន់ ហើយមានមុខតំណែងខ្ពស់ទៀត។ រីចឹងគាត់ឱ្យពួកខ្ញុំមកយកបងឯង ទៅនៅជាមួយគាត់ ហើយយកទាំងឪពុកម្តាយបងឯងផង។ យាយនិងតាឪពុកក្មេកខ្ញុំនោះ លីប៉ុណ្ណឹង និយាយពីថាមហាសប្បាយ! ទេ...ទៅនៅជាមួយកូនប្រសារខ្ញុំហើយ...! កូនខ្ញុំគេរស់នៅសប្បាយ គេមានឋានៈធំអីហូរហែរអីចឹងទៅ។ ម៉ែអ្នោះយ...ចេញទៅមិនបានទាំង៣០០ម៉ែត្រផង ពួកវា សម្លាប់ចោលអស់រលីង (មុខសួត)"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស៊ែ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីថុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៧៥-បំផុសឱ្យពលរដ្ឋចេះសួរយោបល់

"ជួញដូរមនុស្សនេះ បើគេថានាំកូនទៅធ្វើការ ទោះបានប្រាក់ខែប៉ុន្មានក៏ដោយ ត្រូវតែចេះសួរនាំអាជ្ញាធរមូលដ្ឋានផង! សួរឱ្យគេជួយផ្តល់យោបល់ ជួយស្រាវជ្រាវថាតើក្រុមហ៊ុនហ្នឹង ការងារហ្នឹង ឬបុគ្គលមកនិយាយហ្នឹង យ៉ាងម៉េចដែរ? ទុកចិត្តបានទេ ជាដើម។ ចំណែកអាជ្ញាធរ សមត្ថកិច្ចយើងក៏ត្រូវយកចិត្តទុកដាក់ ការពារប្រជាជនយើងដែរ។ យើងមានភារកិច្ចធ្វើមិនមែនបណ្តែតបណ្តោយ ហើយនិយាយថាឱ្យធ្វើម៉េច បើវាអីចឹងនោះទេ...? ត្រូវឧស្សាហ៍ណែនាំឱ្យគាត់ចេះសួរយោបល់យើងដែលជាភូមិ មេឃុំ ឬជាប៉ុស្តិ៍នគរបាល។ បើមិនអីចឹងទេ ទប់មិនជាប់ទេ ព្រោះបទល្មើសនេះស្មុគស្មាញណាស់"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សាសាលាបឋមសិក្សាប្រស៊ែ បឋមសិក្សាស្នែរាន និងបឋមសិក្សាដីថុយ ស្ថិតនៅឃុំបឹងព្រះ ស្រុកបាភ្នំ

១៣៦-ថ្នាក់ដឹកនាំឯលើ ស្គាល់មន្ត្រីមិនអស់ទេ

"**សម្តេចតេជោ** ឬខ្លួនខ្ញុំក្តី យើងមិនស្គាល់មន្ត្រីទាំងអស់ទេ មានតិចតួចខ្លះស្គាល់។ ភាគច្រើន គឺពឹងផ្អែកលើរដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗជាអ្នកលើកដាក់ រាយតម្លៃហើយស្នើឡើងមកទេ។ ឥឡូវដូចជាចប់សព្វគ្រប់អស់ហើយការតែងតាំងអភិបាលរងរាជធានី និងខេត្ត។ ប៉ុន្តែខេត្តពោធិ៍សាត់ដូចជាចុងក្រោយគេបន្តិច ហើយបញ្ហាគឺវានៅត្រង់ថា មានសមាសភាពមួយរូប គាត់ស្នើមកមានឋានៈអនុរដ្ឋលេខាធិការ ដោយស្នើជាអភិបាលរងខេត្ត ដែលវាមិនស្រប។ ដូច្នេះ ទាល់តែលាលែងពីអនុរដ្ឋលេខាធិការសិន ហើយមានព្រះរាជក្រឹត្យត្រឹមត្រូវ ទើបយើងអាចតែងតាំងបាន។ បើមិនអីចឹងទេ យើងតែងតាំងម្តេចបាន ព្រោះអនុរដ្ឋលេខាធិការ មន្ត្រីធំជាងអគ្គនាយកទៅទៀត។ ដូច្នេះហើយបានជាត្រូវសម្រួលរៀបចំឡើងវិញ។ ឯអភិបាលរងក្រុង ស្រុក ខណ្ឌ ដូចជាមិនទាន់រៀបចំអស់ទេ ដោយសារកំពុងពិនិត្យពិចារណា។ អីចឹងមានន័យថាខាងលើនេះ យើងមិនដឹងអស់ទេថា មន្ត្រីក្រោមៗគាត់យ៉ាងម៉េចខ្លះ។ គឺអាស្រ័យលើថ្នាក់ដឹកនាំនៅនឹងកន្លែងជាអ្នកស្នើសុំតែងតាំង"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

១៣៧-មែ៉បង្ខាំងកូននៅខុសច្បាប់! ទម្រាំអ្នកដទៃ?

"ជនរងគ្រោះខ្លះ ពេលយើងសង្គ្រោះបាន គាត់ទៅឆ្លើយថា អត់មានអ្នកណាធ្វើបាបគាត់ទេ...! អ្នកខ្លះថាគាត់មិនបានប្តឹងទេ...! អ្នកប្តឹងគឺពុកម៉ែ ឬសាច់ញាតិគាត់ទេ...! អ្នកខ្លះថាគាត់ប្តឹងមែន ប៉ុន្តែគេអត់បានធ្វើទារុណកម្មអ្វីទេ... ប៉ុន្តែឆ្លើយថាខ្ញុំមិនចង់នៅទេ... ខ្ញុំចង់ចេញ...! ខ្លះថាគេមិនឱ្យខ្ញុំចុះក្រោម...ដើរហាត់ប្រាណ ដើរកំសាន្ត គេឱ្យនៅក្នុងបន្ទប់...។ ទេ...! អាហ្នឹងជាបទល្មើសបង្ខាំងមនុស្សហើយតើ...! ត្រង់ខុសធ្ងន់ ឬស្រាលយ៉ាងណា... វាអាស្រ័យលើតុលាការ គេសម្រេចទៅ។ ព្រោះអ្វីដែលជនរងគ្រោះគាត់និយាយមក វាជាការបិទសិទ្ធិ សេរីភាពហើយ។ សូម្បីតែតាយាយ ឪពុកម្តាយបង្ខាំងកូនទុក នៅគេថាខុសច្បាប់ ចុះទម្រាំអ្នកដទៃ? អីចឹងបានខ្ញុំថាអ្នកឯងមានសិទ្ធិអីទៅបង្ខាំងគេ...?"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

១៧៨-បើក្រុមហ៊ុនមានទំនាស់ជាមួយបុគ្គលិក

"កន្លងទៅរឿងទំនាស់ការងារ នៅក្នុងក្រុមហ៊ុនណាហ្គាវើលដ៍ មានបងប្អូនប្រជាការពារយើងខ្លះ ដំបូងឡើយមានការយល់ច្រឡំ តែចុងក្រោយពួកគាត់ក៏ចូលរួមអនុវត្តប្រកបដោយការអត់ធ្មត់ច្រើនជាមួយកម្លាំងនគរបាលយើង។ បញ្ហានេះត្រូវដឹងថា យើងមិនអាចយកអំណាចរដ្ឋ ទៅដោះស្រាយបញ្ហាប់បញ្ហាតវ៉ាបានឡើយ ព្រោះយើងជាអាជ្ញាកណ្តាលនៃទំនាស់។ ទំនាស់នេះ វាជាទំនាស់រវាងក្រុមហ៊ុន និងបុគ្គលិកទេតើ...! វាមិនពាក់ព័ន្ធផលប្រយោជន៍សាធារណៈទេ។ យើងពាក់ព័ន្ធតែការងារសន្តិសុខសណ្តាប់ធ្នាប់ប៉ុណ្ណោះ។ ត្រង់ក្រុមហ៊ុនត្រូវ ឬបុគ្គលិកខុស វាមិនមែនយើងជាអ្នកសម្រេច ឬក៏ឈរនៅម្ខាងណានោះទេ"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

១៣៩-កម្មករ ក៏ជាម្ចាស់អគារ

"ខ្ញុំសូមសរសើរស្ថាបត្យករ វិស្វករ និងកម្មករ កម្មការិនី ដែលប្រឹងប្រែងបំពេញការងារ ដោយមិនមែនត្រឹមតែបម្រើផលប្រយោជន៍ក្រុមហ៊ុនប៉ុណ្ណោះទេ តែក៏ដើម្បីផលប្រយោជន៍ជាតិដែរ។ ពីព្រោះអគារថ្មីនេះ ជាទ្រព្យសម្បត្តិសាធារណៈ និងក៏ជាទ្រព្យសម្បត្តិបងប្អូនជាកម្មកររនៅទីនេះដូចគ្នា។ សំណង់ថ្មីនេះបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាជនយើងក្នុងវិស័យមហាផ្ទៃ ទាំងបច្ចុប្បន្ន និងទៅអនាគត"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី១៨ខែកញ្ញា ឆ្នាំ២០២២ ពិធីសួរសុខទុក្ខ និងចែករំណោយជូនក្រុមស្ថាបត្យករ វិស្វករ និងកម្មករសាងសង់អគារទីស្តីការក្រសួង

១៨0-កសាងជាតិតាមគោលការណ៍នីតិរដ្ឋ មិនមែនល្បែងទេ!

"ត្រូវមានជំហរឯកភាពគ្នាថា ការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិយើង គឺឈរលើគោលការណ៍នីតិរដ្ឋ មិនមែនផ្អែកទៅលើល្បែងស៊ីសងខុសច្បាប់នោះទេ។ ពិតហើយការបង្ក្រាបល្បែងអនឡាញខុសច្បាប់វាមានការប្រឈម ដោយសារមានអ្នកនៅពីក្រោយ ធ្វើជាខ្នងបង្អែកខ្លះ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងត្រូវយល់ឱ្យត្រឹមត្រូវថា នេះជាអំពើល្មើសច្បាប់ដែលបម្រើផលប្រយោជន៍តែបុគ្គល ឬក្រុមមនុស្សមួយក្តាប់តូចណាមួយប៉ុណ្ណោះ។ វាពុំមែនបម្រើផលប្រយោជន៍សាធារណៈនិងផលប្រយោជន៍ប្រជាជនទូទៅឡើយ។ ការបណ្តែតបណ្តោយឱ្យល្បែងស៊ីសងខុសច្បាប់រីកដូចផ្សិត វាមិនអាចមកជំនួសការវិនិយោគដ៏ត្រឹមត្រូវតាមច្បាប់បានទេ។ អាខុសច្បាប់ហ្នឹងវាមានពន្ធ មានចំណូលស្អីចូលរដ្ឋដូចគេវិនិយោគត្រឹមត្រូវស្អី។ មិនត្រឹមតែប៉ុណ្ណោះ វាថែមទាំងរារាំងការវិនិយោគត្រឹមត្រូវដែលមានទុនច្រើនទៀតផង។ ត្រូវដឹងថា មុននឹងគេយកប្រាក់ មកវិនិយោគគឺគេមើលទាំងអស់។ ជារួមការមកច្រើននៃអ្នកមិនត្រឹមត្រូវ វាមិនអាចមកជំនួសអ្នកល្អៗ និង ទេសចរណ៍បានឡើយ។ វាមានតែរារាំងទៅវិញទេ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២0២២ កិច្ចប្រជុំណែនាំការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

១៨១-វិញ្ញាសាវាស់ឧត្តមគតិ ឆន្ទៈ និងសមត្ថភាព

"បញ្ហាប្រឈមក្នុងការងារ វាច្បៀសមិនផុតឡើយ។ ប៉ុន្តែបើយើងមិនដោះស្រាយទេ បញ្ហានោះវានឹងរីកកាន់តែធំ ដែលយើងពិបាកប៉ាន់ស្មានក៏ថាបាន។ ដូច្នេះ ពេលមានការប្រឈមណាមួយវាក៏ជាឱកាសបញ្ចេញស្នាដៃដើម្បីបង្ហាញឆន្ទៈ និងការប្តេជ្ញាចិត្តក្នុងការបំពេញភារកិច្ច ដូចជាជូនរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋជាដើម។ បើយើងរារែក ឬមិនច្បាស់លាស់ វាមានន័យថា យើងគ្មានការប្តេជ្ញាចិត្ត ហើយក៏មិនអាចបញ្ចេញស្នាដៃដើម្បីបង្ហាញពីការទទួលខុសត្រូវបានដែរ។ ការបង្ក្រាបគ្រឿងញៀនក្តីល្បែងស៊ីសងខុសច្បាប់ក្តី ក៏ជាវិញ្ញាសាសំខាន់ សម្រាប់វាស់វែងឧត្តមគតិ ឆន្ទៈ និងសមត្ថភាពរដ្ឋបាលដែនដី"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ កិច្ចប្រជុំណែនាំការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

១៨២-មេរោគមហារីកសង្គម

"យើងអាចវាយតម្លៃ និងសន្និដ្ឋានបានថា ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ជាមេរោគមហារីកសង្គមដ៏កាចសាហាវ។ ពីព្រោះតាមរយៈបទល្មើសនេះ វានឹងនាំឱ្យបទល្មើសផ្សេងៗ កើតមានឡើងទៅតាមនោះដែរ ដូចជាបទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ គ្រឿងញៀន ភេរវកម្ម លួច ឆក់ ប្លន់ ជំរិតទារប្រាក់ បទល្មើសធ្វើទារុណកម្ម កាប់សម្លាប់ ឬសងសឹក ប្រើប្រាស់អាវុធខុសច្បាប់ បទល្មើសអន្តោប្រវេសន៍ខុសច្បាប់ និងបទល្មើសម្អាតប្រាក់ជាដើម ដែលសុទ្ធតែនាំឱ្យប៉ះពាល់ដល់ការកសាយុត្តិធម៌សង្គម"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ កិច្ចប្រជុំណែនាំការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

១៨៣-អៀនៗជាចរិតមួយនាំឱ្យអន់ថយ

"ខ្មែរយើងច្រើនតែអៀនៗ ទាំងគេទាំងខ្ញុំ កាលពីនៅតូចៗ អៀនៗណាស់ មិនហ៊ាននិយាយ មិនហ៊ានស្តីអីទេ ជួនអីសូម្បីតែដើរមើលមុខចាស់ៗ ក៏មិនហ៊ានដែរ។ អាហ្នឹង ជាចរិតមួយនាំឱ្យអន់ថយ យើងមិនត្រូវមានចរិតហ្នឹងទេ! អីចឹងបានថាកូនចៅយើង បានប្រឡូកក្នុងចំណោមក្មេងៗគ្នាគេ រួចហើយប្រឡូកក្នុងសង្គមក៏លែងសូវអៀនខ្មាស់។ ធ្វើដូច្នេះ គ្នានឹងហ៊ាននិយាយ ហ៊ានថា ហ៊ានសួរ ហ៊ាននាំបញ្ហាទាំងឡាយណាដែលខ្លួនមិនដឹង។ ក្មេងៗ បើកាលណាចេះសួរច្រើន ចង់ចេះចង់ដឹងច្រើន គឺក្មេងហ្នឹងឆ្លាតហើយ។ តែបើធ្វើអ្វីក៏ដោយ ក៏មិនសួរ មិននាំ ឬក៏ថាមិនចេះក៏មិនហ៊ានសួរ ព្រោះតែការខ្លាចខ្មាស់គេ អាហ្នឹងគឺទៅហើយ ចាញ់គេហើយ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សា៧ខ្នង នៅស្រុកស្វាយអន្ទរ

១៨៤-ម្ចាស់ជំនួយគ្មានឱកាសមកថៃទាំទេ

"ក្នុងនាមជាម្ចាស់ជំនួយ ឬជាអ្នកឧបត្ថម្ភ បើនិយាយរួមគឺសប្បុរសជន ខ្ញុំសូមប្រកាសផ្ទេរសំណង់សមិទ្ធផលទាំងអស់នេះជូនប្រជាពលរដ្ឋ ក៏ដូចជារដ្ឋបាលខេត្ត ស្រុក ឃុំ ភូមិ លោកគ្រូអ្នកគ្រូ ដើម្បីធ្វើជាម្ចាស់គ្រប់គ្រង។ សមិទ្ធផលទាំងនេះ ជាទ្រព្យសម្បត្តិសាធារណៈ។ ពួកខ្ញុំជាអ្នកខិតខំប្រមូលបច្ច័យ ឬថវិកាពីសប្បុរសជនមកជួយសាងសង់នេះ មិនមានឱកាសមកជួយថៃទាំគ្រប់ពេលវេលាទេ។ អីចឹងសូមប្រកាសផ្ទេរការគ្រប់គ្រងបន្ត ទៅឱ្យរដ្ឋបាលគ្រប់ថ្នាក់ពាក់ព័ន្ធ ហើយសូមចាត់ទុកថានេះជាទ្រព្យសម្បត្តិ ជាមាស ជាពេជ្រ ជាទុនអភិវឌ្ឍន៍ជាតិរបស់យើងទាំងអស់គ្នា"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សា៣ខ្នង នៅស្រុកស្វាយអន្ទរ

១៨៥-ការគ្រប់គ្រងដែលនាំឱ្យសង្គមបែកបាក់

“គណបក្សប្រជាជនកម្ពុជា មិនមានទម្លាប់ ឬគោលការណ៍គ្រប់គ្រងប្រទេស ដោយមានការបែងចែកប្រជាជនចាស់ ប្រជាជនថ្មី វណ្ណៈលើ វណ្ណៈក្រោម ឬអ្នកមាន បញ្ញវន្តអ្វីនោះឡើយ។ បើគ្រប់គ្រងបែបហ្នឹង មុខជាបំបែកសង្គមខ្លួចតែម្តង។ ព្រោះមនុស្សមុខជារស់សាមគ្គីគ្នាកើត ថែមទាំងរើសរើងទៀតផង។ យើងគ្មានចំណុចរស់ហ្នឹងទេ។ យើងខិតខំលើកទឹកចិត្តមនុស្សគ្រប់រូបថារអាចធ្វើអ្វីបានដើម្បីខ្លួនឯង និងដើម្បីសង្គមជាតិ នាំគ្នាធ្វើទៅ។ ឱ្យតែត្រឹមត្រូវតាមច្បាប់ ខិតខំធ្វើទៅ ហើយយើងមានតែលើកទឹកចិត្តឱ្យធ្វើដើម្បីផលប្រយោជន៍ពួកគាត់ និងសង្គមជាតិយើងរីកចម្រើន”

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សា៣ខ្នង នៅស្រុកស្វាយអន្ទរ

១៨៦-ទេសចរណ៍ និងសក្តានុពលមូលដ្ឋាន

"មិនត្រូវពឹងផ្អែកថាទាល់តែមូលដ្ឋានយើងមានសមុទ្រ ឬមានប្រាសាទ ទើបមានភ្ញៀវមកទេសចរណ៍។ ការរៀបចំតំបន់ទេសចរណ៍ កន្លែងណាក៏អាចរៀបចំបានដែរ ឱ្យតែយើងមានគំនិត។ ទេសចរណ៍សំខាន់ ព្រោះមនុស្សមកចាយលុយ។ ពីមុនយើងថាព្រៃវែងសម្បូរចាប តែឥឡូវចាបព្រៃវែងខ្សត់អស់ហើយ សល់តែឈ្មោះទេ..។ អីចឹងបានខ្ញុំសូមទាញការចាប់អារម្មណ៍ថា សូម្បីតែការរៀបចំផ្ទះសម្បែង ភូមិឋានយើងឱ្យល្អ ក៏វាអាចទាក់ទាញទេសចរណ៍បានដែរ។ ចំណែកហាងលក់ម្ហូបអាហារយើងរៀបចំឱ្យល្អ ទាក់ទាញ អនាម័យ តម្លៃធូរថ្លៃ មានទាំងម្ហូបស្រុកម្ហូបស្រែ អាហ្នឹងទេសចរណ៍គេចូលចិត្តណាស់។ អីចឹងទេ សូមកុំគិតអ្វីពិសេសលើសពីមូលដ្ឋានយើងពេក សំខាន់ចេះថ្នៃប្រឌិត។ ខេត្តបាត់ដំបងអត់មានសមុទ្រ អត់មានអង្គរវត្តទេ ចុះហេតុអ្វីបានជាបាត់ដំបងមានទេសចរណ៍ច្រើនប៉ុន្មានឆ្នាំហ្នឹង? ខ្ញុំសួរទៅគេលាន់មាត់ថាកន្លែងស្អាតៗ ម្ហូបឆ្ងាញ់ៗ..."

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខាឥតខ្នង នៅស្រុកស្វាយអន្ទរ

១៨៧-បទពិសោធធ្វើស្មៀន!

"ស្មៀនឃុំ ស្មៀនសង្កាត់សំខាន់ណាស់។ កុំមើលស្រាល! គាត់ធ្វើការងារចេះច្រើនណាស់ គាត់ធ្វើការជាមួយប្រជាពលរដ្ឋ និងឃុំ សង្កាត់។ ដូច្នេះ គាត់រៀនសូត្របានច្រើន។ សូមទោស មិនមែនខ្ញុំចង់និយាយភ្ជាប់អ្វីទេ ខ្ញុំក៏ធ្លាប់ធ្វើស្មៀនដែរ។ ខ្ញុំធ្វើស្មៀនភូមិ ស្មៀនឃុំ ស្មៀនស្រុក ស្មៀនមេភូមិភាគទៀតផង។ ស្មៀននេះមានឱកាសបានការងារជួយបង្រៀនច្រើនណាស់"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្សា៧ខ្នង នៅស្រុកស្វាយអន្ទរ

១៨៨-ក្បាលមួយ មួកពីរ

"ក្រមប្រឹក្សាឃុំ សង្កាត់ មិនមែនឈ្នះហើយដិះសេះលែងដៃទេ...។ គាត់ទទួលខុសត្រូវពីរទិសឯណោះ ទីមួយ-ទទួលខុសត្រូវជាមួយប្រជាពលរដ្ឋមុនគេ។ កិច្ចការទាំងអស់ក្នុងមូលដ្ឋានគាត់ ទប់ស្កាត់ បញ្ជាបង្ក្រាបចោរលួច ចោរប្លន់ ចោរឆក់ ចោរអំបុកចោរអំបែង ឬល្បែងស៊ីសងខុសច្បាប់ជាដើម។ មិនមែនបើភ្នែកម្ខាង បិទភ្នែកម្ខាងទេ។ ត្រូវដឹងថាប្រជាជនមានបាយហូបឬអត់? គាត់មានផ្ទះសម្បែងរស់នៅសមរម្យឬនៅ...? ពលរដ្ឋប៉ុន្មានមានផ្ទះ? ផ្ទះថ្មប៉ុន្មាន? ផ្ទះក្បឿងប៉ុន្មាន? ផ្ទះស្លឹកប៉ុន្មាន? ចុះអ្នកអត់ផ្ទះ ឬមួយផ្ទះខ្ទម... តើមានប៉ុន្មាន អីប៉ុន្មាន...? យ៉ាងហោចណាស់ត្រូវក្តាប់អាហ្នឹង រកវិធីជួយគាត់តាមលទ្ធភាព និងមិនរើសអើង។ ទីពីរ-ទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ទោះជាគាត់ទទួលបានសន្លឹកឆ្នោតពីពលរដ្ឋក៏ដោយ តែគាត់ក៏ស្ថិតក្នុងអង្គការនីតិប្រតិបត្តិដែរ។ តើទទួលខុសត្រូវអ្វីខ្លះ? គឺគោរពអនុវត្តច្បាប់ គោលនយោបាយ និងគោលការណ៍ លិខិតបទដ្ឋាននានាដែលរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្ត"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខាសាលាខេង នៅស្រុកស្វាយអន្ទរ

១៨៩-លទ្ធផលរមិលគុណពលរដ្ឋឯង

"តំបន់នេះ (ឃុំក្រហៅ ស្រុកកំចាយមារ) ត្រូវខ្មែរក្រហមជាក់គោលដៅកម្ទេចចោល សម្លាប់ចោលទាំងអស់ ទាំងដែលតំបន់នេះជាតំបន់ដែលបានចិញ្ចឹមបីបាច់ឱ្យរីកធំធាត់នូវចលនាខ្មែរក្រហមមួយដោយស្មោះសរ រហូតបង្កើតបាននូវរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេ មិនត្រឹមតែមិនសងគុណ ប្រជាពលរដ្ឋនៅតំបន់នេះទេ ទោះអ្នកធ្លាប់ដងទឹកឱ្យងូត ដងទឹកឱ្យផឹក លាក់នៅលើស្មាកក្នុងផ្ទះក៏ដោយ ទីបំផុត គឺពួកគេសម្លាប់ចោលដូចគេដូចឯង ដោយគ្មានដឹងគុណស្រយៃ។ ដោយសារនយោបាយឆ្កួតលីលាពេលបានអំណាច។ ដូច្នេះ ដោយសារព្រះលោកមិនជួយ ទីបំផុត របបនេះក៏មិនឋិតថេរ។ របបដែលគ្មានការគាំទ្រពីប្រជាពលរដ្ឋ របបកាប់សម្លាប់ ធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋ នឹងមិនអាចឋិតថេរបានឡើយ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ពិធីចុះពិនិត្យ និងព្យាបាលជំងឺរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សេ សុខា** ជូនប្រជាពលរដ្ឋក្នុងឃុំចំនួន៣ នៃស្រុកកំចាយមារ

១៩០-ពញាចក្រី ហេង សំរិន ជាមហាសាក្សី!

*"ការក្រោកឡើងបះបោរតស៊ូប្រឆាំង របបខ្មែរក្រហមនៅតំបន់កំចាយមារនេះ ខ្លាំងក្លាជាងកន្លែងណាៗទាំងអស់នៅកម្ពុជា។ គ្រប់ភូមិភាគ មានចលនាតស៊ូប្រមាណ៤ទៅ៥ចលនា ប៉ុន្តែបើធៀបតំបន់នេះ គឺតំបន់បូព៌ានេះ មានចលនាតស៊ូធំជាងគេ។ មនុស្សប្រមាណជិត២ម៉ឺននាក់ប្រានរត់ភៀសខ្លួនចូលព្រៃតាទក(ព្រៃក្រោយឃុំក្រចៅ) ទាំងឈឺថ្កាត់ ចាស់ជរា ក្មេងតូច និងស្ត្រីពោះធំជាដើម ដោយប្រឈមការខ្វះខាតសព្វបែបយ៉ាង។ ភ្លៀងឆ្នាំ១៩៧៨នោះ គឺមហាភ្លៀងតែម្តងទាំងយប់ទាំងថ្ងៃ លិចលង់តំបន់នេះ។ អីចឹងហើយជម្រកក៏ខ្វះ ស្បៀងក៏ខ្វះ ថ្នាំពេទ្យក៏ខ្វះ បូកបន្ថែមការរុកក្នុងព្រៃតាមបាញ់សម្លាប់ ពីពួកខ្មែរក្រហម គឺវេទនាមហាវេទនា។ មូលហេតុដែលគេដៅយកកន្លែងនេះ ជាគោលដៅត្រូវកម្ទេច ក៏ដោយសារគេចាត់ទុកវាជាមូលដ្ឋានតស៊ូរបស់ **សោ ភីម** អតីតមេភូមិភាគបូព៌ា ដែលគាត់រស់នៅចេញចូលកន្លែងនេះ។ **ប៉ុល ពត** ក្តី! **នួន ជា** ក្តី! អ្នកដឹកនាំមួយចំនួនទៀតក្តី ក៏រស់នៅ និងចេញចូលកន្លែងនេះដែរ ដោយមាន **សោ ភីម** ជួយការពារ និងលាក់ការណ៍។ សាក្សីរស់នៅដល់សល់សព្វថ្ងៃគឺ **សម្តេចមហាពញាចក្រី ហេង សំរិន** លោកជាមហាសាក្សីដ៏រស់រវើក និងជាក់ស្តែងនូវអ្វីដែលខ្ញុំបាននិយាយ"*

ក្រឡាហោមខេង

*ខេត្តព្រៃវែង ថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ពិធីចុះពិនិត្យ និងព្យាបាលជំងឺរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **ស សុខា** ជូនប្រជាពលរដ្ឋក្នុងឃុំចំនួន៣ នៃស្រុកកំចាយមារ*

១៩១-ពេលថ្លែងនៅស្រុកកំណើត

"យើងខ្ញុំមិនបំភ្លេចគុណបំណាច់ និងការធ្វើពលិកម្មរបស់បងប្អូននៅតំបន់នេះ (ស្រុកកំចាយមារ) ទេ។ យើងខ្ញុំខិតខំតាមលទ្ធភាព និងគ្រប់បែបយ៉ាងតាមអាចធ្វើទៅបាន ដើម្បីជួយដោះស្រាយការលំបាក និងសេចក្តីត្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋនៅតំបន់នេះ។ ប៉ុន្តែបងប្អូនក៏បានដឹងហើយថា តួនាទីដឹកនាំរបស់ខ្ញុំ គឺមិនមែនតែមួយឃុំ ពីរឃុំ បីឃុំ ឬមួយស្រុក មួយខេត្តឡើយ។ ខ្ញុំក៏ត្រូវរួមចំណែកដឹកនាំក្នុងក្របខ័ណ្ឌទូទាំងព្រះរាជាណាចក្រកម្ពុជា និងក្របខ័ណ្ឌរាជរដ្ឋាភិបាល។ អីចឹងហើយ យើងខ្ញុំខិតខំចែករំលែកនូវធនធាន នូវអ្វីដែលជាលទ្ធភាពរបស់យើងខ្ញុំ ដើម្បីប្រជាពលរដ្ឋយើង នៅតំបន់ដទៃក៏លោកបានទទួលភោគផលដែរ ទោះបីវាមិនស្មើគ្នាក៏ដោយ ប៉ុន្តែសមរម្យអាចទទួលយកបាន"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ពិធីចុះពិនិត្យ និងព្យាបាលជំងឺរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ***ស សុខា*** *ជូនប្រជាពលរដ្ឋក្នុងឃុំចំនួន៣ នៃស្រុកកំចាយមារ*

១៩២-ខ្មាំងសត្រូវក្នុងសម័យសន្តិភាព

"ខ្ញុំ ថ្នាក់ដឹកនាំ រួមទាំងរាជរដ្ឋាភិបាល ប្រឹងបង្កើតសាលារៀនគ្រប់កម្រិតនៅកំចាយមារនេះ និងនៅទូទាំងប្រទេស ដើម្បីជម្នះភាពក្រីក្រ។ ភាពក្រីក្រ ដែលយើងចាត់ទុកវាជាខ្មាំងសត្រូវមួយ ព្រោះយើងមានសន្តិភាពហើយ ដូច្នេះអត់មានខ្មាំងណាមកវាយជាចំហទៀតទេ។ ខ្មាំងទីមួយ-គឺខ្មាំងល្ងង់ខ្លៅ! ទីពីរ-គឺខ្មាំងអត់ឃ្លាន! និងទីបី-គឺខ្មាំងក្រីក្រហ្នឹងហើយ។ ខ្ញុំមានគំនិតមួយថា ដើម្បីជួយប្រជាពលរដ្ឋយើង គឺបន្ទាប់ពីយើងវាយខ្មាំង ***ប៉ុល ពត*** *ហើយ យើងត្រូវវាយខ្មាំងក្រីក្រ និងខ្មាំងល្ងង់ខ្លៅនេះ។ យើងកុំឱ្យគេថា យើងអ្នកស្រែ ចុងកាត់មាត់ញ្ចកមិនដឹងអ្វី ឬបានតែកូនគេអ្នកធំ ឬអ្នកភ្នំពេញ កូនយើងក្រីក្រអត់ដឹងអី អត់ចេះអី។ យើងមិនឱ្យមានអីចឹងតទៅទៀតទេ។ បើពូកែថាអត់លទ្ធភាព ឥឡូវយកសាលាមកដាក់ហ្នឹងហ្មង...! ដាក់ជិតផ្ទះតែម្តង...ដើរក៏ដល់ ជិះកង់ក៏ដល់"*

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ពិធីចុះពិនិត្យ និងព្យាបាលជំងឺរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ***ស សុខា*** *ជូនពលរដ្ឋក្នុងឃុំចំនួន៣ ស្រុកកំចាយមារ*

១៩៣-កូន និងក្មួយជួយសង់មត្តេយ្យនៅស្រុកកំណើត

"**ស្តើង សុខុម** ជាកូនប្រសារបងស្រីទីមួយរបស់ខ្ញុំ គឺបង **ស សិន** ដែលគាត់ប្អូនស្លាប់ទៅហើយ។ **សុខុម** គាត់ជាប្រធានក្រុមការងារនៅស្រុកកំចាយមារនេះ ជំនួសអា **ថេង** (ឯកឧត្តម **ស ថេង**) ដែលវាស្លាប់ទៅហើយដែរ។ អា **ថេង** វាប្អូនបង្កើតខ្ញុំដែរ។ ដើម្បីជាការនឹកគុណដល់ម្តាយ ដែលបានស្លាប់ទៅនោះ **សុខុម** គាត់សុខចិត្តពីរនាក់ប្តីប្រពន្ធគាត់ចំណាយថវិកាជួយធ្វើមត្តេយ្យសាលាមួយក្នុងទីស្នាក់ការឃុំក្រហៅ ដែលនៅខាងក្រោយសាលាឃុំ។ ប៉ុន្តែវាមិនគ្រប់គ្រាន់នៅឡើយទេ ហើយខ្ញុំក៏បានពិភាក្សាជាមួយគ្រួសារខ្ញុំ និងកូនខ្ញុំ **ស សុខា** ថាឥឡូវ **សុខុម** ធ្វើនៅឯណោះហើយ អីចឹង **សុខា** និងកូនប្រសារខ្ញុំ **សុភី** (លោកជំទាវ **កែ សួនសុភី**) ធ្វើទីនេះទៅ។ តម្លៃប៉ុន្មាន **សុខា** ដឹងហើយ។ ខ្ញុំរីករាយ ព្រោះមត្តេយ្យនេះខ្ញុំធ្លាប់បញ្ជាក់ហើយថាវាជាកន្លែងអប់រំកុមារតាំងពីតូចទៅ"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ពិធីចុះពិនិត្យ និងព្យាបាលជំងឺរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **ស សុខា** ជូនពលរដ្ឋក្នុងឃុំចំនួន៣ ស្រុកកំចាយមារ

១៩៤-ទៅជាថាមហាផ្ទៃប្រមូលអំណាច

"តាំងពីដើមមក យើងបានឯកភាពចាប់ដៃគ្នាថាខិតខំធ្វើកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិយើង ឱ្យទៅជារដ្ឋបាលមួយខ្លាំង និងជារដ្ឋបាលឯកភាព។ យើងគ្រប់គ្រង តាមរបៀបខ្សែទទឹងឱ្យបានខ្លាំង ដើម្បីថ្នាក់ក្រោមយើង ចាត់ចែងបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។ តែវាមិនអីចឹង... ទៅជាមានអ្នកមិនយល់...ហើយទៅជាថាក្រសួងនេះ ឬក្រសួងនោះប្រមូលអំណាច ជាពិសេសចោទមកក្រសួងមហាផ្ទៃថាជាក្រសួងប្រមូលអំណាច។ ប៉ុន្តែខ្ញុំសួរត្រឡប់ទៅវិញថា តើមហាផ្ទៃយកអំណាចមកទុកធ្វើស្អី? មកទុកលើហ៊ឹង ឬលើស្មាក? ដើម្បីតាំងពិព័រណ៌ ឬយ៉ាងម៉េច...? វាមិនមែន អត់មានទាល់តែសោះ! (មុខមាំ) មែនទែនទៅ គឺគ្រាន់តែជាអ្នកដើរតួ ជួយសម្របសម្រួលដើម្បីយកអំណាច ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ឬយកអំណាចមកឱ្យប្រជាពលរដ្ឋនៅមូលដ្ឋានទេតើ...សូមមើលចុះ បើខុស!"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ សម្ពោធអគារសិក្សា និងសមិទ្ធផលនៅឃុំតាប៉ុន ស្រុកសង្កែ

១៩-ត្រូវប្រើគាត់ឱ្យបម្រើប្រជាជន

"យើងខំដុតដៃដុតជើងណាស់ ដើម្បីធ្វើយ៉ាងម៉េចឱ្យឈ្នះការបោះឆ្នោតឃុំ សង្កាត់។ ពេលឈ្នះហើយ តើឱ្យក្រុមប្រឹក្សាធ្វើអីហ្នឹង? យកមកថ្វាយបង្គំ ឬទុកឱ្យថ្វាយបង្គំ? អត់ទេ...! ត្រូវប្រើគាត់ឱ្យបម្រើប្រជាជន មានគណនេយ្យភាពជាមួយប្រជាជនមុនគេបង្អស់។ ចុះបានស្អីមកធ្វើគណនេយ្យភាព បើមិនឱ្យអំណាចគាត់ផងហ្នឹង...? បើយើងមិនផ្ទេរធនធានឱ្យគាត់ផងហ្នឹង? បានស្អីធ្វើគណនេយ្យភាព? វាទាល់តែប្រជាជនគាត់សុំផ្លូវបានផ្លូវ ឃុំរបានឆាប់។ បើថាប្រជាជនមានទំនាស់ដីធ្លី យើងដោះស្រាយជូនគាត់បាន ឃុំរបានឆាប់។ ប្រជាជនទឹកលិច យើងទៅដល់ភ្លាម ឬមានបញ្ហារងគ្រោះ យើងទៅដល់ភ្លាម"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ សម្ពោធអគារសិក្សា និងសមិទ្ធផលនៅឃុំតាប៉ុន ស្រុកសង្កែ

១៩៦-ចែកគ្នាធ្វើការ

"យើងចេញដំណើរ២០ឆ្នាំហើយតើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ប៉ុន្តែនៅជជែកគ្នាឱ្យវែ....! ខ្លះនៅតែល្ងង់...សូមទោសខ្ញុំថាអីចឹងចុះ គឺនៅល្ងង់អីចឹងហ្មង។ ខ្ញុំមិនយល់...ក្រែងរបបយើងជារបបយកប្រជាជនជាធំ យកប្រជាជនជាបង្អែកអ្វី...? ការបម្រើប្រជាជនឱ្យបានល្អ ឬប្រទេសជាតិសុខសប្បាយទៅបាន វាមិនពឹងតែថ្នាក់លើប៉ុន្មាននាក់ហ្មងអាចធ្វើបានទាំងអស់នោះទេ។ ត្រូវចែកការងារគ្នាធ្វើ ចែកឱ្យថ្នាក់ក្រោមគេធ្វើទៅ។ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ធ្វើអីបានឱ្យគេធ្វើទៅ។ ជួយនាំគ្នាបង្កលក្ខណៈឱ្យគេធ្វើបានដោគជ័យទៅព្រោះទឹកដីរបស់គេដែរតើ!"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ សម្ពោធអគារសិក្សា និងសមិទ្ធផលនៅឃុំតាប៉ុន ស្រុកសង្កែ

១៩៧-ធំបំផុតអំណាចគ្រប់គ្រងមនុស្ស!

"មហាផ្ទៃក៏កាត់អំណាចឱ្យថ្នាក់ក្រោមជាតិដែរ ក៏ផ្ទេរទៅឱ្យដែរ នាំគ្នាមើលទៅថា កាត់បុគ្គលិកឱ្យក្រោមជាតិប៉ុន្មាននាក់ សូមមើលទៅ ការតែងតាំងមន្ត្រី យើងផ្ទេរឱ្យសាលាខេត្ត សាលាស្រុកតែងតាំងអស់ហើយ។ គឺគេជាអ្នកតែងតាំង ឬបើត្រូវមកដល់លើនេះ ក៏គេស្នើដែរ មិនមែនក្រសួង ឬមិនមែនខ្ញុំ ជាអ្នកស្នើតែងតាំងនោះទេ។ សព្វថ្ងៃ នៅតែនាយករដ្ឋបាលទេតើដែលខ្ញុំតែងតាំង ហើយតែងតាំងនេះ គឺតែងតាំងទៅតាមខេត្តគេស្នើមកទៀត។ ចំណែកប្រធានមន្ទីរក៏អីចឹងដែរ បើខេត្តគេមិនស្នើមកទេ អត់មានក្រសួងចេះតែមកតែងតាំងស្រែចចិត្តទេ...។ អំណាចផ្ទេរឱ្យធំណាស់...! អំណាចគ្រប់គ្រងមនុស្សអ្ហា! មិនមែនអំណាចធម្មតាៗទេ។ ដូច្នេះ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏មិនអាចបណ្តែតបណ្តោយដែរ។ ពិតហើយថាក្រសួងគេទទួលខុសត្រូវដួយមើល ជួយតម្រែតម្រង់ ប៉ុន្តែក៏គេតាមដានដែរថាយើងហ្នឹងមានទំនួលខុសត្រូវ ឬអត់"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ សម្ពោធអគារសិក្សា និងសមិទ្ធផលនៅឃុំតាប៉ុន ស្រុកសង្កែ

១៩៨-ករណីប៉ូលិសថៃបែកថ្នាំ

"នៅថៃ មានប៉ូលិសម្នាក់គាត់ជក់គ្រឿងញៀន ថ្នាក់លើក៏សម្រេចបណ្តេញចេញ។ ដេញចេញមិនបានប៉ុន្មានថ្ងៃផង ក៏ទៅប្លាញ់ ក៏ទៅកាប់សម្លាប់ក្មេងជាង៣០នាក់ ហើយសម្លាប់ទាំងប្រពន្ធ និងកូនខ្លួនឯងទៀត ប្លាញ់ទាំងខ្លួនឯងស្លាប់ទៀត។ នេះជាឧទាហរណ៍ជាក់ស្តែង និងប្រកបដោយគ្រោះថ្នាក់...សូមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនយកជាមេរៀន យកជាពិសោធ និងជំរុញការអប់រំផ្សព្វផ្សាយទូទាំងប្រទេស។ យើងយើងមើលស្រាលគ្រឿងញៀនមិនបានទេ"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ សម្ពោធអគារសិក្សា និងសមិទ្ធផលនៅឃុំតាប៉ុន ស្រុកសង្កែ

១៩៩-ព្រំដែនសិទ្ធិបញ្ចេញមតិ!

"រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យពលរដ្ឋហ៊ានបញ្ចេញមតិ ក៏ប៉ុន្តែទន្ទឹមគ្នានោះ ក៏ត្រូវទប់ស្កាត់មតិទាំងឡាយណា ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍សង្គមជាតិដែរ"

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ទី២៥ ខែតុលា ឆ្នាំ២០២២ ទទួលជួបពិភាក្សាការងារជាមួយលោក Sarder Umar Alam តំណាងអង្គការយូនីស្កូ (UNESCO) ប្រចាំនៅកម្ពុជា

២០០-ខ្ញុំរៀនពី សម្តេចនាយក!

"ខ្ញុំរៀនពី **សម្តេចនាយក** (**សម្តេចតេជោ ហ៊ុន សែន**) បើប្រជាពលរដ្ឋមានបញ្ហាអ្វី គាត់អាចចូលទៅខំមេន (Comment) តាមហ្វេសប៊ុក (Facebook) ឬផ្ញើសារជូនលោកបាន...។ ខ្ញុំក៏ឱ្យបង្កើតហ្វេសប៊ុក ហើយបើកទទួលមតិយោបល់ប្រជាពលរដ្ឋ។ ពលរដ្ឋគាត់ដឹង ឬមានបញ្ហាអ្វី បញ្ជូនមកតែម្តង មានរាប់ពាន់ករណី។ យើងដោះស្រាយជូនគាត់បានដូចជា៤៥ ទៅ ៥០ភាគរយដែរ។ បន្ថែមលើនេះ ខ្ញុំក៏បង្កើតក្រុមការងារដើម្បីជួយទទួលតាមដានហ្វេសប៊ុករបស់ **សម្តេចតេជោ** និងហ្វេសប៊ុកខ្ញុំ ដើម្បីតាមដានព័ត៌មាននានាទាក់ទងសមត្ថកិច្ចក្រសួងមហាផ្ទៃ។ ល្អតើ...! យើងបើកចំហ ពលរដ្ឋក៏គាត់ហ៊ានឱ្យយោបល់"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាលសាលាភូមិភាគ៥

២០១-អំពើល្មើសពាក់ព័ន្ធហត្ថពលកម្មខុសច្បាប់នៅកម្ពុជា

"ហត្ថពលកម្មបរទេសដែលកំពុងធ្វើការនៅកម្ពុជាយើងនេះ ភាគច្រើនបំផុតខុសច្បាប់។ អាចនិយាយថា៨០ ទៅ៨៥ភាគរយ ខុសច្បាប់។ ខុសច្បាប់ធំទីមួយ-គឺអត់មានលិខិតឆ្លងដែន។ ខុសទីពីរ-ទៅលួចធ្វើការ...។ ចំណែកអ្នកទទួលឱ្យធ្វើការហ្នឹងក៏ខុសដែរ។ មួយទៀត ប្រើទិដ្ឋាការទេសចរណ៍ តែលួចធ្វើការ អាហ្នឹងខុសត្រង់មកទេសចរណ៍ ហែរជាទៅធ្វើការ និងអត់បណ្ណាការងារ។ ថៅកែហ្នឹងក៏ខុសដែរ ព្រោះទទួលជនបរទេសធ្វើការទាំងគេអត់មានបណ្ណាការងារ។ ខុសមួយទៀត គឺមានលិខិតឆ្លងដែន ឬមានទិដ្ឋាការ ប៉ុន្តែអត់មានបណ្ណាការងារ។ សមត្ថកិច្ចយើងរកឱ្យឃើញបញ្ហាហ្នឹង ហើយសិក្សាថែម តើមានខុសស្អីទៀតទេ! ខ្ញុំកំពុងពិចារណាជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ **(ឯកឧត្តមបណ្ឌិត អ៊ិត សំហេង)** ដើម្បីបង្កើនប្រាក់ផាកពិន័យ ព្រោះបើពិន័យតិចពេក វាអត់រាងចាល...។ អីចឹងបង្កើនការផាកពិន័យទាំងហត្ថពលកម្ម និងថៅកែ។ រឿងធំមួយទៀត ក្រុមហ៊ុនថៅកែដែលប្រើហត្ថពលកម្មខុសច្បាប់ មានអាជ្ញាបណ្ណទេ...? បើអត់ត្រូវតែធ្វើតាមច្បាប់ ចែកឱ្យដាច់ អត់មានត្រូវមួយ រួចមួយទេ!"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ពិធីសំណេះសំណាលជាមួយសិស្សនគរបាលសាលាភូមិភាគ៥

២០២-ភស្តុតាងនៃសាមគ្គីភាពផ្ទៃក្នុងជាតិ

*"ជោគជ័យ នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅកម្ពុជា ការពិតហើយ គឺដោយសារការដឹកនាំចាត់ចែងដ៏ត្រឹមត្រូវរបស់ **សម្តេចតេជោ** ប្រមុខរាជរដ្ឋាភិបាល និងគណៈកម្មការប្រយុទ្ធប្រឆាំងកូវីដ-១៩ រួមទាំងអាជ្ញាធរគ្រប់ថ្នាក់។ ក៏ប៉ុន្តែវាក៏អាស្រ័យលើការគាំទ្រ និងការចូលរួមពីប្រជាពលរដ្ឋដែរ ដែលនេះជាការបញ្ជាក់ឱ្យឃើញ នូវសាមគ្គីផ្ទៃក្នុងជាតិ...។ វ៉ាក់សាំងយើងចាក់ដោយមិនបានបែងចែក រើសអើង មិនមែនអ្នកគាំទ្ររាជរដ្ឋាភិបាលទើបចាក់ជូន ហើយអ្នកប្រឆាំងមិនចាក់ មិនមែនទេ យើងចាក់ជូនទាំងអស់ ព្រោះជាពលរដ្ឋខ្មែរដូចគ្នា ហើយក៏មិនមែនតែពលរដ្ឋខ្មែរយើងដែរ សូម្បីជនបរទេសទាំងឡាយនៅកម្ពុជាក៏យើងចាក់ជូនដែរ"*

ក្រឡាហោមខេង

*ខេត្តបាត់ដំបង ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ សម្ពោធអគារសិក្ខាវិទ្យាល័យ **ហ៊ុន សែន** ភ្នំសំពៅ ស្រុកបាណន់*

២០៣-ដុំមាស ដុំពេជ្រ ប្លានពីប្រជុំអាស៊ាន

"ប្រតិភូមេដឹកនាំពិភពលោកដែលមកចូលរួមកិច្ចប្រជុំអាស៊ាននៅប្រទេសយើង ប្រៀបប្លានដឹងការនាំដុំមាស ដុំពេជ្រ នាំប្រាក់មកឱ្យយើងអីចឹងដែរ។ មិនមែនមានកិត្តិយស ឬប្លានមាសប្លានប្រាក់ឱ្យតែទៅ **សម្តេចនាយករដ្ឋមន្ត្រី** ឬថ្នាក់ដឹកនាំរាជរដ្ឋាភិបាលណាមួយនោះទេ គឺសម្រាប់ពួកយើងទាំងមូល។ ត្រូវយល់ថាក្នុងយើងប្លាន:ជាពលរដ្ឋ យើងត្រូវប្រកាន់ឥរិយាបថស្វាគមន៍ភ្ញៀវ។ ស្វាគមន៍យ៉ាងម៉េច...? គឺពេលគណៈប្រតិភូគេឆ្លងកាត់ម្តងៗ បើកងកម្លាំងគាត់សុំឱ្យយើងឈប់សិន សូមយើងនាំគ្នាឈប់។ យើងស្តាប់មួយភ្លែតដូចធម្មតាៗទេ ប៉ុន្តែចំណុចនេះមានតម្លៃណាស់។ ភ្ញៀវបរទេសគេមកនេះ គេមើលតាំងពីរឿងដូច្នេះឡើង...គេនឹងចងចាំឥរិយាបថយើង។ ខ្ញុំធ្លាប់ដែរកាលពីអំឡុងឆ្នាំ៨០ ខ្ញុំទៅទស្សនកិច្ចប្រទេសឡាវ ប្រជាជនគេបង្ហាញការស្វាគមន៍ភ្ញៀវណាស់។ គេឈប់ឡានម៉ូតូគេតែម្តងពេលយើងឆ្លងកាត់ ទោះគេអាចជិះទៅមុខប្លានក៏ដោយ... ខ្ញុំក៏ចងចាំដល់ឥឡូវ។ ចង់និយាយថាវត្តមានចូលរួមកិច្ចប្រជុំ និងអនុសញ្ញាវីយ៉ែល្អៗនឹងជួយទាក់ទាញអ្នកវិនិយោគ ទេសចរ រួមនិងផលប្រយោជន៍ផ្សេងៗឱ្យជាតិយើងទាំងបច្ចុប្បន្ន និង អនាគត"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ សម្ពោធអគារសិក្ខាវិទ្យាល័យ **ហ៊ុន សែន** ភ្នំសំពៅ ស្រុកបាណន់

២០៤-យើងរួមគ្នាពង្រឹងភាពជាម្ចាស់នៅមូលដ្ឋាន

"ខ្ញុំសូមអំពាវនាវជាថ្មីទៀត ដល់សហការីទាំងអស់ នៅក្នុងជួររាជរដ្ឋាភិបាល ថាយើងបានរួមគ្នាធ្វើកំណែទម្រង់ ការទំលាក់មុខងារថវិកា និងធនធានមនុស្សទៅថ្នាក់ក្រោមជាតិ ដើម្បីផលប្រយោជន៍ជាតិយើង ដើម្បីឱ្យពលរដ្ឋ និងរដ្ឋបាលមូលដ្ឋានអាចពង្រឹងភាពជាម្ចាស់។ កាលណាគាត់មានធនធាន មានសិទ្ធិមានអំណាច គាត់នឹងអាចចាត់ចែងការងារបម្រើពលរដ្ឋដោយខ្លួនឯង។ ដូចថាឥឡូវ ភូមិហ្នឹង ឃុំហ្នឹង ខ្ញុំត្រូវតែធ្វើម៉េចឱ្យរីកចម្រើន ព្រោះខ្ញុំមានអស់ហើយ លុយក៏មាន សិទ្ធិក៏មាន អំណាចក៏មាន ទោះថាវាមិនគ្រប់គ្រាន់ តែប្រភពចំណូលយើងមានពីរហើយតើ តាមច្បាប់ គឺថវិការដ្ឋ និងសប្បុរសជន។ កន្លងទៅយើងឃើញក្រុមការងារ និងសប្បុរសជនជួយមូលដ្ឋានច្រើនណាស់ បន្ថែមលើថវិការាជរដ្ឋាភិបាលទំលាក់ឱ្យឃុំ សង្កាត់។ ពង្រឹងភាពជាម្ចាស់? ចង់និយាយថា ក្នុងឋានៈយើងជាអាជ្ញាធរគ្រប់គ្រង ឬជាម្ចាស់ផ្ទះ ជាម្ចាស់ទឹកដីភូមិឃុំហ្នឹង យើងធ្វើម៉េចឱ្យភូមិ ឱ្យឃុំ ឱ្យផ្ទះសម្បែងយើងវាល្អ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ សម្ពោធអគារសិក្សាវិទ្យាល័យ **ហ៊ុន សែន** *ភ្នំសំពៅ ស្រុកបាណន់*

២០៥-ភូមិស្អាតស្រែល្អ

*"ពីដើមគេមានពាក្យថា **ភូមិស្អាតស្រែល្អ** ចង់មានន័យថា ភូមិហ្នឹងគ្រាន់តែគេមកដល់ភ្លាមទាក់ទាញតែម្តង។ ការអភិវឌ្ឍមូលដ្ឋាននេះ វាគ្មានអ្វីកើតឡើងដោយឯកឯងឡើយ វាទាមទារសមត្ថភាពរៀបចំកែច្នៃ និងចូលរួម ទើបវារីកចម្រើនទៅបាន។ ដូច្នេះ ពួកយើងនៅមូលដ្ឋាននីមួយៗ ដែលកាន់តែមានលទ្ធភាពច្រើនជាងមុន តាមរយៈប្រភពចំណូលនានានោះ សូមនាំគ្នាខិតខំរៀបចំមូលដ្ឋានយើង ហើយកៀរគរពលរដ្ឋឱ្យចូលរួម"*

ក្រឡាហោមខេង

*ខេត្តបាត់ដំបង ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ សម្ពោធអគារសិក្សាវិទ្យាល័យ **ហ៊ុន សែន** ភ្នំសំពៅ ស្រុកបាណន់*

២០៦-សារផ្ញើជូន អគ្គស្នងការ ក្រោយកិច្ចប្រជុំអាស៊ាន

"ការសម្រេចបេសកកម្មដ៏មានអត្ថន័យនេះ មិនត្រឹមតែទទួលបានការអបអរសាទរយ៉ាងក្លៀវក្លា ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសមិទ្ធផលដ៏លេចធ្លោមួយ គួរឱ្យស្រប់ស្មែង នាំមកនូវមោទកភាព កិត្តិយស និងកិត្យានុភាពជាតិលើឆាកអន្តរជាតិ ក្នុងទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់កម្ពុជាយើងដែរ។ ជាងនេះទៀត ជោគជ័យដ៏ត្រចះត្រចង់នេះ រួមចំណែកបង្កើនជំនឿទុកចិត្ត កាន់តែខ្លាំងក្លាថែមទៀតមកលើសមត្ថភាព ភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការទទួលរៀបចំធ្វើជាម្ចាស់ផ្ទះព្រឹត្តិការណ៍ជាតិ និងអន្តរជាតិសំខាន់ៗ នាបណ្តាឆ្នាំខាងមុខជាបន្តបន្ទាប់"

ក្រឡាហោមខេង

ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ សារផ្ញើជូន ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ***នេត សាវឿន*** *អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាប្រធានអនុគណៈកម្មការសន្តិសុខ សណ្តាប់ធ្នាប់ និងសង្គ្រោះបឋម នៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤០ និង៤១ និងកិច្ចប្រជុំពាក់ព័ន្ធ*

២០៧-រម្លឹកប្រវត្តិរៀនសូត្រនៅកំចាយមារ

"ខ្ញុំរំលឹកបន្តិចអំពីប្រវត្តិទីតាំងសាកលវិទ្យាល័យ **ជា សុីម** កំចាយមារ។ មែនទែនទៅទីនេះជាអតីតអនុវិទ្យាល័យដែលបង្កើតឡើងនាអំឡុងទសវត្សរ៍ឆ្នាំ៦៥ ឬ៦៦។ ខ្ញុំក៏បានមករៀននៅអនុវិទ្យាល័យនេះ នាអំឡុងឆ្នាំ៦៧ រហូតឆ្នាំ៧០ ក៏កើតមានសង្គ្រាម។ កាលហ្នឹងសាលាមានតែ៦បន្ទប់ទេ ហើយមានមួយបន្ទប់ទុកធ្វើការិយាល័យគ្រូ សល់បន្ទប់រៀនតែ៥។ នៅក្បែរនេះមានវត្តមួយហៅថាវត្តតាកេង វត្តហ្នឹងមានកុដិតែមួយ មានព្រះសង្ឃមួយអង្គ និងកូនសិស្សម្នាក់ គឺឯកឧត្តម **ញឹម វណ្ណដា**។ បើខ្ញុំនិយាយមិនពិតសួរគាត់ទៅគាត់ប្រាយតែជាមួយលោកទេ(សើច) គាត់ស្រួលដើរទៅរៀនជាងគេ ព្រោះជិតសាលា។ គាត់ក៏ប្រឡងចូលធ្វើគ្រូបង្រៀន បង្រៀនកូនៗកម្មករចម្ការកៅស៊ូ។ ក្រោយមក ក៏ចូលតស៊ូជាមួយគ្នា...។ ក្រោយរំដោះឆ្នាំ១៩៧៩ ខ្ញុំបានដឹកនាំធ្វើអគារសិក្សា ហើយក៏ដំឡើងពីកម្រិតអនុវិទ្យាល័យទៅជាវិទ្យាល័យ រហូតសាកលវិទ្យាល័យ។ ឥឡូវយើងយកទីតាំងនេះធ្វើមត្តេយ្យ និងបឋមសិក្សា ហើយរៀបចំឱ្យទីនេះឱ្យសិស្សរៀនពីមត្តេយ្យដល់មហាវិទ្យាល័យតែម្តង"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រនិស្សិតសាកលវិទ្យាល័យ **ជា សុីម** កំចាយមារ

២០៨-ជួយជាតិឱ្យអស់លទ្ធភាព!

"យើងទាំងអស់គ្នាមកប៉ុន្មានទៅវិញប៉ុណ្ណឹង អត់មានយកអ្វីទៅរួចទេទាំងអស់គ្នានេះ...។ អីចឹង ការរួមចំណែកបន្សល់ទុកស្នាដៃ និងសមិទ្ធផល ដល់កូនចៅយើងជំនាន់ក្រោយ ពិតជាមានសារសំខាន់ណាស់។ ដូចសាកលវិទ្យាល័យជាតិ ***ជា សុីម*** *កំចាយមារនេះស្រាប់ ពីដំបូងឡើយគ្រាន់តែជាសាលាអង្គការវេទមហាឫស្សីទេ ដល់តែអង្គការហ្នឹងមានបញ្ហាទៅ ក៏ដកខ្លួនចេញ។ ក្រសួងអប់រំថាអត់លទ្ធភាពទេ សុំបិទសាលានេះ។ តែខ្ញុំស្តាយ ព្រោះបានជាកើតហើយ យើងទៅបិទធ្វើអ្វី...? ឥឡូវខ្ញុំមានលទ្ធភាពប៉ុន្មាន ខ្ញុំខិតខំគ្រប់បែបយ៉ាងដើម្បីជួយឱ្យសាលាដំណើរការបានធម្មតា ដោយយើងខំប្រឹងជាជំហានៗ ក្នុងការអភិវឌ្ឍថែមទៀត។ ខ្ញុំចាំពាក្យហ្នឹងរហូត ខ្ញុំមិនភ្លេចការសន្យាទេ ហើយក៏តាំងពីនោះមក ខ្ញុំបានចូលរួមចំណែកជួយចលនាក្បែរគេរកសាងសមិទ្ធផលក្នុងសាកលវិទ្យាល័យនេះបានជាបន្តបន្ទាប់"*

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រនិស្សិតសាកលវិទ្យាល័យ ***ជា សុីម*** *កំចាយមារ*

២០៩-មជ្ឈមណ្ឌលអប់រំដំបូង និងជាគំរូគេឯង

"ការរៀបចំមជ្ឈមណ្ឌលអប់រំ នៅសាកលវិទ្យាល័យ ជាតិ ***ជា ស៊ីម*** *កំចាយមារ ទើបតែមានដំបូងទេ នៅកម្ពុជា។ អីចឹងទេ ទីនេះមានតួនាទីសំខាន់ ព្រោះបើកន្លែងនេះធ្វើបានជោគជ័យ កន្លែងផ្សេងទៀតអាចយកជាគំរូ។ នៅត្បូងឃ្មុំ យើងក៏អាចធ្វើ មជ្ឈមណ្ឌលនេះដែរ។ ចំណុចនេះ គឺក៏ទាមទារឆន្ទៈគាំទ្រខ្ពស់ ពីក្រសួងអប់រំ យុវជន និងកីឡា។ គណៈគ្រប់គ្រងមជ្ឈមណ្ឌល ក៏ត្រូវតែធ្វើទំនាក់ទំនងជាមួយដៃគូជាតិ និងអន្តរជាតិដែលគេ រៀបចំរចនាសម្ព័ន្ធអប់រំដូច ឬស្រដៀងគ្នា ដើម្បីធ្វើទស្សនកិច្ច រៀនសូត្រពីគេ ដកស្រង់បទពិសោធពីគេ...។ យើងក៏អាចចង សម្ព័ន្ធមេត្រីភាពជាមួយគេ ដើម្បីប្រមូលបទពិសោធថ្មីៗមក អភិវឌ្ឍន៍មជ្ឈមណ្ឌលនេះបានដែរ"*

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រនិស្សិត សាកលវិទ្យាល័យ ***ជា ស៊ីម*** *កំចាយមារ*

២១០-មិត្តបរទេសចាំតែជួយទេ

*"ខ្ញុំបានទទួលព័ត៌មានថា **ស សុខា** បានទាក់ទងជាមួយភាគីបារាំងដែរ ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការចែករំលែកបទពិសោធគ្នា។ ប្រទេសជាមិត្តគេចាំតែជួយយើងទេ ឱ្យតែយើងមានគំនិតច្បាស់លាស់ មានឆន្ទៈប្រាកដប្រជា ពិតជាយកមកបម្រើផលប្រយោជន៍សង្គម។ ខ្ញុំជឿថាមិនលំបាកទេ។ ប៉ុន្មានថ្ងៃមុនខ្ញុំបាននាំទូតឥណ្ឌាមកមើលសាកលវិទ្យាល័យនេះដែរ។ គាត់បានសន្យាអ្វីខ្លះ យើងដឹងហើយ ខាងសាកលវិទ្យាល័យទាក់ទងទៅគាត់ទៅ គេអាចរវល់មិនទាន់បានទាក់ទងយើង។ អីចឹងទាក់ទងទៅ ក្រែងគាត់ជួយពង្រឹងជំនាញកុំព្យូទ័រ ព្រោះគាត់ខ្លាំងខាងហ្នឹង"*

ក្រឡាហោមខេង

*ខេត្តព្រៃវែង ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រនិស្សិតសាកលវិទ្យាល័យ **ជា សុីម** កំចាយមារ*

២១-មិនតំបន់និយមនោះទេ

"ខ្ញុំសូមបញ្ជាក់ជូនថា ខ្ញុំមិនមែនជារដ្ឋមន្ត្រីក្រសួងអប់រំទេ ខ្ញុំជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ប្រសិនណាជាយើងមិនមានគំនិតដើម្បីចូលរួមកសាងវិស័យអប់រំក៏មិនខុសដែរ ច្បាប់អត់ឱ្យធ្វើទេ។ ប៉ុន្តែដោយសារទឹកចិត្ត មនោសញ្ចេតនា ចង់ធ្វើម៉េចចូលរួមបណ្តុះបណ្តាលធនធានមនុស្ស។ បេសកកម្មនេះក៏មិនមែនមានតែខ្ញុំដែរ ថ្នាក់ដឹកនាំយើងជាច្រើនទៀតក៏ធ្វើដូចច្នេះដែរ។ អីចឹងបានជាខិតខំរុញឱ្យវិស័យអប់រំសិក្សាធិការជាតិយើងស្ទុះឡើងលឿន។ ចំណុចនេះជាចំណុចពិសេស និងក៏មិនបាននិយាយថា ជាការរំលោភសិទ្ធិអំណាច ឬតួនាទីភារកិច្ចអ្នកនេះ អ្នកនោះដែរ។ ម្យ៉ាងកន្លែងនេះពិតហើយថាជាស្រុកកំណើតកម្សត់ កម្ររបស់ខ្ញុំដែរ អីចឹងជួយទៅក៏អត់ខុស។ខ្ញុំក៏មិនមែនអ្នកតំបន់និយម គ្រួសារនិយម ភូមិកំណើតនិយមអ្វីដែរ កន្លែងផ្សេងក៏បានជួយ ហើយជួយមុនហ្នឹង និងជួយច្រើនទៀតផង។ ដូចជាសាកលវិទ្យាល័យបាត់ដំបងខ្ញុំធ្វើមុនសាកលវិទ្យាល័យជាស៊ីមកំចាយមារស្រុកកំណើតនេះទៀត។ដោយសារតែឆន្ទៈ និងមនោសញ្ចេតនា ចង់ចូលរួម មិនមែនដោយសារតួនាទីភារកិច្ចតម្រូវត្រូវតែធ្វើនោះទេ ប៉ុន្តែជាការរួមចំណែក"

ក្រឡាហោមខេង

ខេត្តព្រៃវែង ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីប្រគល់សញ្ញាបត្រនិស្សិតសាកលវិទ្យាល័យ ***ជា ស៊ីម*** *កំចាយមារ*

២១២-ឯកឧត្តម ជាវ តាយ សុំលាលែងពីអភិបាលខេត្ត

"ពីដំបូងឡើយ ខ្ញុំបានគោរពស្នើសុំផ្ទាល់មាត់ពី **សម្តេចតេជោ** ពេលប្រជុំសភា...ការពិតទៅ ឯកឧត្តម **ជាវ តាយ** បានទូរសព្ទមកខ្ញុំសុំសម្រាកតែម្តង មិនមែនសុំច្បាប់ពីការងារទេ។ យើងក៏យល់ ដោយសារគាត់ត្រូវការពេលព្យាបាលជំងឺ។ ប៉ុន្តែខ្ញុំក៏បានរម្ងាប់អារម្មណ៍គាត់ ដោយតបទៅវិញថា សូម **ឯកឧត្តម** បន្តខិតខំព្យាបាលចុះ។ ខ្ញុំអត់និយាយអ្វីទាំងអស់ គឺឯកភាព ឬជំទាស់។ ពេលសុំយោបល់ពី **សម្តេចតេជោ** ក៏ឯកភាពថាយើងទុកស្ថានភាពហ្នឹងសិន ទុកពេលឱ្យគាត់ព្យាបាលសិន ហើយរៀបចំឱ្យមានអភិបាលខេត្តស្តីទីដើម្បីដោះស្រាយការងារ ដោយយើងសង្ឃឹមថាទីមួយ-គាត់ជាសះស្បើយឆាប់ និងទីពីរ-ជាការដោះស្រាយអារម្មណ៍គាត់ និងក្រុមគ្រួសារដែរ។ ក៏ប៉ុន្តែ កាលពីថ្ងៃទី៩ខែវិច្ឆិកា ឆ្នាំ២០២២ហ្នឹង នៅវិមានឯករាជ្យខ្ញុំក៏ពិចារណាឡើងវិញ ដោយបានលើកសំណើសុំយោបល់ **សម្តេចតេជោ** ម្តងទៀតថា បើសិនណាយើងទុកបែបនេះ ប្រហែលមានការលំបាកព្រោះនៅមូលដ្ឋាន មានកិច្ចការត្រូវធ្វើច្រើន ពិសេសការរៀបចំបោះឆ្នោត និងការសង្គ្រោះពលរដ្ឋពីជំនន់ទឹកភ្លៀង។ ប្រសិនបើមិនមានក្បាលម៉ាស៊ីនដឹកនាំជាក់លាក់ វាអាចជះឥទ្ធិពលមិនល្អ"

ក្រឡាហោមខេង

ខេត្តពោធិ៍សាត់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រកាសមុខតំណែងឯកឧត្តម **ខុយ រីដា** ជាអភិបាលខេត្តពោធិ៍សាត់ជំនួសឯកឧត្តម **ជាវ តាយ**

២១៣-មិនស្គាល់មុខ និងក៏មិនសូវលឺឈ្មោះ ប៉ុន្តែ...

"ឯកឧត្តម **ខូយ រីដា** ខ្ញុំក៏មិនដែលស្គាល់មុខ និងក៏មិនសូវលឺឈ្មោះប៉ុន្មានដែរ ប៉ុន្តែគាត់ជាមន្ត្រីឆ្លងកាត់នៅទីនេះ (ខេត្តពោធិ៍សាត់) បានចំនួន៨ឆ្នាំដែរ ក្នុងឋានៈជាអភិបាលរងខេត្ត ហើយមុននោះទៀតគាត់ជានាយករដ្ឋបាលសាលាខេត្ត។ នៅ៨ឆ្នាំ គាត់ក៏ផុតអាណត្តិជាអភិបាលរង គាត់មិនអាចបំពេញការងារនៅទីនេះទៀតបានទេ គឺលើកលែងតែបានតែងតាំងជាអភិបាលតែម្តង។ ច្បាប់យើងចែងអីចឹង...! ដូច្នេះហើយគាត់ក៏ផ្ទេរទៅជារងខេត្តប្លាត់ដំបង ដើម្បីរកកន្លែងជ្រកសិន (សើច) តែទៅហ្នឹងបានតែ៨ខែទេ។ អីចឹងបាននិយាយថាធ្វើអភិបាលរងបាន៨ឆ្នាំ ៨ខែ ក៏ធ្វើអភិបាលខេត្ត គាត់ជាអ្នកពោធិ៍សាត់នេះផ្ទាល់"

ក្រឡាហោមខេង

ខេត្តពោធិ៍សាត់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រកាសមុខតំណែងឯកឧត្តម **ខូយ រីដា** ជាអភិបាលខេត្តពោធិ៍សាត់ជំនួសឯកឧត្តម **ជាវ តាយ**

២១៤-ច្បាប់មិនតម្រូវតែយើងមានគោលការណ៍

*"មិនមែនច្បាប់តម្រូវតែជាគោលការណ៍យើងទេ យើងចង់បានអ្នកកាន់មុខតំណែង ជាមន្ត្រីនៅនឹងមូលដ្ឋានផ្ទាល់ ជាអ្នកស្គាល់មូលដ្ឋានខ្លួន និងក៏ជាអ្នកបានដុះដាលភាពជាមន្ត្រីនៅមូលដ្ឋានគាត់ ដើម្បីឱ្យកាន់មុខតំណែងនៅទីហ្នឹងល្អជាងការយកមន្ត្រីពីកន្លែងដទៃ។ **ខូយ រីដា** ជាប្អូន **ខូយ សុខា** អតីតអភិបាលខេត្តនេះដែរ សុទ្ធតែជាកូនចៅអ្នកពោធិ៍សាត់។ អាចនិយាយបានថាមានត្រកូល **ខូយ** ពីរនាក់ហើយ បានធ្វើអភិបាលខេត្តពោធិ៍សាត់ ក្រៅពីនេះយកមកពីកន្លែងផ្សេង"*

ក្រឡាហោមខេង

*ខេត្តពោធិ៍សាត់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រកាសមុខតំណែងឯកឧត្តម **ខូយ រីដា** ជាអភិបាលខេត្តពោធិ៍សាត់ជំនួសឯកឧត្តម **ជាវ តាយ***

២១៥-កុំឱ្យពួកឧក្រិដ្ឋជនកាច់សំបុកទាន់!

"មួយរយៈនេះនៅខេត្តពោធិ៍សាត់មានការណែនាំពាក់ព័ន្ធអំពើជួញដូរមនុស្ស។ ពីមុនមិនសូវមានប៉ុន្មានទេ...តែក្រោយមកបែកសម្បុកពីកំពង់សោម ក៏មកដល់វាលវែង និងមកដល់ថ្មដារ។ ខ្ញុំគ្រាន់តែបើករង្វង់ក្រចកទេថា ថ្មដារ យើងត្រូវសម្អាតពីឥឡូវ កុំទុកឱ្យវាកាច់សំបុក កាច់សំបុកប្រកបដោយអំពើខុសច្បាប់ យើងកុំឱ្យកាច់ បើកាច់ គឺពិបាកធ្វើការហើយ។ កំពង់សោមចង់កាច់សំបុកអ្នា...! ចង់អីវាកាច់ទៅហើយ ថ្ងៃណាក៏ថ្ងៃកាប់សម្លាប់គ្នា។ ខ្ញុំនិយាយហើយថា រាជរដ្ឋាភិបាលវិនិយោគសម្បើមណាស់ រាប់ពាន់លានដុល្លារ ទាំងរដ្ឋាភិបាលផង វិស័យឯកជនផង ក្នុងផង ក្រៅផង នៅកំពង់សោម តែទីបំផុតមក វាចង់ទៅជាកន្លែងឧក្រិដ្ឋកម្មទៅវិញ។ ខ្ញុំសោកស្តាយណាស់ រឿងនេះទាំងអស់គ្នាត្រូវចេះមើលឃើញអនាគតហើយមិនមែនឥណាម្នាក់ធ្វើទេ គឺយើងទាំងអស់គ្នា។ មកដល់ឥឡូវយើងគ្រប់គ្រងបានល្អវិញហើយ តែវាលជាលកន្លែងផ្សេងដែលរដ្ឋបាលនីមួយៗត្រូវប្រយ័ត្ន"

ក្រឡាហោមខេង

ខេត្តពោធិ៍សាត់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រកាសមុខតំណែងឯកឧត្តម ***ខូយ រីដា*** *ជាអភិបាលខេត្តពោធិ៍សាត់ជំនួសឯកឧត្តម* ***ជាវ តាយ***

២១៦-បើគ្មានអំពើល្មើស ម្តេចមានជនរងគ្រោះ?

“នគរបាលយើងនៅមានកម្រិតនៅឡើយ ចំពោះករណីថ្មីៗនេះ។ គាត់រាយការណ៍មកខ្ញុំថា សង្គ្រោះតាមពាក្យបណ្តឹងបានពីរនាក់ ឬបីបួននាក់ តែមួយឃ្លាទៀតគាត់ថា ចៅកែរអត់មានវាយដំច្រំធាក់ទេ មិនប៉ះពាល់ជនរងគ្រោះទេ...។ ខ្ញុំថាបើអីចឹង លោកឯងប្រើពាក្យសង្គ្រោះរបៀបម៉េច...? គ្រាន់តែពាក្យពីរម៉ាត់វាផ្ទុយគ្នាបាត់ទៅហើយ។ អីចឹងមានន័យថា ការយល់ដឹងយើងនៅខ្សោយ ខ្សោយមែនទែន អត់ដឹងច្បាប់ទម្លាប់ថាធ្វើម៉េចបើករណីអីចឹងៗ។ អ្នកខ្លះគាត់ឆ្លើយថាអត់បានប្តឹង ទាំងដែលបានប្តឹងយើងច្បាស់ក្រឡែត។ ឮទៅរកមនុស្សឃើញអីចឹងទៀត មិនប្តឹងយ៉ាងម៉េច? មន្ត្រីយើងកោតចេះតែស្តាប់ ចេះតែជឿកើត។ មួយទៀត គេថាខ្ញុំប្តឹងមែន តែចៅកែក្រុមហ៊ុនគេអត់ធ្វើបាបខ្ញុំទេ តែខ្ញុំអត់ចង់ធ្វើការកន្លែងហ្នឹង។ គេនិយាយអីចឹងមក តើយើងសន្និដ្ឋានយ៉ាងម៉េច...? គេធ្វើបាបហ្នឹងហើយបានជាចង់ចេញ... បើចង់ចេញ ក្រែងមានកិច្ចសន្យាជាមួយគ្នាតើអ្ហឺ... ម៉េចមិនចេញទៅ ចាំមកប្តឹងសមត្ថកិច្ចធ្វើស្អី...។ នែ៎...! បញ្ហាមិនប្រក្រតីវាមាន ម៉េចបានយើងមិនសិក្សា មិនឆ្ងល់ មិនដាក់សំណួរ? នាំគ្នាវិភាគមើល តើវាឡូកហ្សិកទេ?”

ក្រឡាហោមខេង

ខេត្តពោធិ៍សាត់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រកាសមុខតំណែងឯកឧត្តម **ខុយ រីដា** ជាអភិបាលខេត្តពោធិ៍សាត់ជំនួសឯកឧត្តម **ជា វ តាយ**

២១៧-តិចថាអត់យល់មួយ អត់យល់ពីរចុះ!

"ថ្ងៃមុន យើងប្រមូលមនុស្សធ្វើការខុសច្បាប់ជាន់ជិត១ពាន់នាក់។ ខ្ញុំថាចុម... ធ្វើម៉េចអ៊ីចេះ... ចុងក្រោយអត់ទេ...! យើងធ្វើតាមច្បាប់! អ្នកណាធ្វើអ្នកហ្នឹងទទួលខុសត្រូវ! អ្នកឯងធ្វើការងារក្រុមហ៊ុនណា ត្រូវក្រុមហ៊ុនហ្នឹងទទួលខុសត្រូវបាយទឹក និងការបញ្ជូនចេញ។ សំបុត្រយន្តហោះក្រុមហ៊ុនអ្នកឯងត្រូវទិញ។ ទិញហើយមិនប្រាកដថារួចខ្លួនទៀត ខ្ញុំនិយាយចំហអីចឹង ព្រោះអ្នកឯងប្រើពលកម្មខុសច្បាប់...! ខ្ញុំនិយាយចំហចង់ឱ្យដឹងខ្លួន និយាយហើយនិយាយទៀត ខ្ញុំអត់លាក់ប៉ាំងរឿងហ្នឹងទេ។ បើដឹងខ្លួនហើយកុំធ្វើទៀត បើនៅតែធ្វើទៀត គេបង្ក្រាបហើយ។ តិចថាអត់យល់មួយយល់ពីរចុះ! ចុះឱ្យធ្វើអាម៉េចអ្ហា? អ្នកគ្រប់គ្រងសង្គមអ្នកគ្រប់គ្រងប្រទេសជាតិ បើសិនយើងធ្វើអីចឹង។ សួរថាគ្រប់គ្រងរបៀបម៉េច? ខ្ញុំនិយាយឱ្យលឺហ្មង បើកំពុងមានពលករធ្វើការខុសច្បាប់ នាំគ្នារៀបចំឯកសារធ្វើឱ្យស្របច្បាប់ទៅ"

ក្រឡាហោមខេង

ខេត្តពោធិ៍សាត់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រកាសមុខតំណែងឯកឧត្តម **ខូយរីដា** ជាអភិបាលខេត្តពោធិ៍សាត់ជំនួសឯកឧត្តម **ជាវ តាយ**

២១៨-សម័យយើង ឃើញផ្សែងឡានតាមហិត

"យើងមិនពូកែដូចក្មេងៗទេ យើងអត់ចេះដឹងជាងក្មេងទេ ឬអាចនិយាយម្យ៉ាងទៀតថា ក្មេងៗវាចេះដឹងជាងចាស់ៗ។ ខ្ញុំនិយាយអីចឹងត្រូវទេ? តិចថាកូនយើងល្ងង់ជាងយើងចុះ។ កូនចៅយើងកើតមកក្នុងស្ថានភាពល្អជាងយើង យើងកើតមកមានស្អី...ឃើញតែឡាននាំគ្នា រត់ហិតផ្សែងឡានហ្នឹង។ ក្មេងៗឥឡូវកើតមកឃើញឡានពេញផ្លូវ មានផ្លូវល្បឿនលឿនទៀត មានកុំព្យូទ័រ មានអ៊ីនធើណែត ទូរសព្ទ មានប្រព័ន្ធរកឃើញគ្នាគ្រប់កន្លែង។ ចុះចំណែកខ្ញុំ ឬបងៗសក់សៗមុខវេទិកាហ្នឹងចេះទេ...? មានតិចណាស់ចេះដូចគេក្មេងៗ។ សម័យឥឡូវ ក្មេងៗគេអាចរកប្តីប្រពន្ធបានតាមទូរសព្ទ តាមអ៊ីនធើណែត(សើច)។ គ្រាន់តែខុសប៉ុណ្ណោះទេ...ចាស់ៗ មានបទពិសោធជាង ឆ្លងកាត់រឿងរ៉ាវជីវិតច្រើនជាងក្មេង"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខាវិទ្យាល័យជ្រៃ ស្រុកថ្មគោល

២១៩-កូនបង្រៀនឪពុក

"ខ្លួនខ្ញុំផ្ទាល់កាលពីក្មេង ឪពុកខ្ញុំគាត់អត់មានសាលារៀនទេ។ ចុះបើមកដល់ឥឡូវវាប់ទៅគាត់អាយុ១០០ឆ្នាំទៅហើយ។ ពីសម័យហ្នឹងមានមកពីណាស្រុកខ្ញុំហ្នឹង..? មុនសម័យឥឡូវ ១០០ឆ្នាំ ទៅរកសាលាឯណា? ពិបាកណាស់ បើចង់រកសាលារៀន។ តែគាត់លើកទឹកចិត្តឱ្យខ្ញុំទៅរៀន... ទោះបីលំបាកយ៉ាងម៉េចក៏ដោយ។ ដល់តែខ្ញុំរៀន ខ្ញុំចេះអាន ចេះសរសេរ គាត់ក៏ហៅខ្ញុំទៅបង្រៀនគាត់ ជាពិសេសយប់ៗ ឱ្យតែពេលទំនេរគាត់ហៅខ្ញុំទៅបង្រៀនគាត់។ ម្តាយខ្ញុំនៅអង្គុយក្បែរហ្នឹង។ ដល់តែបង្រៀនទៅ (សើច) ដូចថាសិស្សគំហកដាក់គ្រូ។ ដល់តែម្តាយខ្ញុំគាត់លាន់មាត់ថាយី...! ឱ្យកូនបង្រៀន ទៅជាគំហកដាក់វាតិចវាលែងហ៊ានបង្រៀន...ដល់តែអីចឹង ឪពុកខ្ញុំបាត់មាត់...។ ឪពុកខ្ញុំគាត់រៀនចេះ គាត់រៀនចេះអានចេះសរសេររបស់គាត់តែម្តង។ អីចឹងបានន័យថា គាត់ស្រែកឃ្លានការចេះដឹង ប៉ុន្តែដោយសារស្រុកទេសកាលហ្នឹងវាអីចឹង ខុសពីឥឡូវសាលារៀននៅក្បែរផ្ទះ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខាវិទ្យាល័យជ្រៃ ស្រុកថ្មគោល

២២០-ធនធានមនុស្សគឺជាទ្រព្យសម្បត្តិគន្លឹះ

"ធនធានមនុស្ស គឺជាទ្រព្យសម្បត្តិគន្លឹះ ដែលបង្កើតផលិតផល ភោគផល ស្នាដៃ និងសមិទ្ធផលរាប់មិនអស់...។ អ៊ីចឹង នេះជាឱកាសល្អ ក្នុងពេលស្រុកទេសមានសុខសន្តិភាព និងមានស្ថិរភាព យើងត្រូវតែឆក់ឱកាសនេះប្រើឱ្យអស់លទ្ធភាព ដើម្បីអប់រំបណ្តុះបណ្តាល ចំណេះដឹងដល់កូន ដល់ចៅយើង។ ចៀសវាងទស្សនៈថាអញឆ្លងកាត់សម័យលំបាកវេទនាច្រើនឆ្នាំមកហើយ ដូច្នេះសម័យនេះមិនបាច់ធ្វើអ្វីទេ... មិនបាច់ខ្វល់អ្វីទេ..អាហ្នឹងអត់បានទេ កុំយល់អ៊ីចឹងអើ។ ត្រូវយកពេលវេលាល្អនេះខិតខំជួយអប់រំកូនចៅយើង ធ្វើម៉េចឱ្យកូនចៅយើងបានរៀនសូត្រ ព្រោះសាលារៀនមានគ្រប់កន្លែង ហើយត្រូវជំរុញការរក្សាស្ថានភាពល្អនេះដើម្បីអភិវឌ្ឍជាតិសម្រាប់កូនយើងតទៅជំនាន់ក្រោយៗទៀត"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ពិធីសម្ពោធអគារសិក្ខាវិទ្យាល័យជ្រៃ ស្រុកថ្មគោល

២២១-ចាប់បានតែគ្រឿងញៀន មិនទាន់ជោគជ័យទេ

"ពីមុនៗលម្ងៃ នៅខេត្តព្រះសីហនុ មានករណីគ្រឿងញៀនមួយដ៏ធំដែលសមត្ថកិច្ចយើងបង្ក្រាបបាន គឺរហូតដល់ទៅ៨០០គីឡូក្រាម ដែលជាសារធាតុញៀនប្រភេទកេតាមីន។ សមត្ថកិច្ចកំពុងធ្វើការងារនេះយ៉ាងម៉ឺងម៉ាត់។ ដូច្នេះ បើសិនយើងគ្រាន់តែប្រមូលគ្រឿងញៀន តែមិនបានចាប់ឧក្រិដ្ឋជនជាមេក្លោង ឬអ្នកជួញដូរមកផ្តន្ទាទោសទេ វាហាក់ដូចថា បេសកកម្មយើងមិនទាន់ចប់ ហើយមិនជោគជ័យ។ ពីព្រោះហៅថាជោគជ័យបានទាល់តែគ្រឿងញៀនរឹបអូស និងជនល្មើសត្រូវចាប់នាំខ្លួនយកមកផ្តន្ទាទោសតាមច្បាប់។ យើងត្រូវបន្តពន្លាតការស្រាវជ្រាវរកជនល្មើស រួមទាំងបទល្មើសសម្អាតប្រាក់ជាដើម"

ក្រឡាហោមខេង

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ពិធីអបអរទិវាប្រឆាំងការជួញដូរមនុស្ស

២២២-សូម្បីអាល្លឺម៉ង់នៅមានអ្នកប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល

“យើងទើបតែបញ្ចប់សង្គ្រាម និងនាំមកនូវសន្តិភាពបាន ២០ឆ្នាំងជាងទេ។ ថ្មីៗនេះ មានរឿងមួយដ៏គួរឱ្យភ្ញាក់ផ្អើល នៅសហព័ន្ធអាល្លឺម៉ង់មានគណបក្សមួយជារបស់អតីតមេដឹកនាំហ៊ីត្លែ ហើយក៏មានក្រុមមួយ ចង់ប៉ុនប៉ងធ្វើរដ្ឋប្រហារ។ តាមព័ត៌មានទទួលបាន ក្នុងចំណោមរដ្ឋសហព័ន្ធអាល្លឺម៉ង់ទាំង១៦ គោលដៅ ដែលគេប៉ុនប៉ងធ្វើរដ្ឋប្រហារមាន១១រដ្ឋ ហើយគេមានកម្លាំងប្រមាណជាង២ម៉ឺននាក់ ដែលគាំទ្រសកម្មភាព។ នេះជារឿងដ៏ចម្លែក ជាព្រឹត្តិការណ៍មួយដែលយើងគិតថា មិនងាយនឹងកើតឡើងអីចឹងបានទេ ប៉ុន្តែវាកើត! រដ្ឋាភិបាលអាល្លឺម៉ងបានចាត់វិធានការ និងដោះស្រាយ ហើយចាប់អ្នកទទួលខុសត្រូវបានទាំងអតីតសមាជិកសភាអាល្លឺម៉ងទៀត។ គេចង់ប្តូរសង្គមអាល្លឺម៉ងឱ្យទៅជាសតវត្សឆ្នាំ១៨០០។ ចំណុចនេះ ខ្ញុំចង់បញ្ជាក់ថាយើងមិនត្រូវមើលស្រាល មិនថាប្រទេសណាទេ មិនត្រូវមើលស្រាលឡើយ។ ដូច្នេះ បានជាយើងត្រូវតែពង្រឹង និងការពារសុខសន្តិភាព កុំឱ្យមានសង្គ្រាម និងកម្លាំងប្រដាប់អាវុធប្រឆាំងរាជរដ្ឋាភិបាល”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវិទ្យាល័យបរវេល ស្រុកបរវេល

២២៣-លួចមាន់ លួចឆ្កែ អនុវត្តទោសសហគមន៍

"ខ្ញុំបានគិតជាមួយឯកឧត្តម **សក់ សេដ្ឋា** និងឯកឧត្តម **ប៊ុន ហុន** ព្រោះច្បាប់យើងមានចែងអំពីទោសសហគមន៍។ ស្អីទៅហៅថាទោសសហគមន៍..? ពន្ធនាគារសព្វថ្ងៃជាមធ្យមមានជនល្មើសជាប់ឃុំជាង៣ម៉ឺននាក់ហើយ...។ ទោសសហគមន៍ ចង់និយាយថាបើទោសល្មមៗ ទោសមធ្យម កម្រិតតូចៗ ស្រាលៗ អត់ចាំបាច់ដាក់ក្នុងពន្ធនាគារទេ។ ដាក់គាត់តាមមូលដ្ឋានភូមិឃុំដោយមានលក្ខខណ្ឌគ្រប់គ្រងត្រឹមត្រូវ។ ស្រុកគេ ក៍គេបានធ្វើច្រើនដែរហើយ។ ច្បាប់យើងមាន។ អីចឹងយើងត្រូវអនុវត្តហើយធ្វើឱ្យបានត្រឹមត្រូវ សុំឱ្យមានការគាំទ្រពីពលរដ្ឋ និងរដ្ឋបាលនៅកន្លែង។ អ្នកអនុវត្តទោសសហគន៍ មានកាតព្វកិច្ចត្រូវបំពេញ មិនមែនឱ្យមកដេកស៊ីនៅផ្ទះទេ។ ខ្មែរយើងមានទស្សនៈខុសដែរ ឱ្យតែចោរ ឬឱ្យតែគ្នាខុស ដឹងតែពីនាំគ្នាទៅវាយដំហើយ។ អាហ្នឹងគេហៅកាត់សេចក្តីក្រៅប្រព័ន្ធតុលាការ អាហ្នឹងខុសហើយ។ ចុះបើគ្នាខុសទៅហើយ... និយាយទៅមិនមែនថាកាន់ជើងទេ តែបើយើងទៅវាយដំច្រំធាក់គេ យើងក៍ខុសដែរ។ អីចឹង ទោសសហគន៍ យើងអនុវត្តលើអ្នកលួចមាន់ លួចឆ្កែ...។ បើកែខ្លួនល្អ បើមិនកែទេគុណអ្នកឯងថែម"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវិទ្យាល័យបរវេល ស្រុកបរវេល

២២៤-ដេញដើងមន្ត្រីឱ្ងិល យកតែរូចខ្លួន

"នៅសាលាឃុំ សង្កាត់ អ្នកធ្វើការពេញម៉ោងជាងគេគឺមេឃុំ ចៅសង្កាត់ និងស្មៀន។ ទោះជំទប់ទី១ ទី២ ក៏មិនសូវដែរ។ ប៉ុន្តែរដ្ឋបើកប្រាក់ខែឱ្យពេញៗ តិចឬច្រើនតាមតួនាទី ឬយ៉ាងហោចណាស់ក៏៧០ទៅ៨០ម៉ឺនរៀលដែរ។ ធម្មតាទេ... គាត់ក៏ជាប់ឆ្នោតដែរ តែខ្ញុំចង់និយាយថាបើស្រុកគេមួយចំនួន ទោះសមាជិកសភាក៏ដោយ ប្រាក់ខែគេឱ្យតែពេលប្រជុំទេ បើអត់មកប្រជុំ គឺអត់បាន ហើយប្រជុំច្រើនដង បានច្រើនដែរ។ គេកំណត់ប្រាក់គោល ឧទាហរណ៍២០ម៉ឺន ឬ៥០ម៉ឺនរៀល។ ខ្ញុំនិយាយនេះ មិនមែនយើងនឹងធ្វើអីចឹងទេ តែទៅមុខក្រែងអាចធ្វើបាន។ បើប្រជុំយកតែរូចខ្លួន អាណត្តិក្រោយបែបមិនបានឈរឈ្មោះឬឈរដែរ តែគេមិនបោះឆ្នោតឱ្យ។ ចង់និយាយថាកុំបានតែជាប់ឆ្នោតហើយ បើកប្រាក់ខែស្រួលៗនោះ ចូលប្រជុំផ្តល់មតិយោបល់ ដោះស្រាយបញ្ហានៅមូលដ្ឋានឱ្យសកម្ម"

ក្រឡាហោមខេង

ខេត្តប៉ាត់ដំបង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវិទ្យាល័យបរវេល ស្រុកបរវេល

២២៥-វប្បធម៌បែងចែកក្រុមការងារចុះមូលដ្ឋាន

"មែនទែនទៅ ក្រុមការងារចុះមូលដ្ឋាននេះ យើងមានវប្បធម៌ការងាររបៀបនេះយូរហើយ។ គណបក្សយើង មានវប្បធម៌មួយនេះតាំងពីក្រោយឆ្នាំ១៩៧៩មកម្ល៉េះ ដោយពេលហ្នឹងយើងមានក្រុមប្រតិបត្តិការចុះមូលដ្ឋាន ចុះជំរុញពលរដ្ឋបង្កបង្កើនផល វាយខ្ទាំង និងការងារប៉ុន្មានចំណុចទៀត...។ ក្រោយមក យើងក៏ផ្អាកមួយរយៈ រហូតក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ខ្ញុំក៏ស្នើសុំបែងចែកថ្នាក់ដឹកនាំ និងមន្ត្រីបង្កើតជាក្រុមការងារគណបក្ស រហូតឈានទៅបង្កើតបានក្រុមការងាររាជរដ្ឋាភិបាល។ ក្រុមការងារនេះជួយឱ្យមូលដ្ឋានយើងទទួលផលប្រយោជន៍ច្រើនណាស់...។ មើលតែសាលាបវេលយើងនេះទៅ ភាគច្រើនសាងសង់ដោយសប្បុរសជនជាក្រុមការងារនេះឯង"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវិទ្យាល័យបរវេល ស្រុកបរវេល

២២៦-សាលាពុកផុយ ឬគំនិតពុកផុយ?

*"ខ្ញុំធ្លាប់មកសាលានេះជាមួយឯកឧត្តម **ណាំ ទុំ** ព្រោះគាត់ជួយសាលានេះជាមួយខ្ញុំ...។ បើរំលឹកទៅ ក៏មិនចង់និយាយដែរ នាយកសាលា និងលោកគ្រូ អ្នកគ្រូ គាត់ប្រាន់សុំឱ្យខ្ញុំឆៀងមើលសាលានេះ គាត់ថាសាលាទ្រុឌទ្រោមរអ៊ូរអស់ហើយ **សម្តេច**! ពុកផុយរអស់ហើយ។ ខ្ញុំក៏ទៅមើលតាមគាត់សុំ។ ដល់តែមើលទៅឃើញថាសាលាវាមិនងាយពុកផុយទេ តែសូមទោស គឺមនុស្សហ្នឹងពុកផុយតែម្តង។ បន្ទប់ទឹកបន្ទប់អី គឺថាជ្រាបទឹកពេញហ្នឹង គាត់រអ៊ូរចេះថៃទាំតែម្តង ខ្ញុំសូមទោស...។ ទេ... មិនមែនស្តីឱ្យទេ ចង់និយាយគ្នាឱ្យច្បាស់ថា សូមចេះជួយថៃទាំផង។ ព្រោះរដ្ឋនិងក្រុមការងារ លំបាកណាស់ទម្រាំក្បៀតក្បរកថវិកាមកជួយបាន"*

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធសមិទ្ធផលនានានៅវិទ្យាល័យបរវេល ស្រុកបរវេល

២២៧-ប្រវត្តិទីតាំងសង់វិមានឯករាជ្យបាត់ដំបង

*"ការពិតទៅ ពីដំបូងឡើយ យើងមិនចង់សាងសង់នៅកន្លែងហ្នឹងទេ ប៉ុន្តែវាអត់ជម្រើស មិនដឹងថាកន្លែងណាឱ្យសមស្របជាងហ្នឹង។ ពេលសិក្សាដំបូងទៅនេះក៏មានបញ្ហាប្រឈមដោយសារនៅក្រោមវាមានប្រព័ន្ធរំដោះទឹក សាងសង់ដោយមិត្តជប៉ុន (JICA)...។ ដូច្នេះ ត្រូវសិក្សាបញ្ចៀសបញ្ហា។ យើងសិក្សារកឃើញទីតាំងនៅនេះតែម្តង។ អីចឹងគ្មានកន្លែងណាល្អជាងហ្នឹងទេ។ បើមាន ផ្លូវវៀងក្រុងទី១ ត្រង់ពេទ្យយោធាភូមិភាគ។ បើដាក់នៅអន្លង់វិលក៏មិនត្រូវ! អូតាគីក៏មិនត្រូវ ប៉ុន្តែល្អជាងគេម្តុំណា? គឺ **លោកតាដំបងគ្រញូង** (សើច)...។ បើដាក់ហ្នឹងមានតែលើកលោកតាដំបងគ្រញូងចេញ។ ឱ្យលើកទៅណា...? ពលរដ្ឋគាត់ម្តេចនឹងព្រម ទៅមិនរួចទេ។ អីចឹងបានជ្រើសរើសយកកន្លែងនេះ។ ខ្ញុំក៏អរគុណណាស់បងប្អូនពលរដ្ឋ ដែលបានសហការក្នុងការរៀបចំកន្លែងសង់វិមានឯករាជ្យយើងនេះ"*

ក្រឡាហោមខេង

*ខេត្តបាត់ដំបង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ ពិធីបញ្ចុះបឋមសិលាសាងសង់វិមានឯករាជ្យ សួនច្បារ **សម្តេចក្រឡាហោម** និងផ្សារយប់*

២២៨-ដណ្តើមអំណាចតាមចុងបិច កុំចុងកាំភ្លើង!

"យើងបានរៀបចំបោះឆ្នោត ស្របតាមរដ្ឋធម្មនុញ្ញរបស់យើងនេះ គឺដើម្បីជំនួសឱ្យការឡើងកាន់អំណាច តាមរយៈចុងកាំភ្លើង។ កាលពីសម័យធ្វើសង្គ្រាម ប្តីសី ឬកូនចៅយើងនឹងទៅធ្វើទាហាន ឬទៅធ្វើកងទ័ព ដើម្បីច្បាំងដណ្តើមអំណាច។ ប៉ុន្តែសម័យរបបប្រជាធិបតេយ្យ សេរីពហុបក្សយើងសព្វថ្ងៃ គឺប្រជាពលរដ្ឋម្នាក់ ប្រៀបដូចយុទ្ធជនម្នាក់ដែរ មិនមែនយុទ្ធជនកាន់កាំភ្លើងទេ គឺយុទ្ធជនកាន់បិកគូសសន្លឹកឆ្នោតឱ្យគណបក្សណាដែលគាត់ស្រលាញ់។ នេះជាការប្រយុទ្ធដ៏ត្រឹមត្រូវ យើងបានអនុវត្តរបៀបនេះជាង២០ឆ្នាំមក យើងសុខរហូត"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ពិធីបញ្ចុះបឋមសិលាសាងសង់វិមានឯករាជ្យ សួនច្បារ ***សម្តេចក្រឡាហោម*** *និងផ្សារពេលរាត្រី*

២២៩-បើមិនប្រយ័ត្ន យើងអាចលិចលង់

“ឆ្នាំ២០១៩លោក **សម រង្ស៊ី** ប្រកាសចូលមកស្រុកវិញតាមច្រកថៃ។ ខ្ញុំសុំយោបល់ **សម្តេចតេជោ** បង្កើតក្រុមមួយ សហការជាមួយរដ្ឋបាលខេត្តពាក់ព័ន្ធ ជាពិសេសរដ្ឋបាលខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។ **សម រង្ស៊ី** ប្រកាសចូលស្រុកមែន តែប្រកាសឱ្យត្រៀមកងទ័ព មានរៀបចំថវិកា រៀបចំចញ្ចឹមកងទ័ព។ ប្រកាសអីចឹង ប្រែមកដូចជាធ្វើសង្គ្រាមដូច្នេះដែរ នែ៎...មិនមែនមកធម្មតាទេណា! អ្នកគាំទ្រគាត់ម្នាក់ (កញ្ញា សេង ធារី) ត្រូវឃុំខ្លួននៅព្រះវិហារ ដោយសារតែគាំទ្រចលនាហ្នឹង។ ចលនាបែបហ្នឹងយើងមិនគាំទ្រជាដាច់ខាត ពីព្រោះវាជាការបំផុសកងកម្លាំងប្រឆាំងរដ្ឋាភិបាល ផ្ដួលរំលំរដ្ឋាភិបាល មើលស្រាលវាអត់បានទេ។ សូម្បីតែអាល្លឺម៉ង់ ដែលជាសង្គមទំនើប និងស៊ីវិលល័យមួយនៅអឺរ៉ុប ក៏ស្រាប់តែមានចលនាប៉ុនប៉ងធ្វើរដ្ឋប្រហារ។ ឥឡូវគេចាប់ខ្លួនអស់ហើយ...។ សូមកុំមើលស្រាល ទោះបីជាស្រុកទេសរីកចម្រើនយ៉ាងណាក៏ដោយ អារលកបែបនេះនៅតែមាន បើមិនប្រយ័ត្នទេ យើងអាចលិចលង់មិនខាន”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ពិធីបញ្ចុះបឋមសិលាសាងសង់វិមានឯករាជ្យ សួនច្បារ **សម្តេចក្រឡាហោម** និងផ្សារ៣ត្រី

២៣០-ផ្តាំក្រុងបាត់ដំបង

"អ្នកក្រុងបាត់ដំបង សូមបន្តគាំទ្រ និងចូលរួមការពារមេដាយទីក្រុងបៃតងឱ្យខាងតែបាន ពីព្រោះម្យ៉ាងដើម្បីសុខភាពយើង គឺមុនគេបង្អស់សុខភាពយើងហ្នឹងហើយ។ កាលណាមានដើមឈើច្រើន បរិស្ថានល្អហើយ វាជួយទប់កំដៅ ស្រូបយកជាតិពុល...។ យើងគួរតែជំរុញការដាំដើមឈើបន្ថែម កុំទាន់ថាប៉ុណ្ណឹងល្មម...។ ស្រុកយើងស្រួលដាំណាស់ ត្រឹមតែដាំយកម្លប់ យកបៃតងមិនលំបាកទេ ដីយើងល្អ។ ម្យ៉ាងទៀតទីក្រុង បើកាលណាសំរាមពេញទឹកពេញដី វាលែងជាទីក្រុងទៀតហើយ។ គេមើលមក គេចាត់ទុកថាមនុស្សនៅទីក្រុងហ្នឹង ឬថារដ្ឋបាលនិងប្រជាពលរដ្ឋក្រុងហ្នឹងចោលម្បៀតតែម្តង។ សូមទោសចុះ ខ្ញុំនិយាយរាក្រក់ស្តាប់បន្តិចមែន... តែឱ្យក្រុងឃើញតែសំរាម ឬយ៉ាងម៉េច...? អរិចឹងហើយបានជារាជរដ្ឋាភិបាលខិតខំផ្ទេរសិទ្ធិអំណាច និងធនធាន ដើម្បីចាត់ចែងការគ្រប់គ្រងសំរាមនេះមកឱ្យក្រុង ស្រុក ខណ្ឌ។ អរិចឹងទេ នាំគ្នាគិតគូរទៅ បើមិនអរិចឹង គឺទាំងគេ ទាំងខ្ញុំ មកលេងឃើញតែសំរាម គ្មានអារម្មណ៍ចង់មកទៀតទេ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ ពិធីបញ្ចុះបឋមសិលាសាងសង់វិមានឯករាជ្យ សួនច្បារ ***សម្តេចក្រឡាហោម*** *និងផ្សារយប់*

២៣១-ទ្រព្យសម្បត្តិដូនតា

"ស្រុកខ្មែរយើង ជាស្រុកអំណោយផលណាស់។ មិនថាអស្ចារ្យជាងប្រទេសណាទេ ក៏ប៉ុន្តែបើធៀបប្រទេសផ្សេងទៀត គេនៅអន់ គេនៅយ៉ាប់ជាងយើង។ ប្រទេសខ្លះគ្មានធនធានអ្វីទេ បើមានក៏មានតែខ្សាច់ ឬមានតែថ្មភ្នំ...។ តែយើងវិញ មានទាំងអស់ សមុទ្រក៏យើងមាន ទន្លេបឹងបួរក៏មាន ព្រៃឈើក៏មានធនធានធម្មជាតិក្រោមដីក៏មាន។ ទោះមិនហូរហៀរ តែហោចណាស់រ៉ែមាស និងប្រេងកាត...។ នេះជាទ្រព្យដូនតាយើងទុកឱ្យយើងហើយ ដូច្នេះខិតខំប្រើប្រាស់ថែរក្សាវាឱ្យមានប្រយោជន៍"

ក្រឡាហោមខេង

*ខេត្តបាត់ដំបង ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ពិធីបញ្ចុះបឋមសិលាសាងសង់វិមានឯករាជ្យ សួនច្បារ **សម្តេចក្រឡាហោម** និងផ្សារ*រាត្រី

២៣២-សង្គមមួយដែលល្អទៅបាន

“សង្គមល្អ ជាសង្គមមានអ្នកចេះយកអាសារគ្នា ពិសេសក្នុងគ្រាក្រ គ្រាលំបាក ពោលគឺសង្គមដែលមានសមាជិកមិនគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន រកសេចក្តីផ្នូរសម្រាប់តែខ្លួនឯង អាត្មានិយម ដោយបោះបង់ចោលអ្នកដទៃនៅជុំវិញខ្លួនឱ្យឋិតក្នុងភាពខ្វះខាត ភិតភ័យ ឬបាត់បង់សេចក្តីសុខ។ វាក៏មានន័យដែរថាសង្គមល្អ ជាសង្គមដែលមានសមាជិកខិតខំប្រឹងប្រែងរកសេចក្តីសុខសម្រាប់ខ្លួនផង និងសម្រាប់អ្នកដទៃដែលរស់នៅជុំវិញខ្លួន។ បើពុំដូច្នេះទេ សេចក្តីសុខខ្លួន ក៏មិនឋិតថេរបានយូរអង្វែងដែរ។ មនុស្សម្នាក់ៗ មិនអាចចៀសផុតពីការខាតបង់ឡើយ ប្រសិនបើមិនបានប្រាស្រ័យ និងរួមរស់ក្នុងទំនាក់ទំនងល្អជាមួយគ្នាទៅវិញទៅមកក្នុងសង្គម។ ម្នាក់ៗសុទ្ធតែមានតួនាទីការពារសច្ចធម៌ ការពារសេចក្តីសុខ និងអំពើល្អក្នុងសហគមន៍។ ដូច្នេះ មនុស្សម្នាក់ៗត្រូវប្រឆាំងតទល់ លុបបំបាត់អំពើអាក្រក់ពីក្នុងសង្គម”

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធវិហារឥស្លាម នូរុលមុតតាគីន ក្នុងស្រុកពញាឮ

២៣៣-មន្ត្រីខ្មែរឥស្លាម

"នៅពេលយើងធ្វើវិសោធនកម្មច្បាប់ដើម្បីបន្ថែមចំនួនគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ **សម្តេចប្រមុខរាជរដ្ឋាភិបាល** ខ្លួនខ្ញុំ និងឯកឧត្តម **អូស្មាន់ ហាសាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ក៏ជជែកពិភាក្សាគ្នា ដើម្បីដាក់មន្ត្រីខ្មែរឥស្លាមយើងមានសមត្ថភាព ឱ្យកាន់មុខតំណែងទាំងនេះ។ ឥឡូវ យើងដាក់បាន១២រាជធានី ខេត្ត ហើយក្រុងស្រុក ខណ្ឌក៏បានដូចជា៥០នាក់ដែរ។ យើងនឹងខិតខំតទៅទៀត ហើយក៏ត្រូវគិតគុណភាពដែរ។ ត្រូវមើលលក្ខណសម្បត្តិ និងសមត្ថភាពធ្វើការងារ។ យើងនឹងប្រឹងប្រែងទៀតរួមទាំងដាក់នៅក្រសួងស្ថាប័ននានា។ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏មានខ្មែរឥស្លាមយើងដែរ គឺឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ឹម យ៉ាន** ជាអគ្គស្នងការរងទទួលបន្ទុកកិច្ចការចរាចរណ៍"

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២ ពិធីសម្ពោធវិហារឥស្លាម នូរុលមុតតាគីន ក្នុងស្រុកពញាឮ

២៣៤-ធ្វើជាប្រចាំនិងគ្មានទីបញ្ចប់

“កងកម្លាំងយើង ការបណ្តុះបណ្តាល និងហ្វឹកហាត់ត្រូវតែបានឆ្លងកាត់ ធ្វើជាប្រចាំ និងគ្មានទីបញ្ចប់។ ព្រោះស្ថានការណ៍សង្គម និងបទល្មើសមានការវិវត្តគ្មានទីបញ្ចប់ និងស្មុគស្មាញណាស់។ បើយើងតាមមិនទាន់ទេ វានឹងធ្វើឱ្យប៉ះពាល់សន្តិសុខមិនមែនសន្តិសុខធម្មតាៗទេ គឺសន្តិសុខជាតិក៏ថាបានដែរ។ ឧទាហរណ៍ ការចូលលួចឯកសារសម្ងាត់ជាតិ តាមប្រព័ន្ធអ៊ីនធើណែត ឬបទល្មើសឧក្រិដ្ឋកម្មផ្សេងៗទៀត ក្នុងនោះ ក៏មានបទល្មើសគ្រឿងញៀន ជួញដូរមនុស្ស និងអំពើលាងលុយជាដើម។ គេទាក់ទងគ្នាតាមអេឡិកត្រូនិក តាមអនឡាញ។ ចុះបើយើងអត់មានសមត្ថភាព អត់មានជំនាញអេឡិកត្រូនិក ឬអនឡាញ តើដោះស្រាយយ៉ាងម៉េច...អាហ្នឹងវាប៉ះពាល់ហើយ។ ដូច្នេះទេ ការបណ្តុះបណ្តាលហ្វឹកហាត់គ្មានទីបញ្ចប់នេះ មានគោលដៅកសាងសមត្ថភាពនគរបាលគ្រប់រូបឱ្យមានចំណេះដឹងគ្រប់គ្រាន់ក្នុងការបំពេញតួនាទី និងភារកិច្ច ជាពិសេសគឺដើម្បីទទួលបានជោគជ័យគ្រប់កាល:ទេស:។ នេះជាគោលការណ៍រួមមួយ”

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាលកម្រិត១ កម្រិត២ ជំនាន់ទី២ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

២៣៥-វិជ្ជាជីវៈ និងយុត្តិធម៌

"ការរៀបចំរនាសម្ព័ន្ធផ្នែកនគរបាលក្នុងសាកលលោកយើងនេះ វាមិនដូចគ្នាទាំងអស់ទេ។ ប្រទេសនេះក៏រៀបយ៉ាងនេះ ប្រទេសនោះរៀបយ៉ាងនោះអីចឹងទៅ។ ប៉ុន្តែមានចំណុចមួយ ខ្ញុំគិតថាមិនខុសគ្នា គឺការអប់រំបណ្តុះបណ្តាល ឱ្យមានវិជ្ជាជីវៈ ធ្វើប្រតិបត្តិការ ឬបំពេញការងារតាមវិជ្ជាជីវៈ...។ ត្រង់ថាគុណធម៌ សីលធម៌ ឬវិន័យ វាអាចខុសគ្នាខ្លះ។ ធំបំផុតបំពេញការងារដោយវិជ្ជាជីវៈ ហើយស្មោះត្រង់នឹងវិជ្ជាជីវៈ មានន័យថា កាលណាយើងឃើញយ៉ាងម៉េច គឺថាអីចឹង! ឯកសារ ឬភស្តុតាង មិនអាចកែតម្រូវ មិនអាចភូតភរ ដើម្បីប្រគេចបញ្ហានេះ ឬប្រគេចបញ្ហានោះ មិនអាចសទៅជាខ្មៅ រួចហើយក៏បំបិទបញ្ហានៅកន្លែងហ្នឹងដែលទីបំផុតថ្ងៃក្រោយនឹងទៅជាបញ្ហា ឬបើបងប្អូនអញ្ជើញកាសុីគ្រឿងញៀន អញជួយបិទបាំង តែបើអ្នកដទៃមានបញ្ហាតិចតួចសោះ ក៏ពង្រីកឱ្យធំ ឬស្អប់ខ្ពើមផង ក៏នាំគ្នាពង្រីកបញ្ហាយកគ្នាទៅដាក់គុក"

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត១ កម្រិត២ ជំនាន់ទី២ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

២៣៦-ការប្រើកម្លាំងឱ្យចំជំនាញ

"អង្គភាពប្រើប្រាស់កងកម្លាំង ទោះបីជាថ្នាក់ជាតិក្តី ថ្នាក់ក្រោមជាតិក្តី យើងខិតខំប្រគល់តួនាទី និងភារកិច្ចឱ្យស្របតាមចំណេះដឹង និងទៅតាមមុខជំនាញ។ យើងមិនអាចគ្នាចេះធ្វើការងារនេះ ឱ្យគ្នាធ្វើការងារនោះបានទេ...។ បើទទួលខុសត្រូវក្នុងកម្រិតនយោបាយ វាអត់អីទេ ប៉ុន្តែបើទទួលខុសត្រូវកម្រិតជំនាញវាទៅអត់រួច។ ចុះឱ្យគ្នាទៅរៀនធ្វើស្អី បើគ្នាខំទៅរៀនព្រហ្មទណ្ឌ តែឱ្យគ្នាទៅធ្វើការងារសណ្តាប់ធ្នាប់...? ដូច្នេះហើយអង្គភាពប្រើប្រាស់កម្លាំង ត្រូវតែខិតខំប្រើប្រាស់មន្ត្រីជំនាញឱ្យបានសមស្រប។ សូមកុំឱ្យដូចអង្គភាពខ្លះ បញ្ជូនអ្នកមករៀនដដែលៗ ហើយតាំងនិយាយថាមន្ត្រីហ្នឹងប្រើមិនសូវបានទេ ឱ្យវាទៅរៀនទៅ ឬក៏ឱ្យប្រជុំជាប់ហ្មង"

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត១ កម្រិត២ ជំនាន់ទី២ នៅបណ្តិត្យសភានគរបាលកម្ពុជា

២៣៧-ប្រពន្ធ និងតំណែងចៅហ្វាយស្រុក យកមួយណា?

"មានចៅហ្វាយស្រុកមួយ ល្អនោះល្អ និយាយទៅបែបវាលីហើយ បែបបើកមើល បើកស្តាប់ហើយតាមមើល...។ ចង់និយាយថាគាត់ល្អទេ ក៏ប៉ុន្តែប្រពន្ធគាត់អ្នករកស៊ីជួញដូរត្រឹមត្រូវចិញ្ចឹមគ្រួសារ គ្រាន់តែគាត់ មិនព្រមមកតាមប្តី ពេលគ្នាមកធ្វើចៅហ្វាយស្រុក។ មិនមក តែគាត់ដាក់លក្ខខណ្ឌតែម្តងថា បើបងឯងមិនមកទេ យើងលែងគ្នា...ប្តីគ្នាស្តាយប្រពន្ធគ្នាដែរ មានទាំងកូនផង។ អីចឹង ឲ្យបង់ការងារជាចៅហ្វាយស្រុកចោលតែម្តង ដើម្បីមកតាមប្រពន្ធកូន។ ស្តាយ គ្នាធ្វើការល្អសឹងអី។ អីចឹងហើយបានថាមន្ត្រីយើងនៅក្រោមៗកុំយកពីឆ្ងាយ លើកលែងតែមេកើយខ្លះចាំបាច់ ឬត្រូវការជំនាញ សមត្ថភាព និងបទពិសោធ តែបើយើងគ្រប់គ្រាន់ហើយ យកកូនចៅអ្នកនៅមូលដ្ឋានហ្នឹងតែម្តង"

ក្រឡាហោមខេង

ខេត្តកណ្តាល ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត១ កម្រិត២ ជំនាន់ទី២ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

២៣៨-ស្នើទូតអាមេរិកប្រាប់ សម រង្ស៊ី ដកផែនការ

"ក្រោយការបោះឆ្នោតឆ្នាំ២០១៣ ខ្ញុំបានទទួលព័ត៌មានថា **សម រង្ស៊ី** គាត់គ្រោងបន្តហៃប្រាតុកម្ម ដោយមានទាំងធ្វើទីងមោងរូប **សម្តេចនាយក** ហើយដុតដង្កៃតែម្តង...។ ខ្ញុំទទួលព័ត៌មានច្បាស់ ក៏ហៅឯកអគ្គរដ្ឋទូតអាមេរិកមកជួបគ្នានៅក្រសួងមហាផ្ទៃ។ ខ្ញុំបានប្រាប់គាត់ថា ឯកឧត្តម ធ្វើអីចឹងៗបើនៅអាមេរិកប្រហែលមិនអីទេ ក៏ប៉ុន្តែបើហ៊ានតែធ្វើអីចឹងនៅភ្នំពេញ ដឹងតែឆេះឥឡូវហ្នឹង... ដូច្នេះទេ សូមឯកឧត្តម ប្រាប់ទៅ **សម រង្ស៊ី** ឱ្យដកផែនការហ្នឹងចេញជាបន្ទាន់! គេក៏ដកទៅ..."

ក្រឡាហោមខេង

ក្រសួងមហាផ្ទៃ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (គ.ស.ច.គ.)

២៣៩- ជាខ្មែរដែរទេ ម្តេចនិយាយមិនចេះគិត!

“កន្លងទៅថ្មីៗនេះ ខ្ញុំធ្លាប់បាននិយាយពីការធ្វើតេស្តរកគ្រឿងញៀនជាកាតព្វកិច្ច។ មានអ្នកវិភាគគេមកថា ប្រហែលជាស្រុកខ្មែរគ្រប់គ្រងគ្រឿងញៀនលែងបានហើយមើលទៅ។ អ្នកវិភាគនោះ ខ្ញុំថាជាខ្មែរយើងដែរទេ អីចឹងហើយគ្រប់គ្រងបាន ឬមិនបានគួរតែដឹងហើយ។ យើងក៏បានដឹងទាំងអស់គ្នាហើយតើ ហើយការចាត់វិធានការបង្ការរាគ្រាន់ជាងព្យាបាល។ ស្ថានភាពវាមិនទាន់ធ្ងន់ធ្ងរទេ តែបើយើងមិនចាត់វិធានការទេ វានឹងនាំឱ្យស្ថានភាពប្រឈមនឹងធ្ងន់ធ្ងរ ហើយវាប៉ះពាល់សុខភាពពលរដ្ឋ ប៉ះពាល់ធនធានមនុស្ស និងធនធានថវិកាជាតិ”

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ពិធីអបអរសាទរបុណ្យណូអែល និងឆ្លងឆ្នាំសាកល នៅស្រុកសង្កែ

២៤០-បើមិនប្រើវិធីបោះឆ្នោត ខ្មែរនឹងរវល់តែច្បាំងគ្នា

"ខ្ញុំជឿថាប្រជាពលរដ្ឋកម្ពុជាភាគច្រើនលើសលុប ពួកគាត់នឹងបន្តនាំគ្នាអញ្ជើញទៅបោះឆ្នោតតំណាងរាស្ត្រ២០២៣ ដើម្បីជំនួសឱ្យការកាន់អាវុធ ច្បាំងគ្នាឡើងកាន់អំណាច ឬធ្វើសង្គ្រាមកាប់សម្លាប់គ្នា បង្ហូរឈាមគ្នាដើម្បីបានកាន់អំណាច។ អតីតកាលយើងមានគំរូហើយ មានម្នាងច្បាំងឈ្នះក៏ឡើងកាន់អំណាច ចំណែកម្នាងទៀតចាញ់ ក៏ប្រមូលកម្លាំងធ្វើសង្គ្រាមដើម្បីឡើងកាន់អំណាចវិញម្តង។ ដូច្នេះ អាចនិយាយបានថាការងារអ្នកដឹកនាំយើងកាលហ្នឹង ដឹងតែពីច្បាំងទៅច្បាំងមក។ រកពេលធ្វើស្អីជាប្រយោជន៍ជាតិ ដូចសម័យយើងនេះគ្មានទេ។ អីចឹងទេ វិធីបោះឆ្នោតជ្រើសរើសអ្នកដឹកនាំនេះគឺប្រសើរបំផុតហើយ ដើម្បីធានាសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍជាតិ"

ក្រឡាហោមខេង

ខេត្តបាត់ដំបង ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ពិធីអបអរសាទរបុណ្យណូអែល និងឆ្លងឆ្នាំសាកល នៅស្រុកសង្កែ

ខ្លាចអត់ខុសមួយហើយ!

ប៉ុន្តែបើមិនកែ នឹងខុសមួយទៀត!

ប្រវត្តិសង្ខេប និងស្នាដៃរៀបរៀង






ខ្ញុំបាទ **វ៉ែន រតនៈ** កើតនៅភូមិថ្មគរ ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល។ ឪពុកឈ្មោះ **យឹម វ៉ែន** ជាគ្រូបង្រៀនចូលនិវត្តន៍ និងជាមេឃុំ និងម្តាយឈ្មោះ **នៅ សាមិទ្ធិ** ជាកសិករ។ បងប្អូនបង្កើតមាន៧នាក់ ខ្ញុំជាកូនទី៦។

ខ្ញុំបាទមានភរិយាឈ្មោះ **សុខ ថារី** ហើយចំណងដៃនៃជីវិតគ្រួសារពួកយើងគឺបង្កើតបានកូនប្រុសឈ្មោះ **វ៉ែន សាន នៈថារ៉ា** និងកូនស្រីឈ្មោះ **វ៉ែន សាន សុនត្តា**។

ខ្ញុំបាទធ្លាប់បួសជាព្រះសង្ឃ នាអំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រច្បាប់រដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មុនលាចាកសិក្ខាបទដើម្បីចូលបំពេញការងារជាអ្នកសារព័ត៌មាន នៅឆ្នាំ២០១២។ នៅឆ្នាំ២០២៣ ខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត រដ្ឋបាលសាធារណៈ (RULE)។ ប្រកបអាជីពការសែតដល់ឆ្នាំ២០២៣ ខ្ញុំបានចូលបម្រើការងារនៅខុទ្ទកាល័យក្រសួងមហាផ្ទៃ ទទួលបន្ទុកជាអ្នកនាំពាក្យ **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា**។

ក្នុងការងារស្រាវជ្រាវ និងចងក្រង ខ្ញុំបានរៀបរៀងសៀវភៅ **ទស្សនៈសម្តេចក្រឡាហោម ស ខេង** បានចំនួន**៣ក្បាល** និងសៀវភៅ **ក្រឡាហោមខេង អនុស្សាវរីយ៍ក្នុងអន្តរកាលបន្តវេន...**ចំនួន**១ក្បាល**។ ខ្ញុំក៏បានចូលរួមស្រាវជ្រាវ និងសរសេរសៀវភៅចំនួន**៣ក្បាល**ផ្សេងទៀតដែរ រួមមាន សៀវភៅប្រវត្តិតស៊ូ **សម្តេចក្រឡាហោម ស ខេង** សៀវភៅ **ជា ស៊ីម សហស្ថាបនិក២ធ្នូ** និងសៀវភៅ **អនុស្សាវរីយ៍ចូលឆ្នាំបន្ទាយឆ្មារ ឆ្នាំ២០២៣**៕


“មួយជីវិតយើងវាតែប៉ុណ្ណឹង!

អត់មានអ្វីលើសពីហ្នឹងទេ បានន័យថា ជួយប្រជាពលរដ្ឋយើងច្រើនកាលណា

យើងក៏សប្បាយចិត្តប៉ុណ្ណឹង!

ជួយជាតិបានច្រើនកាលណា យើងក៏សប្បាយចិត្តទៅតាមហ្នឹង!

ពីព្រោះមនុស្សយើងទាំងអស់គ្នាកើតមកមានប៉ុន្មាន ក៏ទៅវិញប៉ុណ្ណឹងដែរ

អត់មានអ្វីលើសពីហ្នឹងទៀតទេ។

អ៊ីចឹងហើយនៅពេលយើងមានជីវិត មានលទ្ធភាព យើងខិតខំប្រឹងប្រែង

ដើម្បីជួយស្រុកទេសយើង ជួយកូនចៅយើងទៅអនាគត

វាល្អ វាអត់មានអ្វីខុសទេ”

រចនាដោយ៖ ហេង ដាវ៉ា និង ឃឿន សុខយន់